# វេជ្ជសាស្ត្រខ្មែរបុរាណ

រៀបរៀង និងចងក្រងដោយ

យូ ឆួន



# វេជ្ជសាស្ត្រខ្មែរបុរាណ

# ជាតម្រាព្យាបាលថ្មី

# មានចំរើនត្រូវចិត្ត

# និងសម្ភារ

ដោយ

ប្រើឱសថ

បន្តរាគប

ឧបកិច្ច

អបទេស

ចងក្រងដោយ

យុះ នួន

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
00007384

# អារម្ភកថា

គោលគំនិតដែលខ្ញុំសរសេរសៀវភៅនេះឡើងក៏ព្រោះ ចំពោះចង់រំលឹក និងស្គាល់ពីសម្បត្តិវប្បធម៌ខ្មែរ ផ្នែកខាងវិជ្ជាវេជ្ជសាស្ត្រ ហើយនិងជំនឿដែលខ្មែរយើងធ្លាប់មាន ពីអតីតកាល ដែលនេះកំពុងតែបាត់បង់និងសាបសូន្យទៅបន្តិចម្តងៗ ស្ទើរតែត្រូវលោបលែងឃើញទៅហើយ ។ ហើយរំពឹងតទៅបើគ្មានអ្នកមានគំនិតស្រាវជ្រាវប្រមូលរក្សាទុកទេ នោះប្រាកដជាសាបសូន្យលែងដឹងអ្វីទាំងអស់. កុំថាឡើយផ្នែកវេជ្ជសាស្ត្រ សូម្បីតែបុរាណវត្ថុ បុរាណស្ថាន មានរូបចម្លាក់ ព្រះវិហារ និងក្បាច់ទេពធិតាច្រើនៗនៅតាមកន្លែងខ្លះ ជាច្រើនកន្លែង ដែលត្រូវលោបបាត់ត្រូវលោបលែងឃើញតទៅទៀត ។

វេជ្ជសាស្ត្រខ្មែរបុរាណនេះ បើតាមដែលខ្ញុំកើតទាន់ហើយបានដឹងខ្លះៗមកនោះ ខ្មែរយើងមានវិជ្ជាផ្នែកខាងការព្យាបាលជម្ងឺយ៉ាងពូកែស័ក្តិសិទ្ធបំផុត ដែលអាចព្យាបាលជម្ងឺសាហាវៗ និងជម្ងឺធ្ងន់ៗ ដូចជាជម្ងឺរបេង ជម្ងឺឃ្លង់ អាសន្នរោគ រហូតដល់ហើយជម្ងឺឆ្កែឆ្កួតខាំបានជាទៀតផង (ខ្លាចមិនស្បែក) ។

ខ្មែរនេះព្យាបាលជម្ងឺទាំងខាងផ្ទៃក្នុង (ផ្ទៃពោះ) និងទាំងខាងផ្ទៃក្រៅ (ក្រៅក្រៅ) ដែលមានតែឯកសារត្រឹមត្រូវហើយមិនប្រាកដប្រជា អាចព្យាបាលទៅលើរោគដែលកើតនៅលើសាច់ដុំ

កាយវិការក្ដី ឲ្យលាក់ចេញទៅតាមលំនាំចិត្តរបស់គេបាន ដូចជាគេធ្វើបំប្លែងរូបដែលកើតនៅក្នុងព្រលឹងខ្លួន ឲ្យលាតចេញផុតទៅកើតនៅលើសាច់ទេវិញ ឬរូបដែលកើតមកពីចិត្តគ្នាក់ក្នុងដូចជាក្បាលមនុស្ស ដែលគេយល់ថាល្អប្រពៃណាទៅត្រូវតែពិការជើងម្ខាង,ដូច្នេះគេធ្វើបែបឲ្យលាតចេញផុតទៅកើតនៅលើសាក់ក្បួរនោះទេវិញ ។ល។

ខ្មែរកាលពីដើមខ្ញុំបានគំហើញថា គេមានទម្លាប់និងការពិសោធន៍ច្បាស់លាស់ណាស់ ដូចជានិយាយ,ខ្មែរស្គាល់និស្ស័យរបស់ពួតផល់យកមកប្រើទាំងពណ៌និងមុខមាត់ហាន ដូចយ៉ាងវត្តព្រះកោតក្រី ខ្ញុំឃើញគេយកឫសកក្រៀកក្ដួច បកសៀតនៅលើឆ្មេញហើយយកកាំបិតយ៉ាងមុតដូចជាកាំបិតកោរ មកការពិសោធឲ្យមើល ហើយសង្កេតឲ្យឃើញច្បាស់ថា សត្វកណ្ដុរកាប់មិនមុតប្រាកដមែន ដែលយើងយល់ច្បាស់ថាលើសាច់ល្អដាច់ត្រូវតែដាច់។

ហើយបើយើងត្រាវជ្រាវទៅក្នុងអតីតកាល យើងនិងបានឃើញក្នុងប្រវត្តិសាស្ត្រថែមថា ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ព្រះអង្គបានពង្រីកខាងវិស័យវេជ្ជសាស្ត្រនេះខ្លាំងគួរសរសើរណាស់ ដោយឃើញសិលាចារឹកដែលជាអរោគ្យសាលដល់ទៅ ១០២. ហើយដែលមានពាក្យស្លោកក្នុងសិលាចារឹកអរោគ្យសាលរបស់ព្រះអង្គថ្លែងថា ជម្ងឺរបស់ប្រជារាស្ត្រ ធ្វើឱ្យព្រះអង្គឈឺចុកចាប់ ជាងជម្ងឺផ្ទាល់របស់ព្រះ

អង្គ ព្រោះសៀវភៅច្បាប់ជាគាថាការណកៈនេះហើយ ដែលជាសៀវភៅច្បាប់ របស់ព្រះរាជាទាំងឡាយ ។

ហេតុនេះប្រវត្តិសាស្ត្រនិងសិលាចារឹកបានបញ្ជាក់ឲ្យយើង ដឹងច្បាស់ថា ក្នុងអតីតកាលនាសម័យដែលប្រវត្តិសាស្ត្រខ្មែរយើងក៏មាន ការល្បីល្បាញកំរើនរុងរឿងខ្លាំងណាស់ដែរ ដែលចំពោះវិជ្ជា របស់ខ្មែរយើងបែរជាបាត់បង់និងសាបសូន្យទៅវិញ តាំងពីឥទ្ធិពល របស់ខ្មែរថយចុះ ហើយដែលប្រទេសធ្លាក់ចុះដុនដាបរហូតមក ។ ដោយគ្មានអ្នកដែលមានគំនិតស្រាវជ្រាវ ឬកត់ត្រាទុកដើម្បី រក្សាកេរមរតកទាំងនោះឲ្យបានគង់វង្ស ។

ហើយសម័យដែលខ្ញុំកើតទាន់មកនេះ ច្រើនឃើញតែអ្នក ចេះដែលមានគំនិតលាក់បាំង ដោយមិនចង់ឲ្យអ្នកដទៃចេះផង ។ ហើយក៏មានខ្មែរភាគច្រើនដែលច្រើនមិនរវល់រើពើ និងចំពោះ វិជ្ជាទាំងឡាយនោះៗ ឬយ៉ាងល្អជារូបខ្ញុំជាអាទិ៍ដែលបានឃើញ វិជ្ជាល្អៗ ប្លែកៗ ហើយមិនរវល់យកចិត្តទុកដាក់ទាល់តែសោះ ដែលធ្វើឲ្យខ្ញុំមានចិត្តសោកស្តាយរហូតមកដល់ឥឡូវ ។ ហើយ សព្វថ្ងៃនេះទៀតមានអ្នកខ្លះឮថាចេះចំពោះវិជ្ជាអ្វីមួយ ខ្ញុំបានទៅសាក សួរដើម្បីកត់ត្រាចងក្រងទុក តែអ្នកនោះប្រាប់ថាគេចេះបិទឲ្យ ឮ ឬក៏និយាយដោះសារភូតភរក្នុងគោលបំណងលាក់បិទបាំងមិន ចង់ឲ្យអ្នកផងចេះដឹង ។ល។

ជូនស្មេរការរកេះរើងរបស់ខ្ញុំជូនប្រិយមិត្តអ្នកអាន ទុកជាសៀវភៅរបស់អ្នកអាន និងសម្រាប់បញ្ញវន្តខ្មែរអ្នកដែលកោតគិតត្រូវរ៉ូជាវទៅក្នុងអនាគត ដែលខ្ញុំសង្ឃឹមថាស្នាដៃរបស់ខ្ញុំ ទុកដូចជាប្រទីបបំភ្លឺពួចសម្រាប់បញ្ចាំងឲ្យឃើញត្រូវពេចត្រូវពិតក្នុងទីងងឹត និងជាការត្រួសត្រាយផ្លូវសម្រាប់បញ្ញវន្តខ្មែរទៅក្នុងអនាគតកាល ។

កុសលដែលកើតឡើងពីសំណេរនេះសូមឧទ្ទិសជូន ដល់ទៅវិញ្ញាណក្ខន្ធនៃបុព្វបុរសខ្មែរ សូមលោកជួយដាស់ សតិ សម្បជញ្ញខេមរជនឲ្យមានមនសិការៈរឭកនឹកឃើញពីអតីតកាល ដែលជាសម័យខ្មែរកំពុងរុងរឿងនោះផង ៚ ។

ថ្ងៃច័ន្ទ ១២ កើត ខែបុស្ស ព.ស ២៥៣៩
ត្រូវនឹងថ្ងៃ ទី ១ ខែមករា គ.ស ១៩៩៦

**ឃូ ឆូន**



# យូ ទួន

កើតនៅ: ភូមិ កំពង់ស្វាយ ឃុំ កំពង់ស្វាយ

ស្រុក សិរីសោភ័ណ ខេត្ត បាត់ដំបង

មាតាឈ្មោះ ស្នួន អង (ហៅ ទុក)

បិតាឈ្មោះ ទួន ( មុយ ទួន)

# សារ បញ្ញា

| មាតិកា | ទំព័រ |
|---|---|
| អារម្ភកថា | ក ខ គ ឃ ង |
| **វេជ្ជសាស្ត្រខ្មែរបុរាណ** | |
| វិធានពេទ្យកថា | ១ |
| ចំណេះវិជ្ជាដែលបានទទួល | ៣ |
| ការចេះដឹងដោយចៃដន្យ | ៤ |
| ការចេះដឹងក្នុងផ្លូវសុបិន | ៦ |
| ការចេះដឹងពិសេស | ៩ |
| **របៀបព្យាបាលជំងឺ** | |
| ក- ខាងផ្លូវសម្ភារៈ | ១២ |
| ខ- ខាងផ្លូវចិត្ត | ១២ |
| **ខាងផ្នែកសម្ភារៈ** | |
| ខ្មែរប្រើថ្នាំជារបៀប២យ៉ាង | ១៣ |
| ខ្មែរប្រើថ្នាំក្នុងវិធី២យ៉ាង | ១៣ |
| ខ្មែរប្រើថ្នាំដោយរបៀបព្យាបាល២យ៉ាង | ១៤ |
| **ប្រើថ្នាំជារបៀបការពារជំងឺ** | |
| ពពួកថ្នាំការពារ | ១៤ |
| ពពួកថ្នាំការពារប្រភេទឯង | ១៥ |

ចំពូកផ្កាការពារប្រភេទពេល ---------------------- ១៦

" ប្រភេទព្រាំ ---------- ១៦

" ប្រភេទទេរ ---------- ១៧

" ប្រភេទព្រាំស្រា ---------- ១៩

ទ្រង់ផ្កាឈររបៀបញាណេស៊ី

ចំពូកផ្កាទេរ ---------- ២០

ចំពូកផ្កាទោរ ---------- ៣២

ចំពូកផ្កាបន្ទក់ ---------- ៣៥

ចំពូកផ្កាកញ្ជ្រែង ---------- ៣៧

ចំពូកផ្កាជុស ---------- ៤៣

ចំពូកផ្កាជុក ---------- ៤៦

ចំពូកផ្កាស៊ុមីក ---------- ៤៨

ចំពូកផ្កាចំពុយ ---------- ៥០

ចំពូកផ្កាស្ទូច ---------- ៥២

ចំពូកផ្កាស្នូ ---------- ៥៣

ចំពូកផ្កាឈក់ ---------- ៥៥

ចំពូកផ្កាធំធេង ---------- ៥៦

ចំពូកផ្កាត្រាំ ---------- ៥៩

ចំពូកផ្កាក្រណាត់ ---------- ៦១

ចំពួកថ្នាំពើតោក ------------------------- ៦៤
ចំពួកថ្នាំស្រុង ៦៥
ចំពួកថ្នាំចេព ៦៨

## ប្រើថ្នាំដោយប្រយោល

ចំពួកថ្នាំបិទ ------------------------- ៧០

## វិធីឧបកិច្ច

ឧបកិច្ចមានប្រើជារបៀប២យ៉ាង ------------------------- ៧៤
ឧបកិច្ចដោយប្រើថ្នាំការពារ ------------------------- ៧៥
ឧទាហរណ៍សេចក្តីក្លាហានដែលលើកជា ------------------------- ៧៧
ចំពួកថ្នាំទប់ទល់ ------------------------- ៧៨
ចំពួកថ្នាំស្ងោរក្នុងការទប់ទល់ ------------------------- ៨០
ចំពួកថ្នាំឧបកិច្ចក្នុងការទប់ទល់ ------------------------- ៨៤
ឧបកិច្ចគ្មានថ្នាំ ------------------------- ៨៦

## របៀបប្រើថ្នាំក្នុងផ្លូវទុក្ខរិព

ចំពួកថ្នាំបំផ្លិចបំផ្លាញ ------------------------- ៨៩
ចំពួកថ្នាំរាសីក្តិស ------------------------- ៩២

## មន្តអាគមគាថា

ខ្មែរប្រើមន្តក្នុងការទាំងពេ ------------------------- ៩៥
ឧទាហរណ៍ខាងវេទមន្ត ------------------------- ៩៦

ឧទាហរណ៍នាមពុទ្ធមន្ត ---------------------- ៩៧
ពាក្យសម្រាយខ្មែរសុទ្ធ ---------------------- ៩៩
ពាក្យសម្រាយខ្មែរលាយវេទមន្ត ---------------------- ១០២
ពាក្យសម្រាយលាយពុទ្ធមន្ត ---------------------- ១០២
ពាក្យសម្រាយលាយវេទមន្តនិងពុទ្ធមន្ត ---------------------- ១០៣
កំណត់សំគាល់ ---------------------- ១០៥

## ឱសថព្យាបាលជួចផ្លូវចិត្ត

ចំពូកផ្កាស្ដោះព្រួស ---------------------- ១០៦

## ខ្មែរប្រើមន្តជារបៀប២យ៉ាង

មន្តការពារជំងឺ ---------------------- ១០៨
មន្តព្យាបាលជំងឺ ---------------------- ១១១
ពិធីស្ដោះព្រួស ---------------------- ១១២
ពិធីផ្លុំ ---------------------- ១១២
ស្រោចទឹកប្រោះព្រំ ---------------------- ១១៣
ចារ៍បញ្ចុះ ---------------------- ១១៤

## ព្យាបាលជំងឺខាងផ្លូវចិត្ត

ព្យាបាលដោយសូធ្យថ្មី ---------------------- ១១៥
ព្យាបាលផ្លូវចិត្តដោយការស្ដោះព្រួស ---------------------- ១២០
ប្រើមន្តនិងឧបកិច្ច ---------------------- ១២២

ព្យាករណ៍សោយទីកបត្ត ---- ១២៣
គាថាធ្វើទីកបត្ត ---------- ១២៥
ជំណាលប្រាប់ពីរឆ្លូតការណ៍ -------- ១២៧

ការព្យាករណ៍ធ្វើពិត្តគ្គាះព្រួតពិចម្ចី

ក្រុងសិរិទ្ធិ ---------- ១៣៥
ក្រុងរអេះ ---------- ២៣៦
គ្គាះធ្វើពប្បព្យាររឿង ---------- ១៣៨

ប្រើមន្តផ្សំនិងពិសេស

ប្រើគ្គាះព្រួសនិសថនិងមន្ត ---------- ១៤០
ប្រើយ័ន្តគាថានិងឆ្នាំ ---------- ១៤៣

មន្ត ឧបកិច្ច និសេធ អក្ខរៈ

ការព្យាករណ៍ជប៊ីតុរ ១៤៤
គាថាភាវនាល្អឡើសែក -- ១៤៥
របៀបព្យាករណ៍ទៅតាមថ្ងៃ.ខែ.ឆ្នាំ ---------- ១៤៧
របៀបចារ៉ុកា ---------- ១៤៩

ព្យាករណ៍ដោយសុបិន

វិធីព្យាករណ៍ដោយសុបិន ---------- ១៧២

ព្យាករណ៍ដោយសម្លេង

របៀបព្យាករណ៍ដោយសម្លេង ---------- ១៧៣

## ព្យាបាលរោគទាស់

ពិធីព្យាបាលរោគទាស់ ---------- ១៧៥

ការស្ដារព្រលឹងខ្មែរបុរាណ ---------- ១៧៧

ការធ្វើអក្សរដាក់ឈ្មោះ ---------- ១៧៨

ការពិសោធទៀងពេលទាយទុកករណ៍ ---------- ១៧៩

## ពិធីបញ្ចូលគ្រូ

ពិធីបញ្ចូលគ្រូព្យាបាល ---------- ១៨០

## ការបន់ស្រន់

ការបន់ស្រន់ដើម្បីព្យាបាល ---------- ១៨២

ឧទាហរណ៍ ពីព្រះពុទ្ធរូប ---------- ១៨២

សំដីអ្នកបន់ស្រន់ ---------- ១៨៣

ចៅអធិការវត្តគុក ---------- ១៨៤

ការចំណាំគ្រូខ្មែរបុរាណ ---------- ១៨៧

របៀបទាយរបស់គ្រូខ្មែរ ---------- ១៨៨

រឿងអតីត បច្ចុប្បន្ន អនាគតខុសគ្នា ---------- ១៩២

វាលស្រែខ្ញុំប្រទេសពោធិ ---------- ១៩៤

និទានរឿងថ្មី ---------- ១៩៥

ពាក្យបញ្ចប់ ---------- ១៩៦

# វេជ្ជសាស្ត្រខ្មែរបុរាណ

## វិចារណកថា

បើយើងធ្វើការពិចារណាពីវិធីថ្នាំខ្មែរជាតិពីអតីតកាល ដែលបានរីកចំរើនឡើងដល់ទៅកំពូល នៅរាល់ភូមិភាគអាគ្នេយ៍នាកាលសម័យនោះ ហើយយើងគិតថា៖ រ.វិធីថ្នាំនោះបើខ្វះនូវសម្បត្តិវិសេសចំពោះមុខ ដូចយ៉ាងថ្នាំខាងវិទ្យាសាស្ត្រជាដើម តើវិធីថ្នាំនោះ អាចឋិតថេរនៅជាស្ថេរភាពរាប់សតវត្សបានដែរឬទេ ? នេះជាចំណោទដែលយើងត្រូវលើកយកមកធ្វើវិភាគ ។

បញ្ហាជាចម្បងគឺការរស់នៅរបស់មនុស្ស ព្រោះមនុស្សដែលមានជីវិតរស់នៅបាន ក៏ដោយសារត្រូវការទៅលើអាហារក្នុងការបរិភោគ តែបើត្រូវកើតទាស់រោគកើតឡើងប្រការណ៍ត្រូវរកថ្នាំព្យាបាល តើវិធីថ្នាំនោះមានដែរឬទេ ? ដូច្នោះហើយទើបបានជាយើងឃើញវប្បធម៌ខ្មែរចាស់ពីអតីត មានប្រពៃណីគ្រប់ទិសទី ដែលមានតំបន់កសិកម្មសំខាន់ៗ ក្លាយទៅជាស្ថានសួគ៌ រហូតដល់មានហៅឈ្មោះស្រុកខេត្តទាំងនោះថាស្ថានសួគ៌ ដូចជាខេត្តព្រះសួគ៌ា នៅកម្ពុជាក្រោម ។ ខេត្តសួគ៌លោក នៅក្នុងស្រុកថៃ ។ល។ (ថៃហៅស៊ុវ៉ាន់លោករហូតមកដល់សព្វថ្ងៃនេះ) ។

បញ្ហាជាបន្ទាប់គឺផ្នែកសុខភាព ព្រោះមនុស្សដែលប្រកបការងារ

ទៅបាន ក៏តោងអាស្រ័យនៅលើកម្លាំងកាយ បើប្រសិនជារាងកាយមិនមាំមួនទ្រុឌទ្រោមចុះ ប្រកបដោយមានរោគាព្យាធិ ក៏មិនអាចប្រកបការងារទៅកើត, ហើយបើប្រជារាស្ត្រមានជម្ងឺ ដូចជាអាសន្នរោគ អុតធំស្លាប់អស់ទាំងភូមិៗ តើអរិយធម៌នោះមានដែរដែរឬទេ? ។ល។

ដូចនេះយើងអាចសន្និដ្ឋានបានថា សម្បត្តិវប្បធម៌ខ្មែរកាលពីសម័យរុងរឿង ផ្នែកខាងវេជ្ជសាស្ត្រក៏រីកចំរើនលូតលាស់ខ្លាំងណាស់ដែរ ដូចជាក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ មានមន្ទីរពេទ្យពាំងចំនួនដល់ទៅ១០២ ដែលមានបុគ្គលិកនិងបរិក្ខារផ្តល់ឲ្យយ៉ាងគ្រប់គ្រាន់ ។

ប៉ុន្តែលុះដល់ប្រទេសធ្លាក់ចុះដុនដាប វិជ្ជាទាំងឡាយនោះក៏ត្រូវវិនាសសាបសូន្យទៅជាមួយផងដែរ ម្តេចឡើយនិងបានគង់វង្សនៅឲ្យឃើញជាភស្តុតាង ដូចជាប្រាសាទដែលធ្វើអំពីថ្មនោះ ។

ដូចនោះចំណេះចេះដឹងនៃគ្រូពេទ្យខ្មែរបុរាណ ក្រោយសម័យដែលប្រទេសធ្លាក់ចុះដុនដាបមក គេសង្កេតឃើញពុំមានកម្រិតជាថ្នាក់ ជាជាន់ ខ្ពស់ទាប ឬមានអ្វីជាគ្រឿងសម្គាល់ឲ្យដឹងថា ចេះច្រើន ឬចេះតិច និងមានសមត្ថភាពដល់ត្រឹមណាៗនោះឡើយ ។ មានខ្លះចេះវិជ្ជាព្យាបាលតែមួយមុខគត់ ដូចជាគេចេះព្យាបាលអ្នកដែលត្រូវពស់ចឹក តែបើមានជំងឺផ្សេងទៀតគេមិនចេះ។ល។ មាន

អ្នកខ្លះចេះព្យាបាលខាងជម្ងឺរុក(រុកធំ) តែជម្ងឺផ្សេងទៀត គេមិនចេះ ។ល។

ព្រោះថាៈ វិជ្ជាទាំងឡាយដែលមិនបានកត់ត្រាទុក រមែង, បាត់បង់ ហើយអាចនៅសល់ខ្លះ ដោយសារការចងចាំតៗគ្នាបន្តិចម្នាក់ៗ ហើយមិនប្រាកដទៀតផង, ដែលមានអ្នកខ្លះគេពុំបានតាំងខ្លួនជាអ្នកព្យាបាលជម្ងឺពម្កាត់អ្វីនោះទេ, តែដោយថៃជន្យដែលនៅក្នុងភូមិគ្មាននរណាចេះដឹង ទើបបានជាគេជួយសង្គ្រោះ ។

ក្នុងករណីនេះចំណេះចេះដឹងទាំងឡាយដែលត្រូវពេទ្យបុរាណខ្មែរបានទទួលគឺ:

*១_ ការចេះដឹងដោយប្រាប់គ្នាតៗមក ។*

*២_ ការចេះដឹងដោយឃើញក្នុងសាស្ត្រាស្លឹករឹត ឬក្រាំង ដែលអ្នកខ្លះបានសរសេរនឹងចារទុកមកបន្តិចបន្តួច ច្រើនមិនច្បាស់លាស់ ។*

*៣_ ការចេះដឹងដោយបានឃើញផ្ទាល់ នូវ ការព្យាបាលរបស់អ្នកផង ។*

*៤_ ការចេះដឹងដោយខ្លួនឯង ក្នុងការស្រាវជ្រាវ*

ខ្លះ និងការពិសោធន៍ផ្ទាល់ខ្លួនខ្លះ ។

៥_ ការចេះដឹងដោយចៃដន្យ ។

៦_ ការចេះដឹងផ្សេងទៀត ក្នុងផ្លូវសុបិននិមិត្ត (យល់សប្តិ) ។

៧_ការចេះដឹងពិសេសក្នុងផ្លូវសមាធិកម្មដ្ឋាន

**ការចេះដឹងដោយចៃដន្យ** = ការចេះដឹងនេះដោយហេតុ ដែលនាំចិត្ត ឬបណ្តាលចិត្ត បញ្ចូលចិត្ត ឲ្យគិត ឲ្យនឹកភ្នកឃើញនូវដំណើរការណ៍ ឲ្យកើតមានឡើង ហាក់ដូចជាមានទេវតា ដឹកនាំ ពន្យល់ឬបណ្តាលឲ្យជួបប្រទះ ។ល។

*ឧទាហរណ៍ ទី១_* ក្មេងម្នាក់នៅខេត្តក្រចេះ មានជម្ងឺឈឺ ស្គមរាងកាយឃើញតែឆ្អឹង សាច់ស្បែកស្លាំងដូចជាគ្មានឈាម, ហើយថ្ងៃមួយនោះនាងបង ពនាំយកទៅលេងនៅផ្ទះជិតខាង ដែលគេមានដាំឬសជាច្រើនឃើញផ្លែទុំក្រហមច្រាល ។ ពេលនោះនាងបងដាក់ប្អូននៅក្បែរដើមឬស ហើយលេងលោតអន្ទាក់ជាមួយនឹងក្មេងៗផងគ្នា, ស្រាប់តែមួយស្របក់ក្រោយមកក្រឡេកមើលទៅប្អូន ឃើញកំពុងបេះផ្លែឬសទុំនោះញ៉ាំ ទើបនាងបងស្ទុះទៅភើច

កន្ត្រាក់ទាញយកប្អូន ពាចេញមក ឲ្យផុតឆ្ងាយពីដើមម្ទេស ប៉ុន្តែ នាងប្អូនដែលមានជម្ងឺហើមស្គមស្លេកស្លាំងនោះ ចង់ញុំាផ្លែម្ទេសទុំ ហើយស្រែកទ្រហោយំរើបម្រះចង់ទៅបេះញុំាទៀត ទើបនាងបង ខឹងប្រទេញ្ញាតទៀង ហើយលែងឲ្យទៅបេះស៊ីតាមចិត្ត ដោយ ចោលសំដីថា ឲ្យវាស៊ីឲ្យងាប់ទៅចុះ ! ។ អំពើបែបនេះមិនមែន តែម្តងនោះទេ គឺមានជាច្រើនដងពេកទៀត ។

លុះរយៈកាលកន្លងផុតមកប្រហែលជាបួនខែ កូនក្មេងដែល មានរូបកាយស្គាំងស្គមសាច់ស្លេកស្លាំងនោះ ស្រាប់តែមានសាច់ មានឈាមឡើងស្រស់បស់បន្តិចម្តងៗ ធាត់ធំទ្រលុកទ្រលន់ ដែល ជាហេតុឲ្យសំគាល់បានថា បណ្ដាលមកពីបរិភោគផ្លែម្ទេសទុំ ។

*ឧទាហរណ៍ទី២* គេមានពាក្យចាស់ៗតៗមកថា៖ សត្វគីង្គក់ ជាសត្វដែលមានពិសខ្លាំងពូកែមួយដែរ ដោយគេបានឃើញការ ប្រយុទ្ធគ្នាជាមួយនឹងសត្វក្អែប ហើយគេឃើញបញ្ចេញពិសព្រួស ទៅលើខ្លួនក្អែប ធ្វើឲ្យក្អែបរីងខ្លួនកំរើកលែងរួច ។ ហេតុដូច្នោះ ហើយទើបបានជាគេយកសត្វគីង្គក់ មកប្រើធ្វើជាថ្នាំរំលាប់ពិស ឬ ប្រើធ្វើជាថ្នាំពិស ។ល។

ឧទាហរណ៍ដូចជារោគមួយប្រភេទដែលតែងកើតនៅស្រុកខ្មែរ គេហៅថាកើតទ្រួចពិស, អាការរោគនេះផ្តួចផ្តើមឡើងឃើញ

ពងប៉ូកភ្លើងរលាក ការខ្ទុះពងរលៀសត្រូវរាប់នៅខាងក្នុង ដោយតែរលួកឡើងយ៉ាងឆាប់រហ័ស បណ្ដាលឲ្យអ្នកជម្ងឺឈឺចុកចាប់ហួសវិស័យនិងរត់ទ្រាំបាន។ ដូច្នេះដើម្បីនិងរម្ងាប់នូវអាការឈឺចុកចាប់នេះឲ្យបានទាន់ចិត្ត និងមានប្រសិទ្ធិភាព, គេយកប្រមាត់គីង្គក់បកដាក់បំព្រង់បុកកន្លែងដែលតុប្បខ្ទុះ រួចដាក់សំឡីហើយចាក់ទំលាយប្រមាត់គីង្គក់ចូលទៅ, ត្រឹមមួយស្របក់ក្រោយមក ខ្ទុះចពិសនិងឆ្លាយខ្ទុះចេញមកមួយរំពេច។ ហើយការឈឺចុកចាប់ស្រែកទ្រហោយំក៏បាត់ភ្លាមទៅជាមួយគ្នាផងដែរ ។

**ការបេះដឹងក្នុងផ្លូវសុបិននិមិត្ត** = ការបេះដឹងក្នុងផ្លូវសុបិននេះ បើតាមអ្នកដែលធ្លាប់បានអនុវត្តរួចមកហើយ គេថាមានសភាពស័ក្ដិសិទ្ធណាស់ ។

*ឧទាហរណ៍ទី១*– ស្ត្រីម្នាក់នៅភូមិជន្លាត់ដៃ ក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប, គាត់មានជម្ងឺស្បូនត្រូវ ដោយស្បូនលៀនធ្លាក់ចេញផុតពីទ្វារលោទីមកយ៉ាងវែង ប្រហាណជា២ធ្នាប់ដៃ, បណ្ដាលឲ្យគាត់ពិការដើរទៅណាមិនបានឆ្ងាយទៅក្រៅវែងតែនិងផ្ទះ(ហេតុដែលធ្វើឲ្យស្បូនត្រូវ ឬលៀនចេញមកក្រៅនេះ ដោយសារក្នុងពេលសម្រាលកូន ឆ្មបប្រើកម្លាំងសង្កត់ខ្លាំងពេក) ហើយជម្ងឺរបស់គាត់បានកើតអស់ពេលជាយូរ, ទ្រាំនឹង ក្ដី តែពេទ្យគ្មានលទ្ធភាព

ព្យាបាលគាត់ឲ្យជាបាន ។

ទើបក្នុងពេលយប់មួយនោះគាត់សុបិនឃើញថា: មានតាចាស់ម្នាក់ស្លៀកសពាក់ស បកពន្យល់ប្រាប់គាត់ថា ឲ្យទៅជីកយកឫស..............មកស្ងោរផឹកទៅបាត់ហើយ ។ លុះព្រឹកស្អែកឡើងគាត់ក៏បានអនុវត្តតាមការដែលយល់សប្តិ ។ ហើយជម្ងឺឥន្ទ្រីយ៍ស្រុតដែលលៀនចេញមកជាយូរយារនោះ ក៏រួញលិបចូលទៅវិញដូចដើម បានជាសះស្បើយដូចជាសុបិននិមិត្តប្រាកដមែន ។

ហើយអ្នកភូមិនាំគ្នាសាកសួរដេញដោលគាត់ថា ចុះបើមិនឃើញមានគ្រូឯណាមកព្យាបាលសោះ ម្តេចបានជាគាត់ជាដើររួច? ទើបគាត់រៀបរាប់សារស័ព្ទប្រាប់ពីសុបិននិមិត្តរបស់គាត់ ដល់អ្នកភូមិជាមួយ ហើយឮតៗទូទៅរហូតភូមិជិត-ឆ្ងាយ ។ ប៉ុន្តែគាត់មិនព្រមប្រាប់ថ្នាំនោះ ឲ្យគេបានដឹងផងសោះ, ដោយគាត់សំអាងលេសថា តែបើកាលណាប្រាប់ទៅនឹងសាប លែងពូកែស័ក្តិសិទ្ធដូចដើមវិញទៀត ។

*ឧទាហរណ៍ទី២=* ដើម្បីបញ្ជាក់ពីចំណេះចេះដឹងក្នុងការសុបិននិមិត្ត ឲ្យឃើញជាភ័ស្តុតាងច្បាស់លាស់បន្ថែម ខ្ញុំសូមលើកយកព្រឹត្តការណ៍មួយមកបញ្ជាក់ជូនដូចតទៅ:

លោក ឆួន ម៉ាន កាលកំណើតកើតនៅស្រុក មោង ខេត្ត

បាត់ដំបង ហើយបានភៀសខ្លួនចូលទៅនៅជុំរំជនភៀសខ្លួន ( ខៅអ៊ីដាង ) ។ ថ្ងៃមួយនោះមានគេមកពឹងគាត់ឲ្យទៅជួយសង្គ្រោះស្ត្រីម្នាក់ដែលប្រសូត្របុត្រមិនរួច ដ្បិតគេដឹងថាគាត់ចេះមន្តស្តោះព្រួសពូកែធ្វើឲ្យកូនប្រសូត្រចេញបាន ។ គាត់ក៏ព្រមទៅតាមការអញ្ជើញរបស់គេ, លុះទៅដល់ឃើញមានម្នាក់ យកឫស្សីដែលគេបៀកហើយស្រួចនោះហុចមកឲ្យគាត់, ហើយគាត់ក៏ទទួលយកឫនោះ មកទំពាស្តោះទៅតាមទម្លាប់ដែលគាត់ធ្លាប់ធ្វើពីមុនៗមក, កាលបើកិច្ចនោះបានរួចជ្រះស្រឡះរស់ហើយ គាត់ក៏ត្រឡប់ទៅលំនៅរបស់គាត់វិញ ។ ជាបន្ទាប់ភ្លាមនោះ ស្រាប់តែឃើញថ្ពាល់របស់គាត់ព្រង់ជិតគុប្តធាប ហើមប៉ោងឡើងទាំងសងខាង, ជាហេតុឲ្យពិភាល់ក្នុងចិត្ត មិនដឹងជាកើតរោគអ្វី? មានអ្នកខ្លះឲ្យយោបល់ថា ប្រហែលជាត្រូវរបស់គេហើយ !( គឺត្រូវអំពើ ព្រោះអ្នកដែលបៀកឫឲ្យនោះ គាត់ជាគ្រូដែលទៅព្យាបាលស្ត្រីនោះមុនគេ តែលោក ផាន ម៉ាន មិនបានដឹង ) ។

ដូច្នោះជម្ងឺលោក ផាន ម៉ាន ចេះតែខ្លាំងឡើងៗជារៀងរាល់ថ្ងៃ ដោយដាក់ថ្នាំព្យាបាលមិនជល់ទាល់តែសោះ, ទើបគាត់បន់ស្រន់សំបូងសប្រូងទឹកដល់គុណគ្រូ ផ្តេកខាងមន្តអាគមគាថាដែលគាត់បានសិក្សារៀនសូត្រមកទាំងប៉ុន្មាន សុំឲ្យលោកមកជួយ ។

លុះយប់ឡើងគាត់ទទួលទានដំណេកលក់ទៅ គាត់យល់សប្តិ

ឃើញថា មានគេមកប្រាប់ឲ្យទៅយកទឹកវិរិលក្ដួច ដែលទើបនឹងប្រសូត្រចេញថ្មីៗមកលាបត្រង់កន្លែងដែលកើតរោគនោះ។ ហើយគាត់ក៏បានអនុវត្តតាមដែលគាត់យល់សប្តិ, មិនយូរប៉ុន្មានជម្ងឺរបស់គាត់ ក៏បានជាសះស្បើយយ៉ាងឆាប់រហ័ស ដែលឃើញស័ក្តិសិទ និងជាក់ស្តែង គួរឲ្យអស្ចារ្យបែន ។

ខ្ញុំអ្នកសរសេរសូមបញ្ជាក់ថា នេះជាសំដីដែលមានភស្តុតាងបង្ហាញ និងមានសាក្សី ហើយជាពេលដែលទើបកន្លងមកថ្មីៗផង, ដែលសាមីជនអ្នកជម្ងឺនោះរស់នៅសព្វថ្ងៃនេះ ហើយដែលយើងបានសំគាល់ឃើញថា គាត់ជាមនុស្សសុចរិតត្រឹមត្រូវ មិនភូតភរកុហក់ ព្រោះគាត់ជាអាចារ្យវត្តព្រៃរតនារាមតំបន់ Chelmsford រដ្ឋ Massachusetts ។

**ការចេះដឹងពិសេសក្នុងផ្លូវសមាធិកម្មដ្ឋាន**= ការចេះដឹងនេះ ជាការចេះដឹងខាងផ្លូវវិបស្សនាកម្មដ្ឋាន ដែលច្រើនជាលោកធុតង្គ (រុក្ខមូល) ឬគ្រហស្ថជាតាបសរស់នៅតាមព្រៃចំរើនសមាធិកម្មដ្ឋាន, ដែលច្រើននិយាយថាមានអ្នកសុំ្ពមកប្រាប់ពីថ្នាំ (ឱសថ)ឬក៏ចម្រើនកម្មដ្ឋានទៅឃើញ ឬឃើញមានគេមកពន្យល់ប្រាប់ហេតុភេទផ្សេងៗ ។ល។

*ឧទាហរណ៍ទី១*= គាថាមួយប្រភេទដែលអ្នកប្រាជ្ញខ្មែរ ខាងអក្ខ

អាគមក្នុងសៀវភៅក្រាំង បានចារឹកទុកមកថា ជាបណ្ដុំគាថាប្លែក ប្រភេទខាងផ្លូវព្រះពុទ្ធសាសនា ដែលមានភាពស័ក្ដិសិទ្ធ ក្នុងការ ចារុំ បញ្ចុះ ឬការពារសត្វព្រៃសែក នឹងធ្វើជាកសិណបរិកម្ម ( ជារូប តាងពីកបកកាន់ចិត្ត ) ផ្នែកខាងផ្លូវកម្មដ្ឋានដើម្បីស្រាវជ្រាវរក បត្តិប្រោផ្សេងៗ ,ដែលជាបណ្ដុំគាថាបើកខាងពុទ្ធមន្ត គឺ ច.ភ. ភ.ស ដែលមានអក្សរ ៤ តួនៅក្នុងយន្តក្រាល ៤ ជ្រុង ដូច្នេះ




គាថានេះគេឃើញមានប្រទេសជិតខាង ដូចជាជនជាតិ ថៃ លាវ យកទៅប្រើជាវិធីផ្សេងៗ តែគេមិនបានកែប្រែតួអក្សរទៅ ជាអក្សរសាស្ត្ររបស់គេទេ នៅតែរក្សាដូចដើម ។

*វិធីតាំងសមាធិកម្មដ្ឋានដោយយកគាថានេះជាកសិណគឺ:* គេសរសេរ អក្សរនៅក្នុងយន្តក្រាល ៤ ដូចមានខាងលើនេះ ទំហំល្មមសម្លឹង មើលឃើញច្បាស់ ដែលដាក់ចម្ងាយប្រមាណ ១ ព្យាមឬ១ព្យាម កន្លះ រួចហើយភាវនាថា ច.ភ.ភ.ស. ដោយប្រមូលអារម្មណ៍ឲ្យ

បូលនៅជាប់នឹងគាថា រហូតដល់បើកភ្នែកក៏ឃើញ បិទភ្នែកក៏ឃើញ ដើរ ដេក ឈរ អង្គុយឃើញដូចគ្នា,ពេលនោះឯងហើយដែលគេហៅថា ចិត្តស្លុងស៊ប់ជាប់ទៅក្នុងគាថា ។ ហើយនឹងបង្កើតជានិមិត្តឲ្យឃើញនូវបន្តវិជ្ជាផ្សេងៗ ។

ក្នុងការដែលឃើញនេះគេបានបញ្ជាក់ប្រាប់ថា ឲ្យប្រុងប្រយ័ត្នស្មារតីយ៉ាងប៉ុងម៉ាត់ ព្រោះជួនកាលខ្លះមានឃើញអព្ភូតហេតុ ដ៏អស្ចារ្យដែលបណ្ដាលឲ្យស្លុតស្មារតីប្រព្រឹត្តរហួសប្រមាណហើយទៅជាឆ្កួតវង្វេង វិកលចរិត ។

សេចក្ដីដូចបានរៀបរាប់មកនេះ ស្ដីពីចំណេះចេះដឹងដែលគ្រូពេទ្យខ្មែរបុរាណបានទទួលផ្នែកខាងមុខវិជ្ជាវេជ្ជសាស្ត្រ ។ តទៅនេះនិងស្ដីរៀបរាប់ពីការព្យាបាល ដែលគ្រូពេទ្យខ្មែរបុរាណបានអនុវត្តក្នុងការព្យាបាលជម្ងឺ:

## របៀបព្យាបាល

គ្រូពេទ្យបុរាណខ្មែរព្យាបាលជម្ងឺដោយវិធី ២ យ៉ាងគឺ:

### ១/ វិធីព្យាបាលតាមផ្លូវសម្ភារៈ (ឱសថ ឬ ថ្នាំ) ។

## ២/ វិធីព្យាបាលតាមផ្លូវចិត្ត "ចិត្តវិជ្ជា" (មន្តអាគម ឬឧបកិច្ច ឬអបខេស) ។

**ក-ខាងផ្លូវសម្ភារៈ=** គ្រូពេទ្យបុរាណខ្មែរពឹងផ្អែកទៅលើថ្នាំ( ឱសថ)ដែលផ្សំឡើងពីរុក្ខជាតិនានាមាន សំបក ឫស ស្លឹក ផ្លែ ផ្កា ហើយនិង អ្អឹង ស្នែង កុយ ខ្នាយ ប្រមាត់ រោម ស្បែក សិលា លោហៈ នឹងសត្វល្អិតខ្លះ ហើយនឹងការរុជ (ដុតកំដៅ) កោស ជប់ ចាប់ ។ល។

**ខ-ខាងផ្លូវចិត្ត=** គ្រូពេទ្យបុរាណខ្មែរពឹងផ្អែកទៅលើបន្តអាគម គាថា នឹងការអបខេស ឬ ឧបកិច្ច ហើយនឹងការបញ្ចូលឬបន់ស្រន់ ។ល។

## ខាងផ្នែកសម្ភារៈ

ឱសថទាំងឡាយដែលផ្សំឡើងពីវត្ថុធាតុផ្សេងៗខ្មែរនិយមហៅថាថ្នាំ ។ ទោះជាវត្ថុដែលគេយកមកប្រើសម្រាប់តែរោគ រម្ងាប់រោគ ក៏ហៅឈ្មោះថាថ្នាំ, វត្ថុដែលសម្រាប់ការពារគ្រោះថ្នាក់និងទប់ទល់នូវគ្រោះថ្នាក់ ក៏ហៅថាថ្នាំដូចគ្នាផងដែរ ដូចជាថ្នាំកែ

រោគគ្រុនចាញ់ ថ្នាំកែរោគទាស់ជាដើម ជាថ្នាំព្យាបាល។ ចំណែកថ្នាំដែលស៊ី ផឹក ដើម្បីធ្វើឲ្យសាច់ស្វិតគង់ជាដើម គឺជាថ្នាំទប់ទល់នូវគ្រោះថ្នាក់ ។

## ខ្មែរប្រើថ្នាំជារបៀប២យ៉ាងគឺ

១_គេប្រើជារបៀបការពារជម្ងឺតម្កាត់ និង ជារបៀបព្យាបាលជម្ងឺ ។

២_គេប្រើជារបៀបការពារគ្រោះថ្នាក់ និង ជាវិធីទប់ទល់នូវគ្រោះថ្នាក់ផ្សេងៗ ។

## ខ្មែរប្រើថ្នាំក្នុងអំពើ២យ៉ាង

១_គេប្រើថ្នាំក្នុងផ្លូវ សុចរិត

២_គេប្រើថ្នាំក្នុងផ្លូវ ទុច្ចរិត

# ខ្មែរប្រើថ្នាំដោយមធ្យោបាយ២យ៉ាង

## ១_គេប្រើថ្នាំដោយត្រង់ចំពោះ

## ២_គេប្រើថ្នាំដោយប្រយោល

## I. *វិធីប្រើថ្នាំជារបៀបការពារជម្ងឺ*

វិធីប្រើថ្នាំរបៀបការពារជម្ងឺនេះ មានច្រើនបែបច្រើនប្រការណាស់ មានថ្នាំខ្លះគេប្រើដោយប្រយោលក៏មាន មានថ្នាំខ្លះគេប្រើដោយផ្ទាល់ ដូចជារបៀបចងភ្ជាប់និងសរពាង្គកាយ ដូចជាចងកម្ចង.កដៃជើងដៃក្រវាត់ចង្កេះ ។ល។ ហើយមានថ្នាំជាច្រើនដែលគេប្រើដោយត្រង់ចំពោះក្នុងការព្យាបាលជម្ងឺ ។

### ក. **ចំណុចថ្នាំការពារ**

*ឧទាហរណ៍ទី១* _ ប្រភេទថ្នាំការពារ, ប្រើដោយប្រយោល ។

ដើមទ្រាំង (ពពួកសារព្រឹក្ស ) គេយកបកចងនិងកាំជណ្ដើរ ដើម្បីការពារនូវខ្មោច ព្រាយ បិសាច, ដែលគេមានជំនឿថាអាច និងចូលមកការពារបាន ។ល។

*ឧទាហរណ៍ទី២-* ថ្នាំការពារ ប្រភេទចង.ក ។

គេយកឈើស្អុយ (ឈើនៅស្រុកខ្មែរមួយប្រភេទស្អុយដូចផាលាមក) មកចងនិងរំពោះធ្វើជាខ្សែ.ក ឲ្យកូនក្មេងពាក់ការពារជម្ងឺផ្សេងៗ ដែលគេយល់ថាបណ្ដាលមកពីខ្មោចព្រាយបិសាច ។

*ឧទាហរណ៍ទី៣-* ថ្នាំការពារ ប្រភេទចងដៃឬចង.ក ។

គេធ្វើឧបកិច្ចនិងនិបន្ធយកឫសបនទៅទិសព្យសាន មកកាត់ជាកំណាត់តូចៗ ចងនិងរំពោះទៅ ហើយចង.កដៃឬជើងដៃក្មេង ដើម្បីការពារក្មេងកើតពាន ។

*ឧទាហរណ៍ទី៤-* ថ្នាំការពារ, ប្រភេទថ្នាំចងក្រវាត់ចង្កេះ ។

គេយកវល្លិព្រះក្រុង (លតាជាតិប្រភេទច្រើនមានដុះតាមព្រៃភ្នំ) មកព្រួញញ់ធ្វើជាខ្សែក្រវាត់ សម្រាប់ក្រវាត់ចង្កេះ ដើម្បីការពារនូវជម្ងឺរុត ។ល។

*ឧទាហរណ៍ទី៥-* ថ្នាំការពារ ប្រភេទថ្នាំចងក្រវាត់ចង្កេះ ។

គេឧបកិច្ចនិងនិបន្ធយកដើមក្រូចគ្រប់ប្រភេទ មកធ្វើជាថ្នាំឬចងធ្វើខ្សែចង្កេះ ការពារសត្វអាសិរពិសផងទាំងឡាយ ដូចជាពស់វែកជាដើម ។

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

*ឧទាហរណ៍ទី៦_* ថ្នាំការពារ, ប្រភេទថ្នាំលេប ។

ល្ពៅជាតិមួយប្រភេទ កាលបើផ្លែទុំយូរទៅ គេឃើញសំបកក្រៀមស្វិត ហើយប្រេះបែកបង្ហាញឲ្យឃើញគ្រាប់នៅខាងក្នុង ។ គ្រាប់តូចៗប៉ុនគ្រាប់.គ ពណ៌ក្រហមព្រឿងៗ ហើយមានខ្មៅចុចបន្តិចហាក់ដូចជាគ្រាប់ភ្នែកគោ អ្នកខ្លះហៅថាវល្លិក្រៀមក្រំ ខ្លះហៅថាវល្លិភ្នែកគោ ។ គេយកគ្រាប់ក្រៀមក្រំទុំនេះ ចំនួន ៣ គ្រាប់ ឲ្យអ្នកដែលមិនទាន់កើតកញ្ជ្រិលលេប ដើម្បីការពារកុំឲ្យកញ្ជ្រិលកើតឡើងបាន ។ លេបមួយថ្ងៃ ១ គ្រាប់ ចំនួន ៣ ថ្ងៃ សម្រាប់ការពារក្នុងរយៈពេល ១ ឆ្នាំ ។

*ឧទាហរណ៍ទី៧_* ថ្នាំការពារ, ប្រភេទថ្នាំត្រាំផឹក

ថ្នាំការពារក្រោយដែលប្រសូត្របុត្តហើយដើម្បីកុំឲ្យទាស់ និងចាំសាច់ល្អ ។

ដោយខ្មែរយើងយល់ថា ទាស់គឺជាជម្ងឺដែលកើតឡើងពីការលោភចំណីអាហារ ឬ លោភព្រោះធ្វើការងារហួសកម្លាំង ក្រោយពេលដែលប្រសូត្រកូនហើយ, គេនិយាយថាសរសៃខ្ចី ។ ដូច្នេះការពារកុំឲ្យទាស់ និងឲ្យសាច់ឈាមសម្បុរស្បែក នៅគង់វង្សល្អដដែល គេមានថ្នាំដែលផ្សំជារបៀបការពារ ច្រើនបែបច្រើនយ៉ាង មានខ្លះជាប្រភេទថ្នាំស្ងោរ ខ្លះជាប្រភេទថ្នាំត្រាំ ។

ប្រភេទថ្នាំព្រាំ, ការពារចាស់ ឬលោះ ក្រោយប្រសូត្របុត្រ ។

វត្ថុធាតុដើម= គេកំណត់ឲ្យយកទឹកឃ្មុំក្នុងខែចេត្រ ចំនួន ១ ប៊ែត្រ ហើយនិងស្រា.ស ២ លីត្រកន្លះ ចាក់លាយជាមួយគ្នាដាក់ក្នុងកែវត្របឲ្យជិត ហើយទុកឲ្យចូលរសជាតិគ្នាទើបផឹក ។

វិធីផ្សំ= គេឲ្យចាក់ស្រាទៅក្នុងកែវមុន រួចហើយចាក់ទឹកឃ្មុំជាខាងក្រោយ ។

របៀបផឹក= ថ្នាំនេះផឹកមិនបានដាក់កប្រិតអ្វីទេ ។

កំណត់សំគាល់= អ្នកផឹកថ្នាំនេះគេសំគាល់ឃើញមានសាច់ឈាមស្រស់បស់ល្អស្អាត ។

*ឧទាហរណ៍ទី៨_* ប្រភេទថ្នាំការពារ, ថ្នាំថ្នាំងស្ងោរផឹកក្រោយពេលប្រសូត្របុត្រហើយ ។

វត្ថុធាតុដើម= ១ ដើមអង្រ្កង - ២ ដើមសង្កៃ - ៣ សំបកស្តុកស្តុរ - ៤ សំបករលោយ - ៥ លំពង់ក្រខុបព្រៃ - ៦ ឫសញស្រុក - ៧ ឫស.ញព្រៃ - ៨ ឫស.ញស្បាត - ៩ ស្មៅទឹកដោះខ្លា (គេយកទាំងដើមទាំងឫស)- ១០ ស្មៅព្រសិត(គេយកទាំងដើមទាំងឫស)-១១ ឫសក្រចៅ - ១២ លំពង់ឈើកំពីងពួយ -១៣ ស្លឹកឫស្សីស្រុក ។

វិធីផ្សំ= ចំនួនវត្ថុទាំង ១៣ មុខនេះគេយកភាគស្មើៗ គ្នាទាំង

រលស់ហើយស្ងោរផឹកជាធម្មតារៀងរាល់ថ្ងៃ ។ ប៉ុន្តែគេបានប្រាប់ថាក្នុងទឹកដំបូងត្រូវបង្ហុំភ្លើង ( បាននិយថាពេលដាក់ស្ងោរដំបូងត្រូវប្រើកំដៅឲ្យក្តៅខ្លាំង) ។

របៀបផឹក= មិនហានដាក់គីរិតទេ, ផឹកដូចជាផឹកតែ ។

*ឧទាហរណ៍ទី៩_* ប្រភេទថ្នាំការពារ, ថ្នាំស្ងោរផឹកការពារសុករលក ស្ត្រីដែលមានគភ៌បាន៨-៩ខែគេឲ្យផឹកមុនដើម្បីការពារគឺ

វត្ថុធាតុដើម = ១/វល្លិឪជុំ ២/សម្បកជ្រោយ ៣/សំបករលោយ ៤/សំបក.គ ៥/ខ្ញីទឹក ៦/ម្រេច៣គ្រាប់ ។

វិធីផ្សំ= វត្ថុទាំង៥មុខខាងលើ យកចំនួនស្មើៗគ្នាហើយដាក់ស្ងោរធម្មតា ។

របៀបផឹក= គឺផឹកដូចជាផឹកតែដូរឈ្មោះ ។

*ឧទាហរណ៍ទី១០_*ប្រភេទថ្នាំការពារ, ថ្នាំភ្នាំងស្ងោរការពារសុករលក ស្ត្រីដែលមានគភ៌បាន ៨ ឬ ៩ ខែគេឲ្យផឹកមុន ។

វត្ថុធាតុដើម = ១/ សំបកព្រៃបែកព្រៃជ្រុះ ២/វល្លិដកគន់ (ខ្លះហៅជាសគន់) ៣/បើបព្រលិត.ស-ក្រហម ។

វិធីផ្សំ= វត្ថុទាំង ៣ មុខនេះយកភាគស្មើៗគ្នា ហើយដាក់ស្ងោរជាធម្មតា ។

របៀបផឹកៈ ផឹកជប្ញពាដូចផឹកតែ ។

*ឧទាហរណ៍ទី១១_* ថ្នាំគាំពារ, ប្រភេទថ្នាំក្រាំស្រា, ការពារសុក រសេក, ឲ្យផឹកមុនពេលគភ៌បាន ៨-៩ ខែ ។

វត្ថុធាតុដើមៈ ១/ស្មៅជើងបង្កង ២/ជីរក្រសាំងទំហំ ៣/ជីរ ស (លើងលាក់) ៤/ជីរក្របហប (នាងវង) ៥/សំបកក្រសាំង ។

វិធីផ្សំៈ វត្ថុទាំងរស់នេះយកភាគស្មើៗគ្នា, ៤ មុខខាងដើម យកទាំងដើមទាំងឫស ហើយដាក់ក្នុងកែវចាក់ស្រាឲ្យលិចត្រាំទុក ចំនួន ១ អាទិត្យ សឹមឲ្យផឹក ។

វិធីផឹកៈ ផឹកម្ដង១ស្លាបព្រាបាយក្នុងមួយថ្ងៃ ។

## II. វិធីប្រើថ្នាំជារបៀបព្យាបាលជម្ងឺ

ថ្នាំដែលប្រើជារបៀបព្យាបាលមានច្រើនប្រភេទគឺៈ ជាប្រភេទ ថ្នាំស្ងោរ, ជាប្រភេទថ្នាំត្រាំ, ជាប្រភេទថ្នាំឆ្កង, ជាប្រភេទថ្នាំដុស, ជាប្រភេទថ្នាំលាប, ជាប្រភេទថ្នាំបំពោក, ជាប្រភេទថ្នាំចង, ជា ប្រភេទថ្នាំបន្តក់, ជាប្រភេទថ្នាំស្ងួន (គុលិកា) ជាប្រភេទថ្នាំបិទ, ជាប្រភេទថ្នាំចំហុយ ជាប្រភេទថ្នាំជក់ ជាប្រភេទថ្នាំកម្ទេច។ល។

## ក. ចំណុចថ្នាំស្ងោរ

ថ្នាំដែលឲ្យអ្នកជម្ងឺផឹក ដែលត្រូវស្ងោរ មានច្រើនជំពូកណាស់ មានថ្នាំខ្លះគេឲ្យស្ងោរផឹកទៅតាមធម្មតាមិនបានបញ្ជាក់ឬដាក់កម្រិតហាមប្រាមអ្វីសោះទេ ប៉ុន្តែមានថ្នាំខ្លះគេបានដាក់កម្រិតឲ្យស្ងោរ ដូចជាឲ្យស្ងោរទឹកបីយកទឹកមួយ (១/៣) បានន័យថាក្នុងចំនួនទឹក ៣ ភាគ ឬ ៣ លីត្រ ត្រូវស្ងោរឲ្យខះនៅសល់ទឹកចំនួនតែមួយភាគ ឬ ១ លីត្រ ។ល។

ការស្ងោរដែលមានដាក់កំហិតដូច្នេះ ព្រោះគេធ្វើដើម្បីចំរាញ់យកជាតិថ្នាំឲ្យខ្លាំងលើសពីធម្មតា ។

*ឧទាហរណ៍ទី១-* ប្រភេទថ្នាំស្ងោរផឹក, កំចាត់រោគដង្កូវនៅក្នុងពោះវៀន ដែលហៅថាព្រូន (ព្រូនវែង) ។

វត្ថុធាតុដើម= ឫសទទឹម

វិធីផ្សំ= គេយកឫសទទឹមចំនួនមួយភាគបីនៃកំសៀវ (១/៣) បកស្ងោរទឹក ៣ យកទឹកមួយ ( ១/៣ ) ។

របៀបផឹក= ផឹកមុនពេលបរិភោគអាហារ ពេលព្រលឹមភ្លាក់ពីដំណេក ផឹកឲ្យអស់ចំនួនទឹកដាំ ។

កំណត់សំគាល់= និងឃើញព្រូនស្លាប់ហើយធ្លាក់មក នៅពេល

បន្ទោរបង់លោបក ។ បើមិនឃើញធ្លាក់ទេ ព្រួនទោះនឹងស្លាប់ ហើយក្លាយទៅជាលាបកជាមិនខាន ។

ថ្នាំនេះគេធ្លាប់មានការពិសោធន៍មកជាច្រើន ឃើញថាមាន សភាពស័ក្តិសិទ្ធិមែន, ដូច្នេះបើគ្មានប្រសិទ្ធិភាពទេ នោះប្រាកដជា ផ្សំថ្នាំមិនត្រូវកំរិត ។ បើស្ងោរលើកទី២ ឲ្យផឹកនៅពេលព្រលឹម មិនទាន់បានបរិភោគអាហារម្ដងទៀត ។

*ឧទាហរណ៍ទី២*_ប្រភេទថ្នាំស្ងោរ, ថ្នាំឆ្អាំងស្ងោរផឹកសម្រាប់រោគ សរសៃ (ខ្មែរច្រើនថាសរសៃធ្វើទុក្ខឈឺចង្កេះឈឺខ្នង) ។

វត្ថុធាតុដើម= ១/អង្កោល (ឈើនេះស្រាយសម្បុរលឿង តែ ខ្លឹមក្រហមក្រមៅមានរសជាតិល្វីង) ២/អង្គាញ់ (ប្រភេទឈើនេះ មានផ្កាលឿង ខ្លឹមខ្មៅ មានរសជាតិល្វីងប្រើធ្វើជាបន្លែបាន"សម្ល ផ្កាអង្គាញ់" ) ៣/ហៃសាន (ដើម ស្លឹក ផ្កាស្រដៀងអង្គាញ់) ។

វិធីផ្សំ= វត្ថុទាំងបីមុខខាងលើនេះគេយកតែខ្លឹមទាំងអស់ ចំ នួនភាគស្មើៗគ្នា ហើយដាក់ក្នុងឆ្នាំង ដាក់ទឹកចំនួនបីដងវត្ថុទាំង នោះ រួចដាក់ស្ងោរឲ្យពុះចេញជាតិល្អទើបផឹក

វិធីផឹក=គេផឹកជាធម្មតាដូចផឹកតែ, លុះផឹកអស់ទឹកស្ងោរទី១ គេដាក់ស្ងោរជាលើកទី ២,ប៉ុន្តែស្ងោរលើកទី ២នេះ គេត្រូវស្ងោរ ទឹកពីរយកទឹកមួយ(១/២), កាលបើផឹកអស់ទឹកស្ងោរលើកទី ២

ហើយនៅមិនទាន់សាបថ្នាំទេ នោះគេត្រូវស្ងោរជាលើកទី៣, តែស្ងោរលើកទី៣ នេះ គេស្ងោរទឹកបីយកទឹកមួយ (១/៣) ។

កំណត់សំគាល់= កាលបើស្ងោរដល់លើកទីបីហើយផឹករស់ ត្រូវតែបោះចោលរបស់ស្ងោរនោះទៅទៀត (ដូរថ្នាំថ្មីទៀត) ។

*ឧទាហរណ៍ទី៣*– ប្រភេទថ្នាំផ្អាំងស្ងោរ, រោគសរសៃស្ត្រីដែលទើបឆ្លងទន្លេរួច (ខ្មែរច្រើនផឹកថ្នាំ,ដែលហៅថាថ្នាំសរសៃខ្ចី) ។

វត្ថុធាតុដើម= ១/ឫស.ញស្រុក, ២/ឫស.ញព្រៃ (ឫញស្បាត ដើមមានសណ្ឋានដូចញធម្មតា តែដើមល្អិតតូចៗប្រភេទដើមម្លូស ព្រប់ ធុំក្លិនដូចញ) ៣/បញ្ញើក្អែកទំដើមរលាយ ។

វិធីផ្សំ= វត្ថុទាំង ៣ យ៉ាងនេះ គេយកចំនួនភាគស្មើៗគ្នា ។

វិធីប្រើ= គេស្ងោរជាធម្មតាផឹកដូចផឹកតែ ។

*ឧទាហរណ៍ទី៤*– ប្រភេទថ្នាំស្ងោរផឹក, កែរោគទឹកនោមផ្អែម។

វត្ថុធាតុដើម= ១/ឫសកន្ទួតព្រៃ,(ឈើព្រៃស្លឹកល្អិតៗ ផ្លែមានរសជាតិជូរលាយចត់) ២/ដង្កិតខ្មោច, (មាន២យ៉ាង ដង្កិតធំនិងដង្កិតខ្មោចខុសគ្នាត្រង់ស្លឹកតូចដើមក៏តូច) ៣/ខ្ទឹមស,៧ មើម (កំពឹស) ៤/ម្រេច, ៧ គ្រាប់ ៥/ដែកគោល ១ ។

វិធីផ្សំ= ឫសកន្ទួតព្រៃ និងដង្កិតខ្មោចយកភាគស្មើគ្នា(ដង្កិត

ខ្ទាចយកទាំងដើមទាំងឫស) ហើយដាក់ស្ងោរតាមធម្មតា ។

របៀបផឹក= ផឹករបៀបផឹកតែ ។

កត់សំគាល់= ថ្នាំនេះគេបាន ពិសោធន៍មកហើយច្រើនគ្នា ដែលផឹកទៅឃើញជាគ្រប់គ្នា ។

*ឧទាហរណ៍ទី៥-* ប្រភេទថ្នាំស្ងោរផឹក, ព្យាបាលរោគទាស់ ។

វត្ថុធាតុដើម= សំបកខ្នុំ (ខ្នុំមាន២យ៉ាង ខ្នុំទឹក ខ្នុំគោក) ។

វិធីផ្សំ= យកសំបកខ្នុំទឹក ស្ងោររម្ងាស់ទឹក ៣ យកទឹក ១ ។

របៀបផឹក= ផឹកក្នុងការសង្កេត ។

*ឧទាហរណ៍ទី៦-* ប្រភេទថ្នាំស្ងោរផឹក, ព្យាបាលជម្ងឺកាមរោគ ឬហៅថារោគស្រីឬកើតស្វាយ ។

រោគស្វាយជារោគមួយប្រភេទ ដែលកើតអំពីការឆ្លងរវាងស្ត្រី និងបុរសដែលរួមបវេណី ។ ការសម្គាល់របស់គ្រូខ្មែរថារោគស្វាយ មានលក្ខណៈ ២ យ៉ាងគឺៈ

១- ហៅថារោគស្វាយក្រាប់ ជាប្រភេទរោគដែលស៊ីខាងក្នុង មិនបញ្ចេញឲ្យឃើញច្បាស់លាស់ ។

២- ហៅថាស្វាយបែក គឺរោគស្វាយដែលបែកចេញជាដំបៅ ឲ្យបានឃើញច្បាស់ ដូចជាពងបួរពកក ដែលមិនបានព្យាបាលឬព្យា

បាលមិនត្រូវបណ្ដាលទៅជាដំបៅ ។ល។

ថ្នាំព្យាបាលជម្ងឺកាបរោគនេះ ខ្មែរយើងមានចេះច្រើនបែប ច្រើនយ៉ាងណាស់, តែដែលខ្ញុំលើកយកមកពណ៌នាក្នុងទីនេះ ជាថ្នាំផ្នាំងមួយប្រភេទដែលគេចាត់ទុកថាមានប្រសិទ្ធិភាពគ្រាន់បើគឺៈ

វត្ថុធាតុដើម= ១/គល់រំចេក (រុក្ខជាតិមួយប្រភេទស្លឹកវែងៗ មានបន្ទាទៅហាបស្លឹកទាំងសងខាងដូចស្លឹកប្អាស់, ដើមមានសាច់សាញជាសរសៃ មានឫសផុសសំយុងដូចខ្សែព្ធរ, ស្លឹកប្រើការបានដូចជាត្បាញកន្ទេលជាដើម) ២/គល់ប្អាស់ឬហៅថាក្ដិលប្អាស់, ៣/វល្លិមុខឈ្លាង, ៤/ផ្នាំងឫស្សីស្រុក, ៥/ផ្នាំងឫស្សីព្រៃ, ដែកឬដែកគោលចាស់ៗច្រេះចាប់ចំនួន ៧ ។

វិធីផ្សំ= វត្ថុទាំង ៥ មុខខាងដើមគេយកភាគស្មើរៗគ្នា ។

វិធីប្រើ= គេស្ងោរផឹកជាធម្មតាដូចផឹកតែ ។

*ឧទាហរណ៍ទី៧*_ ប្រភេទថ្នាំស្ងោរ, ព្យាបាលរោគប្រមេះ ។

ប្រមេះជារោគមួយប្រភេទដែលធ្វើឲ្យពិការផ្លូវទឹកមូត្រ ដែលបណ្ដាលឲ្យកើតទៅជាខ្ទុះ ហើយក្លាយទៅជាគ្រាប់យ៉ាងរឹង អាចរាំងរាំងស្ទះផ្លូវទឹកនោម ធ្វើឲ្យអ្នកជម្ងឺពិបាកក្នុងការបន្ទោបង់បស្សាវៈ រហូតដល់បាត់បង់ជីវិតដោយសារទឹកមូត្រមិនចេញក៏មាន ។ រោគនេះមានពីរយ៉ាងគឺៈ ប្រមេះបែបជាទឹកខាប់ៗ ខ្មែរ

យើងហៅថាប្របេះទឹកបាយ ប្រ៉ាងទៀតជាគ្រាប់ៗហើយរឹង គេ
ហៅថាប្របេះគ្រាប់ ។ វិធីព្យាបាលជាប្រភេទថ្នាំស្មោរមានៈ

វត្ថុធាតុដើម= ១/ សម្បកស្វាយព្រៃ, ២/ រំពេរ ។

វិធីផ្សំ= គេដាក់ស្មោរតាមធម្មតា ហើយបន្ថែមរំពេរឲ្យប្រៃល្មម
ផឹកបាន បិនឲ្យប្រៃពេក ។

វិធីផឹក= គេផឹកដូចតែ ជំនួសទឹក ។

*ឧទាហរណ៍ទី៨*_ ប្រភេទថ្នាំឆ្នាំងស្មោរ, កែរោគធ្លាក់ឈាម ។

ខ្មែរយើងមានរោគមួយយ៉ាងដែលធ្លាក់ឈាមតាមមាត់ ជួន
កាលបើធ្លាក់ច្រើនបណ្តាលឲ្យស្ទះស្លាប់ភ្លាមមួយរំពេច ។

វត្ថុធាតុដើម= ១/សម្បកស្តុកស្តុរ ២/កណ្តាលស្បាត ៣/សំ
បកកប្បាស ។

វិធីផ្សំ= សំបកស្តុកស្តុរយក១ភាគ(១/២) កណ្តាលស្បាតដក
យកទាំងដើមទាំងឫស ចំនួនស្មើរស្តុកស្តុរ, ហើយសម្បកកប្បាស
យកចំនួនស្មើរគ្នាដែរ ហើយដាក់ក្នុងឆ្នាំងស្មោរឲ្យពុះ ។

វិធីប្រើ= ស្មោរផឹកធម្មតាជំនួសទឹក ។

*ឧទាហរណ៍ទី៩*_ប្រភេទថ្នាំស្មោរ, កែរោគធ្លាក់ឈាមតាមមាត់។

វត្ថុធាតុដើម= ១/ដើមភ្អែកព្រាប ២/ដើមស្តុកស្តុរ ៣/ដើម

ក្រខុបព្រៃ ៤/ មើមខ្ញីជ្រឹង ៥/ មើមថ្នាំចិន ។

វិធីផ្សំ= វត្ថុ៤មុខខាងដើមយកចំនួនភាគស្មើរគ្នា ឯមើមថ្នាំចិនយក ៤ ពីឡើង ។

វិធីប្រើ= គេស្ងោរផឹកជាធម្មតាឬដូចផឹកតែ ។

*ឧទាហរណ៍ទី១០_* ប្រភេទថ្នាំស្ងោរ, កែរោគក្អក ។

វត្ថុធាតុដើម= ១/ បូររាល ២/ រំបិល ។

វិធីផ្សំ=គេយកបូររាលនេះហើយមកស្ងោរ ដាក់រំបិលស្មានឲ្យប្រែរាចផឹកបាន ។

វិធីប្រើ= ផឹកក្នុងការស្អាបស្អុំ ។

*ឧទាហរណ៍ទី១១_* ប្រភេទថ្នាំស្ងោរ, ផឹកកែរោគគ្រុនចាញ់ (ឬគ្រុនលោះ) ធ្លាក់អណ្ដើក (ប្រហែលធ្លាក់លំពែង) ។

វត្ថុធាតុដើម=. ១/ស្លូលពោតទុំមួយខ្ទបចំនួន៧ ២/ស្លឹកគ្រៃខ្ទបចំនួន ៧ គល់ ៣/ ខ្ទឹមស ៧ មើម ៤/ម្រេច ៧ គ្រាប់ ៥/ដែកគោលច្រេះ១ និងដីដំបូកមួយពំនូតប៉ុន កដៃក្មេង ។

វិធីផ្សំ= ស្លូលពោតនិងគល់ស្លឹកគ្រៃចងជា ៣ ចំណងនិងអាំងពោះខ្មៅ រួចដាក់ចូលទៅក្នុងឆ្នាំងជាមួយនិងខ្ទឹមស ម្រេច ដែកគោល, ទើបយកដីដំបូកមកសូនធ្វើជារូបអណ្ដើក ហើយដាក់ចូលទៅក្នុង

ឆ្នាំងជាមួយផ្កាចំអរស់លើជើងស្ងោរ ដោយប្រើសំដីឧបកិច្ចថា បើកាលណាខ្ញុំស្ងោរទៅរណ្ដើកនេះរលាយ សូមឲ្យរណ្ដើកនៅក្នុងពោះខ្ញុំនោះរលាយផងដែរ ( ពាក្យសូត្រដាស់ក្នុងពេលស្ងោរដូចមានចែងទៅខាងមុខ) ។ ប៉ុន្តែដីដំបូកដែលយកមកស្ងួនធ្វើរូបរណ្ដើកត្រូវឧបកិច្ចរួចសិនសិមឆ្កិះយកមក (ពិធីឧបកិច្ចមានចែងទៅខាងមុខទៀត) ។

វិធីស្ងោរ= ត្រូវស្ងោរឲ្យពុះលុះត្រាតែរលាយរូបរណ្ដើកដែលស្ងួននោះអស់រលីង ទើបដាក់ចេញពីភ្លើងទុកឲ្យរងថ្លាមួយស្ទុះ។

វិធីផឹក=ត្រូវអង្គុយច្រហោង ហើយសិតទឹកថ្នាំចូលមកក្នុងផ្តិល ឬត្រឡោក រួចឧបកិច្ចថា បើកាលណាផឹកទឹកថ្នាំនេះចូលទៅរោគគ្រុនចាញ់ធ្លាក់រណ្ដើកត្រូវតែស្ងួនឲ្យ ទើបផឹកថ្នាំហើយលើកឆ្នាំងថ្នានោះផ្កាប់ចោល ក្រោកដើរចេញទៅហោង ។

កំណត់សម្គាល់=អ្នកដែលបានផឹកថ្នាំនេះបញ្ជាក់ប្រាប់ថា កាលបើគេផឹកថ្នាំរួចហើយ លើកឆ្នាំងផ្កាប់ក្រោកឈរឡើង គេសំគាល់ឃើញថា អាការរោគរណ្ដើកក្នុងពោះរបស់គេហាក់ដូចជាធ្លាក់ចុះមកក្រោមយ៉ាងពិតប្រាកដមែន ។

*ឧទាហរណ៍ទី១២*_ ប្រភេទថ្នាំស្ងោរផឹក កែរោគកន្ទាលត្រអាក។

រោគនេះកើតឡើងនៅលើស្បែក ឡើងកន្ទួលហ៊ើម ហើយ

បណ្ដាលឲ្យរមាស់ចង់តែកេះ ។

វត្ថុធាតុដើម= ១ ដើមខ្ញែរ (ខ្ញែររមាស់) ។

វិធីផ្សំ= ដកយក ៧ គល់ បកកាត់លាងទឹកឲ្យស្អាត ដាក់ក្នុងឆ្នាំងស្ងោរទឹកបីយកទឹកមួយ(១/៣) ។

វិធីប្រើ= ផឹកតាមចម្ងា មិនមានកំហិត ។

*ឧទាហរណ៍ទី១៣-* ប្រភេទថ្នាំស្ងោរផឹក ព្យាបាលជម្ងឺហឺត ។

ហឺតជាអាការរោគដែលពិបាកក្នុងការដកដង្ហើម ថប់ហប់ហត់ ប៉ផ្ដឹតប៉ផ្ដក់ បណ្ដាលមកពីស្លេស្ម៍ដោយសួតមានពិការ ។

វត្ថុធាតុដើម= ១/ ខ្ទឹមស្បែង   ២/ កំពោរ ។

វិធីផ្សំ= យកខ្ទឹមស្បែងមកស្ងោរឲ្យចេញជាតិល្អ ហើយចាក់ទុកក្នុងកែវមួយ រួចទើបយកកំពោរមួយស្លាបព្រាបាយ ទៅលាយនិងទឹកសុទ្ធហើយទុកឲ្យរងថ្លា ទើបយកទៅចាក់លាយនិងទឹកស្ងោរស្បែង កូរឲ្យលាយចូលគ្នាសព្វល្អ ។

របៀបផឹក= ក្នុងការលាយម្ដងនេះត្រូវផឹកឲ្យអស់ក្នុង ១ ថ្ងៃ ហើយស្ទង់មើល តើមានធូរស្រាលឬទេ? ។

កំណត់សំគាល់= បើគាប់កបហើយ អាចនិងបន្ថែមទ្វេឡើង តាមការយល់ឃើញពីគ្រូអ្នកព្យាបាល ។

*ឧទាហរណ៍ទី១៤_* ប្រភេទថ្នាំស្មោរស្រោច កំចាត់ពិសពស់ ។

ជំពូកពស់ប្រភេទខ្លះ បើកាលណាខាំហើយ បណ្តាលឲ្យហើមសាច់ព្រងកន្លែងរបួស រួចចេះតែហើមរាលដាលធំឡើងៗជានិច្ច. បើព្យាបាលមិនត្រូវទេ អាចនឹងរលួយជ្រុះសាច់ចេញបាន ដូចជាពស់ខៀវ ពស់ហនុមានកន្ទុយខ្លាច ។ល។

វត្ថុធាតុដើម= យកវែកព្រឡាក ២-៣ (វែកខ្មែរយើងដួសបាយសម្ល ដែលធ្វើពីព្រឡាកដូង) ។

វិធីផ្សំ= កាត់វែកយកត្រឹម.ក ហើយដាក់ស្មោរទុកឲ្យពុះយូរបន្តិច រួចបន្ថយភ្លើងទុកឲ្យនៅក្តៅឧណ្ហៗ ។

វិធីប្រតិបត្តិ= យកកំណាត់សំពត់ស្អាតជ្រលក់ជូតលើមុខរបួស និងកន្លែងដែលហើម លុះត្រាតែឃើញស្រកហើមទើបឈប់ ។

កំណត់សម្គាល់= កាលបើអ្នករបួសត្រូវជូតដោយទឹកស្មោរវែកដែលនៅក្តៅឧណ្ហៗ អាការហើមក៏ចេះតែស្រកចុះជាលំដាប់ ។

*ឧទាហរណ៍ទី១៥_* ប្រភេទថ្នាំស្មោរ ព្យាបាលជម្ងឺកាមរោគ ។

វត្ថុធាតុដើម= ១/ឫសឫស្សីស្រុក-ព្រៃ ២/សម្បកស្តុកស្តុរ ៣/អំពៅខ្មៅ ៤/ក្តិលឡាស់ ៥/ដូងទុំ ៦/បើបផ្កាចិនសែ ៧/ឫសល្ហុងញីឬឈ្មោល ។

វិធីផ្សំ= សំបកស្តុកស្តុរ, ឫសល្ហុង, ក្តិលឡាស់, បើបផ្កាចិនសែ

ទាំង ៤ មុខនេះយកភាគស្មើៗគ្នា ។ រួចដាក់វត្ថុទាំង ៧ មុខនេះទៅក្នុងឆ្នាំងមួយហើយស្ងោរឲ្យផាស់មុខនិងស្ងោរ ។

របៀបផឹក= មិនបានដាក់កំហិតអ្វីទេ ។

*ឧទាហរណ៍ទី១៦*_ ប្រភេទថ្នាំស្ងោរ កែរោគទឹកនោមផ្អែម ។

វត្ថុធាតុដើម= ១/ឫសល្ហុងល្ពៅ ២/ឫសស្លូវរពាស់ ។

វិធីផ្សំ= វត្ថុទាំង ២ មុខនេះយកចំនួនស្មើៗគ្នា រួចចងនិងរំពោះខ្មៅ ៣ ចំណង ហើយដាក់ដែកច្រេះមួយទៅក្នុងឆ្នាំងស្ងោរ។

របៀបផឹក= ផឹកជាធម្មតារបៀបផឹកតែ ។

*ឧទាហរណ៍ទី១៧*_ ប្រភេទថ្នាំស្ងោរផឹក កែរោគស្រែញ ។

ស្រែញជារោគមួយប្រភេទច្រើនកើតនៅព្រង់ក មានស្រែញក្រាប់ ស្រែញបណ្តើរកូន ស្រែញទាប ស្រែញបែក ។

វត្ថុធាតុដើម= សម្បុកកណ្ដៀរ (កាលបើជីកទៅឃើញដីបែបសផុសៗ រាងមូលឲ្យសំគាល់បានថាជាសំបុក) ។

វិធីផ្សំ= យកដីសំបុកនេះ២ឬ៣សំបុកល្មមដាក់ស្ងោររួម ។

វិធីផឹក= ទុកឲ្យរងផ្លាស់មិនផឹក ។

កំណត់សម្គាល់= ថ្នាំរបៀបនេះគេច្រើនស្ងោរព្រផាស់មុនស្ងោរ។

*ឧទាហរណ៍ទី១៨*- ប្រភេទថ្នាំស្ងោរហើយត្រាំ កែរោគពិសរុងខ្មៀង ។

ពិសជារោគមួយប្រភេទ ដែលឃើញពងដោរនៅលើសាច់ បណ្តាលឲ្យឈឺចាប់ពើតក្រហាយជាខ្លាំង មានច្រើនប្រភេទ ។

ពិសរុងខ្មៀងបើតាមការសង្កេតរបស់ខ្មែរ ថាមានលក្ខណៈ ៥ យ៉ាងគឺ:

១- បើកើតតាមបាតដៃស្តាំឬឆ្វេង ហើយឃើញខ្សៀងខ្មៅជាំ គេឲ្យឈ្មោះថាវង់ព្រះអាទិត្យ ។

២- បើកើតចំចង្អេកដៃស្តាំឬឆ្វេង គេហៅថាចំពាបនាគ ។

៣- បើកើតចំថ្នាំងដៃឆ្វេងឬស្តាំ គេឲ្យឈ្មោះថារុងខ្មៀង ។

៤- បើកើតចំគល់ក្រចកស្តាំឬឆ្វេង គេហៅថាចិញ្ចើមប្រវឹក។

៥- បើកើតចំចុងម្រាមដៃឆ្វេងឬស្តាំ គេហៅថាពស់ភ្លាញ ។

វត្ថុធាតុដើម= ១/អង្ករលីង ២/ឫសល្ហុងញី.ឈ្មោល ៣/ឫសប្រផេញញី.ឈ្មោល ៤/វល្លិកំពោរក្រហម ៥/សំបកករពេ្កាល។

វិធីផ្សំ= វត្ថុទាំង ៥ មុខនេះដាក់ចូលលាយគ្នា ហើយស្ងោរឲ្យពុះយូរបន្តិច រួចទុកឲ្យត្រជាក់សឹមត្រាំ ។

របៀបត្រាំ= ដាក់ចូលឲ្យលិចទៅក្នុងទឹក ។

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
32

# ខ. ចំពូកថ្នាំលាប

លាបគឺជាវិធីមួយយ៉ាងដែលគេធ្វើថ្នាំឲ្យខាប់ឬរាវ អាចជ្រលក់ ឬផ្តិតយកទៅជូតលើស្បែកអ្នកជំងឺបាន ។

*ឧទាហរណ៍ទី១-* ប្រភេទថ្នាំលាប, កំចាត់រោគសើស្បែកមួយ ប្រភេទដែលហៅថារោគស្រែង មានស្រែងដែក ស្រែងផ្កាស្រែង ផេះ ។ល។

វត្ថុធាតុដើម= ១/ស្លឹកហៃសាន (ឈើនេះមានដើម ស្លឹក ផ្កា ផ្លែ ស្រដៀងគ្នានឹងដើមអង្កាញ់ ) ២/ប្រេងកាត ។

វិធីផ្សំ= គេយកស្លឹកហៃសានខ្ចីៗមកបុកឲ្យល្អិត ហើយលាយ ជាមួយនឹងប្រេងកាតឲ្យជោក ផ្អាប់ទុក ១ យប់ ។

របៀបលាប= គេយកមកលាបចំពីលើ ។

កំណត់សំគាល់= កាលបើត្រូវថ្នាំដែលលាប រោគស្រែងនឹង របកចេញពីស្បែក, ហើយលាបបន្ថែមលុះត្រាតែរបកចេញអស់។

*ឧទាហរណ៍ទី២-* ប្រភេទថ្នាំលាប, ព្យាបាលរោគកម ។

កមជារោគមួយប្រភេទ រោគសើរស្បែក ដែលមានមេរោគ បណ្តាលឲ្យរមាស់ ហើយមានទឹករងៃនិងខ្ទុះ ។

វត្ថុធាតុដើម= ១/ស្លឹករាក់.ស (ដើមឈើតូចស្លឹកក្រាសសម្បុរ

ប្រផេះ ជំរ.ស មាន ២ប្រភេទគឺ រាក់ស-រាក់ក្រហមៗ ផ្កាសម្បុរស្វាយស្រគាំ) ២/ប្រេងដូង ។

វិធីផ្សំ= គេកាច់យកព្រួយរាក់សដែលមានចេញជំរ.សៗ បកហាន់ឲ្យល្អិតបន្តិច ហើយលាយជាមួយនិងប្រេងដូង រួចផ្អាប់ទុកមួយយប់ឬពីរយប់ឲ្យចេញជាពិល្អ ។

វិធីប្រើ= គេលាបតាមធម្មតាមិនមានដាក់កំហិតអ្វីទេ ។

កំណត់សំគាល់= ថ្នាំនេះនិងធ្វើឲ្យកបបានសះជាយ៉ាងមានប្រសិទ្ធិភាព ។

*ឱសថបុរាណទីពីរ*– ប្រភេទថ្នាំលាប, កំចាត់រោគរមាស់ទូទៅ ។

វត្ថុធាតុដើម=១/ក្បាលខ្ញាយ, ២/ក្បាលរមៀត, ៣/មើមក្តាតហោរាំ ( ឈ្មោះក្តាតមួយប្រភេទស្លឹកធំៗមានរសជាតិរមាស់ខ្លាំងណាស់ ) ៤/ក្រមួនឃ្មុំ, ៥/គ្រាប់ម្រេច, ៦/ប្រេងដូង ។

វិធីផ្សំ= វត្ថុពីទី១ ដល់ទី៤ យកភាគស្មើរគ្នា, ម្រេចយកកន្លះភាគ (១/២) ហើយបុកឲ្យល្អិតលាយនិងប្រេងដូង ដាក់ដាំរម្លាស់ឲ្យរលាយចូលគ្នាសព្វទាំងអស់ (ប្រយ័ត្នថែភ្លើងកុំឲ្យខ្លោច) ។

វិធីប្រើ= គេលាបថ្នាំនេះតាមធម្មតាគ្មានដាក់កំហិតអ្វីទេ ។

កំណត់សំគាល់= ថ្នាំនេះមានប្រសិទ្ធិភាពយ៉ាងស័ក្តិសិទ្ធ ។

*ឧទាហរណ៍ទី៤_* ប្រភេទផ្កាលាប កែរោគគ្រុនរក ។

វត្ថុធាតុដើម=១/ដើមកបិលភស្តុ(មានញីឈ្មោល)២/ស្ករ.ស។

វិធីផ្សំ= បើរកបានញីឈ្មោល យកទាំងពីរ ហើយបុកលាយជាមួយនិងស្ករ.ស ។

វិធីប្រើ= លាបពីលើគ្រុនរក តាមការយល់ឃើញថាត្រូវលាបប៉ុន្មានដងដែលគួរលាប ។

*ឧទាហរណ៍ទី៥_* ប្រភេទផ្កាលាប កែរោគជ្រុះសក់ ។

វត្ថុធាតុដើម= ១/ខ្លាញ់ជ្រូកឆៅ ២/ពងកំពឹសទឹកសាប ៣/ប្រេងដូង ។

វិធីផ្សំ= គេយកពងកំពឹសបុកឲ្យល្អិត លាយជាមួយខ្លាញ់ជ្រូកនិងប្រេងដូង ចំនួនស្មើរភាគគ្នា ។

វិធីប្រើ= ការលាបនេះគ្មានកំហិតអ្វីទេ លាបទៅតាមការយល់របស់ខ្លួនថាពេលណាដែលគួរលាបទៀត ។

កំណត់សម្គាល់=ផ្កានេះគេសំគាល់ឃើញថា អ្នកដែលជ្រុះសក់ពីក្បាលអស់រលីងគ្មានឫសសរសៃ ហើយលាបផ្កានេះទៅ ឃើញសក់ដុះវិញពេញដូចដើម ។

# គ. ចំណុចថ្នាំបន្តក់

បន្តក់គឺជាវិធីមួយដែលគ្រូពេទ្យបុរាណខ្មែរប្រើព្យាបាលជម្ងឺខ្លះ ដែលកើតនៅលើរាងកាយហើយគេប្រើលេបមិនកើត ដូចជាក្នុងភ្នែក ក្នុងរន្ធត្រចៀក ច្រមុះ ។ល។ និងមានថ្នាំខ្លះដែលមានជាតិពិស ពុលខ្លាំង ដែលគេត្រូវការប្រើត្រឹមដំណក់ ។ ហើយនិងថ្នាំខ្លះសម្រាប់អ្នកជម្ងឺដែលឈឺធ្ងន់ជាប់លែងដឹងខ្លួនប្រាណ លេប ផឹកមិនកើតទើបគេបន្តក់ថ្នាំចូលទៅក្នុងមាត់អ្នកជម្ងឺនោះ ។ល។

*ឧទាហរណ៍ទី១*_ ប្រភេទថ្នាំបន្តក់, បំបាត់រោគឈឺភ្នែក ។

វត្ថុធាតុដើម= ១/ពងខ្យង, ២/សាច់ជូរ.ស ។

វិធីផ្សំ= គេយកពងខ្យងមកប្រពាច់យកតែទឹក លាយឲ្យជាមួយនឹងសាច់ជូរ.ស.បំពង រួចត្រងនឹងកំណាត់សំពត់យ៉ាងល្អិតធ្វើជាថ្នាំដំណក់សម្រាប់បន្តក់ភ្នែកដែលឈឺ ។

របៀបប្រើ= គេបន្តក់ចូលទៅក្នុងភ្នែកដែលឈឺ ២-៣ ដងក្នុង ១ថ្ងៃ តាមការស្ទាបស្ទង់មើលជម្ងឺខ្លាំងឬខ្សោយ ។

កំណត់សំគាល់= ថ្នាំនេះមានប្រសិទ្ធភាព, ទោះជាភ្នែកចាប់ផ្ដើមក្រៀងណាយហើយក៏ដោយ អាចជាបានកុំតែយូរពេក ។

*ឧទាហរណ៍ទី២_* ប្រភេទថ្នាំបន្តក់,ព្យាបាលសត្វល្អិតចូលត្រចៀក ដូចជាដង្កូវ ស្រមោច ។ល។

វត្ថុធាតុដើម= ១/ថ្នាំខ្លាំង,(ថ្នាំជក់) ២/ជ័រល្ហុង, ៣/ទឹកក្រូចឆ្មារ ៤/កំបោរ ។

វិធីផ្សំ= យកថ្នាំខ្លាំងប្រឡាក់ទឹកក្រូចឆ្មារដែលលាយជាមួយនិងជ័រល្ហុង ហើយនិងកំបោររួចច្របាច់យកទឹកបន្តិច ។

វិធីប្រើ= គេបន្តក់ចូលទៅក្នុងរន្ធត្រចៀក ទុកមួយស្របក់ ។

កំណត់សំគាល់= សត្វដែលចូលនោះនិងស្លាប់ ហើយគេផ្អៀងត្រចៀកឲ្យទឹកថ្នាំចេញ សត្វនិងធ្លាក់ចេញមកជាមួយផងដែរ ។

*ឧទាហរណ៍ទី៣_* ប្រភេទថ្នាំបន្តក់ ដាក់រន្ធច្រមុះ កែរោគឈឺក្បាលឬរោគផ្តាសាយ ។

វត្ថុធាតុដើម= បើបរំដេង

វិធីផ្សំ= យកបើបរំដេងបកលាងឲ្យជ្រះស្អាតល្អ ហើយដាក់បុកនិងត្បាល់ឲ្យល្អិត រួចយកកំណាត់ដែលស្អាតបកខ្ចប់ ។

វិធីប្រើ= ឲ្យអ្នកជម្ងឺដេក ហើយច្របាច់បន្តក់ចូលទៅក្នុងរន្ធច្រមុះបន្តិច ។

កំណត់សំគាល់= មួយសន្ទុះក្រោយមក និងមានកណ្តាស់ធ្លាក់សំបោរជាដើម ដែលជាហេតុធ្វើឲ្យរោគឈឺក្បាលបានធូរស្បើយ

ជាពិសេស ។

## ឃ. បំពុកថ្នាំកម្លោច

កម្លោចគឺជាវិធីដែលគេធ្វើឲ្យខ្លោច វិធីកម្លោចនេះមានធ្វើជារបៀបពីរយ៉ាងទៅតាមស្ថានភាពនៃថ្នាំ ព្រោះមានថ្នាំខ្លះគេរកបានដោយងាយ ឬគេមិនត្រូវការឲ្យខ្លោចសព្វទាំងអស់ ដូច្នេះគេធ្វើបែបខ្ជីខ្ជា ដោយយកទៅដុតនិងភ្លើងអណ្ដាត ឬភ្លើងរងើកឲ្យខ្លោចច្រើន ឬតិចតាមគេត្រូវការ, ប៉ុន្តែមានថ្នាំខ្លះដែលគេរកបានដោយកម្រ ហើយគេត្រូវការឲ្យខ្លោចសព្វទាំងអស់មិនមានសេសសល់ នោះគេយកឆ្នាំងឬអំបែងមកដាក់លីងឲ្យខ្លោចបន្តិចម្ដងៗ ទាល់តែខ្លោចអស់ ។

*ឧទាហរណ៍ទី១*- ប្រភេទថ្នាំកម្លោចពោប ,កំចាត់រោគស្បែក ។

រោគឬប្រភេទដែលកើតនៅលើស្បែកក្បាល ធ្វើឲ្យជ្រុះសក់ ហើយសក់មិនដុះឡើងវិញ ធ្វើឲ្យតំបែកស៊ុៗ. បើទុកយូរទៅមិនព្យាបាលទេ មេរោគអាចនិងស៊ីសក់ជ្រុះអស់រលីងគ្មានសល់ ។

វត្ថុធាតុដើម៖ ១/កំណាត់កន្ទេលក្រហម ( កន្ទេលដែលធ្វើពីដើមចែងចែង ហើយគេច្រើនតែជ្រលក់ពណ៌ក្រហម ជាស្មៅកក់ ឬយប្រើរាទ់ដើម្បីលេងៗ ) ២/ខ្លាញ់ជ្រូក ។

វិធីធ្វើ = យកកំណាត់កន្ទេលក្រាលអោយកំដៅពេញខ្លោចរបស់ព្រលោយយកាបូយល៉ែងខ្លាញ់ត្រី ។

របៀបការពារ ការពារឆ្អឹងត្រង់កន្លែងដែលកើតរោគ ។

កំណត់សំគាល់ មិនបូរប៉ុន្មានទិងឃើញសក់ចាប់ផ្តើមដុះឡើងវិញ បន្តិចម្តងៗដោយសារំណោចថ្នាំដែលមានប្រសិទ្ធភាព ។ ថ្នាំនេះសាស្ត្រាចារ្យប្រាក់ឈ្មោះ ជង់.ផរ៉ុប ដែលកើតរោគប្រភេទនេះហើយបញ្ជាទិញថ្នាំទៅពីបរទេសជាច្រើនដូចជាស្រុកបារាំងជាដើមយកទៅលាបតែមិនជាសោះ លុះត្រូវថ្នាំកំដៅចនេះទើបជាហើយដុះសក់ឡើងវិញ ដែលអ្នកផងកោតថាមិនគួរនិងឲ្យជឿកើត ។

*ឧទាហរណ៍ទី២_* ប្រភេទថ្នាំកម្ចាត់ការ, កែរោគ ត្រអក ឬ ពារអក ។

ត្រអក ជាអាការរោគមួយប្រភេទ ដែលមានឡើងជាកណ្តាប់មានទឹករងៃ, ច្រើនតែកើតនៅត្រង់កជើង ។

វត្ថុធាតុដើម ១/ គ្រាប់ម្រះញាំ ២/ គ្រាប់ស្លែង ៣/ ផ្លែខ្នុរ ៤/ ម្រេញជួង ។

វិធីធ្វើ ត្រូវយកទាំងផ្លែទាំងគ្រាប់ ឲ្យបានស្មើភាគនិងគ្រាប់ស្លែង ហើយទាំងពីរមុខនេះរួមគ្នាឲ្យបានភាគស្មើនិងម្រះញាំ ។

វិធីប្រើ វត្ថុទាំងពីរមុខនេះ យកមកកំដៅកសើយលាយជាមួយ

ប្រេងដូងឲ្យចូលជាពិសេស ។

វិធីប្រើ= លាបតាមធម្មតា ដែលមេសល់ផ្តួរក្រោយប៉ុន្មានថ្ងៃ តែពេលលាបគេមានគាថាសូត្រស្រឡាប់បេរ៉ាលា "ឥន្ទ សម្មិ " ។

*ឧទាហរណ៍ទី៣_* ប្រភេទថ្នាំកម្លោចលោប, កែរោគពារក ។

វត្ថុធាតុដើម= ១/ប្រ៉ព្រ ២/សព្វគីង្គក់ ៣/ប្រេងដូង ។

វិធីផ្សំ= គីង្គក់យកចំនួនពាក់កណ្តាលប្រ៉ព្រ ហើយកម្លោចលាយជាមួយនិងប្រេងដូង ។

វិធីប្រើ= លាបតាមធម្មតា តែពេលលាបមានគាថាសូត្រសំឡប់បេរ៉ាថា: ឥន្ទ សម្មិ ។

*ឧទាហរណ៍ទី៤_* ប្រភេទថ្នាំកំពោធផឹក, ព្យាបាលជម្ងឺហឺត ។

ហឺតជារោគមួយប្រភេទដែលមានអាការៈហត់ ថប់ ស្ទះខ្យល់ដកដង្ហើម ពិបាកនឹងដកដង្ហើមចេញចូលយ៉ាងប៉ិត្តប៉ិតក់ បណ្តាលមកពីមានស្លេស្មជាច្រើននៅក្នុងបំពង់ក ដោយហេតុក្នុងតួពិការ ។ ជម្ងឺនេះគេធ្លាប់ព្យាបាលមកបានជាដាច់ត្រឡះយ៉ាងមានប្រសិទ្ធភាព ដោយប្រើថ្នាំកម្លោចមួយប្រភេទ ដែលគេធ្លាប់បានពិសោធជាច្រើនគ្រួចមកហើយគឺ:

វត្ថុធាតុដើម= ១/ស្បែកឈើ... (ក្តួតស្បែក

ទាំងប្ញស,ប៉ុណ្ណេះត្រូវរៀងក្បាល) ៧/ពីនស្លឹកទ្រាំង(រោគស្វ៊ែរ័ត) ដែលគេយកមកតម្រៀបឲ្យបានកម្រាស់ ២ ធ្នាប់ ឬ២សង់ទីម៉ែត្រ និង ប្រវែង ១ ចំអាម ឬ ២ ដេស៊ីម៉ែត្រ ។

វិធីធ្វើ=ជាដំបូងគេយកស្បែកល្អូសមករោលភ្លើង កោសយក រោមចេញឲ្យអស់ ហើយទុកដោយឡែក, រួចទើបយកស្បែកនោះ មកកាត់ជាកំណាត់ៗ ហើយដាក់ទៅក្នុងឆ្នាំងកម្លោច ។ ក្នុងការ កម្លោចនេះគេប្រយ័ត្នភ្លើងមិនឲ្យឆេះខ្លាំងពេក ដែលជាហេតុឲ្យ ឆេះខ្លោចអស់ ត្រូវឲ្យខ្លោចជាសន្សឹមៗបន្តិចម្តងៗ, បើកាលណា ឃើញខ្លោចហើយគេយកមកបុករែងឲ្យទៅជាផង់ដូចជាម្សៅ រួច ដាក់កម្លោចទៅទៀត លុះត្រាតែអស់ស្បែកល្អូស ១ ខ្នង, ហើយ ទើបគេយកស្លឹកទ្រាំងមកកម្លោចលាយជាមួយផង ព្រមទាំងកំទេច រោមដែលកោសទុកនោះ មកកម្លោចលាយជាមួយគ្នាផងទៀត កុំ ឲ្យឆេះសេសសល់ ។ ដើម្បីមិនឲ្យហុយ ត្រូវយកស្ករត្នោតបន្តិច មកប្រឡាក់លាយជាមួយផងទុកជាការស្រេច ។

វិធីប្រើ= ត្រូវឲ្យអ្នកជំងឺទទួលទាន ៤ ដងក្នុង ១ ថ្ងៃ ម្តង ១ ស្លាបព្រាកាហ្វេ ។

កំណត់សំគាល់= ថ្នាំនេះមានប្រសិទ្ធភាពណាស់ កាលបើអ្នក ជំងឺបានទទួលទាននូវថ្នាំនេះជាដំបូង និងឃើញស្លេស្មធ្លាក់មកជា ច្រើនគុណណាស់ រួចទើបធូរចុះតិចទៅៗជាលំដាប់ ។

*ឧទាហរណ៍ទី៥_* ប្រភេទថ្នាំកម្លោចរីករាលរៀប. ព្យាបាលរោគស្ត្រីវាំងរដូវឬរដូវមិនទៀងទាត់ ។

វត្ថុធាតុដើម= ១/ ច្រេះដែក ២/ អង្ករដំណើបខ្មៅ ។

វិធីផ្សំ= យកច្រេះដែក ១ កំប៉ុងទឹកដោះគោ មកកំដៅឲ្យខ្លោច, ហើយយកអង្ករដំណើបខ្មៅ ២ កំប៉ុងទឹកដោះគោ មកលីងឲ្យខ្លោចល្មមកុំឲ្យខ្លោចពេក ហើយបុកលាយជាមួយគ្នាឲ្យទៅជាផង់ម្សៅ ។

វិធីប្រើ= លេប ២ ពេល ក្នុង១ ថ្ងៃ មុនបរិភោគអាហារព្រឹកនិងល្ងាច ម្តង១ ស្លាបព្រាបាយ ជាថ្ងៃទី១ លើកដំបូង ។ លុះថ្ងៃទី ២ ជាបន្ទាប់ត្រូវលេបម្តង ២ ស្លាបព្រាបាយ ហើយពីរដងក្នុង១ ថ្ងៃ ដូចគ្នា ។

កំណត់សំគាល់= ថ្នាំនេះគេធ្លាប់បានពិសោធន៍រួចមកហើយថាមានប្រសិទ្ធិភាពមែន" ព្រោះគេថាជាថ្នាំលោកធុតង្គ" ។

*ឧទាហរណ៍ទី៦_* ប្រភេទថ្នាំកម្លោច, លោយង៉ែក ។

ជម្ងឺប្រភេទ នេះជាជម្ងឺគ្រុនចាញ់ ជាជម្ងឺដែលកើតឡើងពីសត្វល្អិតខាំ មានមូសជាដើម ឬកើតឡើងពីទឹកដីធាតុអាកាសធ្វើឲ្យអ្នកជម្ងឺមានអាការរងាញ័រញាក់ ឬធ្វើឲ្យអ្នកជម្ងឺខ្លះមានសភាពស្លេកស្លាំង អស់កម្លាំងល្ហិតល្ហៃ ។ល។

មានថ្នាំម្យ៉ាងដែលគេធ្លាប់ពិសោធឃើញមានប្រសិទ្ធិភាពគឺៈ

វត្ថុធាតុដើមៈ ១/ដំឡូងមី (ខ្លះហៅដំឡូងឈើ) ២/ទឹកសុីអុីវ ៣/ទឹកខ្មេះពូរ ។

វិធីផ្សំៈ ដំឡូងមីយក ៧ ស្លាប, ទឹកសុីអុីវនិងទឹកខ្មេះពូរយកភាគស្មើគ្នា, រួចកម្លោចស្លាបដំឡូងមីដាក់លាយទៅជាមួយគ្នាឲ្យចូលជាតិ ។

វិធីប្រើៈ ផឹកម្តងឲ្យអស់ចំនួនដែលធ្វើ

កំណត់សម្គាល់ៈ ជួនកាលអ្នកជម្ងឺផឹកតែម្តងប៉ុណ្ណោះ ឃើញជារហូត ។

*ឧទាហរណ៍ទី៥_* ថ្នាំកម្លោច ហើយរោយ តែរោគកាមរោគហៅថាទាបមិទ្យា (ដំបៅ) ។

វត្ថុធាតុដើមៈ ១/ព្រៃទន្សាកន្ទួង ២/ពុំសែនចេស (ជាប្រភេទ កើតពីការលាយកម្ពុរនិងថ្នាំទៀតខ្លះផងសម្បុរសភ្លឺមានពណ៌ព្រឿងបន្តួច ធ្វើមកពីបរទេស) ។

វិធីផ្សំៈ គេយកព្រៃទន្សាកន្ទួងមកកម្លោច ហើយកោសយកកំ-ណុបកិនលាយជាមួយនិងពុំសែនឲ្យទៅជាផង់ល្អ ។

វិធីប្រើៈ គេរោយពីលើដំបៅទាបមិទ្យា ។

កំណត់សម្គាល់ៈ ដំបៅនឹងក្រៀមជាសះក្នុងរយៈពេលពីរ-បីថ្ងៃ ។

# ៦. ចំណុចថ្នាំផុស

ប្រភេទថ្នាំផុសមាន ២ យ៉ាងគឺផុសផឹកឬផុតលោប ។

ផុសគឺជាវិធីមួយបែបដែលគេលាយថ្នាំឲ្យអ្នកជំងឺផឹកឬលោបទៅលើសរពាង្គកាយ ។ ក្នុងពិធីនេះគេច្រើនយកថ្នូកដាប់ឲ្យជ្រៅបន្តិចមានសណ្ឋានដូចចានមួយទូវវែង ដើម្បីដាក់ទឹកច្រើនឬតិចតាមត្រូវការ ទើបគេយកថ្នាំទៅផុសឲ្យជាប់នៅក្នុងទឹកនោះ ។ មានថ្នាំខ្លះគេផុសតែមួយមុខឬពីរមុខបញ្ចូលគ្នា តែមានថ្នាំខ្លះគេផុសបញ្ចូលគ្នាជាច្រើនមុខ, ហើយមានថ្នាំខ្លះទៀតគេដាក់កំរិតឲ្យផុសត្រឹមតែ ២-៣ ដង (២-៣ត្រួក) ។ល។ ជួនកាលអ្នកខ្លះមិនមានថ្មផុស គេយកត្រួយថ្នាំងដីឬវត្ថុអ្វីដែលមេត្រាពេលយកប្រើជំនួស ។

*ឧទាហរណ៍ទី១*- ប្រភេទថ្នាំផុសផឹក, កែរោគចាស់ ។

អ្នកជំងឺដែលមានអាការចុករោយក្នុងខ្លួន ញ័រដៃ ជើង អស់កំឡាំងល្ហិតល្ហៃពេលដើរឆ្ងាយ ងងិតមុខ។ល។ ខ្មែរនិយមហៅថារោគចាស់ ព្រោះច្រើនតែកើតលើស្ត្រីដែលឆ្លងទន្លេរួចហើយ ។

វត្ថុធាតុដើម= ១/គ្រាប់ល្ហុងធំ, ២/ផ្លែអង្កាញ់, ៣/ផ្លែល្វាក់ (ល្វាក់ពេញក្អាះលើក្ដួចត្រាំទៀងលើក្រពាក់,ជាលើពុល) ។

អនុវត្ត= យកប្លុកប្រុងបកដុសនិងថ្មដុសចំនួន ៧ ត្រួក ហើយលាយជាមួយនិងស្រា.សឲ្យអ្នកជប៉ឺផឹកស្ទង់មើលកម្លាំង, បើឃើញកម្លាំងនៅរឹងប៉ឹងមិនប្រែប្រួលទេ នោះគេដុសមួយមុខផ្សេងទៀតចំនួន ៧ ត្រួក លាយជាមួយស្រា.សឲ្យផឹកទៀត, កាលបើផឹកទាំង ២ មុខទៅហើយគ្មានអាការប្រែប្រួលអ្វីប្លែកទេ ទើបគេដុសមួយមុខ ចំនួន ៧ ត្រួកបន្ថែមលាយជាមួយនិងស្រា.ស ឲ្យផឹកជាកិច្ចបង្ហើយ ។

កំណត់សំគាល់= នេះជាប្រភេទថ្នាំដែលគេហាមដាក់កំហិតឲ្យប្រតិបត្តិ ព្រោះបើលើសកម្រិតអាចបណ្តាលឲ្យមានគ្រោះថ្នាក់ ។

*ឧទាហរណ៍ទី២*- ប្រភេទថ្នាំដុសផឹក, ព្យាបាលរោគទាស់ ។

វត្ថុធាតុដើម= ពុងប្រហា (ក្រពះសត្វចពុប្បាទ,មានកំារីងស្រួចជិតសរោម) យកដុសហើយលាយជាមួយនិងស្រា.ស ដាក់ត្រាំទុកក្នុងកែវ ។

វិធីប្រើ- ផឹកក្នុងការស្តារស្ទង់មិនបានដាក់កម្រិតអ្វីទេ ។

កំណត់សម្គាល់= ថ្នាំនេះអ្នកដែលធ្លាប់ព្យាបាលតែងបានសរសើរថាមានប្រសិទ្ធិភាពចំពោះរោគទាស់ ។

*ឧទាហរណ៍ទី៣*- ប្រភេទថ្នាំដុសផឹក កំចាត់រោគក្តៅខ្លួនជាពិស

រុត កញ្ញើរ ។ល។ អាចប្រើរព្យាបាលរោគស្ត្រីរោគទៀតផង ។

វត្ថុធាតុដើម=១/ ជ័ររង្គ (ច្រើនប្រើជាគ្រឿងជ្រលក់ពណ៌ ជ័រមានសម្បុរលឿង សម្រាប់ប្រើជាថ្នាំគំនូរឬប្រើជាថ្នាំបញ្ចុះរោគ) ២/ គល់កន្ទ្រាកខ្មោច ៣/ មើមក្តួច ។

វិធីផ្សំ= វត្ថុទាំង ៣ មុខនេះគេយកមកផុសលាយនិងទឹកសុទ្ធ ឲ្យអ្នកជំងឺផឹក ។

វិធីប្រើ= ថ្នាំនេះមិនបានដាក់កំហិតអ្វីទេ សម្រេចលើអ្នកព្យា-បាលដែលយល់ថាគួរឲ្យផឹកច្រើនឬតិច ។

កំណត់សម្គាល់= គ្រូព្យាបាលដែលធ្លាប់ប្រើថ្នាំនេះ តែងមានអំនួតថា មានប្រសិទ្ធិភាពមែន ។

*ឧទាហរណ៍ទី៤_* ប្រភេទថ្នាំផុសលាយ កែរោគពិសហើម ។

វត្ថុធាតុដើម= ១/ស្លែងធំ ២/ដើមប្រង់ ៣/ផ្សិតឆាគរាង ៤/ទៀបពាយសាក ។

វិធីផ្សំ= វត្ថុទាំង ៤ មុខនេះផុសលាយជាមួយគ្នាហើយពោប។

## ៦. ចំពូកថ្នាំបុក

បុកជាវិធីម្យ៉ាងដែលគេធ្វើថ្នាំឲ្យល្អិតជាម្សៅ ឬ ឲ្យល្អិតខ្ទេច

ទៅជាផង់ទៀត ដើម្បីយកទៅលាយជាមួយវត្ថុរាវ ដូចជាថ្នាំខ្លះគេហាលឲ្យស្ងួតហើយបុកឲ្យល្អិតលាយជាមួយទឹកឃ្មុំស្ងួនធ្វើជាគុលិកាសម្រាប់លេប ។ល។ ប៉ុន្តែវត្ថុដែលនៅស្រស់គេច្រើនបុកឲ្យល្អិតដើម្បីលាយនិងទឹកសម្រាប់ផឹកឬលាប បំពោកជាដើម ។

*ឧទាហរណ៍ទី១_* ប្រភេទថ្នាំបុកលាយផឹក កំចាត់មេរោគ ព្រូន ព្រូនវែង (ដង្កូវនៅក្នុងពោះវៀន) ។

វត្ថុធាតុដើម ១/ ផ្លែរាក់ក្លៀទុំ ២/ ដូងទុំមួយ ។

វិធីផ្សំ- អារកាត់ក្រឡាកដូងបន្តិច ហើយបុកផ្លែរាក់ក្លៀដាក់ចូលទៅក្នុងទឹកដូង រួចចាក់ស្រិតឬត្រងដាក់ក្នុងកែវឬផ្តិល ។

វិធីផឹក= គេផឹកពីព្រឹកព្រលឹមដែលនៅមិនទាន់បរិភោគអ្វី ។

កំណត់សំគាល់= ព្រូននិងធ្លាក់ក្នុងពេលបន្ទោបង់ឧច្ចារៈ ។

*ឧទាហរណ៍ទី២_* ប្រភេទថ្នាំបុក រម្ងាប់រោគពិស ។

ពិសជាឈ្មោះរោគមួយប្រភេទដែលកើតឡើងឈឺញ្ញាំងដោរទៅលើសាច់ បណ្តាលឲ្យលើចាប់ពើត និងបណ្តាលឲ្យទៅជាគ្រុនក្តៅខ្លួនក៏មាន, ដែលកើតឡើងលើសាច់ខ្មៅរាលដូចជាប្តូសា។ល។ ខ្លះគេហៅថាកើតពិស ។

វត្ថុធាតុដើម ១/ មើមក្តាតទេវតា ២/ ទឹកអង្ករ (ទឹកជ្រាំ)

វិធីផ្សំ= បុកបើបក្តាតហោរាំឲ្យល្អិត ហើយយកទឹកជ្រាំដែលរងផ្លា មកលាយជាមួយគ្នា ។

វិធីលាប= គេលាបទុកមុខបន្តិច កុំឲ្យជិតមុខ ។

*ឧទាហរណ៍ទី៣_* ប្រភេទថ្នាំបុក កែរោគធ្លាក់លោម ។

វត្ថុធាតុដើម= ១/ព្រគួនស្រែ ២/ក្តាមស្រែ ៣/ស្រា.ស ។

វិធីផ្សំ= ព្រគួនចំនួន១ក្បាប់ ក្តាម១ ឬ ២ បុកឲ្យល្អិតលាយនិង ស្រា.សឲ្យផឹក ។

វិធីផឹក= តាមបញ្ជាគ្រូអ្នកព្យាបាល ។

*ឧទាហរណ៍ទី៤_* ប្រភេទថ្នាំបុក ផឹក កែរោគគ្រុនចាញ់ ។

វត្ថុធាតុដើម=១/សត្វព្រពីង (លក្ខណៈដូចពីងពាងធ្វើរន្ធក្នុងដី) ២/ ព្រួយខ្ពៅ ។

វិធីផ្សំ= ព្រួយខ្ពៅយកចំនួនច្រើនជាង ហើយបុកវត្ថុទាំង ២ យ៉ាងនេះចូលគ្នាលាយទឹកឲ្យផឹក ។

វិធីផឹក= តាមការស្តាប់ស្ទង់នៃអ្នកព្យាបាល ។

*ឧទាហរណ៍ទី៥_* ប្រភេទថ្នាំបុកលេប កែរោគពិសរលើក ។

វត្ថុធាតុដើម= ១/សំបកទំពូង ២/ សំបកផ្លាស់ ៣/ ត្រួយ

កូនខ្ទោពពួចៗ ។

វិធីផ្សំ=វត្ថុទាំង ៣ បុកទនះបុកលាយគ្នាឲ្យល្អិត ហើយយកទឹកវាលាប ។

## ឆ. ចំពួកថ្នាំស៊ី.ផឹក

មានថ្នាំប្រភេទខ្លះដែលត្រូវឲ្យអ្នកជម្ងឺបរិភោគ ដូចជាចំណីអាហារធម្មតា ហើយដែលមានរសជាតិឆ្ងាញ់ពិសារមិនពិបាកក្នុងការផឹកស៊ី ។

*ឧទាហរណ៍ទី១-* ប្រភេទថ្នាំស៊ីផឹក កំចាត់រោគ រើប ។

រោគនេះកើតនៅលើស្បែកឡើងពងៗ មាន ២ ប្រភេទគឺៈ រើបខ្យល់ឬរើបអង្កាម រើបដែលឡើងពងល្អិតៗស្រដៀងនិងចែងថ្ងៃ បណ្ដាលឲ្យសង្អៀរក្រហាយបន្តិចៗ ,រើបធីឬរើបធំរើបដែលឡើងពងធំៗជាខ្សែ បណ្ដាលឲ្យឈឺសង្អៀរ ។

វត្ថុធាតុដើម= ១/ផ្លែល្ហុងភ្លើងខ្ចីធុនអណ្ដាតវែក ២/លាជធ្វើពីអង្ករដំណើប ៣/ស្ករ.ស ។

វិធីផ្សំ- យកល្ហុងមកអារកាត់ពេលចេញបន្តិច រួចដាក់លាជនិងស្ករ.សបញ្ចូលទៅក្នុងល្ហុង លុះចូលជាតិគ្នាសព្វអស់ហើយ ទើបឲ្យអ្នកជម្ងឺបរិភោគ ។

បរិភោគ= គេបរិភោគឲ្យអស់ទាំងអស់ទាំងទឹកទាំងសាច់ដូង។

កំណត់សំគាល់= ត្រូវតែអ្នកធ្លាប់ព្យាបាលទើបបញ្ជាក់ថា ថ្នាំនេះមាន ភាពស័ក្តិសិទ្ធិមែន ។

*ឧទាហរណ៍ទី២_* ប្រភេទថ្នាំស៊ី-ផឹក កែតំណក់ក្រាំ(របួស) ។

វត្ថុធាតុដើម= ១/តាប៉ែ ២/សំបកស្លូក្រប ។

វិធីផ្សំ= ធ្វើតាប៉ែឲ្យគ្រប់ថ្ងៃ (ដែលហៅថាកើតហើយ)ហើយ ស្ងោរសម្បកស្លូក្របចំនួនមួយពុះ រួចយកទៅចាក់លាយជាមួយ នឹងតាប៉ែ ហើយផ្អាប់ទុកមួយយប់ ។

បរិភោគ= តាមចំណង់ដែលអាចប្រព្រឹត្តទៅបាន ។

*ឧទាហរណ៍ទី៣_* ប្រភេទថ្នាំស្ងោរស៊ី-ផឹក កែរោគឃ្លង់ ។

វត្ថុធាតុដើម= ១/មាន់ ២/ព្រាវ ៣/ទាល់ ៤/ក្តាតហោរា ។

វិធីផ្សំ= មាន់ចំនួន ៧ ស្ងោរឲ្យអ្នកជំងឺបរិភោគមួយខែមាន់១ ឲ្យគ្រប់ ៧ ខែ រួចយកព្រាវ និងទាល់(ទាំងដើមទាំងឫស) ហើយ និងក្តាតហោរា (យកធាង) ទាំង ៣ មុខនេះ (យកភាគស្មើគ្នា) ដាក់ស្ងោរឲ្យអ្នកជំងឺផឹក ។

វិធីផឹក= ត្រូវផឹកទៅតាមកំរិតគ្រូដែលព្យាបាល ដោយគ្រូអ្នក ធ្លាប់បានពិសោធន៍ ។

កំណត់សំគាល់៖ ចេះពោះក្បួន ។

*ឧទាហរណ៍ទី៤_* ប្រភេទថ្នាំលាយផឹក កែរោគឆ្ងតជ្រូក ។

វត្ថុធាតុដើម៖ ១/ លោបហាន់ ២/ ទឹកដូង ។

វិធីផ្សំ៖ យកលោបហាន់សម្បុរ.ស និង លោបហាន់សម្បុរខ្មៅ ដែលមានដើម៩ លាយជាមួយនិងទឹកដូងតាតែ ។

វិធីផឹក៖ ឲ្យផឹកច្រើនដងពុះព្រាតែរស់ ។

កំណត់សំគាល់៖ លោបហាន់ទាំង ២ នេះយកចំនួន ១/៣ នៃ ទឹកដូង ។

## ៨. ជំពូកថ្នាំចំហុយ

ប្រភេទថ្នាំចំហុយមាន ២ យ៉ាងគឺសម្រាប់លាប និង ផឹក ។

ចំហុយគឺជាវិធីដែលគេយកទឹកចេញមកពីជាតិថ្នាំ ដោយមានឆ្នាំងពីរដាក់ត្រួតលើគ្នា និងបិទភ្ជិតមុខយ៉ាងជិតស្លួង ហើយឆ្នាំងខាងក្រោមគេដាក់ទឹក ឆ្នាំងខាងលើគេដាក់ថ្នាំ ។

គេចោះឆ្នាំងខាងលើតបំពង់ចេញមកក្រៅ សម្រាប់បង្ហូរយកចំហាយទឹក ព្រោះតែការពារឆ្នាំងខាងក្រោមត្រូវកំដៅភ្លើង ទឹកត្រូវពុះ ហើយចំហាយទឹកស្ទុះឡើងទៅលើរំរែះចំលើថ្នាំ ។ កាលបើ

ឆ្នាំងត្រូវបិទគ្របជិត ចំហាយទឹកចេញបំពង់ ត្រូវតែចេញមកតាមបំពង់ដែលបង្ហូរ ។ ដូចជារបៀបបិទស្រា (ធ្វើស្រាខ្មែរ) ។

*ឧទាហរណ៍ទី១-* ផ្កាចំហុយមួយប្រភេទ, សម្រាប់លាបកំចាត់រោគរមាស់ ។

វត្ថុធាតុដើម= ត្រុះ, (ប្រដាប់ដងទឹកអង្រៀងដែលគេព្យាញពីឫស្សីលាបជ័រទឹកសម្រាប់ដងទឹកក្នុងសម័យបុរាណ) ។

វិធីធ្វើ= គេយកបកបំបែកជាបំណែកតូចៗ ហើយដាក់ក្នុងឆ្នាំងចំហុយ (ដូចជារបៀបធ្វើស្រា) ដើម្បីត្រងយកទឹក ។

វិធីប្រើ= គេយកទឹកចំហាយដែលចេញមកនោះលាបរមាស់។

កំណត់សំគាល់=គេសំគាល់ឃើញថាផ្កានេះពូកែស័ក្តិសិទ្ធបែត, ទោះជាកំពុងរមាស់យ៉ាងណាក៏ដោយ ត្រូវតែបាត់រមាស់ភ្លាម ។

## បេរ. **ចំពូកថ្នាំស្ងួន** (គុលិកា)

ប្រភេទថ្នាំស្ងួននេះ គេច្រើនស្ងួនធ្វើជាគ្រាប់ ចំពោះថ្នាំដែលមានរសជាតិប្រហាត ក្រពុល ហាង ខារ ល្វីង ជូរ ចត់ ដែលពិបាកទទួលទាន ដើម្បីឲ្យងាយស្រួលក្នុងការលេបចូល កុំឲ្យហានក្អួតចង្អោរមកវិញ ។ វិធីធ្វើនេះមាន ២ បែបផ្សេងគ្នាគឺ:

ក- គេយកថ្នាំដែលផ្សំបញ្ចូលគ្នារួចស្រេចហើយនោះ ទៅបុកឲ្យខ្ទេចល្អិតជាផង់ ហើយយកទៅលាយជាមួយនិងទឹកឃ្មុំ ឬស្ករត្នោត សូនធ្វើជាគ្រាប់តូច-ធំតាមការកប្រិតនិងចូលចិត្ត ។

ខ- គេយកថ្នាំដែលផ្សំគ្នារួចហើយនោះមកស្ងោរយកតែទឹក ហើយរំងាស់ឲ្យខះ (ដូចយ៉ាងរំងាស់ទឹកត្នោតធ្វើស្ករ) ទើបសូនធ្វើជាគ្រាប់តូចធំតាមកប្រិត ដូចជាគេកប្រិតឲ្យសូនខ្នាតទំហំប៉ុនគ្រាប់គ ឬគ្រាប់រពាក់ ។ល។

*ឧទាហរណ៍ទី១-* ប្រភេទថ្នាំសូនគុលិកា, កែរោគខាងសរសៃ ដូចជាថ្លោះ គ្រេច ញ័រដៃ-ជើង ឈឺចង្កេះ ចុកខ្នង ។ល។

វត្ថុធាតុដើម= ១/សប្បុកស្លែងធំ, ២/សប្បុកក្រសាំងពុល, (ដើមនិងផ្លែដូចក្រសាំងធម្មតាប៉ុន្តែពុលបរិភោគមិនបាន) ៣/មើមប្រង់ (ឈ្មោះប្រទាលប្រៀងមានធាងរឹងស្លឹករឹងល្អិតមើមពុល) ៤/វល្លិផ្ទៃព្រៃ (មានពីរប្រភេទរំដេងសនិងរំដេងខ្មៅមានពណ៌ស្វាយក្របៅប្រើជាថ្នាំ) ៥/បារ៉ត (ធាតុរាវមួយប្រភេទស្រដៀងគ្នានិងសំណ) ។

វិធីផ្សំ= វត្ថុទាំង ៤ យ៉ាងនេះគេយកភាគស្មើរៗគ្នា មកស្ងោររំងាស់ឲ្យខះ ទើបចាក់លាយបារ៉តចូលជាមួយក្នុងការប៉ាន់ស្មានឲ្យរឹងសូនធ្វើជាគ្រាប់បាន ហើយសូនឲ្យបានទំហំធំប៉ុនគ្រាប់គ កុំឲ្យធំ

ផាង (នេះគឺកម្រិតខ្លាតនៃចំហាំ) ។

វិធីប្រើ៖ លេបម្តង១គ្រាប់, ហើយលេប ៣ ដង ក្នុង១ថ្ងៃ ។

កំណត់សំគាល់៖ ថ្នាំនេះធ្លាប់បានពិសោធន៍មកហើយ ដែលមានជោគជ័យ ។

## ៧. ចំពូកថ្នាំស្តុំ

ស្តុំគឺជាវិធីព្យាបាលមួយបែប ដែលគេដាក់កំដៅផ្ទាល់ទៅលើសាច់ ត្រង់កន្លែងដែលមានគ្រោះថ្នាក់របួស បណ្តាលឲ្យហើមឬជាំសាច់ ដើម្បីឲ្យស្រកហើមឬជាំ ដោយឆាប់រហ័ស ឬត្រង់កន្លែងណានិមួយដែលគេយល់ថាជាកន្លែងដែលត្រូវស្តុំ, ដូចជាយកស្លឹកម្លូមករោលកំដៅនិងភ្លើងទៀន ហើយដាក់សង្កត់ទៅលើសាច់ត្រង់កន្លែងដែលគេត្រូវធ្វើ ឬគេយកវត្ថុដូចជាដបច្រកទឹកក្តៅហើយយកទៅស្តុំ ឬគេដុតថ្មឲ្យក្តៅហើយយកទៅស្តុំ ។ល។

ក្នុងការស្តុំនេះបើមានគ្រោះថ្នាក់ខ្លាំង ជាជម្ងឺធ្ងន់ដែលអាចធ្វើឲ្យពិការនូវអវយវៈណាមួយ ដែលហៅថាថ្លោះឬគ្រេចនោះ គេមានយកថ្នាំមកប្រើស្តុំជាមួយផងដែរ ដែលហៅថាស្តុំថ្នាំ ។

*ឧទាហរណ៍ទី១*- ប្រភេទថ្នាំស្តុំ , ព្យាបាលជម្ងឺថ្លោះឬគ្រេច ។

ជម្ងឺថ្លោះឬគ្រេចនេះ ខ្មែរយើងថាបណ្តាលមកពីខ្ទាស់សរសៃ ឬ

ក៏ធ្លាក់ត្រាកចេញក្លូវរវេរ ត្រង់សន្លាក់ណាមួយ ដូចជា.កដៃ ក ជើង ក្បាលជង្គង់ ឬត្រគាកដែលហៅថាធ្លោះពោង ធ្លោះត្រគាក ជាដើម ។ ហើយវិធីព្យាបាលមានច្រើនបែបច្រើនយ៉ាង ផ្សេងៗ ទៀត តែដែលលើកយកមកចុះក្នុងទីនេះ ព្រោះគេបានពិសោធន៍ មកជាច្រើនឃើញថាមានសភាពស័ក្តិសិទ្ធិគឺ:

វត្ថុធាតុដើម= ១/ស្លឹកប្រផេញឈ្មោល (ស្លឹកល្អិតៗមានផ្កា ផ្លែចេញពីស្លឹក,មានពីរយ៉ាងគឺប្រផេញញីផ្កាមានសម្បុរសប្រផេញ ឈ្មោលផ្កាមានពណ៌ក្រហម) ២/ស្លឹកប្រផេញញី, ៣/ពន្លៃ .៤/កំពឹងពួយ, ៥/រំបិល ។

វិធីផ្សំ= វត្ថុទាំង ៤ យ៉ាងនេះគេយកចំនួនភាគស្មើៗគ្នា (រំបិលស្រេចនៅលើការប៉ាន់ស្មានដែលធ្លាប់ពិសោធន៍ ) រួចទើបយកមកខ្ទប់និងកំណាត់សំពត់ ហើយដាក់ត្រាំទៅក្នុងទឹកដែលដាំពុះ ឬស្របក់ ទើបលើកយកមកស្អំត្រង់កន្លែងដែលត្រូវស្អំ ។

កំណត់សំគាល់= បើស្អំបានយូរ ហើយច្រើនដងក្នុងមួយថ្ងៃ ជម្ងឺនិងបានធូរស្រាលយ៉ាងឆាប់រហ័ស ។

## ៥. ចំពួកថ្នាំពត់

ពត់ជាវិធីព្យាបាលរោគមួយបែប ដែលគេធ្វើឲ្យផ្សែងរបស់ថ្នាំ

ចូលទៅប៉ះត្រូវនិងអាការរោគខាងក្នុង ដែលគេមិនអាចនិងលាប ចូលទៅបាន ដូចជាក្នុងរន្ធច្រមុះដែលកើតជ្រៅទៅក្នុងឬក្នុងកន្ទើត ។ល។ ដូច្នោះគេព្យាបាលដោយរបៀបជក់ ដោយឲ្យអ្នកជម្ងឺជក់ ដូចគ្នានិងជក់បារីឬជក់ខ្សៀយ៉ាងនោះ ។

*ឧទាហរណ៍ទី១*_ ប្រភេទថ្នាំជក់, កែរោគឫសដូងច្រមុះ ។

ឫសដូងជាឈ្មោះរោគមួយពំពួកមានច្រើនប្រភេទ ដូចជាឫសដូងច្រមុះ ដែលកើតនៅក្នុងច្រមុះ, ឫសដូងបាតកើតនៅរន្ធគូថ ។ ឬឫសដូងរំហោក កើតនៅច្រមុះ នៅភ្នែក បណ្ដាលឲ្យពិងច្រមុះ ខះកន្ទើត, ស្ងួតបំពង់ក, ស្រវាំងភ្នែក, ឈឺមុខ, រីងមុខជាដើម ខ្មែរយើងច្រើននិយមហៅថាកើតឫសដូង ។

ឫសដូងច្រមុះជារោគមួយប្រភេទកើតនៅច្រមុះ មានភាពស្រដៀងគ្នានិងកើតដំបៅ បើព្យាបាលមិនត្រូវទេនិងក្លាយទៅជាដំបៅស៊ីច្រមុះដាច់បាត់ ហៅថាកង្កួតឬកញ្ជួតច្រមុះ ។ របៀបព្យាបាលមួយបែបដែលមានប្រសិទ្ធិភាព ដែលគេធ្លាប់បានពិសោធន៍មកជាច្រើនហើយគឺៈ

វត្ថុធាតុដើម=១/ពន្លៃ ២/រវៀប្រេង ៣/ខ្សៀធ្វើពីដើមឫស្សី

វិធីផ្សំ= វត្ថុទាំងពីរយ៉ាងខាងលើ គេយកមកហាន់ឲ្យស្តើងៗ និងកាត់ជាកំណាត់ខ្លីៗ ហើយហាលឲ្យស្ងួត រួចយកឲ្យល្អិតហោះ

ក្លូលេញ្ញា ។

វិធីប្រើ= គេញាត់ចូលទៅនិងខ្សៀបូស្សី ហើយរុជដក់ជាធ្មូតា ដែលហៅថាដក់ខ្សៀ ។

កំណត់សំគាល់= រោគបូសផ្លូងប្រុបុះនិងសេះជាទាន់ចិត្ត ។

## ឋ. ចំណុចថ្នាំរំងាស

រំងាសគឺជាវិធីមួយបែបដែលគេធ្វើរបស់ស្រស់ឲ្យទៅជាក្រៀបតាមដែលគេត្រូវការ, ប្រយោជន៍បន្ថយរសជាតិនៃថ្នាំឲ្យប្រែខុសពីសភាពដើម ព្រោះក្បៀពមានរុក្ខជាតិខ្លះដែលគេយកបកផ្សំធ្វើជាឱសថនោះ មានរសជាតិ ពុល ប្លុំង ខារ ជូរ ចត់ ក្រពុលប្រហាតខ្លាំងពេក ទើបបានជាគេយកទៅរំងាស ។ ព្រោះកាលណាបើត្រូវនិងកំដៅភ្លើង រសជាតិដើមនិងត្រូវថយចុះខុសពីកាលនៅស្រស់, បើរំងាសទុកយូរឲ្យក្រៀបខ្លាំង រសជាតិដើមក៏ថយចុះច្រើន បើរំងាសទុកយូរឲ្យក្រៀបរហូតដល់ខ្លោច រសជាតិដើមក៏ថយចុះច្រើនទៅទៀត ។

*ឧទាហរណ៍ទី១*- ប្រភេទថ្នាំរំងាស, កែរោគចុះរាក ។

វត្ថុធាតុដើម= ១/សម្បកអង្គាដី (ដើមខ្ពស់សម្បកក្រាស់ ស្លឹកតូចរវៀលៗចេញពីធាង ផ្កាពណ៌សក៏មានក្រហមក៏មាន ស្លឹកនិង

ផ្កាធ្វើជាអន្លក់ឬបន្លែឆ្មាន) ២/សម្បកព្រៃកន្ត្រុក ។

វិធីផ្សំ= វត្ថុទាំង ២ មុខនេះ គេយកភាគស្មើៗគ្នាមកហាលឲ្យស្រៀបស្រពាប់បន្តិច ហើយដាក់ត្រាំក្នុងទឹកធម្មតា ។

វិធីប្រើ= កាលបើឃើញចេញជាពណ៌ហើយ ផឹកបានតាមចិត្តគ្មានដាក់កំហិតអ្វីទេ ។

*ឧទាហរណ៍ទី២_* ប្រភេទថ្នាំរំអង, កែរោគធុះបួស ។

រោគបួសមានអាការឈឺពោះយ៉ាងខ្លាំង ធ្វើឲ្យចង់បន្ទោរបង់លាមកជាញឹកញាប់ដែរតែមិនចេញ បើចេញស្លេស្មខាប់ៗដូចសំបោរ ក្រោយមកធ្លាក់ឈាមបណ្តាលឲ្យកើតជាគ្រោះថ្នាក់ធ្ងន់បើដាក់ថ្នាំមិនជល់ទេ ។

វត្ថុធាតុដើម=១/សម្បកកណ្តោល(ពន្លះពោធិ៍ឬយប្រភេទស្លឹកធំៗ សម្បកក្រាស់ ផ្កាភ្លឺនរណ្ដូប, មានពីរយ៉ាង កណ្តោលព្រៃ ឬស្វាពជាប្រភេទស្ដែ តែផ្លែធំប៉ុនគ្នានឹងកណ្តោលធំ ហើយដូចគ្នាទាំងស្លឹកទាំងផ្លែ) ២/សំបកកន្ទួតព្រៃ (ផ្លែជូរពរាយចត់) ។

វិធីផ្សំ= សម្បកទាំងពីរយ៉ាងនេះ គេយកភាគស្មើគ្នាមកហាលឲ្យស្ងួតបន្តិច ហើយដាក់ត្រាំទឹកធម្មតាឲ្យចេញជាពណ៌ ។

វិធីប្រើ= គេឲ្យផឹកបានតាមចិត្តដែលអាចផឹកបាន ។

*ឧទាហរណ៍ទី៣*_ ប្រភេទថ្នាំរំអាង, ហើយស្ងោរផឹក, កែរោគទាស់ ស្ត្រីដែលកើតកូនខ្ចីហើយទាស់ ។

វត្ថុធាតុដើម៖ ១/ដើមប្លាតកាង, ២/ដើមកន្ធើតចក (ឈ្មោះវៀតណាមប្រភេទ ដើមវែងមានសម្បុរស) ។

វិធីផ្សំ៖ វត្ថុទាំងពីរមុខខាងលើនេះ យកចំនួនភាគស្មើៗគ្នា ហើយរំអាងឲ្យទាល់តែខ្លោច រួចដាក់ក្នុងឆ្នាំងស្ងោរជាធម្មតា ។

វិធីប្រើ៖ ផឹកជាធម្មតា គ្មានដាក់កំហិតអ្វីទេ ។

*ឧទាហរណ៍ទី៤*_ ប្រភេទថ្នាំរំអាង ត្រាំស្រា កែរោគទាស់ ។

វត្ថុធាតុដើម៖ ១/ ដើមកន្ធើតចក(វល្លិ) ២/ ប្លាតកាង ។

វិធីផ្សំ៖ វត្ថុទាំង ២ យ៉ាងនេះយកភាគស្មើៗគ្នា ហើយរំអាងឲ្យក្រៀមខ្លាំងរួចសឹមដាក់ត្រាំ ។

វិធីផឹក៖ ផឹកតាមការស្ទាបស្ទង់ ឬតាមបញ្ជាអ្នកព្យាបាល ។

## គ. ចំពូកថ្នាំត្រាំ

ការត្រាំថ្នាំនេះមានវិធីច្រើនយ៉ាង ដែលខ្មែរយើងពីបុរាណហៅថាត្រាំថ្នាំគឺ៖ ម្យ៉ាងគេយកថ្នាំទៅត្រាំនៅក្នុងធុងឆ្នាំងឬពាងទឹក [illegible]

ម្យ៉ាងទៀតគេយកទៅព្រាំនៅក្នុងត្បូកឬក្នុងភាជន៍ ឬក៏អ្វីមួយដែលធំ ហើយឲ្យអ្នកជម្ងឺដេកព្រាំ ឬអង្គុយព្រាំ ឬដាក់អវយវៈព្រាំចូលទៅក្នុងនោះ ។ ម្យ៉ាងទៀតគេយកទៅដាក់ក្នុងកែវឬប៉ាន់ ហើយចាក់ស្រាឬទឹកធម្មតាឬទឹកដូងព្រាំទុកសម្រាប់ឲ្យអ្នកជម្ងឺផឹក ។

*ឧទាហរណ៍ទី១*_ ប្រភេទថ្នាំព្រាំផឹក ព្យាបាលជម្ងឺធ្លាក់ឈាមពោះវៀន ហាត់ ដែលហៅថាក្លូតឈាម ។

លក្ខណៈអ្នកដែលកើតជម្ងឺនេះ មានរូបរាងស្គាំងស្គម សាច់ស្លេកស្លាំង ហើយយូរៗមានក្លូតធ្លាក់ឈាមមកម្ដងៗយ៉ាងច្រើនជួនកាលបណ្ដាលឲ្យល្ងក់ឈាមស្លាប់ភ្លាមមួយរំពេច ។

វត្ថុធាតុដើម= ១/ផ្លែក្រូចសើច ២/ស្ករ ៣/រំហិល ។

វិធីផ្សំ= យកផ្លែក្រូចសើចបកច្របាច់យកតែទឹក ឲ្យបានចំនួនកន្លះលីត្រ ហើយវាល់ស្ករមួយភាគ និងរំហិលមួយភាគឲ្យបានស្មើគ្នា (ស្ករនិងរំហិលរួមគ្នាឲ្យបានចំនួនកន្លះលីត្រដែរ)ដូច្នេះទឹកក្រូចសើច ស្ករ និងរំហិល លាយបញ្ចូលគ្នាត្រូវបានចំនួនមួយលីត្រ ។ រួចហើយដាក់ក្នុងកែវដែលមានគំរប គ្របរុំឲ្យជិត យកទៅកប់ទុកក្នុងស្រូវជម្រុកឬដោក ចំនួន ៧ ថ្ងៃដើម្បីឲ្យរបស់ថ្នាំមានគុណភាពល្អ និងរលាយចូលជាគ្នា ។

វិធីប្រើ=កម្រិតឲ្យផឹក ៤ ពេលក្នុងមួយថ្ងៃ ផឹកម្ដងចំពួន១ ស្លាប

ព្រាបាយ វៀររាល់ថ្ងៃឲ្យបានទៀងទាត់ ។

កំណត់សំគាល់៖ ថ្នាំនេះគេធ្លាប់បានពិសោធមកហើយ ឃើញមានប្រសិទ្ធិភាពជាក់ស្តែង ដែលអ្នកជម្ងឺបានទទួលទានថ្នាំនេះ អាការធ្លាក់ឈាមក៏ឃើញថយចុះជាលំដាប់ ។

*ឧទាហរណ៍ទី២_* ថ្នាំត្រាំស្រា កែរោគទាស់សរសៃខ្ចី ។

សំដៅយកចំពោះតែស្ត្រីដែលទើបនិងប្រសូត្រកូនថ្មីៗ ហើយមានជម្ងឺទាស់នេះ ដែលហៅថារោគទាស់សរសៃខ្ចី ។

វត្ថុធាតុដើម៖ ១/ឲ្យាវហាវ ៧ គ្រាប់ (គ្រឿងសម្លមួយប្រភេទបកពីប្រទេសចិន) ២/ម្ទេសហឺរ ៧ គ្រាប់ ៣/ម្រេចមួយស្លាបព្រាបាយ ៤/ជីរព្រចៀកប្រួក ៧ សន្លឹក ៥/រំសេវ ១ ពែងអាកោ ៦/ស្រា.សចំនួនដែលអាចត្រាំលិច ។

វិធីផ្សំ៖ ឲ្យាវហាវ ដំបំបែក, ម្ទេសហាន់ឲ្យល្អិត, ម្រេចបុកឲ្យខ្ទេច, ជីរព្រចៀកប្រួកហាន់ឲ្យល្អិតផងដែរ រួចលាយវត្ថុទាំង៤មុខនេះដាក់ចូលទៅក្នុងកែវ ហើយចាក់ស្រា.សឲ្យលិច បិទគំរបគ្របឲ្យជិតទុកឲ្យចូលជាតិថ្នាំ ។

វិធីផឹក៖ ឲ្យផឹកម្តងមួយស្លាបព្រាបាយ ។

កំណត់សំគាល់៖ ថ្នាំនេះមានប្រសិទ្ធិភាពចំពោះរោគទាស់សរសៃខ្ចី ដែលគេធ្លាប់មានការព្យាបាលមកជាច្រើនគ្នា មានអ្នកជម្ងឺ

ខ្លះជិតដល់នូវក្តីមរណៈទៅហើយ ដែលមិនអាចនិងហារកាត់ផើកផ្កាបាន ត្រូវគេគាស់ធ្វេញបញ្ឈក កាលបើជាតិថ្នាំនេះចូលដល់ អ្នកជម្ងឺមានអាការប្រែប្រួលឲ្យសំគាល់បានថាថ្នាំជល់ហើយ ។

*ឧទាហរណ៍ទី៣_* ប្រភេទថ្នាំត្រាំស្រា កែរោគចាស់សរសៃខ្ចី ។

វត្ថុធាតុដើម= ១/ខ្ទឹមស ២/ប្រេច ៣/ប្រេងភ្លើង ៤/រំសេវ។

វិធីផ្សំ= ខ្ទឹមសនិងប្រេចយកភាគស្មើគ្នា ហើយបុកឲ្យល្អិត. ប្រេងភ្លើងយកពាក់កណ្តាលខ្ទឹមប្រេចហើយបុកឲ្យល្អិតដែរ, រំសេវយកពីរដងលើសគេ រួចដាក់ទៅក្នុងកែវ ចាក់ស្រា.សចូលគ្របឲ្យជិត ត្រាំទុកឲ្យចូលជាតិគ្នា ។

វិធីផឹក= ឲ្យផឹកក្នុងការស្លាបស្លុងជា ៣ ដងក្នុងមួយថ្ងៃ ម្តង១ស្លាបព្រាកាយ ។

*ឧទាហរណ៍ទី៤_* ប្រភេទថ្នាំត្រាំ កែរោគហឺត

វត្ថុធាតុដើម= ១/ សំបុកអង្ក្រង ២/ ស្រា.ស ។

វិធីផ្សំ= សំបុកអង្ក្រងយកចំនួន៧សំបុក ដាក់ចូលក្នុងកែវមួយធំ ហើយចាក់ស្រាឲ្យលិច រួចគ្របយ៉ាងជិតល្អយកទៅកប់ក្រោមជណ្តើរទុកចំនួន៧ថ្ងៃ រួចហើយគាស់យកទៅកប់និងស្រូវចំនួន ៧ ថ្ងៃទៀត ។

វិធីផឹក៖ ឲ្យផឹក ៤ ពេលក្នុងមួយថ្ងៃ ម្តង ១ ស្លាបព្រាបាយ ។

កំណត់សំគាល់៖ ផឹកព្រឹកព្រលឹម ថ្ងៃត្រង់ ល្ងាច មុនចូលដំណេក ។

*ឧទាហរណ៍ទី៩_* ប្រភេទថ្នាំព្រាំ កែចុកខ្នងចង្កេះ ។

វត្ថុធាតុដើម៖ ១/សំបុកកណ្តៀរ ២/ស្រា.ស ។

វិធីផ្សំ៖ យកសំបុកកណ្តៀរដាក់ចូលទៅក្នុងកែវមួយ រួចចាក់ស្រាចូលទៅឲ្យលិច ហើយយកទៅកប់និងស្រូវទុកចំនួនកន្លះខែ។

វិធីផឹក៖ មុនបរិភោគអាហារព្រឹកល្ងាច ម្តងមួយពែងចក ។

## ឃ. **ចំពូកថ្នាំច្របាច់**

មានថ្នាំប្រភេទខ្លះគេច្របាច់ពូតយកតែទឹកឲ្យអ្នកជម្ងឺផឹកក៏មាន ដូចជាថ្នាំប្រៀងដែលគេប្រើរម្ងាប់ពិសពស់គឺៈ

*ឧទាហរណ៍ទី១_* ព្យាបាលពស់ចឹក ពស់ពិសគ្រប់ប្រភេទ ។

វត្ថុធាតុដើម៖ ១/ផ្លែក្រូចសើច ២/ថ្នាំជក់

វិធីផ្សំ៖ គេច្របាច់ទឹកក្រូចសើចដាក់ទៅលើថ្នាំជក់ (ថ្នាំខ្លាំង) ហើយច្របាច់ថ្នាំជក់បញ្ចេញទឹកលាយគ្នានិងទឹកក្រូចសើចឲ្យអ្នកជម្ងឺផឹក ។

វិធីផឹកៈ គេឲ្យផឹកចំនួន ១ឬ២ ស្លាបព្រាបាយជាដំបូង កាលបើក្អួតធ្លាក់មកមិនអស់ ទើបគេឲ្យផឹកបន្ថែម ។

កំណត់សម្គាល់ៈ អ្នកដែលធ្លាប់ពិសោធន៍ក្នុងការប្រើថ្នាំនេះ គេតែងពោលសរសើរថា ថ្នាំនេះមានប្រសិទ្ធិភាពណាស់ ។

*ឧទាហរណ៍ទី២_* ថ្នាំច្របាច់ផឹក រម្ងាប់រោគផ្ដាសាយ ក្អក ។

វត្ថុធាតុដើមៈ ១/ជីរព្រចៀកដំរី (ខ្លះហៅថាជីរព្រចៀកជ្រូក, ខ្លះហៅជីរព្រចៀកក្រាស់, ខ្លះហៅជីរទ្រូហាំង ឬ ទ្រូបឹង ២/ជីរអង្កាប ៣/ស្ករស ។

វិធីផ្សំៈ គេយកជីរទាំងពីរមុខនេះមកច្របាច់យកទឹក (លាយទឹកបន្តិច) ហើយដាក់ស្ករឲ្យមានរសជាតិផ្អែមល្ហែមៗ ។

វិធីផឹកៈ គេអាចផឹកបានតាមចិត្ត ។

## ៣. បំពួកថ្នាំបំពោក

បំពោកគឺជាវិធីដែលគេយកថ្នាំទៅពោសនៅពីលើរាងកាយអ្នកជម្ងឺ ដោយយកថ្នាំដែលច្របាច់ឬបុកឲ្យល្អិតនោះលាយជាមួយនិងវត្ថុរាវដូចជាទឹក រួចយកទៅបំពោកលើរាងកាយត្រង់កន្លែងដែលគេយល់ថាត្រូវបំពោក បើកន្លែងត្រង់ណាដែលពិបាកដាក់ឲ្យជាប់

នៅបាន នោះគេយកក្រហាប្លុកខ្សែងមករុំ ។

*ឧទាហរណ៍ទី១_* ថ្នាំបំពោកឲ្យត្រជាក់ កែរោគក្ដៅខ្លួន ។

រាងកាយដែលមានសីតុណ្ហភាពក្ដៅខ្លាំងហួសកម្រិត ដោយសារមានជម្ងឺដូចជាគ្រុនក្ដៅឬគ្រុនពិសជាដើម៖

វត្ថុធាតុដើម= ១/ត្រួយត្រឡាច លាយស្លឹកខ្ញី ២/ត្រួយននោងសាញ លាយស្លឹកខ្ញី ។

វិធីផ្សំ= គេយកត្រួយទាំងពីរមុខនេះ ទៅបុកឲ្យខ្ទេចជាក់ទឹកឲ្យបានជាតិផ្សើម ។

វិធីធ្វើ= យកទៅបំពោកលើខ្លួនអ្នកជម្ងឺដែលក្ដៅខ្លួន តាមកន្លែងដែលគេយល់ថាគួរធ្វើ ។

កំណត់សម្គាល់= មានអ្នកខ្លះគេកោសយកពោះនិងសាច់ត្រឡាចខ្លះ លាយជាមួយផងក៏បាន ។

## ព. ចំណួតថ្នាំស្ទុង

ស្ទុងគឺជាវិធីមួយបែបដែលគេធ្វើឡើងដើម្បីបង្អប់ថ្នាំ ប្រយោជន៍កុំឲ្យចំហាយផ្សែងដែលហុយចេញពីថ្នាំចេញទៅទីដទៃទៀតបាន, ឲ្យហុយត្រង់ស្ពោះទៅត្រូវចំលើសរពាង្គកាយអ្នកជម្ងឺតែម្ដង ដូចជា

ក្នុងមុខ កេក្រការដេញប៉ះមៀលតាមុខ ក្នុងព្រៃរាំពោករក្រការមៀលតាព្រៃនោះ កុំឲ្យពិបាកបែរផ្សេងចេញរួច ។

*ឧទាហរណ៍ទី១-* ប្រភេទថ្នាំក្នុង. ស្រីឆ្លងទន្លេរួចហើយ ។

ស្រីខ្មែរនៅតាមជនបទក្រោយពេលប្រសូត្រកូនរួចហើយ គេសង្កេតឃើញមានសភាពប្រែប្រួលណាស់ច្រើនផ្នែកខាងរូបកាយ មានខ្លះឃើញស្គមស្រពោនស្លុតចុះដូចមនុស្សមានជម្ងឺ ,ប្រហែលជាប្រាសចាកអនាម័យម្ដងប្រាសចាកវិទ្យាសាស្ត្រក្នុងពេលប្រសូត្រ ។ ព្រោះមានខ្លះប្រសូត្រកូនបានចំនួនប្រហែលមួយខែឬពីរខែកន្លងផុតមក ហើយទៅរួមរស់ជាប្ដីប្រពន្ធនឹងស្វាមី ស្រាប់តែបណ្ដាលឲ្យមានគ្រោះថ្នាក់ដែលហៅថាទាស់ចំណោក ។ ហើយមានខ្លះទៀតបរិភោគចំណីអាហារប្លែកៗ ក៏ស្រាប់តែទាស់រឹងផ្ដាសដួលស្លាប់ក៏មាន ។ល។

ក្នុងការបំបាត់រោគទាស់ចំណោកនេះ គេមានវិធីផ្សំថ្នាំម្យ៉ាង ដែលធ្វើឲ្យយោនីស្ត្រីដែលប្រសូត្រកូនរួចហើយនោះ បានរួមរួញជាដូចដើម និងបំប្លែងកៀងវិញដូចជាមិនធ្លាប់មានកូនគឺៈ

វត្ថុធាតុដើម= ១/អង្គ្រង, ២/ពន្លៃ ។

វិធីផ្សំ= អង្គ្រងយកទាំងសំបុក (ស្មានចំនួនតិច-ច្រើនតាមត្រូវការ) ពន្លៃយកទាំងមើមទាំងឫស ចំនួន ២ ដងអង្គ្រង ។

អនុវត្ត= គេយកវត្ថុទាំងពីរមុខខាងលើនេះ មកដាក់ក្នុង

នៅក្នុងឆ្នាំងមួយហើយបិទគំរបយ៉ាងជិត ចោះដាក់បំពង់បង្ហុយទៅលើ ដើម្បីឲ្យចំហាយផ្សែងហុយតាមប្រហោងបំពង់ទៅត្រូវប៉ះចំកន្លែងដែលឆ្អុង ( នេះសំដៅយកផ្ទះខ្មែរដែលច្រើនតែសង់ខ្ពស់ផុតពីដី ហើយគេដុតភ្លើងដាំឆ្នាំងនៅពីក្រោម) ។ ក្នុងការឆ្អុងនេះគេតម្រង់បំពង់ផ្សែងឲ្យចំទ្វាមាសស្ត្រីដែលឆ្អុង ដោយគ្របយ៉ាងជិតដើម្បីឲ្យហប់ បើគេចង់ឲ្យត្រូវសព្វសរពាង្គកាយទាំងអស់ គេគ្របឲ្យជិតខ្លួនទាំងអស់ និងជួយបូសំពត់ក្រាស់ៗ ។

កំណត់សម្គាល់= គេសង្កេតឃើញថា ស្ត្រីដែលបានឆ្អុងថ្នាំនេះតែងមានសាច់ឈាមស្រស់បំព្រង ហើយស្វាមីនាងតែងនិយាយលួចលាក់ប្រាប់គេថា ភរិយាគេប្រដូចបាននិងស្រីក្រមុំ ។

*ឧទាហរណ៍ទី២*- ប្រភេទថ្នាំឆ្អុង, ធ្វើមុខឲ្យមានសម្រស់ ស្អាត។

វត្ថុធាតុដើម= ១/រមៀតក្រចករអក (មើមតូចខ្លីខុបៗសម្បុរក្រហម) ២/ពន្លៃ ,៣/ព្រះអង្កោល (ប្រទាលមួយប្រភេទមើមធំជាងរមៀតប្រើជ្រលក់យកពណ៌លឿង) ៤/វល្លិរមៀត (ប្រភេទវល្លិម្យ៉ាងសម្បុរលឿងដូចរមៀត) ។

វិធីផ្សំ= វត្ថុទាំងបីមុខខាងដើមគេយកមើមលាយនិងដើមខ្លីៗ, ឯវល្លិរមៀតគេយកតែដើមនិងស្លឹក, ហើយវត្ថុទាំង៤មុខនេះ គេយកភាគស្មើរគ្នាទាំងអស់ ។

អនុវត្ត= វត្ថុទាំង៤យ៉ាងនេះ គេយកបកស្ងោរក្នុងឆ្នាំងមួយ ហើយស្តុងមុខ គឺគ្របឲ្យជិតឲ្យប្រូវចំហាយផ្សែងឲ្យត្រូវចំមុខ ។

កំណត់សំគាល់= ស្ត្រីដែលស្តុងមុខនេះ មុខស្អាតជាងធម្មតា ។

*ឧទាហរណ៍ទី៣*– ប្រភេទថ្នាំស្តុង កែរោគឈឺក្បាលវិលមុខ ។

វត្ថុធាតុដើម= ១/គល់ស្លឹកគ្រៃខ្ទបចំនួន៦គល់ ២/ផ្លែក្រូចឆ្មារចំនួន៧ផ្លែ ៣/ស្លឹកក្រូចសើចចំនួន១ចុកដៃ ៤/សាច់ដូង.សចំនួន១ដុំប៉ុនក្រូចឆ្មារ ។

វិធីស្ងោ= វត្ថុទាំង៤យ៉ាងនេះដាក់ក្នុងឆ្នាំងមួយស្ងោរ ។

វិធីស្តុង= គេយកភួយឬសំពត់ក្រាស់ៗគ្របឲ្យជិតពីក្បាលចុះមក ជាពិសេសឲ្យចំហាយត្រូវមុខនិងក្បាលច្រើនជាង ។

*ឧទាហរណ៍ទី៤*– ប្រភេទថ្នាំស្តុង កែរោគឬសដូងបាត ។

វត្ថុធាតុដើម= ១/ សាច់ដូងខៀវ ២/អាចម៍សេះ ។

វិធីផ្សំ= កិនសាច់ដូងខៀវឲ្យល្អិត ហើយលាយជាមួយនិងអាចម៍សេះ ។

របៀបស្តុង= ធ្វើយ៉ាងណាឲ្យចំហាយផិតទៅនិងរោគឬសដូង ហើយបញ្ចេញផ្សែងឲ្យតំ ។

កំណត់សំគាល់ - ចំពោះការផ្សំថ្នាំនេះ ជាពិសេសធ្វើឲ្យរោគ

នេះរឹក រួចទើបកាត់ផ្តាច់ជាខាងក្រោយ ។

## ៦. ចំពូកថ្នាំចត

ចតគឺជាវិធីដែលគេតបផ្សារភ្ជាប់, ពិធីនេះគេធ្វើចំពោះតែឆ្អឹងដែលបាក់បែក ដូចជាបាក់ដៃបាក់ជើងជាដើម ដោយសំអាងទៅលើបន្តគាថាស្តូផ្លុំស្តោះព្រួស" ផ្នែកខាងផ្លូវចិត្ត" ដូចបានរៀបរាប់នៅក្នុងចំពូកនៃការព្យាបាលខាងផ្លូវចិត្តទៅខាងមុខទៀតនេះ, ប៉ុន្តែការចតនេះគ្រូខ្មែរខ្លះបានប្រើថ្នាំលាបផ្សំផងដែរ ។

*ឧទាហរណ៍ទី១_* ថ្នាំចតប្រភេទថ្នាំកម្លោចលាប, ព្យាបាលបាក់ឆ្អឹងដៃ.ជើង ។

វត្ថុធាតុដើម= ១/ដូងដុះ (ដូងដែលដុះចេញជាពន្លកហើយ) ២/ដើបស្នាយ ៣/សត្វលាយញី (ប្រភេទសត្វស្វា,តែខ្មែរយើងបានជំនឿថាសត្វនេះវាយស្លាប់ហើយអាចរស់វិញ ដូចជាបេះដូងកន្ត្រកវះយកចេញមកក្រៅហើយ តែនៅមានជីពចរ) ៤/ឈ្លើងធំចំនួន៧ ។

វិធីផ្សំ= គេយកដូងដែលដុះចេញពន្លកនេះបកចម្រាញ់យកតែប្រេង ហើយយកវត្ថុទាំងបីមុខនោះមកកម្លោច (វិធីកម្លោចមាន

ប្រាប់រួចហើយ) ហើយយកទៅហាលជាប្លុកតិចៗ ដុំស្ងួតទើបយកប្រមូលទុក នោះ ឲ្យចូលជាពិក្ខុសេព ។

វិធីប្រើ៖ គេយកមកចូលក្នុងប្រទេះឡាំងល្អពីរដង ។

កំណត់សម្គាល់ ក្នុងការព្យាបាលនេះត្រូវខ្ចីខ្លះប្រើកសិណពាក់ អជ្ជី ពុទ្ធី ធម្មី សង្ឃី ព្រះភក្តិ បរិក្ខុត្តម្ពន្ធលាយ ខេ ។

*ឧទាហរណ៍ទី២_* ថ្នាំគ្រាប់ប្រភេទក្រូច, សម្រាប់ព្យាបាលរោគ ក្អក់រ៉ាំង ។

វត្ថុធាតុដើម៖ ១/ក្រូចឆ្មារតូច ២/ស្ករទឹក ៣/ ស្ករត្នោត ៤/ស្ករសរាប៉ូវឡើត (ដើម្បីប្រភេទដំឡូងយកមកកាន់ តែដើម្បីយកៗ បើការលេណាគាត់នឹងឃើញមានស្ករទេញមកប្រហាបផ្ទួលការ) ។

វិធីផ្សំ៖ ស្ករត្រូវជាពិចារ ៣ មុខ គេយកចំនួនស្មើៗគ្នា ។ ហើយគេយកក្រូចឆ្មារទៅដាក់រំងាស់ក្នុងថ្នាំងប្ដូរវិសែស (ត្រីកក្ដឹង កំដៅល្មម) លុះក្រូចឆ្មារទាល់តែពុះហើយ គេដាក់ស្ករទឹកចូល រួចកូរ ឲ្យចូលគ្នាល្អ ទើបដាក់ស្ករ ២ មុខផ្សេងទៀត រហូតកូរ ឲ្យចូលគ្នាល្អឲ្យកើតជាក្រូចឆ្មារខាប់ ។

វិធីប្រើ៖ ដូចឧទាហរណ៍ ទី១ ខាងលើ ។ ។

កំណត់សំគាល់៖ ត្រូវខ្ចីប្រើនប្រើផ្សំដោយយកតាមគោលគាថា ។

ពិធីព្យាបាលរោគឆ្អឹងដូចបានរៀបរាប់មកនេះ ជាការព្យាបា លអោយត្រូវចំពោះ ដូចមានថែមពីខាងដើមថា អោយ ត្រូវចំពោះតាមរោគាយប្រយោគ ៗ

ឥឡូវនេះសូមបង្ហាញពីការព្យាបាលដោយប្រយោល ដូចមានជា ឧទាហរណ៍គឺៈ

## ១. ប្រភេទថ្នាំបិទ

## ប្រើដោយប្រយោល(ពិតពិពោះ)

ប្រភេទថ្នាំបិទ- បិទគឺជាវិធីដាក់ថ្នាំភ្ជាប់ទៅលើស្បែក, វិធីនេះគេ ប្រើដើម្បីខ្ចប់ឬបុកឲ្យល្អិត ហើយយកទៅដាក់នៅពីលើ។ ដូចជា គេយកស្លឹកឈើមកដើម្បីខ្ចប់ ឬចំពាត់ឲ្យល្អិត ឬ បុកនិងត្បាល់បុក ហើយយកទៅបិទកន្លែងមានរោគ ។ល។

*ឧទាហរណ៍ទី១*- ប្រភេទថ្នាំបិទ, ដំបៅទៀងពាល់ពោះ ប្រើថ្នាំ ពោតក្រហម ។

ថ្នាំនេះប្រើចំពោះស្លឹកដែលទើបនឹងប្រមូលរួចថ្មីៗ ដោយទឹក ពោតកន្លះ (ត្រូវរកឲ្យបានថ្នាំក្ដៅព្រោះបិទសំរាប)ហើយ យកព្យាបាលត្រូវចងទៀតបើដាក់ការបើកស្រាបញ្ចូលតាមក្នុង។

ក្នុងការព្យាបាលនេះគេមានពិធីព្យាបាលបែបដោយប្រយោល

ពី គេយកស្លឹកល្ពៅ (ល្ពៅពុំទាន់ចាស់) មកបុកច្របាច់យកទឹកលាយជាមួយទឹកឃ្មុំ ៣ រួចយកទៅរុំនិងប្រោះលើក្បាលដែលឈឺនោះ បើឈឺក្បាលខាងឆ្វេង គេរុំប្រាបខាងដៃខាងស្តាំ តែបើឈឺក្បាលខាងស្តាំ គេរុំប្រាបខាងដៃខាងឆ្វេងទៅវិញ ។

កំណត់សម្គាល់៖ របៀបប្រើថ្នាំបែបបុរាណនេះ គេធ្លាប់បានការពិសោធន៍មកហើយ ថាមានសភាពត្រឹមត្រូវមែន ។

*ឧទាហរណ៍ទី២៖* របៀបប្រើថ្នាំបែបបុរាណ ប្រភេទថ្នាំលាប ព្យាបាលជម្ងឺពាន (ក្មេងកើតពាន) ។

ពានមានច្រើនប្រភេទ រោគដែលកើតក្នុងមាត់ពីកណ្តាលជើងអណ្តាតឲ្យតែឡើងក្រាស់ហើយពុកពុះៗក៏ហៅថាពានដែរ ។ ចំពោះកូនក្មេងជារោគមួយប្រភេទដែលកើតនៅក្នុងមាត់ ហើយមានចេញពងសក្បុសពេញមាត់ហើយនិងអណ្តាត អណ្តាតឲ្យធើផ្សារក្រហម ដែលឲ្យតែសម្រេងក្មេងមិនបានពេលបៅ ក៏ហៅថាពានដែរ (ប្រែពណ៌ជាឲ្យខៀវនោះមិនស្អាត) ។

វត្ថុធាតុដើម៖ ១/ពីសែ, ២/ស្លឹកម្រុំគួច ។

វិធីផ្សំ៖ គេយកពីសែ ១ ចំណៀងទុំ និងស្លឹកម្រុំគួច ៧ ស្លឹក (ម្រុំគួចស្រស់) បុកឲ្យខ្ទិចប្លុកលាយជាមួយទឹកឃ្មុំ ។

អនុវត្ត៖ ការលាបលើពងក្មេងហើយតែក្រោយមកទៅលើអណ្តាត

ក្បាលក្មេងកុំត្រូវរង្អើក ។

កំណត់សំគាល់- បន្ទាប់ពីបិទថ្នាំបកក្នុងកំឡុងពី ៣ - ៥ ម៉ោង ក្មេងនឹងបន្ទោរបង់ឧច្ចារៈ (ចុះរាគរូស ) ដែលឃើញពពាបក.ស ក្បាលព្រួចគ្នាក្នុងលាមក ។ លុះថ្ងៃជាបន្ទាប់មកទៀតពានដែលនៅក្នុងលាមក ក៏មានសភាពធូរស្រាលចុះជាលំដាប់ថ្ងៃ រហូតដល់ជាដាច់ស្រឡះ ។

*ឧទាហរណ៍ទី៣_* ប្រភេទថ្នាំបិទ ដោយត្រង់ចំពោះ តែរោគកាមរោគដែលមានហើមសាច់ ។

វត្ថុធាតុដើម- ១/ផេះកណ្តាលជើងក្រាន ២/ ផ្លែក្រូចឆ្មារ ។

វិធីធ្វើ=យកផេះកណ្តាលជើងក្រានបកច្របាច់ទឹកក្រូចឆ្មារដាក់លាយឲ្យសើម ។

វិធីប្រើ= យកបកបិទពាសពីលើសាច់ដែលហើម ។

កំណត់សំគាល់= អាការហើមនិងឃើញស្រកយ៉ាងឆាប់ ។

*ឧទាហរណ៍ទី៤_* ប្រភេទថ្នាំបិទដោយត្រង់ចំពោះ តែរោគពិស។

វត្ថុធាតុដើម- ១/ ដើមពិឡូងព្លុក ២/ ស្លឹកចំបី ៣/ ផ្លែល្ហុងខ្ចី ៤/ ស្លឹកបើងញ៉េះ ៥/ មើមខ្ញីប.ស ៦/ ស្ពាស ។

វិធីធ្វើ ៤ មុខខាងលើហាលយកកិនចូលគ្នាភាគគ្នា ហើយ

ឬរុក្ខទាំងអស់ខាងនេះ លាយជាមួយស្រា ស ។
វិធីប្រើ- ប្រើលាបពីរពេល ។

**ឧទាហរណ៍ដូចដែលបានរៀបរាប់មកហើយពីខាងដើម បង្ហាញពីរបៀបការពារ និងព្យាបាលជម្ងឺខាងផ្លូវសម្ភារៈ ដែលគ្រូពេទ្យបុរាណខ្មែរពឹងផ្អែកទៅលើនិស្ស័យ ឬជំនឿ ។**

តទៅនេះនឹងបង្ហាញពីរបៀបប្រើថ្នាំការពារគ្រោះថ្នាក់ និងការទប់ទល់ ដែលមិនមែនជាជម្ងឺ ដូចមានចែងពីខាងដើម ដែលមានទាក់ទងក្នុងពិធីឧបកិច្ចផ្សេងៗជាមួយគ្នាផង ។

ឧបកិច្ចគឺជាពិធីមួយដែលខ្មែរពីបុរាណនិយមធ្វើរឿយ ក្នុងការបំភ្លៃ ដំណើរ ឬបំភ្លៃកិច្ច ដោយកាយវិការ ឬពាក្យសំដី ដែលគេសម្មតិទៅតាមសេចក្តីត្រូវការ. ដូចយ៉ាងគេធ្វើឧបកិច្ចឈ្មោះសំបក ឬដកយកឫសឈើមកធ្វើថ្នាំជាដើម មុននឹងឈ្មោះឬដក កាប់ កាត់ យកសំបក ដើម ស្លឹក ឬមើម ឫស នៃរុក្ខជាតិទាំងឡាយនោះ គេប្រើវាចានិយាយបញ្ឆោតថា អ៊ុំឮថាលោកគ្រូអ៊ំាងពូកែណាស់ ! អាចនឹងកំចាត់បង់មួយជម្ងឺ..........បានយ៉ាងស័ក្តិសិទ្ធ . ហើយគេបញ្ចេញសំដីដោយខ្លួនឯងថា អើ ! ហើយពូកែរស្ទើរមែន....... គេធ្វើជាសំណួរហើយនឹងចម្លើយដោយខ្លួនឯង រួចហើយគេថា បើឮគ្នា

ស្បូលមិនអង្គរភាកន្ត្រួសរាំងប្រាណ ។ល។ ឬគេធ្វើឧបកិច្ចដោយយករំ
បន្ទើរ កកេរយកសំបកឈើមកធ្វើជាថ្នាំ. ឬគេរត់បន្ទើរពុទ្ធយក
ស្លឹករុក្ខជាតិ ។ល។

គេសំគាល់ឃើញថាពិធីប្រើឧបកិច្ចនិងអបទេស ច្រើនតែខាងផ្លូវភ្លេង ផ្លូវទុច្ចរិត ដែលជាអំពើអកុសលដូចជាទុព្ពិជ្ជាប្រយោគ ដែលគេហៅថាអំពើ គឺគេច្រើនធ្វើឧបកិច្ចក្នុងផ្លូវសម្លាប់ដោយអាថ៌កំបាំងដើម្បីសម្លាប់មនុស្សឬធ្វើមនុស្សឲ្យដល់នូវក្ដីអន្តរាយ ដែលជាអំពើព្យាបាទ ។

វិធីឧបកិច្ចមានប្រើជារបៀប២យ៉ាងគឺ:

១_ឧបកិច្ចដើម្បីការពារ និងទប់ទល់នូវគ្រោះថ្នាក់មិនមែនជំងឺ ៕

២_ឧបកិច្ចដើម្បីការពារ និងព្យាបាលជំងឺ ។

## ក. ឧបកិច្ចប្រើថ្នាំការពារ

ហេតុដែលខ្ញុំលើកយកពិធីការពារនិងទប់ទល់ ដែលមិនមែនជាការព្យាបាលជំងឺមកពណ៌នាក្នុងទីនេះ ព្រោះចង់បញ្ជាក់ឲ្យឃើញពីសម្ពុភាពខ្មែរបុរាណ ដែលចេះប្រើឱសថនិងចេះប្រើខាងផ្លូវកិច្ចវិជ្ជាទៅលើទីវើផ្សេងៗ ហើយចម្លែកៗនិងអស្ចារ្យគួរកោត ។

*ឧទាហរណ៍ទី១_ ពិធីឧបកិច្ច ដោយប្រើថ្នាំការពារ ។*

គេធ្វើឧបកិច្ចយកដើមព្រូកធ្នារ ដើមព្រូកចេក និងដើមព្រះព្រៅយកទៅនឹងកំណាត់សំពត់ ហើយយកដេរភ្ជិត តម្រៀបចងភ្ជាប់ផ្លូវដើមផែដើម្បីការពារនៅពេលដែលគេលូករន្ធនាៗ កុំឲ្យពស់ខាំ ( មានខ្លះហ៊ានរហូតដល់លូកចាប់ពស់ទៀតផង ) ។

*ឧទាហរណ៍ទី ២–* ពិធីឧបកិច្ចក្នុងការប្រើផ្កា ដើម្បីការពារនូវគ្រឿងសព្រាវុធ ។

គេធ្វើឧបកិច្ចនិងនិបន្ធយក ប្រទាលខោងផ្លាយ (ប្រទាលនេះមានស្លឹកនិងមើមសម្បុរស្វាយ) មករុំនិងកំណាត់សំពត់.ស ហើយដេរភ្ជិតធ្វើជាខ្សែត្រូការពារអាវុធប្រហារ មាន ធ្នូ ស្នា កាំភ្លើង ជាអាទិ៍ ដែលគេមានជំនឿថាជាគ្រឿងបញ្ចៀសបាញ់មិនត្រូវ ។

*ឧទាហរណ៍ទី ៣–* ពិធីឧបកិច្ចដោយប្រើផ្កា ក្នុងការការពារនូវគ្រោះថ្នាក់អន្តរាយ ដែលគេមានជំនឿថាពូកែក្នុងកិច្ចការពារ ។

ដើមចន្ទ្រានខេត្ត ( អ្នកខ្លះហៅថាដើមរឹងកើង ឬដើមគរាំងសែស ) តែក្នុងពេលដែលគេត្រូវការប្រើធ្វើជាថ្នាំការពារ គេឲ្យហៅថាដើមបែកផ្សែងទៅវិញ (ហៅជារបៀបឧបកិច្ច) ព្រោះដើមនេះមានរឿងពណ៌នាថា គេបាញ់បែកផ្សែង "ហើញតែផ្សែង" តែមិនត្រូវមនុស្ស ។ ដោយគេធ្វើឧបកិច្ច និងព្រឹកៗ

ឫសឈើកុក្រឹងក៏លោកស៊ីពក់ រួចគេរក្សា ធ្វើជារបៀបថ្នែត្រូវការពារ អាវុធប្រហារគេ ។

*ឧទាហរណ៍ទី ៤_* ពិធីប្រើថ្នាំក្នុងកិច្ចការពារនូវគ្រោះថ្នាក់ផ្សេងៗ ដែលគេអាចជឿនិងធ្វើឧបកិច្ចយកមកប្រើដូចជាៈ

ជើងក្រានថ្មុះ, នៅប្រទេសខ្មែរអ្នកធ្វើដំណើរតាមព្រៃគេតែងកាត់ឈើជា ៣ កំណាត់ស្មើរួច ហើយបោះចូលទៅក្នុងដី បញ្ឈរធ្វើជាជើងក្រាន ដាក់ឆ្នាំងចំអិនអាហារ ។

តែបានពេលខ្លះមិនស្លាប់ ហើយរស់ឡើងពន្លកលូតលាស់ ដូចជាគេផ្សាំ, នោះគេសំគាល់ឃើញថា បើឈើទាំង ៣ កំណាត់នេះរស់ដុះឡើងទាំង ៣ ព្រមគ្នា គឺជាអព្ភូតភ័ណ្ឌ ដែលគេបានចំណាំចាំទុកមកថា នឹងក្លាយទៅជាវត្ថុពូកែស័ក្តិសិទ្ធ ដែលកម្ររកបាន។

ហើយគេយកមកធ្វើជាថ្នាំពាក់នៅក ឬក្រវាត់ចង្កេះ ឬក៏គេយកទៅឆ្លាក់ធ្វើជាព្រះពុទ្ធរូបតូចៗ សម្រាប់ការពារនូវគ្រឿងសស្ត្រាវុធទាំងពួង ។

**ឧទាហរណ៍នេះគឺពិធីប្រើថ្នាំក្នុងកិច្ចការពារ ដែលខ្មែរនិយមធ្វើឧបកិច្ច ដូចមានចែងមកពីខាងដើម ។**

ពេលនេះនឹងបង្ហាញជូនពីវិធីប្រើថ្នាំ ក្នុងការទប់ទល់នូវគ្រោះ

ផ្ទាត់ធ្លាប់ជាឧទាហរណ៍ ។ ហេតុដែលខ្ញុំលើកយករឿងពេលនោះ ក្នុងទីនេះ ព្រោះចង់បញ្ជាក់ឲ្យដឹងថាខ្មែរក្នុងបុរាណសម័យ លោកបានគិតប្រើប្រែងស្រាវជ្រាវគ្រប់វិស័យទាំងអស់ ទើបបានជាវិស័យធម៌ខ្មែររីកចំរើនដល់ទៅកំពូល, ដែលធ្វើឲ្យអ្នកប្រាជ្ញលើសាកលលោក មានការកោតស្ញប់ស្ញែងយ៉ាងខ្លាំង ។

សេចក្តីក្លាហាននៃមេដឹកនាំ និងកងទ័ពដែលមិនរុញរានៅក្នុងរណរង្គ រមែងប្រកបទៅដោយជំនឿដែលធ្វើឲ្យទុកចិត្ត នៅលើសមត្ថភាពរបស់ខ្លួន, សិលាចារឹកនៅ **ឆានថវរ** ពោលសរសើរពីព្រះបាទ **ជ័យវរ្ម័នទី២** ថា: ពេលប្រយុទ្ធនៅក្នុងសមរភូមិ ព្រះអង្គហោះផ្លោះពីលើខ្នងដំរីជាព្រះទីនាំង ទៅគង់នៅលើក្បាលដំរីរបស់សត្រូវ ហើយទ្រង់ប្រហារជីវិតបីដូចជាគ្រុឌដែលហោះស្ទុះទៅចាប់ស្រុបសម្លាប់ពស់នាគនៅលើកំពូលភ្នំយ៉ាងដូច្នោះ ។

ប្រវត្តិសាស្ត្រចែងថា កងទ័ពខ្មែរសម័យបុរាណក្លាហានណាស់ មានការហាត់ហ្វឹកហ្វឺនយុទ្ធវិធីជាច្រើន ដូចជាគុនដាវ គុនដំបង ហៅគុនល្បុក្កតោ ហាត់កាប់ដោយដាវ ដោយផ្គាក់ ហាត់ចាក់ដោយលំពែង ដោយស្នា ហាត់ប្រដាល់ ហាត់ចំបាប់ ហាត់ជិះសេះ ជិះដំរី បាញ់ធ្នូ បាញ់ស្នា មានចារុំបញ្ចុះ សាក់ទៅលើសរពាង្គកាយ មានអាវយ័ន្ត កន្សែងយ័ន្តសម្រាប់ជូតក្បាល មានអាវក្រោះ ស៊ីរាប់ពាក់ការពារ និងផឹកថ្នាំពិតគង់ជាដើម ។

## ន. បំណុកថ្នាំទប់ទល់ (ប្រើពីក្រៅ)

*ឧទាហរណ៍ទី១.* ថ្នាំទប់ទល់ ជាប្រភេទថ្នាំចង ឬពាក់ ឬស្លូក សៀតឲ្យប៉ះពាល់ត្រូវសាច់ ដែលហៅថាថ្នាំស៊ិត ។

ថ្នាំផាររៀបទប់ទល់នូវគ្រឿងសស្ត្រាវុធ ។

លោជាតិប្លែកប្រភេទឈ្មោះវល្លិព្រលោកត្រី ខ្មែរយកមកប្រើ ធ្វើជាខ្សែចងពាក់នៅក្រវាត់ ឬធ្វើជាកងពាក់នៅកដៃ, ប៉ុន្តែ បើគ្មានច្រើនទេនោះ គេយកតែ ១ ចំរៀកតូច ប៉ុនឈើចាក់ធ្មេញ មកសៀតនៅជើងក្បួញ ដើម្បីធ្វើឲ្យស្បែកគង់ស៊ូកាប់មិនមុត ។ ដែលជាហេតុអញ្ជើញគួរឲ្យឆ្ងល់, ព្រោះមានអ្នកខ្លះហ៊ានយកកាំបិត ដែលមានមុខមុត ដូចជាកាំបិតចិតផ្លែឈើជាដើមមកកាប់ពិសោធ ឲ្យមើលទៀតផង ។

កំណត់សំគាល់ គេសំគាល់ថាជាវល្លិព្រលោកត្រី ពិត ឬមិន ពិតបាន ដោយធ្វើការពិសោធន៍ គឺគេយកវល្លិព្រលោកត្រីទៅ ដាក់ក្នុងអាចម៍ត្រី ហើយកាប់ពិសោធន៍សាកមើល បើមិនមុតទេ គឺ ពិតជាវល្លិព្រលោកត្រីមែន ។

*ឧទាហរណ៍ទី ២.* ប្រភេទថ្នាំទប់ទល់ ដោយទំពាស៊ី ។

យកប៉ុលប្រាណ (ប្រភេទលើកើ) មកទំពាស៊ី ដើម្បីឲ្យស្លឹក

ចាក់និងត្រូវលើ ក្នុងការប្រយោល ពីងរាល់ព្រួញវិញរំលែក, នេះ ក៏ជាវិធីដែលខ្មែរប្រើថ្នាំដើម្បីទប់ទល់នូវគ្រោះថ្នាក់ប្លុកដែរ ។

*ឧទាហរណ៍ទី ៣_* លោកជាតិមួយប្រភេទលក្ខណៈជា វល្លិធារ (កាចស្លឹកស្រៀងគ្នានឹងដើមធារធំ ដែលកាចស្លឹក ៣ ក្នុងមួយទង ខ្លះហៅថាធារស្លឹក ៣) ។ គេយកឫសវល្លិធារនេះមកកិនលាយ ជាមួយនឹងឆ្លាយកក ហើយបង្អុកកាន់ជល់ ដែលបញ្ជូល់ប្រើខ្លាយ ការពារកុំឲ្យចាក់ប៉ុត ។ នេះក៏ជាប្រភេទថ្នាំដែលគេប្រើជាររៀបទប់ ទល់មួយដែរ ។

បំភាប៖ ថ្នាំប្រភេទនេះខ្ញុំពុំអាចបង្ហាញជាក់ខាត ព្រោះជាវិធី ណាមួយកុំបីប្រើប្រព្វឹត្តការពីសោធចិត្តគេនោះ ព្រោះជាចំណោះដែល នេះពិត្តាប ។

*ឧទាហរណ៍ទី ៤_* ប្រភេទថ្នាំទប់ទល់, ដោយទំពាស៊ី ។

ប្រទាលមួយប្រភេទ កាចលំអួនដែលពីរណ្ឌក់ងទើគ្រាប់ គេ ហៅថាប្រទាលតិរ្ជាក់. គេយកប្រទាលនេះមកលាយជាមួយនឹងស្លា ហើយទំពាស៊ីដើម្បីឲ្យដែរក្លៀត ណាក្នុងមួយរយ ពេលដែលចាប ទាន់បង្គោររបស់ការ ៖ ។

កំណត់សំគាល់ ប្រទាលនេះគេប្រើលក្ខខ្ញុំតារាងតាត់ ។

## ប. ចំពូកថ្មីរស្មោរ

ប្រភេទផ្កាទប់ទល់ក្នុងគ្រោះថ្នាក់, ចំពូកផ្កាស្មិតគង់ ជាប្រភេទផ្កាផ្លាងសម្រាប់ស្មោរពីក ។

ចំពូកផ្កាស្មិតគង់ទាំងឡាយ ខ្មែរច្រើនធ្វើពិធីឧបកិច្ច រួចនិមន្តលោក, ទើបយកមកស្មោរ ។ តែមុននិងស្មោរគេតែងសូធ្យជាស់ជាមុនសិន ដូចមានគាថាជាឧទាហរណ៍តទៅនេះ៖

ឱម ចោជចោឃរ អញ្ជើញព្រះបន្ទូក ជាស់ព្រះដើមផ្កា ។ នេះគាថានិមន្ត មុននិងកាត់ ស្ទោះ ជីក កាច់ កាប់ បេះយកមក ដែលគេមានជំនឿថា អាចធ្វើឲ្យផ្កានោះខ្លាំងពូកែឡើងថែមទៀត (គាថានិមន្តនេះមានច្រើនផ្សេងៗទៀត) ។

មុននិងស្មោរគេសង្កេតឃើញមានធូប ៣ សរសៃ ដោតនៅលើកាត់ផ្លាង ដែលគេសំគាល់ថាព្រួចជាស់រួចជាស្រេចហើយ ។ គាថាជាស់នោះមានច្រើនបែបណាស់ ទៅតាមការនិយមរបស់គ្រូម្នាក់ៗ ដែលគេយល់ថាពូកែ, ដូចមានឧទាហរណ៍ខ្លះៗនេះ៖

អដ្ឋិ មស្ទុំ ការយេ កេសា លោមា នខា ទន្តា អលោ មំសំ ន្ហារុ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យករ៉ំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឬ

ទរិយំ ករីសំ មត្ថលុង្គំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តំ (នេះជាគាថាសូត្រព្រោស ឬព័ទ្ធសីហាក៏បាន ផ្នែកខាងពុទ្ធបក្ខ ដែលលើកយកមកជូនជាឧទាហរណ៍ក្នុងទីនេះ ហើយនៅមានផ្សេងៗទៀតជាច្រើន) ។ ពិងមានខ្លះជាគាថាជាស់ខាងផ្នែកវេទមន្ត ដូចជាៈ

**ឱម ជាស់កើង មហាជាស់កាំង ទើបគ្រូប្រើអញ្ញ បេសរ់ធំអរតំអររគមតរថរ បេសរ់ធំអរកតែ្យបណេខយ័ន្ត្រមន្ត វិញ្ញា ឱមបេសរ់មហារបេសរ់ សោររណើបេសរ់ បេសរ់តីអបេសរ់តំអរ បេសរ់ ពន្ធូនិ ជាស់កាំង ភរអ ស្វាហៈ ។**

*ឧទាហរណ៍ទី១-* ប្រភេទថ្នាំទប់ទល់, ជាថ្នាំផ្អាំងស្ទាវតឹក ហៅថាថ្នាំគង់ (គឺធ្វើស្បែកឲ្យស្អិតខុសធម្មតា) ។

ដើមដង្កោដុះលើក្បាលដំបូក (ឈ្មោះនេះមួយប្រភេទមានពីរយ៉ាង ដង្កោ-ដង្កោខ្មោចៗស្លឹកស្រដៀងនឹងដង្កោ តែផ្លែតូចៗ) ។ រៀបពិធីបន្តូលនិងបកិច្ចធ្វើទៅតាមធម្មតា តែត្រូវមានធូប ៩, ទៀន ៩, និងបារី ៩, ការសូត្រជាស់មានជាធម្មតា ។

កំពេញស្ទាវតឹក ៣ ផ្អាំងទៀងទៅ (យកផ្កាថ្នាំស្ទាវនេះទុំបិង

ក្រាប់ផែលក្រពេញលោហ និងពិតថ្នាំដែលធ្វើឲ្យក្រពេញលោហធាតុទៀត (ឧ. ភេសជ្ជៈ) ។

*ឧទាហរណ៍ទី១២_* ថ្នាំត្រូវគេប្រើក្នុងការទប់ទល់, ជាប្រភេទថ្នាំផ្ទាំង ស្ដៅភ្លើក ។

- ដើមតម្រីក្រុះលើក្បាលដំបូក ។

របៀបធ្វើថ្នាំ និងប្រើ ជាផ្លែវៀលប្អូន ដែលមានទៀង ៥ គ្រាប់ ៥, ចារី ៥ ។

របៀបស្ដៅភ្លើកត្រូវគេយកចំនួន ៣ ថ្នាំងយ៉ាងតិច ( គ្មានគ្រាប់ពិសោធនៅឡើយ) ។

*ឧទាហរណ៍ទី១៣_* ថ្នាំត្រូវគេប្រើក្នុងការទប់ទល់, ជាប្រភេទថ្នាំផ្ទាំង ស្ដៅភ្លើក ។

១/ ពណ៌ក្រហមលើគេរៀបក្បាល ២/ លើពងក្បាល ៣/ រាងកាយ ។

ព្រឹកនេះគេមកភាគច្រើនគ្នា ស្ដៅភ្លើកយ៉ាងតិចមួយ ៣ ថ្ងៃ ។

ពពីធ្វើក្ដីព្រមព្រៀងរបៀបលាក់ត្រូវការណ៍ ។

ឧទាហរណ៍ពេលដែលការទប់ទល់នេះ គឺជាប្រភេទថ្នាំដែល

ប្រើក្នុងការទប់ទល់ដោយព្រលឹងនិងពោះ ។

*ឧទាហរណ៍ទី៥*_ ប្រភេទថ្នាំគល់ ស្ងោរផឹកក្នុងការទប់ទល់ ។

១/ ប្រហាត់សត្វទោចឲ្យបានចំនួន៧, ២/ប្រហាត់ត្នោតព្រាហ្មណ៍ ចំនួន៧, ៣/ ប្រហាត់ពពាយញី(ភាញី)ចំនួន៧, ៤/វល្លិអង្គុត់សចំនួន ៧ គល់, ៥/វល្លិអង្គុត់ក្រហមចំនួន ៧ គល់, ៦/ប្រហាត់ផ្អែព្រៃ ចំនួន៧ ,៧/ប្រហាត់ពស្រូលចំនួន៧, ។

វត្ថុទាំង ៧ យ៉ាងខាងលើនេះ គេយកមកស្ងោរហើយផឹកលុះត្រាតែសាបរសជាតិទើបឈប់ ។

នេះជាវិធីទប់ទល់មួយយ៉ាងសំខាន់ ដែលអ្នកចេះវិធីថ្នាំនេះបានបួកអាងថា អាចធ្វើឲ្យស្ថិតគង់ពលរបស់ទៅក្នុងទៀតផង ។

បំភាម= ប្រភេទថ្នាំយ៉ាងនេះ ខ្ញុំអ្នកធ្វើសំនេរសូមហាមជាដាច់ខាត, ប៉ុន្តែដែលលើកយកមកពណ៌នាក្នុងទីនេះ ដោយចង់បញ្ជាក់ឲ្យឃើញថា ខ្មែរពីបុរាណកាលមានការស្រាវជ្រាវសម្រើរណាស់គ្រប់វិស័យទាំងអស់ ។

សូមបញ្ជាក់ថាប្រភេទថ្នាំស្ថិតគង់ក្នុងការទប់ទល់នេះ ខ្មែរយើងមានចេះជាច្រើនពពួកណាស់ ដែលខ្ញុំបានជួបប្រទះខ្លះៗ ក្នុងការសង្កេតបានឃើញ ដែលទទួលថាប្រសិទ្ធិ ដែលធ្វើឲ្យខ្ញុំនឹកស្ញើច ចង់សិក្សាវិជ្ជានិងសារប្រយោជន៍នៃបុរាណ (សូមមើលទំព័រ

រាល់ដែលខ្ញុំសរសេរក្នុងសៀវភៅទស្សនៈវិញ្ញាណ) ។

## ៨. ចំណុចថ្នាំឧបកិច្ច

ពិធីឧបកិច្ចក្នុងការទប់ទល់ ដែលមានប្រើថ្នាំដោយត្រង់ចំពោះ និងដោយប្រយោល ។

*ឧទាហរណ៍ទី១*_ ពិធីឧបកិច្ច និងប្រើថ្នាំដោយប្រយោល ដើម្បីទប់ទល់និងសត្វពាហនៈប្ដូរប្រភេទពី "គោ" ។

ខ្មែរចិញ្ចឹមគោសម្រាប់ប្រើការអូសទាញ នង្គ័ល រនាស់ ភ្ជួររាស់ដី និងអូសរទេះ ។ ហេតុនោះមុននិងប្រើគោទាំងនោះបាន គេត្រូវហ្វឹកហ្វឺនឬហៅថាផ្សាំឬផ្សាំងឬបង្ហាត់វារួចសិន, ព្រោះសត្វទាំងនោះហាក់ដូចជាដឹងខ្លួនថា ការប្រើឲ្យអូសទាញនោះ គឺជាការហត់នឿយលំបាកខ្លាំងណាស់ ហើយក្រាញមិនព្រមធ្វើ ។

ព្រោះមានគោខ្លះទទឹងរឹងរូសមិនព្រមឲ្យចាប់ ហើយហ៊ានដេញជល់ម្ចាស់ទៀតផង និងមានគោខ្លះទៀតចេះធ្វើពុតជាសន្លប់ ឬងាប់ មិនព្រមចូលរួសនឹមក្នុងពេលដែលគេហ្វឹកហ្វឺនបង្ហាត់វា រហូតដល់ម្ចាស់យកភ្លើងដុតកន្ទុយ ហើយនៅតែមិនចង់ស្ទុះក្រោកទៀតផង ។

ប្លុះក្នុងការបណ្ដាក់ព្រឹកព្រឹកគោនេះ គេអាចពិធីឧបកិច្ចប្រៀង ដែលគេធ្វើឲ្យសត្វពាហនៈទាំងនោះសំរេចបើកសត្វ ធានាពិធីរើក បណ្ដាក់ រួចពិធាក់ប្លុចប្រុងគឺៈ

គេឧបកិច្ចបត់ដង្កើមច្បូតយកស្លឹកប្រុះព្រៅ អកល្ងើទៅណាក់ដែ ហើយចាប់កន្ទុយខ្សែគោនោះ, ប្លុះគោដែលត្រូវចាប់កន្ទុយ ខ្សែ និងល្អាយទៅជាសំរេចហើយសត្វរាងក្បាលនិងបាន ។

គំណាត់សំគាល់ៈ វិធីនេះគេបានសំគាល់ឃើញថា មានសភាព ស័ក្តិសិទ្ធចំពោះសត្វគោ ឯសត្វពាហនៈផ្សេងទៀតដូចជាក្របី ឬ សេះ នៅមិនទាន់ដែលឃើញមានអ្នកពិសោធនៅឡើយ ។

*ឧទាហរណ៍ទី២*_ពិធីឧបកិច្ចក្នុងការចប់ចល់ ដោយស្ដោះព្រួស។

ការរើកប្លុរាំគោដូចឧទាហរណ៍ ទី១ ខាងលើនេះ មានពិធី ប្រៀងទៀតក្នុងការស្ដោះព្រួសគឺៈ

គេទៅធ្វើឧបកិច្ចយកព្រួយកណ្ដាល (កណ្ដាលធំ) និងព្រួយ បន្លាស្អិត នៅវេលាកណ្ដាលថ្ងៃត្រង់ ដោយបញ្ចេញវាចាថាៈ ឮ ថាលោកត្រូវកែផ្សាំងគោអែនទេ ? អើ ! លើងខ្ញុំពូកែអែន ! បើដូច្នោះខ្ញុំសូមនិមន្តលោកត្រូវទៅស្ដោះគោខ្ញុំដែលឆ្លង.....។ល។ រួចហើយគេក្ដិចយកមក ។

របៀបស្ដោះ= គេយកព្រួយទាំងពីរបុកអោយទំពា ហើយស្ដោះ

ប្រួលពីក្បាលទៅកន្ទុយ ។

*ឧទាហរណ៍ទី៣*_ ពិធីឧបកិច្ចក្នុងការទស្សន៍ទាយវិធីឈ្មោះប្រួល ដែលមានអក្សរជាតួប្រុស ក្នុងការរៀបរៀងឲ្យគេចូលចិត្តមិនខាន ហើយនេះគឺ:

គេរត់រកឈ្មោះទាំងឡាយជើងរបស់គេ ( ពិណជាតិគោល ឬយ៉ាប្រភេទ ហើយរឹងស្ទឹករម្លើយ សណ្ឋានផ្កាត្រូវទៀងនិងផ្ទៃរបស់គេ ) ក្លិបយកប៉ុនមកទំពាឈ្មោះប្រុសពីកន្ទុយទៅក្បាល ដោយការវិធានាជាទ្រង់ពេលយ៉ាងតិច ៧ ចប់ជា: ឱ្យអាវស បដិខា មិ ឈ្មោះឲ្យបានច្រើនជាងមុនក្រោំតែគោរពទោះសារង ។

**សេចក្តីដូចបានរៀបរាប់មកនេះជាផ្នែកខាងផ្លូវសម្ភារ: ដែលខ្មែរប្រើថ្នាំជារបៀបការពារ និងជារបៀបចប់ពល់ផ្លូវគ្រោះថ្នាក់ ដោយមានវិធីឧបកិច្ចលាយឡំជាមួយ ។**

**ពេលនេះនឹងបញ្ជាក់ជូនជាឧទាហរណ៍ខ្លះៗ អំពីវិធីឧបកិច្ចក្នុងការព្យាបាលជម្ងឺ ដែលមិនមានប្រើថ្នាំ ។**

## ៨. ឧបកិច្ចគ្មានថ្នាំ

*ឧទាហរណ៍ទី១*_ វិធីព្យាបាលរោគដោយឧបកិច្ច ដែលមិនប្រើ

និសធ ហើយបើធ្វើត្រូវទៅតាមរបៀបនិងបានទទួលលទ្ធផលយ៉ាង ជាក់ស្តែង ដែលគេធ្លាប់មានការពិសោធន៍មកជាច្រើនរួចហើយ។

រោគមួយប្រភេទកើតនៅលើស្បែក ឃើញឡើងសម្បុរស្រ ផេះ ដូចកាលឡើងកណ្តាប់បណ្តាលឲ្យស្ទៀររបកពាស់ គេហៅថា កើតភ្លឺ ។ ចំពោះបុរសដែលកើតភ្លឺនេះ គេមានកិច្ចឲ្យធ្វើដោយ ពិធីឧបកិច្ចយ៉ាងដូច្នេះគឺ

គេឲ្យសង្កេតមើលស្រីក្រមុំព្រហ្មចារីយករភាវទូនាប់ទៅរោគ, កាលបើឃើញហើយ ឲ្យលួចយកបង្កូពត្រុសអង្អែលត្រង់កន្លែង ដែលកើតភ្លឺនោះ ហើយរោគភ្លឺនិងបាត់ទៅវិញយ៉ាងស័ក្តិសិទ្ធ ,ឲ្យ តែប្រាកដជាស្រីក្រមុំព្រហ្មចារីមែន (បានន័យថាស្រីបរិសុទ្ធ) ។

ឧទាហរណ៍ ទី១ នេះបញ្ជាក់ឲ្យឃើញថា គ្រាន់តែកិច្ចមួយដែល ធ្វើដោយពុំមានបន្ទុកគាថាអ្វីសោះនោះ អាចនិងកំចាត់បង់នូវរោគា ពិពួកខ្លះបានយ៉ាងស័ក្តិសិទ្ធ ។ ដូច្នេះកិច្ចដែលគេប្រើឲ្យធ្វើគឺជា របៀបដ៏សំខាន់ក្នុងការរៀបចំពិធីទាំងឡាយ ដូចជាជប ស្តោះ បាយសី ធូប ទៀនជាអាទិ ដែលគេប្រើថាត្រូវរុចធូប ១សរសៃ ឬ ៣ សរសៃ, តែបើយើងរុច ២សរសៃ នោះអាចនិងគ្មានប្រ សិទ្ធិភាពទេវិញ ។ល។

*ឧទាហរណ៍ទី២_* រោគមួយប្រភេទកើតនៅលើស្បែក ដូចត្រូ

និងរោគកើតភ្លឺដែរ គេហៅថារោគបុន(កើតបុន) ជារោគដែលកើតនៅត្រង់បុន ដោយចេញជាកន្ទួលៗមានគ្រាប់, មាន ២យ៉ាង គឺបុនឡាក់គ្រាប់ល្អិតៗ បុនពិបូកគ្រាប់ធំៗ មានខ្ទុះឈាមស្រដៀងគ្នានិងរបួសទ្រនិច ។

ចំពោះបុរសដែលកើតរោគបុននេះ គេឲ្យធ្វើកិច្ចដូចគ្នានិងកើតភ្លឺដែរ តែខុសត្រង់ថា: បើកើតភ្លឺគេឲ្យយកក្រវាទ្រនាប់ស្រីក្រមុំព្រហ្មចារី តែបើបុរសដែលកើតបុនគេឲ្យយកក្រមាស្រីក្រមុំព្រហ្មចារីបកព្រពុសជូតរង្វេលទេវិញ ។

ផ្នែកសម្ភារៈ (ឱសថ) ដូចដែលបានពណ៌នាមកហើយ ជាឧទាហរណ៍ខ្លះៗ ដែលមានទាំងឧបកិច្ចផ្សំជាមួយផង គឺសុទ្ធតែក្នុងផ្លូវសុចរិត ដែលមានបង្ហាញពីរបៀបការពារនិងជួយសង្គ្រោះ ដោយការព្យាបាល និងពិធីទប់ទល់នូវគ្រោះអន្តរាយផ្សេងៗ ដូចមានចែងពីខាងដើមថា ខ្មែរប្រើថ្នាំក្នុងផ្លូវ ២ យ៉ាងគឺ: ក្នុងផ្លូវសុចរិត ហើយនិងក្នុងផ្លូវទុច្ចរិត ។

## III. វិធីប្រើថ្នាំក្នុងផ្លូវទុច្ចរិត

(ជាអំពើអកុសល និងរៀបរាប់ជាឧទាហរណ៍ )

ប្រភេទថ្នាំដែលប្រើក្នុងផ្លូវទុច្ចរិត គឺជាពួកថ្នាំដែលប្រើជារបៀប

បំផ្លិចបំផ្លាញ ឲ្យកើតមានគ្រោះថ្នាក់អន្តរាយផ្សេងៗ ដែលជាចំណែករកអំពើអកុសល ដូចជាថ្នាំបំពុល ថ្នាំសណ្តំ ឬថ្នាំដែលធ្វើឱ្យកើតជម្ងឺគ្រាត់ផ្សេងៗ ។ល។

ចំពួកថ្នាំទាំងនោះ ខ្មែរយើងបានការកេះពិងច្រើនបែប ច្រើនយ៉ាង ដូចជាថ្នាំចំពួកខ្លះ ធ្វើមនុស្សឱ្យស្លាប់ភ្លាមឬយឺតពេល ចំពួកថ្នាំខ្លះទៀតធ្វើមនុស្សឱ្យក្លាយទៅជាជនពិការ និងបានប្រភេទថ្នាំខ្លះធ្វើមនុស្សឱ្យទៅជាឆ្កួតវង្វេង វិកលចរិត ។ល។

ខ្ញុំចង់ពណ៌នារៀបរាប់ខ្លះៗជាឧទាហរណ៍ ដើម្បីបញ្ជាក់ជូនមិត្តអ្នកអានអំពីប្រភេទថ្នាំអាសិរ្វិសខ្លះ ដែលខ្ញុំបានដឹងច្បាស់ថាជាថ្នាំបណ្តាលឲ្យកើតមានគ្រោះថ្នាក់ប្រាកដមែន ។

*ឧទាហរណ៍ទី១-* ប្រភេទថ្នាំដែលធ្វើមនុស្សឲ្យកើតជំងឿ ។

វិធីផ្សំ= គេយកចំពួកអាសិរ្វិសទាំងឡាយនោះ(មានច្រើនមុខ) ទៅត្រាំនិងស្លឹកដើមស្វាយគគីរ (ពោះប្រភេទដើមនេះវាងតែរហាស់, ស្លឹកវាដើរជិតក៏រហាស់ដែរ) ហើយយកទៅល្បួចផ្តិតនិងសំពៀក បំពាក់អ្នកដែលត្រូវធ្វើ ។ ( វិជ្ជានេះយើងមិនត្រូវធ្វើទេ តែខ្ញុំចង់បញ្ជាក់ប្រាប់ឲ្យដឹងជាឧទាហរណ៍ ) ។

ហេតុនេះជំងឿដែលកើតឡើងពីថ្នាំអាសិរ្វិសនេះ មានអាការសញ្ញាវិកាលច្រើនទៀង ព្រោះតែការពោរថ្នាំនេះទៅនៅវ៉ាត្រូវតាក់

ក្នុងប្រអប់កន្ត្រងណា ពេលដាក់ប្រអប់កន្ត្រងនោះនឹងក្លាយទៅជាជីវៀ ព្រោះជីវៀនោះរួចចេញពីកន្លែងទៅប្រអប់ណា កន្ត្រងប្រអប់នោះក៏ក្លាយទៅជាជីវៀតែម្តងទៀត ។

កំណត់សំគាល់ អ្នកដែលចេះវិធីផ្សំថ្នាំនេះបញ្ជាក់ថា មិនអាចនិងរកត្រូវកញ្ចក់ពេលធ្វើជាបានទេ បើគេមិនបានដឹង ។ តែបើដឹង គេត្រូវតែយកទឹកប្រហុកទៅលាបលើជីវៀនោះ មិនយូរប៉ុន្មាន ជីវៀនឹងជាសះឯង ។

*ឧទាហរណ៍ទី២_* ថ្នាំបំពុល, បំពុលដោយការបរិភោគ ។

ថ្នាំប្រភេទនេះខ្មែរយើងមានចេះច្រើនណាស់ គេអាចធ្វើឲ្យមនុស្សពុលស្លាប់ភ្លាមឬយឺតពេលដោយទាន់ហន់ ឬក៏ទុកឲ្យយូរថ្ងៃទើបស្លាប់ក៏បាន ។ យើងលឺចាស់ៗពីរណាព្រាប់ថា ខ្មែរចេះរៀបចំពិធីបំពុលថ្នាំ រួចជាគេថ្នាំថា ឲ្យពុលស្លាប់និងវត្ថុអ្វីមួយដែលកំពុងបរិភោគក្នុងបច្ចុប្បន្ន តែពេលបច្ចុប្បន្នកំពុងបរិភោគមិនមានគ្រោះថ្នាក់អ្វីទេ, ប៉ុន្តែទៅអនាគតបើបរិភោគប៉ះចំអាហារដដែលនោះ ទើបត្រូវទទួលគ្រោះថ្នាក់ ។ (វិធីបំពុលថ្នាំនេះគេច្រើនធ្វើឡើងនិងខ្លួនហើ) ។

*ឧទាហរណ៍ទី៣_* បំពុលតាមខ្យល់ដែលដកដង្ហើម ចំណាប់ដៀង ។

ការប្រើផ្សែងពិពុលនេះ គេធ្វើដើម្បីឲ្យក្រុមស្រុកដេកលក់មិនឲ្យភ្ញាក់ ឬមនុស្សដែលត្រូវចំហាយផ្សែងនៃថ្នាំបណ្ដាលឲ្យងងុយដេក ហើយដេកលក់លង់លែងដឹងខ្លួន ដែលគេហៅថាត្រូវថ្នាំគេសណ្ដំ ។ ថ្នាំប្រភេទនេះអ្នកដែលចេះដឹង ច្រើនតែពួកជនទុច្ចរិត ដែលធ្វើចោរកម្ម គេប្រើថ្នាំសណ្ដំដើម្បីឲ្យម្ចាស់ផ្ទះដេកលក់លង់ ចូលលួចទ្រព្យសម្បត្តិ ។

*ឧទាហរណ៍ទី៤*_ប្រភេទថ្នាំខ្លះដាក់តាមទឹកផឹក, ដោយធ្វើមនុស្សឲ្យឆ្កួតវង្វេង(វិកលចរិត)ដែលមានអ្នកខ្លះបានពណ៌នាប្រាប់ថា គេអាចធ្វើមនុស្សឲ្យឆ្កួតបានយ៉ាងពិតប្រាកដមែន ព្រោះគេប្រាប់ពីវត្ថុធាតុដែលយកទៅផ្សំ ដូចជាសត្វពពកវិលដាវើប (សត្វល្អិតមួយប្រភេទសម្បុរខ្មៅហើរលើទឹកវិលចុះវិលឡើង និងថ្នាំផ្សំជាច្រើនមុខទៀត ដែលខ្ញុំចាំមិនបាន," មិនយកចិត្តទុកដាក់") ។

*ឧទាហរណ៍ទី៥*_ ប្រភេទថ្នាំរាសរិត្តស ដែលគ្រាន់ចូលទៅក្នុងពោះ កាលបើបុកចូលទៅក្នុងសាច់បន្តិចបន្តួច ដូចជាថ្នាំដែលគេយកទៅលាបនៅមុខព្រួញ មានធ្នូ ស្នាជាដើម សម្រាប់ប្រហារសត្វធំៗពួកម្រឹគជាតិ ឲ្យស្លាប់ភ្លាមបានមួយរំពេច ដែលគេនិយាយហៅថាជ័រអក់។ ពីពួកថ្នាំប្រភេទនេះគេកានផ្សំទៀងជាច្រើនមែន

យ៉ាងខុសៗគ្នា ទៅតាមការចេះដឹង និងតាមការនិយមក្នុងតំបន់និមួយៗដែលគេរស់នៅ ដូចជាវិធីផ្សំមួយប្រភេទគឺៈ

គេកាត់ដើមចេកឲ្យផុតគល់ (ដែលហៅថាក្តិល) ហើយធ្វើឲ្យរាងប្រឡុកដូចចានដើម្បីឲ្យទឹកចេញមកហើយដក់នៅ ទើបគេយកក្បាលពស់វែកទៅត្រាំនៅក្នុងនោះ រួចគេយកជ័រឆក់ (ជ័ររុក្ខជាតិម្យ៉ាងពោធពិស) ជ័រពុះ ដាក់ក្នុងបំពង់មួយ ហើយយកទឹកចេកដែលត្រាំក្បាលពស់វែកមកលាយជាមួយគ្នាក្នុងបំពង់ ទើបគេយកព្រួញទៅដាក់ត្រាំទុកក្នុងនោះជាការស្រេច ។ កាលបើព្រួញនេះត្រូវផ្តាប្រាបចូលទៅខាងចុងព្រួញដែលត្រាំនោះ ព្រួញនេះនិងក្លាយទៅជាព្រួញអាសិរ្តិសយ៉ាងសាហាវ អាចពិឃាតសត្វប្រីតឲ្យស្លាប់បានភ្លាមមួយរំពេច ។

វិធីផ្សំមួយយ៉ាងទៀតគឺៈ គេស្លាប់ពស់វែកយកមកចងកន្ទុយឡើងលើ ហើយយកក្បាលសំយុងចុះក្រោម ទើបយកបំពង់ត្រងពីក្រោមឲ្យចំត្រង់ក្បាល, កាលបើពស់នោះហើមឡើងនិងមានទឹកស្រក់ធ្លាក់ចុះមកត្រូវចំបំពង់ដែលត្រង ។

ទើបគេទៅកាប់ចេកផ្កាត្រឹមគល់ ហើយអារឆៀលឲ្យរាងប្រឡុកបត្តិចត្រង់ក្តិល ដើម្បីឲ្យទឹកចេញមកហើយដក់នៅ, រួចទើបគេយកទឹកចេកផ្កានោះទៅលាយជាមួយនិងទឹកពស់ ហើយយក

ប្រហាក់ផ្អាក់ហើកដាក់ហោរក្របួយការងទៀត រួចទើបយកកញ្ចញទៅក្រោ
ទៅក្នុងពិធីនោះទុកជាការស្រួល ។

កំណត់សម្គាល់ក្នុងការពិសោធ - បើចាញ់ត្រូវហើយៗប្រើតនោះ
រត់ទៅស្ទាបផ្កាឈើពីកន្សែងដែលត្រូវ គេសិតាល់ថាជ័ររក់នោះមិន
ពូកែទេ ដូច្នោះរបៀបធ្វើពីរនេះគេចន្លះប្រហាក់ប្រហែល, បើរបៀប
ធ្វើទីបួនគេបន្ថែមជ័ររក់ ។

ការប្រយ័ត្ន៖ ចង្កូបរបស់គេ បើកាលណាចាញ់ត្រូវសព្វជួល
ស្ទាបភ្លាម គេតែងតែរកសាច់ត្រង់កន្សែងដែលត្រូវញញួនោះទោស,
ដោយគេដឹងថាពិសម្ងាត់ម្នាខ្សោយប៉ុណ្ណោះ ហើយគេរកសាច់
ទៀតទៅតាមទំហំពិសដែលត្រូវនោះទោស ។

បញ្ញត្តិ៖ ខ្ញុំអ្នកធ្វើសៀវភៅនេះលើកយកជំពូកផ្នែករាសិស្តសបកពណ៌នា
ក្នុងទីនេះ ដោយចង់បង្ហាញជាឧទាហរណ៍ ពីការចេះដឹងនិងសមត្ថ
ភាពខ្មែរបុរាណយើងប៉ុណ្ណោះ មិនអនុញ្ញាតឲ្យអ្នកណាយកវិជ្ជានេះ
ទៅប្រតិបត្តិធ្វើការពិសោធន៍ជាដាច់ខាត, បើនរណាប្រការល្មើស
និងបទបញ្ញត្តិនេះ ត្រូវទទួលសក្តិសិទ្ធនៅក្នុងលោកផ្ដន្ទាទោសកុំបីត្រា
ប្រណីឡើយ ។

ក្នុងការព្យាបាលខ្មែរបុរាណគេច្រើនប្រើថ្នាំក្រៀតជំពូកពោធិ៍ ស្ទើរ
តែគ្រប់ប្រភេទនៃការព្យាបាលគ្រប់ ឬ ពេល ដែលគេត្រូវធ្វើជា

ក្អក (សម្រាប់អង្គុយភ្លក់ហៀរ, ដែលហៅថាខាក់) ហើយគេតែង គិតពុល្អាញ់ញ្ញាណឬល្អាងិត គេចេះប្រើថ្នាំកាត់ធ្វើវិធីឲ្យសះស្បើយ បាន ដែលជាហេតុអស្ចារ្យគួរឲ្យភ្ញាក់ ។

សេចក្ដីអត្ថាធិប្បាយដូចដែលបានរៀបរាប់មកហើយពីខាងលើ ទាំងប៉ុន្មាន គឺជាផ្នែកខាងផ្លូវសម្ភារៈ ដែលមានប្រើថ្នាំទាំងខាងផ្លូវល្អនិងផ្លូវអាក្រក់, ទាំងខាងព្យាបាលនិងការពារ, ទាំងខាងការពារនិងចប់ចល់, ទាំងប្រើឧបកិច្ចនិងដោយប្រយោល ដូចដែលបានថ្លែងមកពីខាងដើម ។

តទៅនេះនឹងបញ្ជាក់ជូនផ្នែកខាងផ្លូវចិត្ត ដែលហៅថាចិត្តវិជ្ជា ដែលខ្មែរយើងពឹងផ្អែកលើមន្តអាគមគាថា និងឧបកិច្ចឬអបទេស ដែលឃើញមានប្រើផ្សេងនិងខាងផ្លូវសម្ភារៈ ហើយដែលមានទាំងខាងផ្លូវសុចរិត និងផ្លូវទុច្ចរិតដូចគ្នា ។

## IV. ផ្នែកមន្តអាគម

**មន្តអាគម**= ដែលហៅថាមន្តអាគម គឺឫទ្ធិខាងផ្លូវចិត្ត (មនោមយិទ្ធិ) ដែលសម្ដែងពីការឲ្យឃើញថា ជាសភាវៈសក្តិសិទ្ធិប៉ុណ្ណោះ ដែលអាចនឹងបង្កើតឲ្យកើតជាគ្រោះថ្នាក់ ឬ អាចនឹងកំចាត់បង់ និងការពារនូវគ្រោះថ្នាក់បាន ។

ហើយដែលលើកយកបត្តរភាគរបស់ពេលនោះក្នុងទីនេះ ព្រោះមានការទាក់ទងក្នុងការព្យាបាលជម្ងឺផ្នែកខាងផ្លូវចិត្ត ដូចមានតែងពីខាងដើមថា ខ្មែរបុរាណព្យាបាលជម្ងឺទាំងខាងផ្លូវសម្ភារៈនិងខាងផ្លូវចិត្ត ។

អាគមខ្មែរប្រកបទៅដោយអំពើទាំង ៣ គឺ **កាយកម្ម វចីកម្ម** និង **មនោកម្ម** ។ ហេតុដែលប្រកបទៅដោយទ្វារទាំង ៣ គឺ កាយ វាចា ចិត្ត នេះហើយ ទើបបានជាអាគមខ្មែរក្នុងបុរាណកាលមានឫទ្ធានុភាពខ្លាំងពូកែលើសគេ ។

ម្យ៉ាងទៀតអាគមខ្មែរតែងប្រព្រឹត្តទៅក្នុងផ្លូវ ២ យ៉ាងគឺ:

១- ចំណែកខាងផ្លូវល្អ ដែលជាអំពើសុចរិត គឺក្នុងផ្លូវជួយសង្គ្រោះឬជួយការពារនូវគ្រោះថ្នាក់អន្តរាយ ដែលកើតមានឡើងឬបំរុងនិងកើតមានឡើង ។

២- ចំណែកខាងផ្លូវអាក្រក់ ដែលជាអំពើទុច្ចរិត គឺក្នុងផ្លូវបំផ្លិចបំផ្លាញបង្កបង្កើតឲ្យកើតមានជាគ្រោះថ្នាក់អន្តរាយ ។

ក្នុងអំពើទាំង ២ យ៉ាងនេះ អាគមខ្មែរមានបញ្ញត្តិញាណពិធីការ្យជា ២ វិធីគឺ:

**ក_ វិធីបញ្ចេញខាងវចីភេទ ក្នុងការភាវនាឬសូត្រដែក គាស់ក្រើនរំលើក និងសូត្រប្រាប់ ។**

**ខ_ វិធីបញ្ចេញជាតួអក្សរ: ដែលហៅថាអក្សរមូល ឬអក្សរខម**

សម្រាប់ចារបញ្ចុះ សាក់នៅលើសពាង្គកាយ ឬសម្លឹក ដូចជាស្លឹករឹត ស្លឹកត្នោត និងបន្ទះដូចជាបន្ទះស្ពាន់ ចង់ងែង សំណ មាស ឬធ្វើជាឡេត ដែលហៅថា កថា ។ និងមានប្រភេទខ្លះទៀតដែលទាញជាយ័ន្តលាយជ្រៀបញ្ចូលគ្នា ដូចមានចារនៅលើថ្នាំងសំពត់ ដែលហៅថាកន្សែងយ័ន្ត ឬធ្វើជាអាវពាក់ ហៅថាអាវយ័ន្ត ។ល។

ហើយក្នុងពិធីបញ្ចេញបាដិហារិយ្យទាំង ២ យ៉ាងនេះ ច្រើនអនុលោមទៅលើព្រហ្មញ្ញសាសនា ហើយនិងព្រះពុទ្ធសាសនាជាមូលដ្ឋាន ដែលឃើញមានច្រើនជាពាក្យបាលី នៅក្នុងវេទមន្តនិងពុទ្ធមន្ត ក្នុងការបញ្ចេញវិធីភេទឬរូបអក្ខរៈ ។ ប៉ុន្តែដែលឃើញមានច្រើនលើសលប់ជាងគេគឺពុទ្ធមន្ត (ខ្មែរកាន់សាសនាព្រាហ្មណ៍មុនសាសនាព្រះពុទ្ធ, តែក្រោយសម័យប្រទេសធ្លាក់ចុះដុនដាបមកគេមិនសូវឃើញមានអ្នកចេះខាងវេទមន្តទេ ) ។

តទៅនេះនិងបង្ហាញពីបទចងក្រងខ្លះ ជាឧទាហរណ៍ក្នុងការបញ្ជាក់ជូនដល់មិត្តអ្នកអានគឺៈ

**ឧទាហរណ៍ទី១=** ឱម ឬ ឱំ នេះជាពាក្យសង្ខេបបទសន្ធិនៃអក្សរ ៣ តួគឺៈ អ.ឧ.ម. ដែលមានន័យថា អ គឺជាព្រះវិស្ណុ (VISNU) , ឧ គឺជាព្រះ សិវៈ (SIVA) , ម គឺព្រះព្រហ្ម

(BRAHMA) ។ ដែលជាពាក្យសម្រាប់ហៅព្រហ្មញ្ញដ៏ជាទេវតាខាងដើមបទវេទមន្ត និងជាពាក្យសូត្រប្រឆ្លើយឆ្លងពេលធ្វើពិធីសូត្រប្រកាសជ័យជំនះ ដែលជាវិជ្ជាសរណៈរបស់ពួកព្រាហ្មណ៍អ្នកកាន់ព្រហ្មញ្ញសាសនា ។

**ឧទាហរណ៍ទី២=** ម.អ.ឧ. នេះជាពាក្យសង្ខេបនៃគម្ពីរព្រះត្រៃបិដកក្នុងព្រះពុទ្ធសាសនា មាន ៣ គឺៈ **ព្រះវិន័យ**, **ព្រះសូត្រ**, និង **ព្រះអភិធម្ម** ។ បានសេចក្តីថា ម បានដល់ព្រះគម្ពីរព្រះវិន័យទាំង ៥ គម្ពីរ ។ អ បានដល់គម្ពីរព្រះអភិធម្មទាំង៧ គម្ពីរ ។ ឧ បានដល់គម្ពីរព្រះសូត្រទាំង ៥ គម្ពីរ ។ ហើយមានន័យម្យ៉ាងទៀត ក្នុងវណ្ណៈមានសេចក្តីថា ម គឺជាពូជនិមិត្តរូបការចាប់បដិសន្ធិក្នុងឧទរព្រះមាតា ។ អ អក្សរនេះជាតួអង្គមានបញ្ចក្ខន្ធ ៥ គឺដៃពីរ ជើងពីរ និងក្បាលមួយ ។ ឧ ព្រះករកើតឡើងបានគម្រប់ខែទើបប្រសូត្រពីឧទរ ។ល។

ហើយគាថាក្នុងពុទ្ធមន្តគេនិយមប្រើពាក្យជាច្រើនដែលអ្នកប្រាជ្ញខ្មែរបុរាណខាងសៃវសាស្ត្របានចងក្រងឡើង ដែលហើយមានច្រើនជាព្រះធម៌ដែលព្រះសម្ពុទ្ធទ្រង់ត្រាស់សម្ដែងដែលគេយកមកជា សត្តបរិត្ត ដូចជាៈ

៣. ស្វា. សុ នេះជាបទព្រៃសរពោះពុទ្ធសាសនិកជន ជាបទរំលឹកដល់ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលហៅថាត្រៃប្រណោម ជាអក្សរដើមបទគឺ៖ ៣ បានដល់ ឥតិបិ សោ ភគវា អរហំ.........................។ ស្វា បានដល់ ស្វាក្ខាតោ ភគវតា ធម្មោ...................។ សុ បានដល់ សុបដិបន្នោ ភគវតោ សាវកសង្ឃោ..................។ល។

និងមានគាថាជាច្រើនដែលអ្នកប្រាជ្ញបុរាណខ្មែរខាងពុទ្ធាគមណរបរាប ដកស្រង់ចេញពីគម្ពីរព្រះត្រៃបិដក ឧទាហរណ៍ដូចជា៖

អា បា ម ចុ ប ដែលហៅថា បណ្តូលព្រះបិដក ។

ទី ម សំ អំ ខុ -ជ- បណ្តូលព្រះសូត្រ ។

សំ វិ ធា បុ ក យ ប បណ្តូលព្រះអភិធម្ម ។

អ សំ វិ សុ លោ អ បុ ស ពុ ភ នេះជាបណ្តូលមហាពិគុណ ។

សីលំ ឧជ្ជុមេ បរិសុទ្ធំ នេះហៅថាបណ្តូលសីល ។

ចេ ចា សុ ចេ ម ភោរា អ អំ ធិ ចេ នេះជាបណ្តូលព្រះពុទ្ធអង្គ ។

សំ ឱ អ អ នេះហៅថាបណ្តូលព្រះពុទ្ធគោតម ។

ភ ល ប ប នេះជាបណ្តូលព្រះអាកាសក្រប ។

អ ឈ ទិ នេះជាបណ្ដូលបើនទោង ។ល។

ព្រះគាថាដែលអ្នកប្រាជ្ញបុរាណខ្មែរ ដកស្រង់ចេញពីត្រៃបិដក យកមកប្រើក្នុងផ្លូវបន្ដអាគម អ្នកដែលបានរៀនសូត្រហើយប្រតិបត្តិ ច្រើនមានអំនួតថាពូកែស័ក្ដិសិទ្ធ ដោយគេធ្លាប់មានជួបប្រទះនូវឧប្បត្តិហេតុរួចមកហើយ ឬ ខ្លះថាធ្លាប់បានពិសោធន៍រួចមកហើយ ។ល។

ពពួកបណ្ដូលគាថាទាំងឡាយផ្នែកខាងពុទ្ធបន្ដ ឬផ្នែកខាងវេទបន្ដ ខ្មែរយើងពីសម័យបុរាណច្រើនហៅថា អថ៌ន ឬ បេរថ៌ន ដែលក្លាយមកពីពាក្យសំស្ក្រិតថា អថចិន ដោយកាត់.វចេញទៅត្រឹមតែ.ន ។ ហើយប្រើជាបន្ដអាគមសម្រាប់សូត្រសែកហៅ ឬក៏បណ្ដេញភូតបិសាចជាដើម ឬធ្វើពិធីបញ្ចុះគោលចារឹកដែលសន្មតថាជាជ័យភូមិ ដូចពែងពុថា បញ្ចុះអថ៌ន ។ល។

**ឧទាហរណ៍ទី៣**=មានពាក្យចងក្រងដែលជាពាក្យសំរាយខ្មែរសុទ្ធ មិនមានលាយឡំដោយវេទបន្ដឬពុទ្ធបន្ដ ដូចជាបទរំលឹកគុណខ្មែរចង្អុះមួយប្រភេទថាៈ **សូមរំលឹកដល់គុណព្រះពេជ គលព្រៃវៃ និងមហាស្រទំ ។ល។**

គាថាមួយប្រយោគដែលគេមានជំនឿថាចងខ្មោចបិសាច ឬធ្មប់អាបដែលចូលក្នុងខ្លួនមនុស្ស មិនឲ្យចេញរួចក្នុងពេលដែលគេចាប់សួរចម្លើយ មានជាពាក្យសម្រាយសុទ្ធថា៖

**ចើបអញ្ជើញព្រះព័ន្ធ អញ្ជើញព្រះព័ន្ធ អញ្ជើញព្រះពិធ អញ្ជើញព្រះធរិទ្ធ ជួយមងមំណាងគ្រូអញ ៥ ផាន់ ព័ន្ធមំណាងមង៥គ្រួធ ធញ្ញធព័ន្ធវណ្ណផាន់សើង្គា កុំឲ្យពីងពាអា អាមស្រាយស្បើយបោង ។**

មួយប្រយោគទៀតដែលជាគាថាស្រាយដោះលែង មុននិងឲ្យចេញទៅ ដែលជាពាក្យសម្រាយខ្មែរសុទ្ធដែរថា៖

**ចើបអញ្ជើញព្រះពិធ ចើបអញ្ជើញព្រះពាយ អញ្ជើញព្រះធរាយណ៍ ជួយស្រាយមំណាងគ្រូអញ៥ផាន់ ព័ន្ធមំណាងគ្រូអញ៥គ្រួធ រលូធរលួធមេញទៅ កុំឲ្យពីងនៅក្នុងរូបកាយបោង ។**

ហើយក្នុងផ្លូវទុព្ពិជ្ជា ( ក្នុងផ្លូវអកុសលកម្ម មានច្រើនដែលជាពាក្យសម្រាយខ្មែរសុទ្ធ ) ដូចជាវិជ្ជាមួយប្រភេទដែលគេយក ប្រទាលផ្លុកផ្គុរបកឧបកិច្ចធ្វើ ហើយមានគាថាសូធ្យសែកជាពាក្យសម្រាយសុទ្ធថា ផ្គររអើយច្រងៀង អញ្ជើញព្រះមន្តចុះមកទាំងគប់ អញ្ជើញមហាស្រមុប់ចុះមកទាំងប្រាំ អញ្ជើញគ្រូអ្នក អញ្ជើញ

ត្រូវរី ទើបត្រូវប្រើអញឱ្យកាន់ឈើកោះ ឱ្យចាំង..............ធ្លាក់ ចាយពីហាត់ ធ្លាក់របាត់ពីដៃ ធ្លាក់ស្បៃពីក ទើប................ (បានតទៅទៀតតែមិនត្រូវចេះ គេះប្រាប់ជាឧទាហរណ៍តិច) ។

គាថានេះបើយើងស្តាប់ឮហាក់ដូចជាសូធ្យលេងគួរឲ្យចង់សើច ប៉ុន្តែអ្នកដែលចេះរបៀបធ្វើគេអាចធ្វើឲ្យស្ត្រីភេទទួលយំស្រណោះអាណិតដោយគ្មានហេតុបច្ច័យអ្វីទាល់តែសោះ ។

គេសង្កេតឃើញថាៈ ក្នុងផ្លូវពុទ្ធាចារ ដូចជារំពើរំពាន់ ឬបន្ត ស្នេហ៍ជាដើម ច្រើនតែមានគាថាសូធ្យសែកជាពាក្យសម្រាយខ្មែរសុទ្ធ និងពោយជាប្លូយវេទមន្ត ។

ឧទាហរណ៍ដូចជាពុទ្ធិមួយប្រភេទ ដែលគេហៅថាបន្តខាប គន្លងជើង នោះមានពាក្យឧទានខាងដើមបទជាពាក្យសម្រាយខ្មែរ ថាៈ **និមស្រូប មហាស្រូប ទើបត្រូវប្រើអញ ឱ្យស្រូបនូវគន្លងជើងគេហោង ជើងជាន់នូវដី គ-ន្លងប្រុសស្រី កុំបីអាចថាវ**.....................ទើបបាន វេទមន្តបន្ថែមទៅទៀត ( ខ្ញុំសូមបញ្ជាក់ដោយវិញ្ញូតថា គាថានេះ បើអ្នកដែលធ្លាប់ដឹងនិងធ្លាប់ឃើញ ពីធុដិហារ្យខាងសៃយសាស្ត្រ ប្រហែលគេព្រឺខ្លាចជាប្រាកដ) ។

ដូចនេះអាគមខ្មែរធ្វើឱ្យឃើញសំគាល់បានថា បើគាថាដែលជាសម្រាយខ្មែរសុទ្ធនិងវេទមន្តច្រើនតែក្នុងផ្លូវទុរាចារ រីឯចំណែកពុទ្ធមន្តគេសង្កេតឃើញ មានច្រើនតែក្នុងផ្លូវការពារឬទប់ទល់និងជួយសង្គ្រោះ ។

**ឧទាហរណ៍ទី៤=** មានពាក្យចងក្រង ជាពាក្យសម្រាយខ្មែរលាយផ្សំបញ្ចូលជាមួយនឹងវេទមន្តដូចជាៈ

ឱម្នះ អង្គអញឯងឈ្មោះនាងគង្ហីងព្រះធរណី ផុសឡើងអំពីវេទបល្ល័ងពេជ្រ លេចឡើងជាកសិណសាក្សី ទើបគ្រូប្រើអញផ្គាញ់សត្រូវទិសទាំងប្រាំបី ឲ្យចាញ់បារមីអញក្សិណក្ស័យបាក់បបខ្លបខ្លាច ឱមះ សិទ្ធិស្វាហៈ ។

**ឧទាហរណ៍ទី៥=** មានពាក្យចងក្រងជាពាក្យសម្រាយខ្មែរសុទ្ធលាយបញ្ចូលជាមួយនិងពុទ្ធមន្តដូចជាៈ

នមត្ថុ បការសេន្ធោ សង្ឃា អរហំ ឱខ្លួនអញអើយ មានឫទ្ធិអំណាចដូចរាជសីហ៍ នមោពុទ្ធាយ នមពាន ។

**ឧទាហរណ៍ទី៦=**នឹងមានពាក្យចងក្រងខ្លះដែលបញ្ជាក់ឲ្យ

ដើងពីដំណើរទៅកាន់ព្រះនិព្វាន ហើយដែលឮល្បីថាពូកែស័ក្តិសិទ្ធ ដូចជាគាថាផ្កាញ៉ីហាររបួយវត្តថាៈ

អាយន្តុ ភោន្តោ ឥធ ទាន សីល នេក្ខម្ម វិរិយ បញ្ញា ខន្តី សច្ច អធិដ្ឋាន សមេត្តុបេក្ខា យុទ្ធាយ ទោ ទុនាទិ គតន្តុច **លោកសូមព្រមចិត្តជួយ ទោះជិតឬឆ្ងាយកុំបីឃ្លៀតឃ្លៀង អស់អញ្ជើញបំពេញ នូវបារមីទាំង ទៅកាន់និព្វានផុតបាបវដ្តភព ៗ**

គាថាផ្កាញ៉ីហារនេះគេប្រើជាច្រើនបែបច្រើនប្រការគឺ ខ្លះគេភាវនាក្នុងពេលមានអាសន្នអន្តរាយ, ខ្លះសូត្រស្រែកដីជុំគ្រវែងចោលទៅទិសទាំង ៤ ឬ ៨ ទិសការពារសត្រូវនានា, ខ្លះគេសូត្រស្រែកធ្វើទឹកមន្តព្រោះព្រំ ។ល។ ហើយដែលល្បីថាពូកែស័ក្តិសិទ្ធ ។

**នមោបារមីទេថ**=មានពាក្យចងក្រងដែលជាពាក្យសំរាយខ្មែរសុទ្ធ លាយផ្សំបញ្ចូលជាមួយវិទមន្តហើយនិងពុទ្ធមន្តដូចជាៈ

នមោពុទ្ធាយ ទើបអញញើញទៅព្រាក្សទេព្តាគ្រប់ជាន់ ទាំងគ្រុឌគន្ធព្វក្នុងរូបភព និងយក្ខគន្ធព្វនាគទាំងឡាយ ស្ថិតនៅស្ថានសួគ៌ ទិព្វវិមានទីជិតឆ្ងាយ ឬ នៅវៀងរាយ ឯនាយ ព្រៃភ្នំព្រែក ក្នុងទឹកលើគោកនាអាកាស ដោយអំណាចតេជះព្រះជិនស្រី ទើបអញបញ្ចេញឫទ្ធិបារមី កំចាត់បង់ចង្រៃអាក្រក់ពងទាំងពួង ឱ្យខ្ទេចរលើកអាការបើក ឱ្យរលួយ កម្រើកលោកក្រើកដី រលើកខ្មោចក្រុង

ខ្លួនក្រឡួនក្នុងផ្ទៃ របើកព្រៃព្រាយព្រៀក្សអារក្សអ្នកតា ឱមសិទ្ធិស្វាហា ស្វាហាយ ប អ ក ស អអហំ អំ.អអ.ឥ.ឮ. ព្រាយបោះព្រាយហើរ ព្រាយដើរលើដី ព្រាយស្លាប់កូនខ្ចី ស្លាប់កូនក្នុងផ្ទៃ បេព្រាយករក្ងារខៀវ បេព្រាយរំសាយសក់ ធ្មប់អាបធ្លូលធ្មុក ធ្មបគ្រោះ ទោះជាវិវើវិពាន់ផងនានា ទើបគ្រូប្រើអញលើកធ្នូសរពាញ់ផ្កាញ់ហារសព្រូវ ខ្លួបខ្លាចរំភោចចេស្តា អញផ្ទែងចេញទៅគ្រប់សព្វទិសា ខ្លាចក្រែងអរអារធ្លត់ញាប់ញ័រ ក្លាយទៅជាខ្យល់បក់ពោកផាត់ផាយ រំលើរំលោយរំលើងទាំងភ្លុំ ធ្លាក់បែកខ្ទាត់ខ្ទាយ វិនាសអន្តរាយ អអសោសសោ ពីងខាត់ពីងខិន ធ្នូសរព្រះពន្លុំនៅអាកាស បីដូចរន្ទះល្បះអសុរហារសព្រូវពាធាទិសទាំងប្រាំបីពាក់បបខ្លួបខ្លាច ធូវប្ញទ្ធិវិរពាចខ្លាចព្រះពារមី ពីងញ៉ាប់ញ័រស្លូតរន្ធត់ស្ទារពី ពីងភិតពីងភ័យចរវៃលោចេញទៅ ។

នេះជាគាថាដែលគេធ្វើទឹកបន្តស្រោចទឹកអ្នកជម្ងឺ ដែលគេយល់ថាត្រូវបន្តវិញ្ញាអ្នកដទៃ ឬក៏ធ្មប់អាបព្រាយបិសាច ។

**ខមាបារលើទី៨** = នេះគាថាស្តោះពិសប្ញួយប្រយោគ (១បេ) ដែលបានវេទបន្ទុំផ្សិនិងសប្រាយថាៈ

ឱមសត្ថ ឱមភសត្ថ ទើបគ្រូប្រើអញឲ្យស្តោះ ពិសទឹក ពិសភ្លើង ពិសហើប ពិសហល់ ពិសទប់ ពិសទល់ ពិសវល់ខាន់

ស្លាក់ ទិញបន្ទះអញ្ចើយធ្លាក់លើដីប្លូករពេ លើភ្លឺរពោយ ឡិមអ៊ីចាវ ឆាំ ឡិមអ៊ីចាវឈ ស្តាប់បង្អាប់អញ្ចេះគ្រូបាឡារេ ឡិមសិទ្ធិ ស្វាហះ ៗ

## ពាំណាត់ស៊ាំណាល់

អាគមខ្មែរខាងការបញ្ញើញវិធីភេទ មានពាក្យដែលគេមិនអាចស្តាប់បាន ព្រោះមិនមែនជាពាក្យបាលីឬពាក្យសម្រាយដូចជា៖

១- ម្ពើកសម្ពី **ឆមអះ**

២- កធិប កធិវ

៣-**ឡិម ឥត ទិលាឈុឈុ** ព្រះជាព្រះមន្ត នពោនភ្លុ ។

៤- **អះ អះ កះឡូវណាំពាំង អះប៉ះប៉ុម ណៀវស ពាំង ពាំង ពាំង ៗ**

ដូចនេះបើស្តាប់ពាក្យថា ម្ពើកសម្ពី កធិប កធិវ នពោនភ្លុ ឬ អះ អះ កះឡូវណាំ មិនដឹងជាមានន័យថាដូចម្តេច ។

ប្តូរហេតុដូចដែលបានរៀបរាប់មកទាំងអម្បាលម៉ានពីខាងលើ នេះ បញ្ជាក់ឲ្យឃើញថាផ្នែកខាងបន្តអាគម ដែលជាទំនោរខាង

ផ្លូវចិត្ត (ដែលគេហៅថាចិត្តវិជ្ជា) បុរាណខ្មែរយើងច្រើនពឹងផ្អែកផ្សៀ ទៅលើសក្ការៈ និងអក្សរសាស្ត្រ លាយផ្សំបញ្ចូលគ្នាក្នុងការសូធ្យ សែកដើម្បីឲ្យមានប្រសិទ្ធិភាពរឹងរឹតតែខ្លាំងក្លាឡើង ។

ប៉ុន្តែមានឱសថខ្លះគេប្រើព្យាបាលរបៀបដូចផ្លូវចិត្ត ដោយទំ-ពារស្តោះព្រួស ដែលគ្មានបន្តគាថាអ្វីសោះនោះក៏មានដែរ ។

## V.ឱសថព្យាបាលដូចផ្លូវចិត្ត

*ឧទាហរណ៍ទី១_* ប្រភេទថ្នាំស្តោះព្រួស កំចាត់ពិសពស់ ។

វត្ថុធាតុដើម= បញ្ញើក្អែកនៅដើមក្រូចសើច ។

វិធីប្រើ= គេយកបញ្ញើក្អែកមកទំពាហើយស្តោះព្រួស ពីត្រង់កន្លែងដែលត្រូវពស់ចឹក ដេញចុះទៅក្រោម ។

កំណត់សំគាល់= ពិធីស្តោះនេះដែលមានប្រសិទ្ធិភាព ព្រោះគេសំគាល់ថា បានរៀនពីគ្រូ ។

របៀបរៀន= ការរៀនជបព្រូវឲ្យមាន ផេះជើងក្រាន១ព្រ-ទៀត ហើយកាត់ស្លឹកត្នោតធ្វើជារាងបូជជួសក្រាក់ស្លុក១ទៀត ពីរលើក កំពូន៤ទៀត ។

*ឧទាហរណ៍ទី២_* ប្រភេទថ្នាំស្តោះគ្រុន ឬ ឆ្លោះ ។

វត្ថុធាតុដើម៖ ដើមគ្រួច(ឈើឬឃ្មុប្រភេទអាចសណ្ដែកវល្លិ៍)
វិធីប្រើ៖ គេយកឫស ឬ ដើម មកទំពារស្ដោះពេលព្រើក ។
កំណត់សំគាល់៖ គេប្រើតែនិបន្តពោលពិធីអារក្ខ ។

*ឧទាហរណ៍ទី៣*_ ប្រភេទថ្នាំស្ដោះគ្រុនឬផ្លោះ គ្មានគាថា ។
វត្ថុធាតុដើម៖ ១/មើមស្លាសេះ ២/ស្លា
វិធីផ្សំ៖ យកមើមស្លាសេះ៧ និងស្លា៧ចំណិត ទំពារលាយគ្នា ហើយស្ដោះ ។ មានខ្លះគេយកឫសរំញាញ (ប្រភេទពពួកអាច បន្លាដុះនៅតាមវាលស្រែ) មកហាន់ជា៧ចំណិត លាយនិងស្លា ។

ឯពិធីប្រើមន្តអាគម ខ្មែរប្រើរបៀបដូចគ្នានិងប្រើឱសថយ៉ាង នោះដែរគឺ:

## ខ្មែរប្រើមន្តអាគមជារបៀប២យ៉ាង

១_ គេប្រើមន្តគាថាជារបៀបការពារជំងឺតម្កាត់ និងជារបៀបព្យាបាលជំងឺ ។

២_ គេប្រើមន្តគាថាជារបៀបការពារគ្រោះថ្នាក់ និងជាវិធីទប់ទល់នូវគ្រោះថ្នាក់ ។

# VI.មន្តប្រើការពារជម្ងឺ

*ឧទាហរណ៍ទី១_* គេចារគាថានេះ ចុះក្នុងយ័ន្តក្បាល ៤ ធ្វើជាកថា ដាក់ក្នុងបដ្តុះស្ពាន់ ឬសំណ ពាស ចង.កកូនក្មេងការពារនូវជម្ងឺដែលកើតឡើងបណ្តាលមកពីព្រាយបិសាច ។



*ឧទាហរណ៍ទី២_* គេចារយ័ន្តនេះចុះក្នុងស្លឹកត្នោតឬស្លឹករឹត ឬក្នុងបដ្តុះស្ពាន់ សំណ ដាក់ត្រាំក្នុងពាងទឹកឬក្អម សម្រាប់ផឹក ងូត ការពារជម្ងឺគ្រុនរងា ។ល។



ឧទាហរណ៍ទី៣_ គេចារជាយ័ន្តនេះក្នុងបន្ទះស្ពាន់ឬសំណរឬ មាស ទង់ដែង ឬរូជាកដា "ឡូត" ក្រវាត់ចង្កេះស្ត្រីមានគភ៌ ចាប់ តាំងពីពេលដែលដឹងថាមានកូន ដើម្បីរក្សាគភ៌ឲ្យបានសេចក្ដីសុខ ប្រាសចាកអន្តរាយគ្រប់បែបយ៉ាង ។



ឧទាហរណ៍ទី៤_ គេចារគាថានេះដាក់ក្នុងស្លឹករឹត ឬស្លឹកត្នោត ហើយយកទៅត្រាំនៅក្នុងពាង ឬក្អមសម្រាប់ទុកផឹកដើម្បីការពារ អន្តរាយផ្សេងៗ ។

និ មំ សំ អំ ខុ (នេះចារមួយសន្លឹក) ។

អ ឆា ម ចុ ប (នេះមួយសន្លឹកទៀត) ។

ឧទាហរណ៍ទី៥_ គេចារជាយ័ន្តរបៀបនេះ យកទៅបិទភ្ជាប់និង សសរសរកន្លោង ឬខាងលើទ្វារចូល ដើម្បីការពារព្រាយបិសាច ។

ទោះបីជាកន្លែងណាដែលមានបិសាចកំពុងយាយីការ នោះក៏គេយក គាថានេះអាចនិងកំចាត់បានយ៉ាងស័ក្តិសិទ្ធ ដោយការភាវនាសូត្រ ដែរ និងគេធ្វើពិធីផ្សេងៗទៀត ។



*ឧទាហរណ៍ទី២_* យ័ន្តនេះសម្រាប់ចារបញ្ចុះដាក់ក្នុងបន្ទះសំណរ ឬក្ដាន់ ទង់ដែង ឬរធ្វើជាកថាច្រកបញ្ចូលរំពោះខ្ចុកធ្វើជាខ្សែក សម្រាប់ចង.កក្មេង ការពារបិសាចផងនាៗ ។



*ឧទាហរណ៍ទី៣_* យ័ន្តនេះសម្រាប់ចារបញ្ចុះដាក់ក្នុងបន្ទះសំណរ ឬក្ដាន់ ទង់ដែង ឬរធ្វើជាកថាច្រកបញ្ចូលរំពោះខ្ចុកធ្វើជាខ្សែក សម្រាប់ចង.កក្មេង ការពារជំងឺផងទាំងឡាយដែលបណ្ដាលមកពីពួកខ្មោចព្រាយបិសាច ។



អាគមដែលបានលើកជាឧទាហរណ៍មកនេះ គឺជាវិធីប្រើមន្តការពារជម្ងឺពហ្កាត់ ដូចមានចែងពីខាងដើមហើយថា ខ្មែរប្រើមន្តជារបៀបការពារនិងព្យាបាល ។ តទៅនេះគឺជារបៀបប្រើមន្តក្នុងការព្យាបាល ។

## VII វិធីប្រើមន្តព្យាបាលជម្ងឺ

ឯវិធីប្រើមន្តជារបៀបព្យាបាលជម្ងឺនេះ មានច្រើនបែបច្រើនយ៉ាងណាស់, ជួនកាលគេប្រើម្លូ-ស្លាក្នុងការទំពារស្ដោះព្រួស ជួនកាលគេប្រើត្រឹមធូប-ទៀនដុតសូធ្យផ្លុំ ឬ រុណសប្រាក់ដាក់ក្នុងទឹកដើម្បីព្រោះព្រំឬស្រោចស្រពក្នុងការកំចាត់បង់ជម្ងឺ ជួនកាលមានចារុំជាកថាចងកឬក្រវាត់ចង្កេះ ដែលជារបៀបការពារឬព្យាបាល និងមានវិធីឧបកិច្ចឬឧបទេសផ្សំចូលជាមួយផងទៀត ។ល។

### ក. ពិធីស្ដោះព្រួស

ការស្តោះព្រួសជាកាពព្យកិច្ចមួយ ដែលគ្រូពេទ្យខ្មែរបុរាណតែង អនុវត្តទៅលើការព្យាបាលជម្ងឺផ្សេងៗ ។ ជួនកាលគេស្តោះព្រួស ដោយទំពាស្លាម្លូ ជួនកាលគេស្តោះព្រួសដោយទំពាថ្នាំ ឱសថ តែបើកាលណាគេស្តោះព្រួសទៅលើខ្លួនអ្នកជម្ងឺហើយ បន្ទាប់មក គេច្រើនតែផ្លុំរស់រយៈពេលមួយដង្ហើម (តែមានឱសថខ្លះនិងជម្ងឺ ខ្លះគេហាមមិនឲ្យផ្លុំក៏មានដែរ) ។

ក្នុងការដែលទំពាស្លា.ម្លូ.ឬឱសថនោះ គេឃើញមានរបៀប ២យ៉ាងគឺៈ យ៉ាងគេទំពាបណ្តើររាយមន្តអាគមគាថាបណ្តើរ យ៉ាង ទៀតគេសូត្រឲ្យសែកនៅលើថ្នាំ ឬម្លូ.ស្លា រួចទើបទំពាស្តោះជាខាង ក្រោយ ឬគេសូត្រសែករួចហើយទំពាស្តោះព្រួសបណ្តើរភាវនា បណ្តើរថែមទៀតក៏មាន, ហើយមានថ្នាំខ្លះដែលគេប្រើទំពាស្តោះ ព្រួស ដោយមិនបាច់សូត្រឲ្យបន្តគាថាអ្វីសោះនោះក៏មានដែរ ។

## ខ. ពិធីផ្លុំ

ផ្លុំជាពិធីមួយដែលគេប្រើមន្តអាគមស្រូវ ,គេច្រើនសូត្រផ្លុំនៅ ត្រង់ចំណុចសំខាន់ៗនៃរាងកាយ ដែលគេមិនអាចស្តោះព្រួសកើត ដូចជាក្នុងភ្នែក ក្នុងត្រចៀក ក្នុងគ្រាប់ភ្នែក ។ល។ ឧទាហរណ៍ ជម្ងឺរុតធំ ដែលគេចាត់ទុកថាជាជម្ងឺមួយដ៏សាហាវ ហើយមាន

កើតចេញពីកណ្ដាលគ្រាប់ភ្នែក តែកាលណាព្យាបាលជាទៅ ភ្នែកអ្នកជំងឺត្រូវតែខ្វាក់, ដូចនោះត្រូវតែព្យាបាល គេត្រូវប្រើមន្តផ្លុំបំបែរឲ្យចេញផុតពីក្នុងគ្រាប់ភ្នែក ឲ្យទៅកើតនៅលើសាច់ខាងក្រៅក្បែរនោះទៅវិញ ។ ឯវិធីផ្លុំនេះគេភាវនារាយមន្តគាថាជាប់នៅក្នុងមាត់ឬក្នុងចិត្តជានិច្ច គ្រាន់តែមិនបញ្ចេញឲ្យឮប៉ុណ្ណោះ ។

## គ. ស្រោចទឹកឬព្រោះព្រំ

ស្រោចទឹកជាវិធីមួយដែលគេមានជំនឿទៅលើមន្តគាថា និងមានជំនឿទៅលើវត្ថុជាទីគោរពសក្ការៈ ដែលខ្មែរយើងមានជំនឿទៅលើសាសនា មានព្រហ្មញ្ញសាសនា ហើយនិងព្រះពុទ្ធសាសនា ។ល។ ដែលគេមានជំនឿថាកាលបើសូត្ររំលើកទឹករួច អាចនិងជួយប្រសិទ្ធិឲ្យមានជោគជ័យ ឬជៀសផុតពីគ្រោះអន្តរាយ ឬអាចធ្វើឲ្យបានធូរស្បើយពីរោគាព្យាធិបាន ។

ក្នុងពិធីនេះគេច្រើនយកទៀនបកផុតឲ្យឆេះហើយភាវនាសូត្រសម្រក់ដំណក់ទៀនចូលទៅក្នុងទឹកផ្តិល ឬធុង ថាំង ពាង ដែលគេហៅថាទឹកមន្ត សម្រាប់ព្រោះព្រំឬលុបលាងមុខមាត់ ផឹក ងូតលាបស្រឡាបលើសរីរាង្គកាយ ។

## ឃ. ចារ៉ុបញ្ចុះ

វិធីចារ៉ុបញ្ចុះនេះ ជួនកាលគេធ្វើជាយ័ន្ត្រ ដែលមានតួអក្សរជាពាក្យបាលីឬអក្សរខមផ្សំលាយបញ្ចូលជាមួយគ្នា, ជួលកាលគេចារ៉ុជាតួអក្សរឬលេខ ដែលភាគច្រើនសុទ្ធតែជាពាក្យបាលី ។ គេច្រើនចារ៉ុដាក់ក្នុងបន្ទះស្ពាន់ បន្ទះសំណ ឬមាសសន្លឹក ដែលអាចមូរបានជាបំពង់ ឬក្បូរ សម្រាប់ស្លូកខ្សែរំពោះឬស្លូព្រ ដើម្បីចងធ្វើជាខ្សែ.ក ឬខ្សែក្រវាត់ហៅថាខ្សែចង្កេះ ។ មានជួនកាលគេយកព្រីក្សាជាពិន្ទុះដូចជាស្លឹកត្នោត ស្លឹករឹតបកចារ៉ុផងដែរ ដើម្បីដាក់ព្រំក្នុងពាងទឹកឬពុងថាំង សម្រាប់ផឹក ឬសម្រាប់ងូត ។ល។ គេសំគាល់ឃើញថាវិធីចារ៉ុគាថានេះ គេធ្វើឡើងច្រើនតែក្នុងកិច្ចការពារជម្ងឺ មិនសូវមានច្រើនជារបៀបព្យាបាលជម្ងឺទេ ដូចមានចែងជាឧទាហរណ៍នៅខាងលើ ។

ដូចនេះពិធីស្តោះព្រួស ផ្លុំ ស្រោចទឹក ឧបកិច្ច អប់ខ្មុស និងចារ៉ុបញ្ចុះ សុទ្ធតែពិធីព្យាបាលខាងផ្លូវចិត(**មិន្តមិជ្ជា**)ដូចមានចែងពីខាងដើមថា របៀបព្យាបាលមានពីរគឺខាងផ្លូវចិត្តនិងផ្លូវសម្ភារៈ។

## ការព្យាបាលខាងផ្លូវចិត្ត

ការព្យាបាលខាងផ្លូវចិត្ត ភាគភាគច្រើនដែលប្រើមន្តគាថាផ្សំ

ជាមួយសម្ភារៈ (ឱសថឬថ្នាំ) ។ ប៉ុន្តែការព្យាបាលខាងផ្លូវចិត្តដែលជារោគកើតខាងផ្លូវចិត្ត ហៅថារោគប្រសាទដូចជារោគកើតឆ្កួត ឬរោគដែលគេមានជំនឿថាត្រូវអ្នកណាមួយធ្វើ (ផ្នែកខាងទុព្ពិជ្ជា) ដូចជាត្រូវស្នេហ៍ឬត្រូវអំពើអំពាន់គេជាដើម ឬក៏ត្រូវធ្មប់រាបចូល ធ្វើឬខ្មោចព្រាយបិសាចចូលសន្ធិ ។ល។

ការព្យាបាលខាងផ្លូវចិត្តនេះ ដែលតែងតែឃើញប្រើមន្តអាគមគាថា ក្នុងការស្ដូផ្លុំ ឬស្ដោះព្រួស ហើយមិនធ្វើជាទឹកមន្តព្រោះព្រំ ឬស្រោចស្រព ដែលពឹងផ្អែកទៅលើសម្ភារៈ មានទៀនធូបជាដើម សម្រាប់ដុតបូជាឬដុតសម្រក់ ។ល។

## **ពិធីស្ដូផ្លុំ** (ព្យាបាលផ្លូវចិត្ត)

*អត្ថាធិប្បាយ*- សូមបញ្ជាក់ជូនជាភស្តុតាងក្នុងសម័យខ្មែរក្រហម កាលពីឆ្នាំ ១៩៧៦ នៅសហករណ៍ **ក្បាឈមួស ភូមិ អារី ស្រុក ពាមព្រឡ ខេត្តឈធរម៉ង** ។ កម្មាភិបាលខ្មែរក្រហម បានប្រើយុវជនយុវនារី ឲ្យទៅកាប់ឆ្ការព្រៃមួយកន្លែង ដែលអ្នកស្រុកហៅថា ព្រៃ **ប្រាប** ។

ហើយព្រៃត្រង់កន្លែងនោះ អ្នកភូមិនៅជិតៗនោះ គ្មាននរណាមួយដែលហ៊ានចូលទៅកាប់ឆ្ការ ធ្វើអ្វីៗទាល់តែសោះ ព្រោះអ្នក

ភូមិទាំងនោះគេដឹងច្បាស់ថាជាកន្លែងគ្រោះថ្នាក់ ដែលគេបានព្រមានប្រាប់ដល់កូនចៅៗមកតាំងតែពីយូរយារម្លេះ ។

ឃើញដូច្នោះអ្នកភូមិឈ្មោះតា **ឡុច** បានខ្សឹបប្រាប់ លោកតា **ប៊ុន ហ៊ីង** ថា៖ អ្នកឯងចាំមើលចុះ ! ដីព្រង់ណោះមិនដែលមាននរណាហ៊ានទៅធ្វើអ្វីផ្ដេសផ្ដាសទេ បុខជាមិនឈ្លះនឹងសែងទេមើលទៅ ! (បានន័យថាសែងខ្មោចយកទៅកប់) ។

សំដីព្យាករណ៍របស់តា ឌុច ជាការព្រាកដណាស់, យុវជនយុវតីអភ័ព្វទាំងឡាយនោះត្រូវទទួលរងគ្រោះថ្នាក់ ដែលឃើញសែងក្នុងមួយថ្ងៃៗពី ២០ ទៅ ៣០ នាក់ គ្មានពេលថ្ងៃណាមួយជារៀងរាល់ថ្ងៃ ហើយដែលបានបាត់បង់ជីវិតទៅចំនួនរាប់រយនាក់ ដោយគ្មាននរណាហ៊ានចេញមុខតវ៉ាទាមទារ ឬពន្យល់ប្រាប់ហេតុផលអ្វីទាំងអស់ ព្បិតខ្លាចខ្មែរក្រហមសម្លាប់ ។

ក្នុងថ្ងៃមួយប្រពន្ធលោកតា ប៊ុន ហ៊ីង ( ឈ្មោះ ម៉ក់ កែប ) បានរត់មកប្រាប់ប្ដីក្នុងក្ដីភិតភ័យតក់ស្លុត និងយំទួញសោកស្ដាយថា៖ កូនស្រីយើង ! ( ឈ្មោះនាង គិមហេង ហ៊ីង អាយុ ១៦ ឆ្នាំ ) ឃើញគេសែងចេញមកហើយ ! ហើយបាត់ដង្ហើមស្ងៀមឈឹងគ្មានឃើញកម្រើកអ្វីបន្តិចបន្តួចសោះ ! ប្រហែលជាស្លាប់ផុតទៅហើយមើលទៅ ! ។

ពេលនោះលោកតា ប៊ុន ហ៊ីង ឮដូច្នោះភិតភ័យស្លន់ស្លោស្ទុះ

រត់ទៅហើយក្ដី. ហើយកាលពីព្រឹកព្រលឹមនោះក្ដីចាប់ផ្ដើមទៅ ហើយ ។ ព្រោះក្ដីចាប់ផ្ដាច់ផ្លូវពីភិតពីមុខ (ពីព្រោះទៅ ជាថ្នាំ) កិច្ច ១ ឬ ២ ថ្ងៃក៏ធូរស្រាលហើយ ។

ឃើញដូច្នោះតា គុត ដែលទៅជិតនោះដែរ បានសុំប្រាប់ តា ប៊ុន ហ៊ុង ផង ឲ្យប្រញាប់ទៅរកគ្រូលោកតាអ្នកដែលនៅ ភូមិជិតនោះ ដែលពីមុនគាត់ជាលោកសង្ឃធ្វើជាអាចារ្យ ហើយ ត្រូវខ្មែរក្រហមផ្សឹកឲ្យចេញពីវត្ត ទើបគាត់ចេះធ្វើកំរោល (កំ រោលបេចូល, ព្យាសកប្រាល, ដេញកំរោល, ខ្មែរសំណៀបយកព្រាយ បិសាចដែលអាចធ្វើមនុស្សឲ្យស្លាប់បាន ) ។

ឮដូច្នោះលោកតា ប៊ុន ហ៊ុង បានឆ្លើយប្រាប់តា គុត ផង ថា កំរោលបែបនេះខ្ញុំក៏ចេះធ្វើដែរ ! តែមិនដឹងជាទៅរកថ្នាំឯណាបាន ! ទើបតា គុត រត់ទៅយកថ្នាំពីផ្ទះគាត់យកមកឲ្យ (ព្រោះតា គុត មានគំនិតលាក់ថ្នាំទុកមិនឲ្យខ្មែរក្រហមដឹង) ។

ភ្លាមនោះលោកតា ប៊ុន ហ៊ុង បានសូត្រពិធីព្យាសកំរោលមិន ទាន់ចាំងចប់សព្វគ្រប់ផង ស្រាប់តែកូនស្រីដែលដេកស្លូកស្លឹងនោះ ឃើញមានដង្ហើមស្ទុះឡើង ដែលជាហេតុបញ្ជាក់ឲ្យដឹងថា មាន ជីវិតរស់ឡើងវិញហើយ ។

ខណៈនោះតា គុត បានឃើញហេតុការណ៍ ដ៏អស្ចារ្យដូច្នេះ ក៏ស្ទុះសំរើកឡើងហើយខ្លាំង ដោយសេចក្ដីត្រេកអរថា អាហា !

ណា ! រស់ហើយហ្ន៎ ! ។

ដំណើររបស់តា ឌុក បានចាស់ស្មារតីបន្តិចម្តងៗដល់ពេល នៅទីនោះ ឲ្យពីងផ្តល់ឲ្យគ្នាថា លោកតា ម៉ុន ហ៊ុង បានធ្វើពិធីសូត្រមន្តការពារកូនរបស់គាត់ឲ្យរួចផុតពីសេចក្តីស្លាប់ទៀតបាន។ ហើយក្នុងពេលជាមួយគ្នានោះ ក៏បានពឹងឲ្យទៅដល់ជនពាលើក្នុងខ្មែរក្រហមម្នាក់ ដែលមានកូនត្រូវគ្រោះថ្នាក់ដូចគ្នានឹងកូនលោកតា ម៉ុន ហ៊ុង ដែរ ។

ទើបគេហៅលោកតា ម៉ុន ហ៊ុង ឲ្យទៅធ្វើការពារឲ្យកូនរបស់គេក្នុងពេលនោះ ហើយនិងកូនអ្នកដទៃទៀតជាច្រើនគ្នា ដែលបានរស់ឡើងវិញទាំងរស់គ្នាគ្មានខូចខាតមួយឡើយ ។ ជាហេតុធ្វើឲ្យខ្មែរក្រហមមានជំនឿទៅលើការពារ ហើយបានជួយឧបត្ថម្ភលោកតា ម៉ុន ហ៊ុង យ៉ាងពេញទំហឹង រហូតដល់មានបុគ្គលអង្គការពិងព្រឿងបរិភោគផ្សេងៗឲ្យដល់គ្រួសារលោកតា ម៉ុន ហ៊ុង ទៀតផង ។

ដំណើរជាឧទាហរណ៍ ដែលបានរៀបរាប់មកនេះ គឺជារឿងពិតជាក់ស្តែងដែលកើតនិងកន្លងមកក្នុងពេលថ្មីៗនេះ ហើយដែលលោកតា ម៉ុន ហ៊ុង និងភរិយា ព្រមទាំងកូនស្រីគឺនាងតិប នៅកំពុងរស់នៅ នៅទីក្រុងកូវែល រដ្ឋកាលីហ្វញ៉ា ដែលខ្ញុំសូមជូនការពារក្នុងសៀវភៅនេះផងដែរ ។ ហើយក្នុងការនេះ

យោគអង់គ្លេសត្រូវត្រៀមទុកតាំងពីពេល ដូចកង់វៀនផ្ទុក ធូរបន្តិច អាចទាក់ទងផ្ទាល់និងគាត់បានតាមត្រូវការ ។

*ឧទាហរណ៍ទី១_* បង្គោលគា និងវៀនក្បាលល ដែលគាត់បានប្រាប់ខ្ញុំមានដូចតទៅ ៈ

១/ រូប ទុក ១ សរសៃស្ល ៣ សរសៃ (ពោរ ២ សរសៃ)។

២/ ផ្តិលក្បាល (លើព្រះព្រឹទ្ធ) ទៅរកពុកមុខលើង ។

៣/ ស្លឹក ៣ សន់ ផ្លុំ ៣ ដង, ស្លឹក ៩ សន់ ផ្លុំ ៣ ដង, ស្លឹក ៧ សន់ ផ្លុំ ៣ ដង ។

**សុគតោ សុគ ឋានំ សុគតោ សន្តំ សុគតោ យាមិ សុគតោ យាមំ អតិបរាជ (សៀន) ឥតិតា ចេ ន មិជ្ជា ៗ**

នេះជាវិធីព្យាបាលខាងផ្លូវចិត្ត (ចិត្តវិទ្យា) ដែលប្រើបន្ទុំអាគមជាវៀនបន្តិ និងប្រើព្រឹកដែលបរុសបុសរូបតូចព្រឹត្តិរ៉ុយោត្ត គ្មានធ្វើទឹកបន្តប្លុំស្តោះព្រួសអ្វីទាំងអស់ ។ (វេលាវៀនបង្គោលគានេះ បើលោក អ្នកពោលវៀនឬក៏ផង់ពីងក្បាល អាចសាកសួរផ្ទាល់បានតាមត្រូវការ, ព្រោះពិធីវៀនបន្ទុំអាគមខ្មែរយើងត្រូវមានវៀន ជាស្លាកកើ ចាស់តា និងពិធីផ្សេងៗ បើធ្វើខុសពិធីអាចពិនិត្យមើលច្បាប់ ...

ឬក៏ចៀរកេទ កូនកេទ ក្រោកកេទ ។ល។

*ឧទាហរណ៍ទី២_* ការព្យាបាលផ្លូវចិត្ត ដោយវិធីស្ដោះផ្លុំ ។

**យតោហំ ភគិនិ អរិយាយ ជាតិយា ជាតោ នាភិជានាមិ សញ្ចិច្ច បាណំ ជីវិតា វោរោបេតា តេន សច្ចេន សោត្ថិ តេ ហោតុ សោត្ថិ គព្ភស្ស ២**

គាថានេះជាពុទ្ធមន្ត សម្រាប់ជួយសង្គ្រោះស្ត្រីដែលប្រសូត្រ ពុំរួចខ្លួន ។

ភាវនា ៣ ចប់, ៥ ចប់, ៧ ចប់ ស្ដោះពីក្បាលចុះទៅ ។

កំណត់សំគាល់៖ គាថានេះបើតាមសម្ដីអ្នកដែលចេះ និងបាន ការពិសោធរួចមកហើយ គេថាមានប្រសិទ្ធភាពមែន ។ ព្រោះ គាថានេះបើប្រែចេញជាសេចក្ដីថា៖

ម្នាលប្អូនស្រី ! តាំងពីខ្ញុំបានកើតហើយ ដោយអរិយជាតិ មិនចេះរំលងផ្ដាច់ជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូម សិរីសួស្ដីកើតមានដល់នាង សូមសិរីសួស្ដីកើតមានដល់គភ៌ (ទារក) ។

*ឧទាហរណ៍ទី៣_* ការព្យាបាលផ្លូវចិត្ត ដោយពិធីស្ដោះផ្លុំ ។

គាថាស្ដោះកំចាត់ពិសវិក្សា (វិក្សា) ដូចតទៅ៖

ននេហឹ នាគោ ក្រុទ្ធោ មមេ

ស្តោះពីក្បាលចុះទៅក្រោម (លើកទី១)

លើកទី២ ននេហឹ ក្រុទ្ធោ នាគោ មមេ ។

គាថានេះមានអ្នកធ្លាប់បានសាកល្បងរួចមកហើយ ដែលបានទទួលជោគជ័យយ៉ាងប្រចះប្រចង់ គឺលោកអាចារ្យ គាំ លោកបានប្រើគាថានេះស្តោះឲ្យខ្មែរក្រហមម្នាក់ ដែលត្រូវក្រុមនៅយ៉ាងជំណាំ ស្រែកទ្រហោរំពាវនាវឲ្យគេជួយ ដោយប្រកាសថាបើស្តោះទៅបាត់ឈឺឬមិនបាត់នោះ ឥតមានប្រកាន់ទោសពៃរ៍ អ្វីទេ ដែលក្នុងកាលពេលនោះលោកអាចារ្យ គាំ បានទទួលរង្វាន់ដ៏ជាទីគាប់ចិត្ត គឺបានអាហារបរិភោគយ៉ាងឆ្អែត ( ព្រោះក្នុងកាលគ្រានោះ អ្នកណាបានអាហារបរិភោគប្រៀបស្មើនិងបានវត្ថុពិសេស) ។

*ឧទាហរណ៍ទី៤_* ការព្យាបាលផ្លូវចិត្ត ក្នុងការស្តោះព្រួស ។

អានគាថាដែលជាពុទ្ធបន្ទូល ដែលព្រះសម្ពុទ្ធត្រាស់ប្រាប់ថា:

សព្វាសីវិសជាតីនំ ទិព្វមន្តាគទំ វិយ យន្នាសេ-
តិវិសំឃោរំ សេសញ្ចាបិបរិស្សយំ អាណាក្ខេត្តម្ហិ ស-
ព្វត្ថ សព្វទា សព្វបាណិនំ សព្វសោបិ និវារេតិ ប-
រិត្តន្តម្ភណាម ហេ ។

ព្រះគាថានេះគេសម្រាប់ស្តោះកំចាត់ពិសសត្វខាំឬចុក ដូចជា

ខួរក្បាល ពុំព្រម ស្រែកពេលណោះ ។ ដែលការតម្រូវក្បាលក្នុងស្រូវ
ប្រាកដប្រើក្នុងខួរ ។

## ការព្យាបាលផ្លូវចិត្ត ប្រើមន្ត និង អាបធ្មប់

អាបធ្មប់ ឬ អំពើ គឺជាការបញ្ចៀសរបស់ព្រលឹងឲ្យចៀសចេញពីរាងកាយ ឬចូលក្នុងរាងកាយទៅ, ដែលជាវិធីបង្វិលម្ខាង មិនឲ្យព្រលឹងប្រែ ឬក៏ជាអាបធ្មប់អាចមិនឲ្យឆ្លងពីម្នាក់ទៅម្នាក់ទៀត ឬក៏ ព្រលឹងរបស់ដែលកើតហើយ ឲ្យទៅកើតនៅកន្លែងផ្សេងទៀត ។ ឧទាហរណ៍ដូចជាកើតដុំសាច់ក្នុងក្បាលជម្ងឺ ដែលជាជំងឺដ៏ធ្ងន់ ពេទ្យមិនអាចព្យាបាលបានទេ អ្នកជម្ងឺអាចនឹងពិការភ្នែកដើម្បី, ឬឈ្មោះគ្រូខ្មែរធ្វើអាបធ្មប់ថា" បើកើតក្រោយកន្លែងនេះអញ្ជឹងភ្លាមទេ ! អញ្ជឹងគាត់ត្រូវតែដាក់កន្លែងឯណោះ" បើការធ្វើអោយដុំសាច់ដែលបាត់ឲ្យចេញពីក្បាលជម្ងឺ ទៅកើតនៅកន្លែងដទៃវិញ ។

# ព្យាបាលផ្លូវចិត្តដោយវិធីថ្មី

*ឧទាហរណ៍ទី៥_* ការព្យាបាលខាងផ្លូវចិត្ត ដោយថ្នាំខ្មែរ ។

ពីពេល ព្រឹកព្រលឹម ដែលកើតមិនធ្លាប់ព្រួយស្លុត ហើយគ្រូ
ត្រូវតែពិនិត្យ ដោយប្រយ័ត្នទៅ ត្រូវតែពីការគោរពទៀតផង

ទុក ប្រយ័ត្នត្រូវប្រើថ្នាំពីរ មួយគេការពារកុំឲ្យកើតរោគជ្រុលចំពោះ
ដែលគេត្រូវការទុក ប្តូរការឧទាហរណ៍ដូចនេះ៖

ថ្នាំ៖ ស្ទ្រេះខេរ អគ្គខេរ លេប ៣ គាប់ ថ្ងៃ ៣ ដង ពីរថ្ងៃ ទៅក្រោយរោគ ។

លេប ២១ គាប់ ថ្ងៃ ៣ ដង មិនដែលទៅរកមេរោគ ។

លេប ៣៩ គាប់ ថ្ងៃពីរដែលទៅរកមេរោគ ៣ ដង ហើយទៅក៏ការទ្រាំរោគប្រភេទ៖ ត្រូវល្អប្រាកដ់ពីមុនចេញការធៀប្រាំនេះ (ថ្នាំពិចដែលគេពិសោធហើយ ចំពោះការព្យាបាលអ្នកជំងឺ) ដែលអ្នកដែលធ្លាប់ព្យាបាលអ្នកជំងឺ ត្រូវតែប្រកែកទៀតហើយពិនិត្យមើលឲ្យបរិស ចេញការធៀប្រាំមេរោគដែលទៅក៏រក្សាទុកនោះ ។

## ព្យាបាលក្លូវមិត្តហោយប្រើទឹកមន្ត

*ឧទាហរណ៍ទី១* – ការព្យាបាលក្តៅខ្លួន ដែលត្រូវទឹកក្តៅត្រជាក់ ។

ពិធីព្យាបាលរមៀលដោយដាក់ (ស្តាក់រមៀល) ។

វិធីព្យាបាលនេះ គេយកទឹកត្រជាក់ដាក់ក្នុងត្រួលថ្លើមរបស់ទឹកក្តៅត្រជាក់ ដូចការពាហាហា៖

**ទី២ ទឹក។ ចំណប់ក៏ប៉ុនស្ទើរ ភ្លឺប៉ុនដូក** ។

លេបក្រៅ ១០០ ដង ។

កត់សំគាល់   គេច្រើនស្រោចទឹកមន្តពីលើក្បាលចុះមកក្រោម ដើម្បីឲ្យទឹកមន្តស្រោចពីលើក្បាល រឿងចង្រៃត្រូវតែរលុបធ្លាក់ចុះទៅក្រោម ឬក៏ខ្មោចចេញមកតាមរយៈជើងវិញជាក្រោយ ដោយអំណាចទឹកមន្ត ។

*ឧទាហរណ៍ទី៧_* ការព្យាបាលផ្លូវចិត្ត ,ដែលបណ្ដុះស្លៀកសែកធ្វើទឹកមន្តស្រោះព្រំ ស្រោចស្រព ផឹក ប្រឹត ។ល។

ការព្យាបាលជម្ងឺខាងផ្លូវចិត្តដោយប្រើទឹកមន្តនេះ គេសង្កេតឃើញថាខ្មែរបុរាណយើងនិយមធ្វើពិធីនេះច្រើនណាស់ ដូចជាជម្ងឺខ្លះដែលគេព្យាបាលរួចជាស្រេចហើយ ហើយគេធ្វើទឹកមន្តស្រោះព្រំក៏ត្រូវចាត់ទុកជាកិច្ចបង្ហើយ ដែលគេយល់ថាដើម្បីជ្រះស្រឡះនូវគ្រោះកាចចង្រៃទាំងឡាយទាំងពួង ដោយអំណាចទឹកមន្ត ។ តែជាពិសេសគេច្រើនព្យាបាលខាងរោគប្រសាទ គឺរោគខាងផ្លូវចិត្ត ដូចជារោគឆ្កួតជាដើម ។

គាថាដែលគេប្រើក្នុងការស្លៀកសែកធ្វើទឹកមន្តនេះ ច្រើនតែជាគាថាដែលដកស្រង់ចេញពីព្រះពុទ្ធសាសនាស្ទើរតែទាំងអស់ ដែលគេហៅថាបរិត្តមន្ត ឬសត្តបរិត្ត ដូចជាគាថាលើកយកមកជូនជាឧទាហរណ៍ខ្លះតទៅនេះ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

(បីដង) ។

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជា-
ចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិ-
សទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ
ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូ
ហីតិ ។

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ
ភគវតោ សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ
សាវកសង្ឃោ សាមីចិបដិបន្នោ ភគវតោ សាវក-
សង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុ-
គ្គលា ឯសភគវតោ សាវកសង្ឃោ អាហុនេយ្យោ
បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អ-
នុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

សព្វីតិយោ វិវជ្ជន្តុ សព្វរោគោ វិនស្សតុ មា តេ
ភវត្វន្តរាយោ សុខីទីឃាយុកោ ភវ អភិវាទនសី-
លិស្ស និច្ចំ វុឌ្ឍាបចាយិនោ ចត្តារោ ធម្មា វឌ្ឍ-
ន្តិ អាយុ វណ្ណោ សុខំ ពលំ ។

សព្វពុទ្ធានុភាវេន សព្វធម្មានុភាវេន សព្វសង្ឃា-
នុភាវេន ពុទ្ធរតនំ ធម្មរតនំ សង្ឃរតនំ តិណ្ណំ រត-
នានំ អានុភាវេន ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេ
ន បិដកត្តយានុភាវេន ជិនសាវកានុភាវេន សព្វេ
តេ រោគា សព្វេ តេ ភយា សព្វេ តេ អន្តរាយា
សព្វេ តេ ឧបទ្ទវា សព្វេ តេ ទុន្និមិត្តា សព្វេ តេ
អវមង្គលា វិនស្សន្តុ

អាយុវឌ្ឍកោ ធនវឌ្ឍកោ សិរិវឌ្ឍកោ យសវ-
ឌ្ឍកោ ពលវឌ្ឍកោ វណ្ណវឌ្ឍកោ សុខវឌ្ឍកោ
ហោតុ សព្វទា ទុក្ខរោគភយា វេរា សោកា សត្តុ
ចុបទ្ទវា អនេកា អន្តរាយាបិ វិនស្សន្តុ ច តេជ
សា ជយសិទ្ធិ ធនំ លាភំ សោត្ថិភាគ្យំ សុខំ ពលំ
សិរិ អាយុ ច វណ្ណោ ច ភោគំ វុឌ្ឍី ច យសវា
សតវស្សា ច អាយូ ច ជីវសិទ្ធី ភវន្តុ តេ ។

ភវតុ សព្វមង្គលំ រក្ខន្តុ សព្វទេវតា សព្វពុទ្ធានុ-
ភាវេន សព្វធម្មានុភាវេន សព្វសង្ឃានុភាវេន ស-
ទា សោត្ថីភវន្តុតេ ។

សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ បញ្ច-

សតសហស្សានិ នមាមិ សិរសា អហំ

ឯតេសំ ធម្មានំ សង្ឃានំ អាទរេន នមាមិហំ នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយា វិនស្សន្តុ អសេសតោ សម្ពុទ្ធេ បញ្ចបញ្ញាសញ្ច ចតុវីសតិសហស្សកេ ទសសតសហស្សានិ នមាមិ សិរសា អហំ

ឯតេសំ ធម្មានំ អាទរេន នមាមិហំ នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ សម្ពុទ្ធេ នវុត្តរសតេ អដ្ឋចត្តាឡីសសហស្សកេ វីសតិសតសហស្សានិ នមាមិ សិរសា អហំ

ឯតេសំ ធម្មានំ សង្ឃានំ អាទរេន នមាមិហំ នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ ។

កំណត់សំគាល់- ការព្យាបាលខាងផ្លូវចិត្ត ដោយពិធីត្រូវតែ [illegible]

នៅទៀតទេ ! ដូចនេះរឿងពិតហេតុដែលអ្នកខ្លះបានជួបប្រទះនៅក្នុងគ្រាថ្មីៗនេះ ធ្វើឲ្យគេនឹងវិបល្លាស ជាឧបសគ្គរាំងស្ទះផ្លូវដំណើរជីវិតរបស់គេ ដូចខ្ញុំនឹងលើកយកមកពណ៌នាក្នុងទីនេះ ដើម្បីជាឧទាហរណ៍ និងជាសក្ខីភាពដល់មិត្តអ្នកអានក្នុងការពិចារណាដូចតទៅ ៖

លោក **គិត.ស៊ាង.ហោ** និងនាង **សេងលី.គិត** ជាភរិយា មានអាស័យដ្ឋានស្ថិតនៅក្នុងរដ្ឋ កុណិកទិកិត (Connecticut) ។ ក្នុងឆ្នាំ ១៩៨៨ បាននាំគ្នាមកទិញហាងលក់ម្ហូបអាស៊ីមួយនៅតំបន់ឡូវែល (Lowell, MA.) ឈ្មោះហាងទន្លេសាប (ក្រោយមកប្រែដាក់ឈ្មោះគិរីរម្យ) ។

ដោយយល់ឃើញថា អាសយដ្ឋាននៅឆ្ងាយពេក ក្នុងការធ្វើដំណើរចុះឡើង ទើបនាំគ្នាមកជួលគេហដ្ឋានមួយនៅត្រង់តំបន់វែសហ្វត( 7 Town form rd,West ford MA.ផ្ទះមួយគ្រួសារ.) ដែលមានជីដូនម្នាក់ និងកូនប្រុសបីនាក់នៅជាមួយ ។

ជារៀងរាល់ថ្ងៃព្រលឹមឡើង លោក ហោ និង ភរិយា តែងនាំគ្នាចេញពីផ្ទះទៅលក់ចំណីនៅហាងបាត់ទៅ ហើយកូនទាំងបីនាក់ក៏នាំគ្នាទៅសាលារៀនអស់ ។ ដូចនេះជីដូនឈ្មោះលោកយាយ រឿង.ឈាយ.ស៊ិម ត្រូវនៅចាំផ្ទះម្នាក់ឯង ។

[illegible]



គេហដ្ឋាននេះដែលមានអព្ភូតហេតុធ្វើឱ្យលោក ចោរ
និងភរិយា នៅមិនបាន សម្រេចចិត្តចុះចេញ ។

ពេលយប់នៅលើផ្ទះ ហើយក៏រុះទៅនៅលើដីខាងក្រៅ ព្រោះបើយប់ពេក រង់ចាំគេៗចេញពីសាលារៀនមកវិញទើបហ៊ានចូលផ្ទះ ។

កាលបើដឹងថាជីដូនធ្វើយ៉ាងនោះ លោក ហោ ក៏បានសាកសួរដេញដោលអំពីហេតុ ដែលគាត់មិនព្រមនៅលើផ្ទះនោះ ។ ហើយគាត់បានឆ្លើយត្អូញត្អែរប្រាប់ថា គេមិនចង់ឲ្យអញនៅលើផ្ទះនេះទេ ! ។

លោក ហោ កាលបើឮដូច្នោះ ក៏លែងរវល់យកចិត្តទុកដាក់ និងសម្ដីរបស់ជីដូនដែលរៀបរាប់ប្រាប់ ដោយមានគំនិតយល់ថា ព្រោះតែគាត់ខ្លាចនោះហើយ ទើបបានជានិយាយកុហកថា គេមិនឲ្យគាត់នៅលើផ្ទះ ។

ដូច្នោះការដែលរស់នៅក្នុងគេហដ្ឋាននេះ បានធ្វើឲ្យគ្រួសារ លោក ហោ មានឧបទ្ទវហេតុប្លែកៗ និងឃើញនូវអព្ភូតការណ៍ផ្សេងៗ ដែលបានកត់សម្គាល់ដូចតទៅ៖

ក/ ថ្ងៃមួយលោកយាយ ណោយស៊ុប គាត់ចូលទៅក្នុងគេហដ្ឋាននេះ ហើយគាត់និយាយថា បេស្រីនោះវាច្រានគាត់ផ្ដួល (ស្រីខ្មោច)ហើយបន្ទាប់ក្រោយពីដួលនោះមក គាត់ក៏ក្លាយទៅជាមនុស្សវិកលចរិត និយាយផ្ដេសផ្ដាសលែងដឹងខុសត្រូវ ។ ឃើញដូច្នោះលោក ហោ ក៏នាំគាត់យកទៅឲ្យលោកគ្រូរាចទឹកជាច្រើនកន្លែង រហូតដល់ទៅរដ្ឋ កាលីហ្វ័រនី (CA) ទើបបានជីវិតរស់គាត់

ជាស្បើយឡើងវិញ ។

៦/ ថ្ងៃក្រោយមកទៀត កូនស្រីទីបួនឈ្មោះ **ស៊ាង.ហេង.គិត** មានអាការមិនស្រួលក្នុងខ្លួន គេះតែរស់ក្ដៅខ្លាំងហួសពេក ធ្វើឲ្យរៀនសូត្រអ្វីមិនកើត ហើយលែងចង់រៀន, ទើបលោក ហេង នាំទៅឲ្យពេទ្យព្យាបាល ។ លោកវេជ្ជបណ្ឌិតបញ្ជាក់ប្រាប់ថា កូននេះគ្មានកើតរោគអ្វីទេ ! វាធ្លាក់កម្លាំង (MONO) ។ ហើយលោក ហេង ក៏ខំព្យាបាលកូនទៅតាមវិធីពេទ្យដែលបានបង្គាប់បញ្ជាមក, ប៉ុន្តែអាការៈរោគនៅតែដដែល ។ លុះដល់ផ្លាស់ផ្ទះចេញផុតពីគេហដ្ឋាននោះមក ជីវិតរបស់ ស៊ាង.ហេង.គិត ក៏ត្រឡប់តែជាឡើងវិញ ដែលជាហេតុឲ្យសំគាល់បានថាបណ្ដាលមកពីផ្ទះដែលនាំឲ្យកើតឧបទ្ទវហេតុទាំងនោះ ។

ព្រោះមានឧបទ្ទវហេតុផ្សេងទៀតដែលធ្វើឲ្យយើង ដូចជាការហោយធ្លាក់មកនៅជាប្រយផង ហើយត្រូវតែមានជំពុកស្រប្រកួត ដូចជាគោកហោយ ណោកសុំ ដូច្នោះ ។ មិនតែប៉ុណ្ណោះលោក ហេង ដែលជាមេគ្រួសារក៏មានអាការៈរោគកើតឡើងផ្សេងៗគួរឲ្យខ្លាច ដូចមានកើតដំបៅធំៗនៅលើខ្លួនជាដើម ។

ហើយអព្ភូតហេតុដែលបានបង្ហាញឲ្យឃើញថា ក្នុងគេហដ្ឋាននេះមានខ្មោចបិសាចមកយាយី ព្រោះឃើញមានអព្ភូតហេតុកើតផ្សេងៗដូចតទៅ

១/ថ្ងៃមួយនាង តេរេសើ បានឃើញក្នុងក្តីស្រមៃ គឺពេលដេកនៅមិនទាន់លក់ស៊ប់នៅឡើយ ដែលឃើញស្ត្រីបិសាចនោះមកឈរនៅមាត់ទ្វារ បង្ហាញរូបរាងលក្ខណៈនិងអាកប្បកិរិយាផ្សេងៗ ឲ្យដឹងថា ស្ត្រីបិសាចនេះមានបំណងនិងបៀតបៀនមកលើគ្រួសារនាងដែលរស់នៅក្នុងគេហដ្ឋាននេះ ។

២/ ថ្ងៃមួយនោះប្អូនថ្លៃឈ្មោះ ស៊ុខ.ចាន់.សេខ ទូរស័ព្ទមកប្រាប់លោក ហោ ថាមិនបានមកទេក្នុងថ្ងៃនេះ ព្រោះត្រូវធ្វើដំណើរទៅ ហ្វីឡាដិលហ្វៀ (Philadelphia) ។ ហើយនៅវេលាយប់នោះ ប្រហែលជាម៉ោងមួយភ្លឺ ស្រាប់តែឮសូរមនុស្សគោះទ្វារយ៉ាងខ្លាំង, ទើបលោក ហោ ស្ទុះរត់ទៅបើកទ្វារ ដោយចេញសំដីថា ចុះប្រាប់អញថាទៅ ហ្វីឡា ម៉េចក៏ឆាប់មកដល់ម្លេះ? តែលុះដល់រកមើលមនុស្សមិនឃើញ, ហើយរកមើលរថយន្តក៏មិនឃើញមានទៀត, ទើបលោក ហោ ដើរចូលមកកាន់កន្លែងដេកវិញ ។ ខណៈនោះមិនទាន់និងបានប្រាសខ្លួនដេកផង ស្រាប់តែឮសម្លេងគោះទ្វារយ៉ាងខ្លាំងម្តងទៀតជាលើកទីពីរ ហើយលោក ហោ ក៏ស្ទុះរត់ទៅបើកទ្វាររកមើលម្តងទៀត តែមិនឃើញមានអ្វីសោះ ជាហេតុធ្វើឲ្យមានក្តីសង្ស័យ និងនឹកពិភាល់ក្នុងចិត្ត ហើយចេញទៅដែកដើររកមើលតាមគុម្ពតែមិនឃើញមានអ្វី ។

គេហដ្ឋាននេះដែលលោក ហោវ និងភរិយាជួលនៅថ្មី ចម្ងាយ
ប្រហែល ២ ម៉ៃល៍ ពីផ្ទះចាស់ ។



៣/ នៅវេលាយប់មួយនោះកំពុងអង្គុយលើគ្រែ នាងសេងលី ក្រឡេកមើលទៅឃើញទ្វារទូដែលដាក់សម្លៀកបំពាក់ បើកបិទៗ រុញចុះរុញឡើងហើយឃើញសាឡុង (Sofa)ដែលនៅក្បែរនោះ វិលខ្ទាល់ដូចគេចាប់បង្វិល, ទើបនាង សេងលី ស្ទន់ស្លោ ស្រែក ភ្ញាក់សម្លេងឡើងថា ខ្មោចលងហើយៗ ! លោក ហេង សួរ បញ្ជាក់ថា ខ្មោចលងឯណា ម្តេចក៏អញមិនឃើញ? ។ ដោយ ឃើញប្ដីស្លោះ នាងសេងលី ឈប់ហ៊ានដេកលើគ្រែក្នុងបន្ទប់នោះ ហើយនាំប្ដីទៅដេកនៅបន្ទប់ជាមួយនិងកូនៗនោះទៅវិញ ។

៤/ ថ្ងៃមួយប្អូនប្រុសនាំប្រពន្ធមកដេកនៅក្នុងផ្ទះនោះ ហើយ ប្រពន្ធចុះទៅមួតទឹកនៅជាន់ទី ១ បាត់ទៅ ស្រាប់តែខ្មោចបិសាច នោះមកចាប់ហែកមាត់ប្ដីដែលកំពុងដេក ធ្វើឲ្យស្រែកមិនរួច ទំរើ បម្រះបែកញើសញួរញើសទំរាំតែប្រពន្ធឡើងមកដល់ ទើបបានវា លែង ដែលជាការជាក់ស្ដែង ។

៥/ ថ្ងៃមួយបងប្អូនមកពី វ៉ាស៊ីនតុន (Washington) ហើយ ចុះដើរទៅលេងឯទីនៅក្រៅផ្ទះមើលទេសភាពជុំវិញ ស្រាប់តែ ឃើញដើមពោធិ៍ក្បែរផ្ទះយោលចុះយោលឡើង ហាក់ដូចជាខ្យល់ បក់បោកយ៉ាងខ្លាំង តែពោធិ៍ផ្សេងទៀតដែលនៅជិតនោះដែរ គ្មានឃើញកំរើករំពើកអ្វីសោះ ជាហេតុធ្វើឲ្យពិភាល់ក្នុងចិត្ត ហើយ ក៏ត្រូវតែរត់ទៅរកនៅក្នុងផ្ទះឲ្យរកគ្នាយើង ។

ដោយឃើញអព្ភូតការណ៍ ដែលកើតមានឡើងជាហូរហែរបន្តបន្ទាប់ដូច្នោះ លោក ហោ និងភរិយាបានសម្រេចចិត្តចាកចេញពីគេហដ្ឋាននោះ ទៅជួលផ្ទះមួយនៅផ្សេងទៀតចម្ងាយប្រហែលពីរម៉ៃល៍ (Mile) ពីគ្នា ។

ក្នុងការដែលឡើងនៅលើគេហដ្ឋានថ្មីនេះ លោក ហោ បានរៀបចំការពារទុកជាមុនរួចស្រេច ដោយបាននិមន្តលោកគ្រូសង្ឃាធិបតី **សៅ.ឃន** វត្តព្រៃរតនារាម តំបន់ឆិបហ្វូត ទៅធ្វើពិធីផ្សេងៗ ស្រោចទឹកព្រះព្រំពិងព័ទ្ធសីមាជាដើម ។

ក្នុងកម្លុងមិនយូរប៉ុន្មាន នៅវេលាយប់មួយនាង សេងលី នៅមិនទាន់ដេកលក់ស៊ប់នៅឡើយ ស្រាប់តែស្រវៃឃើញស្រីបិសាចដែលធ្លាប់ឃើញកាលនៅផ្ទះចាស់នោះ មកឈររវើតតាមបង្អួចបង្ហាញខ្លួនឲ្យឃើញម្ដងទៀត ទើបនាង សេងលី ស្រែកឡើងថា: ម៉ែងចូលមកបើល៍......! ចូលមក ? តែខ្មោចបិសាចនោះមិនហ៊ានចូល ឬក៏ចូលមិនរួច ។

ហេតុដែលលើកយករឿងនេះមកពណ៌នាក្នុងទីនេះ ព្រោះចង់បញ្ជាក់ឲ្យឃើញថា គ្រួសារលោក គិត.តាំង.ហោ ដែលបានគេចផុតពីគ្រោះថ្នាក់ដែលខ្មោចបិសាចយាយី ក៏ដោយសារពុទ្ធមន្តដែលព្រះសង្ឃសូត្រផ្សាយរំលើកពីកដល់ ។

ដូចនោះហើយបានជាក្នុងប្រទេសកាណាដា ខ្មែរយើងគេតែងពឹងពៀ

ទៀនទៅលើទឹកអប្ប ដែលតែងតែឃើញព្រះសង្ឃសូត្របរិត្ត ហើយ អាចារ្យដាក់ទឹកប្លួយផ្តិលធំ ហានបិទទៀនដុតភ្ជាប់និងមាត់ផ្តិល.លុះ លោកសូត្រជិតនិងបញ្ចប់ លោកដែលគង់នៅមុខគេបង្អុស់តែងតែ សប្រក់ទៀនដាក់ទឹកផ្តិល រួចយកស្លឹករុក្ខជាតិ (ច្រើនយកស្លឹកពោធិ៍) ជ្រលក់ប្រោះព្រំបាចសាចឲ្យដល់ពុទ្ធបរិស័ទទូទៅ ។

## ព្យាបាលផ្លូវចិត្តដោយពិធីស្តោះព្រួស

ការស្តោះព្រួសនេះ ហាក់ដូចជាកាតព្វកិច្ចរបស់គ្រូពេទ្យខ្មែរ បុរាណ ព្រោះគេសង្កេតឃើញថាការព្យាបាលជម្ងឺភាគច្រើនដែល ឃើញគ្រូពេទ្យខ្មែរ ស្តោះព្រួសទៅលើរាងកាយអ្នកជម្ងឺ ពិសេស គឺក្នុងពេលដែលអ្នកជម្ងឺក្តៅខ្លួន រហូតដល់មានបន្ទុតាថាខ្លះឈ្មោះ ហៅថា ក្រុងសិរីវឌ្ឍិ ដែលគេសំដៅទៅលើភាពត្រជាក់ ។ ហើយ មានខ្លះគេចេះប្រើបន្ទុក្រុងសិរីវឌ្ឍិនេះ ធ្វើឲ្យត្រជាក់ទាល់តែជាន់ទៅ លើភ្លើងបានទៀតផង, ដូចជាគេដុតដែកឲ្យឆេះឡើងក្រហម រួច គេយកជើងជាន់ទៅលើដែកកំពុងឆេះនោះ មិនក្តៅសោះ ។ល។

*ឧទាហរណ៍ទី៨_* វិធីព្យាបាលផ្លូវចិត្ត. ដោយមានម្លូទំពារស្តោះ ព្រួស ដូចជាគាថាស្តោះពិសប្លួយប្រភេទហៅថាក្រុងសិរីវឌ្ឍិគឺ:

ឱមសិរិទ្ធិស៊ំភ សិរិទ្ធិសាឃ ព្រះពាយរបស់ព្រែក ចេញមក ពីព្រះឧទរ ហូរចេញពីព្រះឱស្ឋ ព្រោះព្រំដោយទឹកអម្រិត ស្លិតទៅ ព្ទ័អាកាស បាចសាចស្រោចស្រពរំលត់ភ្លើងរះកល្ប ព្រព្យា មហាប្រថពី ដោយបន្តឫទ្ធិព្រះក្រុងសិរិទ្ធិ បិតនៅក្នុងព្រាលព្រជាក់ ដូចបេព្រិល ររិលធូរបេពិស ជ្រុះចេញអំពីខ្លួន ធ្លាក់ទាំងក្របួនរំ ពីរអង្គ ធ្លាក់ទាំងវង្សសង្ការ ព្រជាក់ល្ហិតល្ហៃ សព្វសាច់សរសៃទាំង ផ្ទើមប្រមាត់ បេព្រាយខ្លាយខ្លាត់ បេពិសបេររុត បេររាប អង្គអញ បង្ក្រាបកុំបីពីងពោះទៅពីងព្រះអាទិត្យ កុំបីពីងពោះទៅពីងព្រះ ចន្ទ្រ ព្រះត្រូវអង្គអញល្បោះក្រុងសិរិទ្ធិ មានឫទ្ធិជ័យ មានឫទ្ធិជោគ ទើបអញស្ងូត្រហៅ ឯហិ ឯហិ អាគច្ឆាហិ អាគច្ឆាហិ ភ គ ម ព្ទ ឆ យ ឡ ភ សោ ឱ ឯហិ ឯហិ អាគច្ឆាហិ ៗ

ភាវនា ៧ ចប់, ស្តោះ ៣ ដង, ហើយផ្លុំ ៣ ដង ។ និងធ្វើ ជាទឹកមន្តព្រោះព្រំ ។

នេះជាការព្យាបាលខាងផ្លូវចិត្ត ដែលត្រូវប្រើមន្តក្នុងការស្តោះ ព្រួសនិងផ្លុំស្រោចទឹក ។

*ឧទាហរណ៍ទី៩_* គាថាស្រោចទឹកឬព្រោះព្រំនិងស្តោះព្រួសរបស់យ៉ាង ហៅថាក្រុងរេះ បានជាពាក្យឧទានដូចតទៅ:

ឱម ព្រះនារាយណ៍ ព្រះពាយផាត់ អញ្ជើញមកកំចាត់រោគពាធា ព្រះពិស្ណុស្រោចស្រពព្រះគង្គា គណនាបីដូចទឹកអម្រឹត ប្រសិទ្ធិជោគដោយព្រះព្រហ្ម ទោះជាយក្ស.យម.អារក្សរុក្ខពា.ខ្មោចព្រាយ បិសាច បន្ទាថា ធ្មប់.អាប.អំពើអំពាន់ផងនានា ខ្លបខ្លាចអំណាចព្រះកេតុ, ទើបត្រូវប្រើអញព្រោះព្រំពាចសាច (បើស្ដោះឲ្យថា "ស្ដោះព្រួស") ទឹកបន្តនៃព្រះគាថា ទៅលើរូបកាយប្រុសស្រី តូចធំ កំឡោះក្រប៉ុក្ដីណោ បីដូចព្រះអគ្គីក្ដៅក្រហល់ក្របាយ រោលរាលរលត់រលាយពីងពោង, ទើបត្រូវប្រើអញអញ្ជើញក្រុងរេះ មហាក្រុងរេះ រេះទឹករេះដី រេះព្រៃព្រឹក្សា រេះភ្នំបព្វតា រេះទាំងអាកាសវេហាស៍ រេះទាំងព្រាយក្រឡាព្រាយហោះព្រាយហើរ ព្រាយដើរនៅដី ព្រាយស្លាប់កូនក្នុងផ្ទៃ រេះទាំងព្រាយក្សាលក្រាំបី ព្រាយកន្ទោងខៀវ ព្រាយត្រូវប្ដាយដើប ព្រាយផើបពោះធំ ទ្រុំធំកំរោល ពីងរត់ពីងពោលចាកចោលចេញទៅ កុំបីពីងនៅក្នុងរូបអង្គប្រាណ ឱម ព្រះពាយផាត់ មហាផាត់ផាយ ផាត់ទាំងស្ពុះហ៍អបាយ កំឡោះក្រប៉ុព្រហ្មចារីសាវកែអត់ប្ដី ផាត់ផាយ ផាយផាត់ កំចាយកំចាត់រលាយរលត់ ករវៃណេចេញទៅ កុំឲ្យពីងនៅពុកពីងកំណើត ប្ដាយពីងបង្កើត ពីងខ្លាចបារមីនៃព្រះពិស្ណុទឹកបន្តព្រោះព្រំដោយព្រះនារាយណ៍ រលាយពីងពោង ឱមសិទ្ធិស្វាហា ស្វាហាយ អឱម ៗ

*ឧទាហរណ៍ទី១០_* វិធីព្យាបាលផ្លូវចិត្ត ប្រើប្លូស្លាទំពារស្ដោះព្រួស នេះជាគាថាស្ដោះពិសមួយប្រភេទដែរ ។

ឱមសិរីទ្ធិសំអ ឱមសិរីទ្ធិសាឃេ ព្រះពាយបក់ព្យាកបកពី ទិសឧត្តរ ហូរចេញពីព្រះឱស្ឋ អញស្ដោះចេញទៅ ត្រូវអង្គអ្នក មានជម្ងឺឈឺក្ដៅក្រហាយ ស្លាប់ទាំងមេព្រាយមេពិសកន្ទាលមេព្រែរាក ស្លាប់ទាំងមេពិសផន្ទុធន្ទ ស្លាប់ទាំងមេពិសផន្ទុធន្ទពុំទ្ធ មេពិសកើត ក្នុងមាត់ហៅថាមេពិសដំបូក ទើបគ្រូប្រើអញឲ្យស្ដោះ ត្រូវដំបូកៗ រលំ ត្រូវភ្នំៗរលាយ មេពិសខ្លាត់ខ្លាយ ឱនាសន្តិ **ដ៏អរអរ ដ៏អប ដ៏អប្ប ដ៏អនិ ដ៏អនី អុំអ៊ិអ៊ិរអៈ ៦**

ភាវនាស្មូត្យសែកប្លូស្លា ៣ ដង រួចហើយទំពាស៊ីជួចធប្លូពា ពែបុនទិងស្ដោះ ភាវនាបញ្ចើរ ស្ដោះព្រួស រួចផ្ញុំ ៣ ដង ។

*ឧទាហរណ៍ទី១១_* វិធីព្យាបាលផ្លូវចិត្ត ជាគាថាស្ដោះពិសមួយប្រភេទ ហៅថាក្រុងសិរិទ្ធិដែរគឺៈ

ឱមក្រុងសិរិទ្ធិ រាជាវនោ ទើបគ្រូប្រើអញប្រាប់ទាំងពិសទឹក ទើបគ្រូប្រើអញប្រាប់ទាំងពិសភ្លើង ទើបគ្រូប្រើអញប្រាប់ដំបូករលំ ទើបគ្រូប្រើអញប្រាប់ទាំងភ្នំរលាយ ទើបគ្រូប្រើអញប្រាប់ទាំងពិសភ្លើងទាំងទ្វារ ឱនសន្តិ ។

គាថានេះមានអ្នកខ្លះហៅថាលោកបួតរាងផា ដុតដែកឲ្យឆេះឡើងក្រហម ហើយផាត់បាន ។

*ឧទាហរណ៍ទី១២*– វិធីព្យាបាលផ្លូវចិត្ត ,ដែលប្រើមន្តគាថាស្តោះព្រួស និងផ្លុំ ក្នុងការផ្សារ.ពភ្ជាប់ឆ្អឹងដែលបាក់ ដូចជាបាក់ដៃជើងជាដើម ដោយប្រើមន្តគាថាសូត្យសែកទៅលើសម្ភារៈ និងប្រើប្លូស្លាចំពាស្តោះព្រួស ដែលហៅថាចព ។

វិធីចពគ្រូបុរាណខ្មែរយើងមានការចេះដឹងច្រើន ដែលមានវិធីប្លែកៗពីគ្នា និងមានមន្តគាថាផ្សេងៗគ្នាទៀតផង ហើយមានគ្រូខ្លះច្រើនប្រើទាំងខាងផ្លូវសម្ភារៈនិងខាងផ្លូវចិត្ត ។

វិធីព្យាបាលមួយយ៉ាងជាឧទាហរណ៍, កាលបើគេដឹងថាដៃបាក់ឆ្អឹងហើយ គេរេងដាវបែងដូចដាវបែងព្រួល យកទៅរុំនៅត្រង់កន្លែងដែលបាក់នោះ ដោយទាញឆ្អឹងឲ្យត្រង់ប្រសព្វមុខគ្នា ហើយរឹតឲ្យតឹងដើម្បីកុំឲ្យឆ្អឹងគ្រាកប្រែប្រួលប្រជ្រួសឃ្លាតខុសមុខពីគេ, រួចហើយទើបគេភាវនាមន្តគាថាស្តោះព្រួស ពីលើព្រួលដែលរឹតនោះ (ព្រួលដែលរេងត្រូវឲ្យរយោល "រង្វើល") ។

គេសំគាល់ឃើញគាថាចពនេះ មានខ្លះជាវេទមន្តលាយផ្សំនិងសម្រាយ មានខ្លះជាពុទ្ធមន្តលាយផ្សំនឹងសម្រាយ ហើយមានខ្លះជាពុទ្ធមន្តសុទ្ធសាធ ដូចគាថាខាងក្រោមនេះដែលល្បីល្បាញថាពូកែ

ពក្តិពិក្តពីពក្តប្តក្តពក្តពាល ។

សព្វពុទ្ធានុភាវេន សព្វធម្មានុភាវេន សព្វសង្ឃានុភាវេន ពុទ្ធរតនំ ធម្មរតនំ សង្ឃរតនំ តិណ្ណំ រតនានំ អានុភាវេន ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តំ សព្វេ តេ រោគា សព្វេ តេ អន្តរាយា វិនស្សន្តុ។

សូធ្យ ៣ ចប់ ស្ដោះព្រួស ៣ ដង ផ្លុំ ៣ ដង ។

សូធ្យ ៩ ចប់ ស្ដោះព្រួស ៣ ដង ផ្លុំ ៣ ដង ។

សូធ្យ ៧ ចប់ ស្ដោះព្រួស ៣ ដង ផ្លុំ ៣ ដង ។

## VIII. ប្រើមន្តផ្សំនិងឱសថ

ការព្យាបាលដោយប្រើមន្តគាថាផ្សំនិងឱសថនេះ គេសង្កេតឃើញគ្រូពេទ្យបុរាណខ្មែរប្រើច្រើនលើសលប់ជាងគេ ក្នុងការព្យាបាលជម្ងឺទូទៅ ព្រោះគេយល់ឃើញថា ពិធីព្យាបាលខាងផ្លូវចិត្តបើប្រើផ្សំជាមួយនិងឱសថផង ប្រាកដជាបានប្រសិទ្ធិភាពជាងប្រើឱស

ផងទេ ហើយដែលគ្មានកត់សម្គាល់ឃើញថា មានការព្យាបាលខ្លះ ដែលឃើញប្រើទាំងបន្ទាគាថាសូធ្យសែក ទាំងរក្ខវិធី ហើយនិងឱសថទៅជាមួយព្រមគ្នាតែម្តង ។

*ឧទាហរណ៍ទី១_* ព្យាបាលផ្លូវចិត្ត, ផ្សំជាមួយនិងឱសថក្នុងការស្តោះព្រួស ដូចជាការព្យាបាលអ្នកដែលត្រូវពស់ចឹកគឺៈ

ឱសថ = ១ ឫសជន្លុស, ២ ស្លាចំពិត ។

វិធីផ្សំ= គេទៅនិបន្តធ្វើឧបកិច្ចជីកយកឫសជន្លុស ដែលចាក់ទៅរកទិសព្យសាន (អ្នកខ្លះហៅដើមពូនកាយ) មកហាន់ជា ៧ ចំណិត ហើយលាយជាមួយនឹងស្លា ៧ ចំណិតដែរ ។

ប្រតិបត្តិ= ទំពាឱសថហើយនិងស្លាស្តោះអ្នកជម្ងឺ ពីក្បាលទៅដល់ចុងជម្ងើម ហើយឈប់ត្រឹមពោះ, រួចទើបស្តោះពីត្រឹមខាងក្រោមផ្ចិតពោះ រហូតទៅដល់ចុងជើង ។ ដោយភាវនាសូធ្យសែកនូវបន្ទាគាថាដូចនេះ៖

**ឱម ស្រូបអោយស្រូប អើបត្រូបប្រើអញស្រូបមាំង ៣ យប អើបត្រូបប្រើអញស្រូបមាំង ៣ជាន់ អើបត្រូបប្រើអញមេម៉ាន់ ជាន់ក្បាលកម្ពុយ ឱម ឆិភី ឆិភំ ឆិទេភ្លូវ ភីភរស្វាហា ។**

ពិធីព្យាបាលនេះមានភស្តុតាងនៅកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប ដែលគេមិនទុកសង្ឃឹមថាអ្នកជម្ងឺនិងបានរស់ឡើង

វិញទាល់តែសោះ ។ ហើយត្រូវអ្នកព្យាបាលក្នុងពេលនោះឈ្មោះ **ឋាន់ឋិ** ទីលំនៅឿចុងកាល់ (ឧត្តរមានជ័យ) ដែលខ្ញុំទុកជាសក្ខីភាពក្នុងសំនេរនេះ ។

*ឧទាហរណ៍ទី២_* រោគបបួយប្រភេទ ក្នុងការព្យាបាលក្អែបខ្វាំ ដែលប្រើផ្សំជាមួយនិងឱសថ ហើយគេសន្មាល់ថាមានប្រសិទ្ធិភាពឬយដែរគឺ:

ឱសថ= ១/ គេយកភ្លូបាត ៧ព្រួយ (វុក្ខជាតិមួយប្រភេទស្លឹកមមិសៗ ផ្លែរាងមូលជាព្រមកស្រទាប់ៗ មានពីរយ៉ាងភ្លូធំ ភ្លូបាត) ២/ គ្រាប់ល្ហុងខ្មែរ ៧ គ្រាប់ (ល្ហុងមួយប្រភេទ ធាងវែង ស្លឹកធំឆែកៗ ផ្លែជាចង្កោម មានរោមនៅសំបកគ្រាប់ធ្វើប្រេងបាន) ៣/ សំបកពង្រប៉ុនប្រហាបដៃ (ឈើមួយប្រភេទសាច់រឹង គេប្រើនយកធ្វើជាភ្លៅរទេះ ផ្លែជាចង្កោម មានរសជាតិជូរ) ។

ប្រតិបត្តិ= វត្ថុទាំង ៣ មុខនេះរួបបញ្ចូលគ្នា ហើយទំពាស្ដោះដោយវាយបន្ទុគាថាថាដូច្នេះ៖

**មឈិឝ ឈិភទេ** ស្ដូច្បេ ៣ ចប់ ផ្ទុំ ៣ ដង, ស្ដូត្រ ៩ ចប់ ផ្ទុំ ៣ ដង, ស្ដូច្បេ ៧ ចប់ ផ្ទុំ ៣ ដង, ពីលើចុះមកក្រោម ។

*ឧទាហរណ៍ទី៣_* ព្យាបាលដោយមន្តគាថា ផ្សំនិងដំណែ ។

ព្យាបាលរោគមួយប្រភេទ ហៅថារោគត្រអក ។

អាការរោគនេះ ឃើញឡើងជាកណ្តាប់ មានទឹករងៃ ច្រើន កើតនៅកជើង ហើយឡើងក្រមរក្រាស់ម្លឹក ពិបាកនឹងព្យាបាល ដាក់ថ្នាំឲ្យជល់បាន ។

វត្ថុធាតុដើម= ១/សព្វគង្គក់ពីរឬបីវារងឲ្យស្ងៀប ២/គ្រាប់ អង្គញ់ ៣/គ្រាប់ស្វែងធំ ៤/ខ្ទេរ (វល្លិមួយប្រភេទមានបរិស រហាស់ណាស់) ៥/ ប្រេងដូង ។

វិធីផ្សំ= គេកម្លោចវត្ថុទាំង ៤ មុខខាងដើម ហើយដាក់លាយ ចូលជាមួយគ្នានិងប្រេងដូង រួចយកទៅដំារម្ងាស់ឲ្យរលាយចូលជា ពិគ្គាព្យ ទុកជាបានការ ។

វិធីប្រើ= មុននិងលាបគេភាវនាមន្តសូត្រសែកចំនួន ៧ ចប់ថា **កធិច កធិវ, កធិច កធិវ, កធិច កធិវ, កធិច កធិវ, កធិច កធិវ, កធិច កធិវ, កធិច កធិវ,** ។

ព្រណោម= ហាមមិនឲ្យប៉ះពាល់ត្រូវទឹកចំនួន ៣ ថ្ងៃ ។

កំណត់សម្គាល់= អ្នកដែលធ្លាប់មានពិសោធន៍នូវផ្សំនេះ គេ ថាថ្នានេះមានប្រសិទ្ធិភាពមែន ។

## ការព្យាបាលចំរបផ្លូវចិត្តនិងសម្ពោះ

*ឧទាហរណ៍ទី៤_* មានជម្ងឺខ្លះគេសង្កេតឃើញការព្យាបាលមាន

ចំពោះផ្លូវចិត្ត និងសម្ភារៈទៅស្របជាមួយគ្នាតែម្តង ដូចជាការព្យាបាលជម្ងឺក្អួតខាំជាពីរយ៉ាងគឺៈ

១/ ពិធី=គេគូររូបក្ដាមដាក់ក្នុងយ័ន្តក្បាលបួន ហើយដាក់ចូលទៅក្នុងបាតផើង (គួរលើក្រដាសក្រាស់កុំឲ្យរអាប់រលោយ ឬសំពត់ ទំហំប៉ុនបាតផើង) រួចហើយចាក់ទឹកឲ្យពេញដើម្បីធ្វើទឹកមន្ត។



គេធ្វើទឹកមន្តនិងទឹកផើងនេះ ដោយសូធ្យសែកគាថាដូច្នេះ

ឆតិ មោរតិ ឥ រវិ ររ ( ១០៨ ចប់) ហើយស្រោចព្រោះព្រំទៅលើអ្នកជម្ងឺ ។

២/ សម្ភារៈ= គេយកឫសកន្ទួតស្រុក បកផុសលាយជាមួយនិងទឹកអង្ករឲ្យអ្នកជម្ងឺផឹក ។

កំណត់សំគាល់= គេបានកត់សំគាល់ឃើញថា ក្អួតមួយនោះចូលទៅខាំគោក្នុងក្រោល ហើយនិងសេះមួយ ។ ហើយគោទាំង

អស់នោះភ្លាស់បានព្យាបាលដោយមន្តនេះ ប៉ុន្តែសេះគេមិនបានបានព្យាបាលទេ ហើយឃើញសេះនោះរួច, ជាហេតុឲ្យគេកត់សំគាល់បានថា មន្តនេះពូកែស័ក្តិសិទ្ធមែន ។

## IX. មន្ត . ឱសថ . ឧបកិច្ច . អក្ខរ

ជួនកាលមានពិធីខ្លះឬជម្ងឺខ្លះ បុរាណខ្មែរយើងប្រើមន្តអាគមគាថាជារបៀបព្យាបាលជម្ងឺផង និងជារបៀបការពារជម្ងឺផងស្របទៅជាមួយគ្នា ដែលមានទាំងប្រើឱសថនឹងការឧបកិច្ចផ្សំជាមួយ, ថែមទាំងមានចារុំបញ្ចុះជាតួអក្ខរៈចងភ្ជាប់និងសរពាង្គកាយអ្នកជម្ងឺទៀតផង ឧទាហរណ៍ដូចជាការព្យាបាលជម្ងឺស្គន់ ។

ស្គន្ធ ឬ ស្គន់ ជាឈ្មោះបិសាចមួយពួកជាអ្នកបណ្ដាលឲ្យកើតជម្ងឺ , ខ្មែរយើងមានជំនឿនិងហៅឈ្មោះជម្ងឺ ដែលកើតឡើងដល់ក្មេងតូចៗ បណ្ដាលឲ្យមានអាការៈឈឺប្លែកៗ មានតឹងដើមទ្រូងផ្អើះៗ ភ្នែកបញ្ឈរ ក្ដាប់ដៃក្ដាប់ជើងជាដើម ថាជាជម្ងឺស្គន់ដែរ ដែលហៅថាស្គន់ជាន់ ។

ជម្ងឺស្គន់នេះបុរាណខ្មែរយើងបានឲ្យឈ្មោះខុសៗគ្នា ទៅតាមឆ្នាំទាំង១២ និងទង្វើក្នុងកិច្ចព្យាបាល ដែលមានពិធីប្លែកៗខុសគ្នាទៀតផង ។ ការព្យាបាលជម្ងឺនេះ គេឃើញមានវិធីផ្សេងដែរ

មានប្រសិទ្ធិភាពគ្រាន់បើ ដោយការព្យាករណ៍ទៅតាមថ្ងៃ ខែ ឆ្នាំ កំណើត និងការស្តោះព្រួស ស្ងួនរូបតំណាង ហើយចារ្យ៍យន្តធ្វើជាកថាចងឲ្យក្មេងដែលកើតស្កន់នោះ និងស្រោចទឹកបន្តព្រោះព្រំ ដូចមានគាថាសូត្យសែកភាវនាស្តោះព្រួសឬស្រោចទឹកថាៈ

ឱម្នះប្រសិទ្ធី ទើបគ្រូប្រើអញស្តោះ ទើបគ្រូប្រើអញព្រួស ទើបគ្រូប្រើអញស្តោះស្កន់នេះ ទើបគ្រូប្រើអញដេញស្កន់ខ្មោចព្រាយ ទើបអញដេញស្កន់ខ្មោចគេធ្វើ ទើបអញស្តោះស្កន់ខ្មោចសន្ធំ ទើបអញកាន់មន្តនេះ ទើបអញឈូសដីៗរលំ ទើបរអញឈូសភ្នំៗរលើង ទើបអញផាន់ភ្លើងៗរលត់ ទើបរអញផាន់ដង្គត់ៗរលាយ ទើបរអញផាន់ដំបូកៗរាប ទើបរអញចុះប្រាបរំងាប់ពីង ត្រូវស្លាប់បង្គាប់

អញជាគ្រូបាធ្យាយ ចរណៃចេញទៅ **ស្វាហះ**

**ឱម នមោ ពុទ្ធាយះ ។**

គាថានេះប្រើស្ដោះព្រួសឬធ្វើទឹកបន្ត (ច្រើនស្ទូត្រ ៧ ចប់)។

គាថាមួយផ្សេងទៀតប្រើដូចគ្នា (សូធ្យ ៧ ចប់ដែរ) ។

**ឱម្ហះ** ស្កន់ទប់ ស្កន់ទល់ ស្កន់ហល់ ស្កន់ហើម ស្កន់ម្ដាយដើម ស្កន់ស្វា ស្កន់ខ្លា ទើបគ្រូប្រើអញឲ្យស្ដោះពេលព្រឹក ត្រជាក់ដូចត្រឡាច ស្ដោះពេលល្ងាចត្រជាក់ដូចននោងសាញៀ **ឱម្ហ សិទ្ធិស្វាហះ ។**

*ឧទាហរណ៍ទី១_* ពិធីព្យាបាលជម្ងឺស្កន់ ក្មេងកើតឆ្នាំ ជូត ។

កូនក្មេងប្រុស.ស្រីណាកើត ឆ្នាំជូត ខែពិសាខ ជេស្ឋ អាសាឍ ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក មិគសិរ បុស្ស មាឃ ផល្គុន ហើយនឹងថ្ងៃ ច័ន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ បើត្រូវ

ស្តន់ផាន់ ឈ្មោះថាស្តន់ប៉ៀប ។

**របៀបស្តោះស្តន់ទៀត** (ប្រើទាំងផ្លូវសម្ភារៈទាំងផ្លូវចិត្ត) ខាងផ្លូវចិត្ត, បន្តគាថាដូចមានគាថា ២ បទនៅខាងដើម ។ ខាងសម្ភារៈមានៈ

១- ព្រួយផ្អិត (ឈ្មោះឈើតូចមាន ២ ប្រភេទគឺផ្អិតខ្មោច ដើមតូចស្លឹកតូចខុសគ្នា) ។

២- ម្រេចគ្រាប់ ។

៣- គល់ស្លឹកគ្រៃ ។

វត្ថុទាំង ៣ យ៉ាងនេះគេយកបកទំពាលាយជាមួយនឹងទឹកធម្មតា ហើយព្រួសទៅលើក្មេងស្តន់នោះដោយខ្លាំងៗត្រង់ស្មា ចាប់ផ្តើមព្រួសពីស្មាស្តាំដេញទៅរកស្មាឆ្វេងដោយភាវនាគាថាដូចមានចែងនៅខាងលើ ។ បើប្រសិនជាស្តោះទៅហើយមិនបានធូរស្បើយទេនោះ គេប្រែឱសថថ្មីផ្សេងទៀតគឺ

១- ស្លឹកកញ្ជើបាយដាច (ឈើដើមមានបន្លាខ្ទិៗស្លឹកស្រដៀងនឹងស្លឹកសុរភី ផ្លែមានរសជាតិហាងៗបន្តិច ប៉ុន្តែគេអាចបរិភោគបានផ្លែទុំៗ) ។

២- ស្លឹកជីរអង្កាម ។

៣- ឬស្សីជើងក្រានមេម៉ាយ ។

វត្ថុទាំង ៣ យ៉ាងនេះ យកមកទំពាលាយជាមួយនឹងទឹកដោះគោ

ហើយស្តោះព្រួសដោយខ្លាំងៗ ចាប់ផ្តើមពីស្មាស្តាំទៅឆ្វេង ។
ហើយចារុំជាយ័ន្តធ្វើកថាចង.កកូនក្មេងនោះដូច្នេះ ។



បើជប្រើស្តូន់នេះចាប់ផ្តើមជាន់ពីថ្ងៃ អាទិត្យ ខែចេត្រ ឈ្មោះ ថាស្តូន់សុទន្តា ព្រោះជាការលំបាកក្នុងការព្យាបាល ។

បើជាហើយៗចង់ផ្តាច់ បុននឹងផ្តាច់ឲ្យយកដីពុងស្តាន ស្ងួនធ្វើរូបសត្វប៉ៀវ ព្រង់ក្បាលដាក់ពណ៌ក្រហម និងកន្ទុយដាក់ពណ៌លឿង ខ្ទួនស រួចយកបកបោសបញ្ចៀសបញ្ចេរចោលទៅ (ឧបកិច្ច) ។ ហើយចារុំជាយ័ន្តចង.កក្មេងនោះដូចនេះ ។

| | | |
|---|---|---|
| ឱ | ឆ | ត៌ |
| អ | ឱ | ឡោ |
| ន | អ | ឡ |
| មោ | ឃ | ឈ |
| ន | គ | ឥ |
| សំ | អ | ត៌ |

*ឧទាហរណ៍ទី២*- ពិធីព្យាបាលជម្ងឺស្គន់ ក្មេងកើតឆ្នាំ ឆ្លូវ ។

កូនក្មេងប្រុសស្រីណាកើតឆ្នាំឆ្លូវ ខែជេស្ឋ អាសាឍ, ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក មិគសិរ បុស្ស មាឃ ផល្គុន ចេត្រ និង ថ្ងៃអង្គារ ពុធ ព្រហស្បតិ៍ សៅរ៍ អាទិត្យ ច័ន្ទ បើត្រូវស្គន់ជាធ់ ពេញ្ញាះថាស្គន់ផ្លែ ។

របៀបស្តោះស្គន់ផ្លែនេះ ឲ្យយកវត្ថុ ៤ យ៉ាងគឺៈ

១- ស្លឹកព្រះក្រាប (ស្មៅមួយប្រភេទស្លឹកធំៗដុះរាបនិងដី) ។

២- ស្លឹកព្រះខ្លប (មានបន្លាបើពាល់ត្រូវចេះក្តោបស្លឹក) ។

៣ ស្រូវ ( ស្រូវអោន ២ កួរង ,ស្រូវតាដុះទៅតាមស្រែ បើបកើតស្លឹកហាងរួញ ) ។

៤- សំបកក្រូចសើច ។

៥- សង្រែកដាច់ ( ខ្មែរគេច្រើនយកវល្លិ៍ឬផ្ដៅធ្វើវែករបស់ផ្សេងៗហើយត្រូវធ្ងន់ដាច់ ) ។

វត្ថុទាំង ៥ យ៉ាងនេះ យកបកស្ដោះលាយជាមួយនឹងស្រាសធម្មតា ហើយស្ដោះចាប់ផ្ដើមពីខាងលើដេញចុះមកក្រោម នឹងពីខាងឆ្វេងដេញទៅរកស្ដាំ ។ រួចសរសេរជាយ័ន្តធ្វើជាកថាចងកក្មេងស្កន់នោះដូចគំរូនេះ ។



ប៉ុន្តែបើកើតឆ្នាំ ឆ្លូវ ខែពិសាខ ថ្ងៃច័ន្ទ ឲ្យផ្លាស់មុខថ្នាំខ្លះក្នុងការស្ដោះ ប្លែកខុសគ្នាគឺ:

១- ព្រះក្រាប ។

២- ព្រះខ្លប ។

៣- អង្រែង (គេកោសយកជាកំទេច) ។

៤- ប្រះ (គេច្រើនយកព្រួយ ) ។

៩  បើរស្មៅចិនចែស ។

វត្ថុទាំង ៩ យ៉ាងនេះ គេយកមកចំពោះស្ពានស្នាបួយនិងទ្វារ.ក ស្ពានពីលើចេញចុះមកក្រោម ។ តែបើជាហើយៗពាក់កណ្ដាលស្ពាន ហៅថាផ្ដាច់ មុននឹងផ្ដាច់ត្រូវសែន ឲ្យយកដីក្រោមជើងវិលពៅ ស្ងួនធ្វើរូបខ្មែសប្តូរអៀង កន្ទុយខ្មៅ ជើងក្រហម ហើយឲ្យយក ស្មៅចិញ្ចៀនបោសបញ្ចូរចោលទៅ។ រួចហើយធ្វើជាយ័ន្តចង.ក ដូចមានគំរូនេះ ។



ការស្ងួនធ្វើជារូបហើយបោសនេះ គឺជាពិធីរបស់ខេសដែលខ្មែរ យើងពីបុរាណមានជំនឿ ហើយនិយមធ្វើក្នុងការបញ្ចៀសឬបញ្ចេរ ឲ្យគេចវេះចេញឆ្ងាយ ឬឲ្យប្រាសចាកចេញទៅ ។ ជាការបង្អែងឬ ពង្វាងមិនឲ្យត្រូវព្រង់ ។ល។

កំណត់សម្គាល់= បើជប្រីស្ពានឆេះចាប់ផ្ដើមជាន់ពី ថ្ងៃសុក្រ ខែ ពិសាខ ពេញ្ញាះថាស្ពានឆ្លុន ព្រោះពិបាកព្យាបាល ។

*ឧទាហរណ៍ទី៣–* ពិធីព្យាបាលជម្ងឺស្គន់ ក្មេងកើតឆ្នាំខាល ។

កូនក្មេងប្រុសស្រីណាកើតឆ្នាំខាល ខែទាំង១២ ថ្ងៃច័ន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ ព្រោះជាស្គន់ក្ដាមជើង ។

របៀបដោះស្គន់ក្ដាមជើងនេះ ត្រូវយកវត្ថុ ៤ មុខដោះគឺៈ

១/ស្លឹកសំបួរកក់ (ក្បួនយកស្លឹក, សំបួរមានបីប្រភេទ) ។

២/ប្រទាលវង់ព្រះអាទិត្យ (ប្រទាលនេះសណ្ឋានព្រាវ តែធាង និងស្លឹកតូចៗជាងព្រាវ) ។

ទំពារវត្ថុទាំង ២ យ៉ាងនេះដោះជាមួយនិងទឹកធម្មតា ពីខាងស្ដាំទៅឆ្វេង ១ទីងខ្លួន ។ បើមិនកប់ឲ្យផ្លាស់ថ្នាំថ្មីគឺៈ

១/ ស្លឹកសង្កែ (ស្រួយ) ។

២/ ស្លឹកទៀប ។

៣/ ស្លឹកព្រុះ (ប្រភេទប្រទាលបើបក្ររូប អាច២យ៉ាង) ។

ដោះលាយនិងស្រា.ស ហើយធ្វើយ័ន្តនេះចង.ក ។



តែបើកើតថ្ងៃអង្គារ ខែជេស្ឋ គេឲ្យផ្លាស់ផ្កាស្ពោះជួច្ចេះគឺ

១/ស្លឹកសំបូរ ។

២/ប្រទាលវង់ព្រះអាទិត្យ ។

៣/ស្លឹកសង្កែ ។

៤/ស្លឹកទៀប

៥/ព្រោះ (ប្រទាលឬឫសប្រភេទពោធិ៍ពីរក្រឡូរ ស្រ្តិនគេហៅ)។

វត្ថុទាំង ៥ យ៉ាងនេះយកមកស្ពោះលាយជាឬយនិត្រា.ស ពីខាងឆ្វេងទៅស្តាំ ពីក្រោមទៅលើ ហើយធារុំជាយ័ន្តបង.ក្បួនបានជាគំរូនេះ ។




បើចង់ផ្ដាច់ហើយតែរង ឲ្យយកដីទៅរាត់កំពង់បីជុំ គួចធ្វើរ

ស្រ្តី ក្បាលខ្មៅខ្លួន.ស ជើងនៀវ។ ក្នុងការរោគសបញ្ចៀសបញ្ចោរ ចោលេ ឲ្យយកដីបោសបញ្ចោរចោលេ ។

កំណត់សម្គាល់=បើស្គន់នេះចាប់ផ្ដើមជាន់ពីថ្ងៃអាទិត្យ ឈ្មោះថាស្ដេចស្គន់ ព្រោះពិបាកក្នុងការព្យាបាល ។

*ឧទាហរណ៍ទី៤=* ពិធីព្យាបាលជម្ងឺស្គន់ ក្មេងកើតឆ្នាំថោះ ។

កូនក្មេងប្រុសស្រីណាកើតឆ្នាំថោះ ថ្ងៃអាទិត្យ ចន្ទ អង្គារ ព្រហស្បតិ៍ សុក្រ សៅរ៍ និងខែ មិគសិរ បុស្ស មាឃ ផល្គុន ចេត្រ ពិសាខ ជេស្ឋ ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក ឈ្មោះថាស្គន់ ភ្លាយដើប ។

របៀបស្ដោះស្គន់ភ្លាយដើបនេះ គេឲ្យយកវត្ថុ ៣ យ៉ាងគឺៈ

១/ ដើបរ្លប (ទំាងដើបទំាងស្លឹក) ។

២/ ប្រទាលក្បាលខ្លា

៣/ ឫសខ្លែងពីរ

ទំពារវត្ថុទំាង ៣ មុខនេះស្ដោះជាមួយនិងស្រា.ស ។ បើស្រីឲ្យស្ដោះពីក្បាលចុះទៅក្រោម, បើប្រុសឲ្យស្ដោះចាសឡើងលើមកវិញ ។ ហើយធ្វើយ័ន្ត្រនេះចង.កឲ្យ ។



បើកើតឆ្នាំថោះ ខែ អាសាធ ថ្ងៃ ពុធ ត្រូវផ្លាស់ថ្នាំក្នុងការស្តោះព្រួសដូច្នេះគឺៈ

១/ ស៊ុំ (ព្រួយឬស្លឹក) ។

២/ ប្រទាលក្បាលខ្លា ។

៣/ ខ្លែងពារ (ព្រួយឬស្លឹក) ។

ចំណាំ=

ស្តោះលាយជាមួយនិងទឹកធម្មតា ពីលើចុះមកក្រោម(បើស្រី) ប្រុសពីក្រោមឡើងទៅលើ ។

កំណត់សំគាល់=

បើផ្តាច់ហើយសែនឲ្យយកដីស្ងួតធ្វើរូបស្ត្រីមានក្បាល.ស ខ្លួនប្រាប និងជើងជឿង ហើយបោសបញ្ចៀសបញ្ចូររទោល, និងចារ៉ុជាមន្ត្រគង.ក យ៉ាងដូច្នេះៈ



*ឧទាហរណ៍ទី៥_* ព្យាបាលជប៉ីស្តូន់ ក្មេងកើតឆ្នាំរោង ។

ក្មេងប្រុសស្រីណាកើតឆ្នាំរោង ខែមិគសិរ បុស្ស មាឃ ផល្គុន ចេត្រ ពិសាខ ជេស្ឋ អាសាធ ភទ្របទ អស្សុជ កត្តិក និងថ្ងៃ អាទិត្យ ច័ន្ទ អង្គារ ពុធ សុក្រ សៅរ៍ ឈ្មោះថាស្តូន់រាជសីហ៍ ។

របៀបស្តោះស្តូន់រាជសីហ៍ ផ្លែកខាងឱសថមានៈ

១/ ស្លៀកក្រវ៉ាញជ្រូក

២/ ប្រេង (ត្រាប់)

៣/ ស្រូវ (ស្រូវមានស្រូវភ្លាំង-ស្រូវរពក្តាស.មួយណាក៏បាន)។

៤/ ស្លឹកបាយម៉ាត(មានពីរប្រភេទ ស្រុក-ព្រៃ យកព្រួយ)។

វិធីស្តោះ ទិសាវត្ថុទាំង ៤ មុននេះត្រូវយកប្លូកនិងត្រា.គរ

បើការស្តោះបញ្ឆោតពីក្រោមឡើងទៅលើ ពីខាងស្តាំទៅខាងឆ្វេង

និងចារជាយ័ន្តចង.កឲ្យដល់ក្មេងនោះយ៉ាងនេះៈ



កត់សំគាល់=តែបើកើតឆ្នាំរោង ខែស្រាពណ៍ ថ្ងៃព្រហស្បតិ៍ ប្រើថ្នាំស្តោះដូចគ្នា តែឲ្យចារយ័ន្តចង.ក យ៉ាងនេះ ។



បើឈប់ស្តោះដែលហៅថាផ្តាច់ មុននិងផ្តាច់ដោយត្រូវសែន ឲ្យយកដីក្នុងព្រពាំង សូនរូបរាជសីហ៍មានក្បាលខ្មៅខ្លួន.ស ជើងក្រហម ហើយយកស្លឹកស្តៅបោសគ្រវាសបញ្ចេរចោលទៅ ។

កំណត់ចំណាំ=

បើជប៉ីនេះចាប់ផ្តើមកើតពីថ្ងៃអង្គារ ខែពិស្ស គេឲ្យព្រោះតា ស្តេចស្ទន់ ព្រោះពិបាកព្យាបាល ។

*ឧទាហរណ៍ទី៦_* ព្យាបាលរោគប្រឹស្កន់ ក្មេងកើតឆ្នាំរោងញី ។

ក្មេងប្រុសស្រីណាកើតឆ្នាំរោងញី ខែមិគសិរ បុស្ស មាឃ ផល្គុន ចេត្រ ពិសាខ ជេស្ឋ អាសាធ ស្រាពណ៍ ភទ្របទ កត្តិក និង ថ្ងៃអាទិត្យ ចន្ទ អង្គារ ពុធ ព្រហស្បតិ៍ សៅរ៍ បើស្កន់ជាន់ឈ្មោះ ថាស្កន់ក្រពើ ដែលប្រើថ្នាំស្ដោះមាន៖

១/ សម្បកក្រូចសើច ។

២/ ដីប្លី (ប្រភេទម្លូ) ។

៣/ ព្រួយអន្លង់វិត (រុក្ខជាតិមួយប្រភេទមានសណ្ឋានវល្លិ មានមែកច្រើនតែមួយគូៗទន្ទឹមគ្នា ឯស្លឹកក៏មួយគូៗទន្ទឹមគ្នាដែរ មានបន្លាច្រើនតែមួនៗដុះចេញពីគល់ទងស្លឹក ក្លិនក្រពុល) ។

វិធីស្ដោះ= ទំពាវត្ថុទាំងបីមុខខាងលើនេះ ស្ដោះលាយជាមួយនិងស្រា.ស ចាប់ពីក្បាលចុះមកក្រោម ៩ ដង និងស្ដោះខទឹងខ្លួន ៣ ដង ហើយចារយ័ន្តនេះចង.ក ។



បើកើតថ្ងៃសុក្រ ខែភទ្របទ ឲ្យបន្ថែមថ្នាំស្ដោះផ្សេងទៀតគឺ៖

១/ ព្រួចសើច ។

២/ ពីប្លី ។

៣/ ព្រួយកន្ទ្រង់ ។

៤/ ម្រេច ។

វិធីស្ដោះ= ទំពារវត្ថុទាំង ៤ មុខនេះស្ដោះហោយនិងទឹកធម្មតា ពីលើចុះមកក្រោម ។ និងចារជាយ័ន្តចង.កយ៉ាងដូច្នេះ ។



បើឃើញថាជាហើយចង់ផ្ដាច់ ត្រូវតែសេនឲ្យយកដីដំបូកសូនធ្វើរូបក្រពើ ដែលបានក្បាលក្រហម ខ្លួនស ជើងខ្មៅ ហើយយកស្លឹករាជរ្កឹសបោសបញ្ចោរចោលទៅ (រាជរ្ពឹស ឬហៅ រាជព្រឹក្ស ដើមនេះបានផ្កាព្រុំរុងរឿង ស្លឹកធំៗរាងជាបស្រួច ផ្កាចង្កោមវែងៗ សម្បុរលឿងខ្ចី ផ្លែមូលវែង ច្រើនដុះនៅលើដីទួលឬក្បាលដំបូក)

បើជម្ងឺនេះចាប់ផ្តើមកើតពីថ្ងៃព្រហស្បតិ៍ ខែ ភទ្របទ ឈ្មោះថាស្តេចស្កន់ ព្រោះលំបាកក្នុងការព្យាបាល ។

កំណត់ចំណាំ៖ បើជម្ងឺនោះឃើញរោគដែលហើយញាក់ជើងក្មេង ឲ្យធ្វើយ័ន្តចងកដូចមានគំរូនេះ ។




*ឧទាហរណ៍ទី៧–* ពិធីព្យាបាលជម្ងឺស្កន់ ក្មេងកើតឆ្នាំ មមី ។

ក្មេងប្រុសស្រីឯណាកើតឆ្នាំមមី ខែមិគសិរ បុស្ស មាឃ ផល្គុន ចេត្រ ពិសាខ ជេស្ឋ អាសាឍ ស្រាពណ៍ ភទ្របទ កត្តិក និងថ្ងៃ អាទិត្យ ច័ន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ ឈ្មោះថាស្កន់ស្វា សម្ភារៈដែលយកមកស្តោះមាន៖

១/ ព្រួយអន្លង់វិត ៧ ព្រួយ ។

២/ អំបិលគ្រួស ៧ គ្រួស ។

របៀបស្តោះ៖ ទំពាវត្ថុទាំង ២ មុខនេះ ស្តោះលាយជាមួយនឹងក្រាសាចិត្តន ៤ ដង លើពោះក្រោម និងស្តោះបញ្ចូន

ទៀងលើចំនួន ៣ ដង ហើយគារជាយ័ន្តចង.កយ៉ាងនេះ ។




តែបើក្មេងនោះកើតឆ្នាំមមី ខែអស្សុជ ថ្ងៃសៅរ៍ ត្រូវផ្លាស់ប្តូរថ្នាំស្តោះផ្សេងទៀតគឺៈ

១/ ប្រទាលក្បាលខ្លា

២/ ព្រួយកន្ទ្រង់

៣/ ចិត្រមូលភ្លើង (ខ្លះហៅផ្សិតរមូលភ្លើង)

៤/ មើមខ្ទឹ ៧ ចំណិត

៥/ រំបិល ៧ ក្រួស.

វិធីស្តោះ= ចំពោះវត្ថុទាំង៥ យ៉ាងនេះ ស្តោះលាយជាមួយនិងទឹកធម្មតាទទឹងខ្លួនពីត្បូងទៅត្បូង និងចំកណ្តាលខ្លួន ។

បើមើលឃើញថាជាហើយត្រូវតែចងក្តាប់ ឲ្យយកស្លឹកម្ទេសក្ដួតក្រ អានក្បាលខ្មៅ ខ្លួនលឿង ជើងដែល ។ ហើយឲ្យយកស្លឹកលោក

ហ៊ាតបោសគ្រវាសចោលទៅ ។ និងធ្វើជាយ័ន្ត្រចង.កដូច្នេះ ។

| | | | |
|---|---|---|---|
| ព្វ | ឃ | ៧ | ៩ |
| ឆ | ទទ | ៣ | ៧ |
| ឡ្វា | ៣ | ៩ | ៧ |

កត់សំគាល់= បើជប៊ីស្កន់នេះចាប់ផ្ដើមកើតឡើងពីថ្ងៃ ពុធ ខែអាសាធ ហៅថាស្ដេចស្កន់ ព្រោះលំបាកក្នុងការព្យាបាល ។

*ឧទាហរណ៍ទី៨* _ ការព្យាបាលជប៊ីស្កន់ ក្មេងកើតឆ្នាំមមែ ។

កូនក្មេងប្រុសស្រីណាកើត ឆ្នាំមមែ ខែមិគសិរ បុស្ស មាឃ ផល្គុន ចេត្រ ពិសាខ ជេស្ឋ អាសាធ ស្រាពណ៍ ភទ្របទ អស្សុជ និងថ្ងៃ ចន្ទ អង្គារ ពុធ ព្រហស្ប សុក្រ សៅរ៍ ឈ្មោះថាស្កន់ស្វា

ឱសថដែលប្រើស្ដោះមាន÷

១/ ប្រែងភ្លើង ។

២/ ពន្លៃ (បើមឫស្សីក) ។

៣/ ប្រេះព្រៅ ។

វិធីស្ដោះ= ទំពាវត្ថុទាំង ៣ យ៉ាងនេះ ស្ដោះជាមួយនិងទឹកជាធម្មតា បញ្ច្រាសបីដងពីក្រោមឡើងលើ និងបណ្ដោយដងខ្លួនប្អូន

ផង ដោយព្រួសខ្លាំងៗ ។

តែបើមិនកបទេ ឲ្យយកវត្ថុផ្សេងទៀតគឺៈ

១/ ព្រួយផ្ទីរាចប៍ហាន់ ។

២/ ប្ញស ប្ញសប្បេកព្រៃ ។

ចំពោះស្តោះលាយជាមួយនិងស្រា.ស ហើយចារយ័ន្ត្រនេះចង.ក






កំណាត់ចំណាំ=

បើកើតខែកត្តិក ថ្ងៃអាទិត្យ ឱសថដែលយកមកស្តោះមានៈ

១/ ព្រួយអង្គ្រង ។

២/ ពន្លៃ ។

ស្តោះលាយជាមួយនិងស្រា.ស បញ្ជោសឡើងលើ,បណ្តោយផងខ្លួន ។

បើជាហើយត្រូវតែឆ្អាក់ ឲ្យយកពីក្រោមជើងក្ងោកស្ទូចរួចរស្វាមានក្បាលខ្មៅ ដៃក្រហម ខ្លួនខ្មៅ ជើងវៀងហើយយកស្លឹកប្រះពោសបញ្ចូលគោលទៅ ។

រួចចារយ័ន្ត្រនេះចង.កដូចមានជាគំរូខាងក្រោមនេះ ។

| | | |
|---|---|---|
| អ៊ | ក៊ | |
| ឡ | ត៍ | |
| ម | ហ | យ |
| ឆ | ត៍ | ខ្លា |

កំណត់សំគាល់ - ស្ទន់ស្វានេះបើចាប់ផ្តើមជាន់ពីថ្ងៃសុក្រ ខែភទ្របទ ឈ្មោះថាស្តេចស្ទន់ ព្រោះពិបាកក្នុងការព្យាបាល ។

*ឧទាហរណ៍ទី៩_* ព្យាបាលជម្ងឺស្ទន់ ក្មេងកើតឆ្នាំ វក ។

ក្មេងប្រុសស្រីណាកើតឆ្នាំ វក ខែបុស្ស មាឃ ផល្គុន ចេត្រ ពិសាខ ជេស្ឋ អាសាធ ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក និងថ្ងៃអាទិត្យ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ ឈ្មោះថាស្ទន់ក្តាយ ទើរ ។

ឱសថដែលប្រើឈ្មោះព្រួសមាន៖

១/ ស្លឹកប្រះព្រៅ ។

២/ សម្បកស្តុកស្តុរ ។

៣/ ព្រៀរព្រៀយ ។

៤/ ក្រវាញ ។

ចំពោះវត្ថុទាំង ៤ មុខនេះពោលជារួមគ្នានិងស្រុក.ស ស្តោះទទឹងខ្លួនបីដង និងបណ្តោយដងខ្លួនបួនដង ។ បើមិនគាប់ការ ឲ្យប្រែយកឱសថផ្សេងទៀតគឺ:

១/ សប្បកដង្កោ (ដង្កោធំ) ។

២/ សប្បកជ្រួយ ។

៣/ ស្លឹកចេកក្រពុំ ។

៤/ ស្លា-ម្លូ ។

ចំពោះវត្ថុទាំង ៤ មុខនេះ ស្តោះទទឹងខ្លួន ៣ ដង និងស្តោះបណ្តោយ ៤ ដង ។ ហើយចារយ័ន្តចង.កក្មេង ។



ចំណាំ- បើកើតឆ្នាំ រក ខែមិគសិរ ថ្ងៃច័ន្ទ ថ្នាំស្តោះរោគៈ

១/ ផ្លែចេកត្រាប់ ។

២/ ព្រួយប្រះទេស ។

ចំពោះស្តោះហោយនិងស្រា.ស ស្តោះទទឹងហើយនិងបណ្តោយដងខ្លួនពីឆ្វេងទៅស្តាំ។ បើជាហើយត្រូវតែងផ្តាច់ ឲ្យយកដីក្បាលដំបូកស្លួចធ្វើរូបស្នងខ្លួន លាបក្បាលក្រហម ដៃស ខ្លួនខ្មៅ ជើង

ចៀង ។ ហើយយកស្លឹកកន្ទួតបោសគ្រវាសបញ្ចេញចោលទៅ ។ និងចារជាយ័ន្ត្រដូចនេះចង.កដូច្នេះ ។




កំណត់សំគាល់= បើជប៉ីនេះចាប់ផ្ដើមជាន់ពីថ្ងៃសៅរ៍ ឈ្មោះគេថាស្ដេចស្គន់ព្រោះពិបាកក្នុងការព្យាបាល ។

*ឧទាហរណ៍ទី១០_* ព្យាបាលជប៉ីស្គន់ ក្មេងកើតឆ្នាំ រកា ។

កូនក្មេងប្រុសស្រីណាកើតឆ្នាំ រកា ខែមិគសិរ ផល្គុន ចេត្រ ពិសាខ ជេស្ឋ អាសាធ ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក និងថ្ងៃ អាទិត្យ ច័ន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ ឈ្មោះថាស្គន់ក្ដាមដើរ ។

ឱសថប្រើក្នុងការស្ដោះព្រួសរោគ៖

១/ ព្រួយចៀង (ស្លឹកបែបផ្លូវប្រហាតបន្តិច ប្រើស្លឹកអន្លក់)។

២/ ព្រួយប្រេះ (ស្លឹកឬផ្លែក៏បាន) ។

វិធីស្ដោះ= ទំពាវត្ថុទាំងពីរមុខនេះ ជាមួយនឹងស្រា.ស ស្ដោះ

ចាប់ពីឆ្វេងទៅស្តាំ ហើយចារយ័ន្តចង.ក ដូចនេះ ។




កំណត់ចំណាំ=បើកើតឆ្នាំរកា ខែបុស្ស ឲ្យជូរថ្នាំផ្សេងទៀតគឺៈ

១/ ប្រះព្រៅ (ស្លឹកឬឬស) ។

២/ សម្បកស្តុកស្តុរ ។

ចំពោះស្តោះជាមួយនិងស្រា.ស ពីស្តាំទៅឆ្វេង ។ បើជាហើយៗ ចង់សែនផ្ទាច់ ឲ្យយកដីក្រោមដើមស្លាបកសូនរូបស្នួងខ្លួន ដែលមានក្បាលលឿង ខ្លួនក្រហម ហើយយកស្លឹកប្រះព្រៅបោសគ្រ-វាសបញ្ចូរចោលទៅ ។ និងចារយ័ន្តចង.ក ដូច្នេះ ។



កំណោត់ចំណាំ៖ បើជម្ងឺនេះចាប់ផ្ដើមជាន់ពីខែកត្ដិក គេសំគាល់ថាជាស្ដេចស្កន់ ព្រោះពិបាកក្នុងការព្យាបាល ។

បើញាក់ជើងឆ្វេង ឲ្យចារជាកថាចង.កម្ទេះ ។




*ឧទាហរណ៍ទី១១*- ព្យាបាលជម្ងឺស្កន់ ក្មេងកើតឆ្នាំ ច ។

កូនក្មេងប្រុសស្រីណាកើតឆ្នាំច ខែមិគសិរ បុស្ស មាឃ ផល្គុន ចេត្រ ពិសាខ អាសាឍ ស្រាពណ៍ ភទ្របទ អស្សុជ កត្ដិក និងថ្ងៃ អាទិត្យ ចន្ទ អង្គារ ព្រហស្បតិ៍ សុក្រ សៅរ៍ ឈ្មោះថាស្កន់រាជរថ ។

ឱសថដែលប្រើស្ដោះក្នុងការព្យាបាលស្កន់នេះមាន៖

១/ ចិត្រប្លូលភ្លើង ។

២ ពីរព្រុតការទំរំ ។

៣/ ជីរសំពៅ ។

ទំពារវត្ថុទាំង ៣ មុខនេះ ស្ដោះជាមួយនិងទឹកឃ្មុំចាប់ពីស្មា ឡើងទៅ ។ ហើយការពារជាយ័ន្ត្រចង.កក្មេងនោះផង ។




ចំណាំ= តែបើក្មេងនោះកើតឆ្នាំច ខែជេស្ឋ ថ្ងៃពុធ ឲ្យយក ផ្កាស្ដោះមានខុសគ្នាបន្តិចគឺ៖

១/ ចិព្រប្លូលភ្លើង ។

២/ ជីរក្រសាំងទំហំ ។

៣/ មើមផ្កាចិន ។

ទំពារវត្ថុទាំង ៣ មុខនេះ ស្ដោះលាយជាមួយនិងស្រា.ស ចាប់ ពីត្រឹមស្មាឡើងទៅ ។ បើឃើញថាជាហើយឲ្យចងអំពរប់ ត្រូវតែសេន ឲ្យយកដីក្រោមជណ្ដើរសូនរូបស្នងខ្លួន មានក្បាលពពែស ខ្លួនក្រ ហប ដៃខ្មៅ ជើងពៀង ហើយលោសត្រូវាសរបញ្ជូរចោលទៅ ។ រួចការពារជាយ័ន្ត្រយ៉ាងនេះចង.កឲ្យ ។



*ឧទាហរណ៍ទី១២*- ការព្យាបាលជម្ងឺស្កន់ ក្មេងកើតឆ្នាំ កុរ ។

ក្មេងស្រីប្រុសស្រីណាកើតឆ្នាំកុរខែមិគសិរ បុស្ស ហាឃ ចេត្រ ពិសាខ ជេស្ឋ អាសាធ ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក និងថ្ងៃ អាទិត្យ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ បើស្កន់ជាន់ឈ្មោះ ជាស្កន់ ឪឡ ។

ឱសថដែលប្រើស្តោះព្រួសក្នុងការព្យាបាលជម្ងឺស្កន់នេះមាន៖

១/ ព្រួយស្លាប ។

២/ ព្រួយក្រាំង ។

៣/ សម្បកក្រូចសើច ។

៤/ ពន្លៃ (ស្លឹកម្ទេស) ។

ទំពាវត្ថុទាំង ៤ យ៉ាងនេះពាយជាមួយនិងស្រា.ស ស្តោះពីក្រោមឡើងលើ ។ រូបយ័ន្តនេះចង.កត្បូ ។



ប៉ុន្តែបើក្មេងនោះកើតឆ្នាំកុរ ខែផល្គុន ថ្ងៃច័ន្ទ ឲ្យយកស្លាបព្រួញស្ពា (ធម្មតាព្រួញគេតែងធ្វើស្លាបបើរឿត្យរព់ព្រុំ) ស្ពោះលាយជាមួយនិងស្រា.ស ពីក្រោមឡើងលើ ។

កត់សំគាល់= បើឃើញថាជាហើយៗចង់លរប់ ត្រូវសែនផ្ដាច់, ឲ្យយកដីនៅក្នុងទឹកមកសូនរូបស្នងខ្លួន ក្បាលក្រហម ជើងដៃខ្មៅ ខ្លួនស ។ហើយយកស្លឹកត្នោតពោសត្រវ៉ាសបញ្ចូរបោលទៅ ។ និងធារជាយ័ន្ត្រចង.កឲ្យយ៉ាងដូច្នេះ ។



កត់ចំណាំ=បើជម្ងឺនេះចាប់ផ្ដើមពីថ្ងៃ ច័ន្ទ ខែមាឃ ចាត់ ទុកថាជាស្ដេចស្លន់ ព្រោះពិបាកព្យាបាល ។

គំហើញ= ការព្យាបាលជម្ងឺស្លន់ដោយពិធីស្ដោះព្រួសនេះ បើតាមដែលខ្ញុំធ្លាប់ដឹងនិងធ្លាប់ឃើញមកហើយ អាចស្ដោះជាទៅបាន ចំពោះក្មេងដែលជម្ងឺនេះទើបនឹងកើតឡើងថ្មីៗ ដែលនៅមិនទាន់ធ្លាប់ តែបើធ្លាប់ជាន់ជានិច្ចកាលមកយូរហើយ កប្រមិនឃើញជា ព្រោះបើតាមពេទ្យវិទ្យាសាស្ត្រ គេបញ្ជាក់ប្រាប់ថា ក្មេងនោះមានសាច់ដុះព្រង់បំពង់.ក ឬក៏ក្មេងនោះមានជាតិប្រេះចូលទៅក្នុងខ្លួន (ក្នុងពោះ) ដោយហេតុម្ដាយខ្វះអនាម័យក្នុងពេលកាត់ផ្ចិត ។ល។

## X. ពិធីព្យាបាលដោយអុជ

អុជគឺជាវិធីមួយបែបដែលគេដុតឲ្យឆេះជាភ្លើងដើម្បីកំដៅទៅលើសរសៃក្នុងកាយអ្នកជម្ងឺ ត្រង់កន្លែងណាមួយ ដោយមានខ្នាតច្បាស់យ៉ាងត្រឹមត្រូវ ព្រោះបើកាលណាអុជខុស អាចបណ្ដាលឲ្យមានគ្រោះថ្នាក់ ធ្វើឲ្យអ្នកជម្ងឺទទួលរងគ្រោះ ក្លាយទៅជាជនពិការអវយវៈណាមួយ ដោយសារសរសៃដែលត្រូវកម្ដៅភ្លើងខ្លាំងអាចទៅជារួញខ្វិន បណ្ដាលឲ្យស្ទះឈាមរត់មិនរួច ។

ឯសម្ភារៈដែលយកមកដាក់ដុតរុជនេះ គេច្រើនយកផលនៃរុក្ខជាតិ ដែលហៅថាប៊ុយ ដែលអាចធ្វើឲ្យឆេះជាអណ្ដើក ដូចយ៉ាងប៊ុយទន្សេ ប៊ុយចំបក់ ។ល។ ដោយយកមកលញ់ជាដុំបូលៗ ប៊ុនចុងចង្កេះ ឬគ្រាប់ត គ្រាប់ពុទ្រាតាមការនិយមគ្រូអ្នកព្យាបាលធ្លាប់មានការពិសោធន៍ ។

ដោយហេតុដែលបណ្ដាលឲ្យមានគ្រោះថ្នាក់នេះហើយ ទើបបានជាខ្ញុំមិនយកមកចុះក្នុងទីនេះ ព្រោះការរុជនេះ បើមិនធ្លាប់មានការពិសោធ ដោយចេះមិនច្បាស់លាស់ ប្រាកដជាមានគ្រោះថ្នាក់ ដូចគ្នានិងអ្នកខ្លះចាក់ថ្នាំឲ្យក្មេង ហើយធ្វើឲ្យក្មេងនោះក្លាយទៅជាជនពិការដូច្នោះ ព្រោះតែខ្លួនចេះមិនច្បាស់ ។

## XI. ព្យាបាលដោយជប់

ជប់= គឺជាវិធីស្រូបបឺតទាញស្បែកនៅលើរាងកាយអ្នកជម្ងឺ ។ ក្នុងពិធីនេះគេមានធ្វើជាច្រើនបែបយ៉ាង ដូចជាយកផ្តិលឬកូនក្រឡឬបំពង់ ហើយដាក់សំឡីគញ្ចាត់ចូលទៅក្នុងនោះ រួចដុតភ្លើងឲ្យឆេះចេញជាអណ្ដាត ហើយគ្របទៅលើស្បែកតាមរាងកាយអ្នកជម្ងឺ ត្រង់ចំណុចដែលគេយល់ថាត្រូវជប់ ។ ម្យ៉ាងទៀតគេយកទៀនអកបិទភ្ជាប់នៅលើឈើស្ដៀម ដូចការក្រញាកាក់ស្លឹកត្នោត

ដែលគេកាត់ជាបន្ទះឬបេះរាចដាក់បន្ទុំទៅលើសាច់បាន ហើយដុតចៀននោះឲ្យឆេះឡើង រួចយកពែងឬកែវ,បំពង់ ឬគ្របរកកំពោរគ្របពីលើភ្លើងចៀននោះ ។ល។

ប៉ុន្តែមានវិធីម្យ៉ាងដែលគេជប់ជាទូទៅ ពេញសរពាង្គកាយអ្នកជម្ងឺ ដោយមិនរើសកន្លែង ហើយដែលគេសម្គាល់ថាមានប្រសិទ្ធិភាពជាងគេ គឺគេយកបំពង់ឫស្សីតូចៗដែលកាត់ទុកថ្នាំងម្ខាង(មានសណ្ឋានដូចបំពង់ត្រងទឹកត្នោត)ប្រវែងបីថ្នាំងដៃ (៣ សង់ទីម៉ែត្រ) ដាក់ស្ងោរជាមួយនិងទឹកថ្នាំនៅក្នុងឆ្នាំងមួយធំ (ថ្លាង) លុះទឹកពុះយូរល្មមចូលជាតិថ្នាំសព្វរស់ហើយ ទើបគេស្រង់លើកចេញមកម្តងមួយៗ ដែលឃើញមានចំហាយផ្សែងនៅក្នុងបំពង់ រួចទើបគេយកទៅគ្របនៅពីលើសាច់អ្នកជម្ងឺ ត្រង់កន្លែងដែលគេធ្វើជំនោះ (ជោះ) ឬអារសាច់ឲ្យបុកបន្តិចដើម្បីមានឈាមចេញមក ។ល។

កាលបើបំពង់ស្រង់ចេញពីក្នុងឆ្នាំង ហើយយកទៅដាក់ពីលើសាច់, ចំហាយផ្សែងក្នុងបំពង់នេះត្រូវបឺតសាច់ភ្ជាប់បកនិងបំពង់ ហើយឈាមក៏ចេញមកកកជាប់នៅក្នុងបំពង់ដែលជប់នោះ ។

ហើយគេបានសង្កេតឃើញថា ក្រោយពីបេះយកបំពង់ចេញមក ឈាមដែលកកនៅក្នុងបំពង់នោះ មានពណ៌សម្បុរប្លែកៗខុសគ្នា និងមានខាប់មានរាវខ្លះកើតទៅជាពពុះ ដែលធ្វើឲ្យគ្រូអ្នកព្យាបាលមានទំនាយផ្សេងៗ ទៅតាមការដែលគេធ្លាប់បានពិសោធន៍

រួចបកហើយ ។

## XII. ល្បែងលេងយកចាប់

ចាប់= ក្នុងន័យពាក្យថាចាប់នេះ គេច្រើនសំដៅយកទៅលើកិច្ចអនុវត្ត ៣ យ៉ាងគឺៈ ចាប់សរសៃ ចាប់ខ្យល់ និងចាប់ខ្មោច ព្រាយ ធ្មប់ អាប ។ល។

ចាប់សរសៃ= វិធីនេះមានច្រើនបែបយ៉ាង ដែលគេធ្វើរបៀបប្លែកៗពីគ្នា ទៅតាមការស្ទាត់ជំនាញនិងការប៉ិនប្រសប់របស់អ្នកចាប់សរសៃម្នាក់ៗ ។

ចាប់ខ្យល់= ជាវិធីមួយបែបដែលគេប្រើម្រាមដៃពីរ គឺម្រាមកណ្ដាលនិងម្រាមចង្អុលចាប់តៀតច្បិចទាញស្បែកច្រំដែលៗ លុះត្រាតែឡើងក្រហមទើបឈប់ ។ ប៉ុន្តែមានខ្លះគេច្រើនយកលោហធាតុដូចជាស្លាបព្រា ព្រាក់សេនជាដើមទៅកោសនៅលើស្បែក ទាល់តែឡើងក្រហមជាំដូចគ្នា ក៏ហៅថាចាប់ខ្យល់ដែរ ។

ចាប់ខ្មោច ព្រាយបុធ្មប់អាប= ក្នុងពិធីនេះគេច្រើនយកកំពោរសម្រាប់បៀកប្លូមកសូធ្យសែកបញ្ចូលបន្តគាថា ហើយគូសដៅជុំវិញទៅលើ.កដៃ កជើង និងបំពង់កអ្នកជំងឺ ដែលគេហៅថាចង (គឺបុននិងចាប់ព្រួចចងកុំឲ្យរត់) ដូចមានគាថាចងខ្លះថា នទន្ទាឃ

ពាន្ធន៍  អធិដ្ឋាមិ (មានច្រើនសូមមើលត្រង់ទំព័រ ១០០ ឬ ១៩៨) រួចហើយទើបគេស្ទាបរកពាបកន្លែងដែលគេសង្ស័យ,កាលណាបើស្ទាបទៅប៉ះត្រូវចំ  ប្រាកដជាឃើញរត់ចុះរត់ឡើងហាក់ដូចជាជីពចរដូច្នោះ  ប៉ុន្តែមានសភាពច្បាស់លាស់ឲ្យដឹងថា មានវត្ថុអ្វីមួយដែលរត់នៅក្នុងសាច់ និងធ្វើចលនាគេចវេះចុះឡើង ដែលឲ្យគេសង្កេតបានថា ជាធ្នូប់អាបចូលប្រាកដមែន ។

បើកាលណាស្ទាបរកទៅពុំឃើញមានអ្វីទេ នោះគ្រូចាប់ដឹងថាមនុស្សធ្វើពុតក្លែងក្លាយ  ហើយគេយករបួសលាយជាមួយនិងស្រកីដូងដុតបំពក់ឲ្យល្អក់កណ្តាស់  ព្រោះត្រាតែសារភាពថាចេញហើយទើបឈប់ ។

ខ្ញុំសូមរៀបរាប់បញ្ជាក់ប្រាប់ថា  វិធីស្ទាបរកធ្នូប់អាបចូលនេះខ្ញុំធ្លាប់បានស្ទាបក្នុងការពិសោធរួចមកហើយ ដែលខ្ញុំយល់ច្បាស់ថាជាការពិតប្រាកដមែន  ព្រោះនៅគ្រាមួយនោះស្ត្រីម្នាក់ឈ្មោះយាយ ទីឌ ត្រូវធ្នូប់ចូល ហើយខ្ញុំក៏បានទៅក្នុងពេលនោះដែរ ។ គ្រូចាប់ធ្នូប់កាលបើឃើញខ្ញុំអង្គុយជិតនោះចាំសង្កេតមើលដូច្នោះគេយល់ច្បាស់ថាខ្ញុំប្រាកដជាមិនជឿ , ទើបគេបង្ហាញប្រាប់ខ្ញុំថាៈ នេះ ! នេះ ! ជួយស្ទាបមើល ! ខ្ញុំក៏យកដៃស្ទាបទៅតាមគ្រូគេប្រាប់ ហើយប្រទះឃើញវត្ថុដែលរត់នៅក្នុងសាច់ពិតប្រាកដមែន, ព្រោះកាលបើរត់គេចទៅខាងណា គ្រូគេប្រាប់ថាៈ  នេះរកខាង

ណោះទៀតហើយ ! ខ្ញុំក៏ស្ទាបទៅទៀតឃើញពិតពូឆ្ពោះវែង ជាច្រើនលើកច្រើនគ្រា ដែលបញ្ជាក់ឲ្យខ្ញុំយល់ច្បាស់ថាឥតមានភូតភរកុហក់ឡើយ ។

សេចក្ដីដូចបានរៀបរាប់មកហើយពីខាងលើ គឺជាការព្យាបាលខាងផ្លូវចិត្តដែលប្រើផ្សំជាមួយសក្ការៈ ហើយដែលជាអំពើសុចរិត ។ ឯចំណែកខាងអំពើទុច្ចរិតជាទុព្ពិជ្ជា បុរាណខ្មែរយើងមានចេះច្រើនឥតគណនា ព្រោះកាលពីដើមដែលប្រទេសរុងរឿងមិនទាន់ធ្លាក់ចុះ បើយើងធ្វើវិភាគមើលទៅលើការស្រាវជ្រាវរបស់ខ្មែរយើងនិងបានឃើញគ្រប់វិស័យ ដែលមានស្នាដៃទុករហូតមកដល់សព្វថ្ងៃ តួយ៉ាងដូចជាត្នោត ដើមត្នោតដែលឃើញមានច្រើនជាងគេ គឺដុះនៅប្រទេសខ្មែរ, ដូចនេះបញ្ជាក់ឲ្យឃើញថា ខ្មែរជាអ្នករកឃើញស្ករត្នោតមុនគេ ។

ហើយបើយើងធ្វើវិភាគទៅលើចំរើនៃការស្រាវជ្រាវនិងការពិសោធន៍ យើងនិងនឹកស្ញើចអំពីស្នាដៃនេះ ព្រោះផ្កាត្នោតដែលចេញផ្លែផ្កាមិនមែនដើមទាបៗអាចឈោងដល់ ដើម្បីធ្វើការសាកពិសោធន៍នោះទេ ត្រូវតែដាក់ជណ្ដើរឬចងជាអន្ទាងឡើងទើបដល់ ។ ហើយក្នុងការដែលគេគាប់ផ្កាយកទឹក ដើម្បីឲ្យបានទឹកចេញមកបាននោះ លុះត្រាតែគេត្រូវពិធី ។ ក្នុងការគេគាប

ខ្វាង ដែលគេហៅថាជ្រុលដៃ ទឹកមិនចេញក៏មាន ជួនកាលស្រាល ដៃពេកមិនគេនទឹកចេញក៏មាន ហើយគារនេះមិនមែនធ្វើតែក្នុង មួយថ្ងៃឬមួយពេលប៉ុណ្ណោះទេ ដោយមានធ្វើជាច្រើនថ្ងៃនឹងច្រើន លើកច្រើនគ្រា រហូតដល់មានយកទឹកទៅព្រំាផ្កាទៀតផង ។ ជួន កាលកាំបិតមិនមុតឬក៏ចិតមិនត្រូវទំនង ទឹកមិនចេញក៏មាន ។ល។

ដូចនេះយើងនឹងបានឃើញថា ការពិសោធន៍នេះ ត្រូវប្រើ សេចក្ដីព្យាយាមយ៉ាងមោះមុត ប្រៀបបាននិងការពិសោធន៍ធ្វើ យន្តហោះដូច្នោះ ដែលយើងគួរកត់សំគាល់ទុកថា ខ្មែរអ្នកស្រាវ ជ្រាវធ្វើស្ករត្នោត ចាត់ទុកជាអ្នកប្រាជ្ញមួយក្នុងចំណោមអ្នកប្រាជ្ញ នៅលើសាកលលោកក្នុងការស្រាវជ្រាវ ទុកស្នាដៃជាប្រយោជន៍ ឲ្យដល់មនុស្សជាតិ ។

ឧទាហរណ៍អំពីត្នោតនេះបញ្ជាក់ឲ្យឃើញថាខ្មែរយើងពីបុរាណ កាល គេបានស្រាវជ្រាវនឹងធ្វើការពិសោធន៍ ទុកជាស្នាដៃហើយ ជាកេរដំណែលមក ជាច្រើនឥតគណនាគ្រប់វិស័យទាំងអស់ ។ ប៉ុន្តែជាអកុសលរបស់ខ្មែរយើង ស្នាដៃជាកេរដំណែលដែលមាន មកទាំងអម្បាលម៉ាននោះ គ្មានស្ថិរភាពគង់វង្សនៅដដែល ឬរីក ចំរើនតទៅទៀតបានឡើយ, មានតែវិនាសបាត់បង់សាបសូន្យទៅ បន្តិចម្ដងៗ តាំងតែពីដើមសតវត្សទី១៤ ដែលខ្មែរចុះថយឥទ្ធិពល នៅភូមិភាគអាស៊ីប៉ែកអាគ្នេយ៍មក ។

ដូចជាគេប្រើអក្សរសាស្ត្រក្នុងការជ្រើសរើសដើម្បីដាក់ឈ្មោះ កូនប្រុស ស្រី ទៅតាមខែ ឆ្នាំ ថ្ងៃកំណើតដោយមានប្រាថ្នាចង់បានជោគជ័យសិរីមង្គល ដែលគេមានជំនឿជឿថា កុំឲ្យកូនរបស់គេមានជម្ងឺឈឺថ្កាត់ និងឲ្យបានគង់វង្សមានជីវិតយឺនយូរ ហើយលុះដោយតំបូន្មានមាតាបិតា មិនចចេសរឹងរូស ព្រហើនកោងកាច ។ល។

នេះបើយើងគ្មានការពិសោធន៍ ហើយមិនបានពិចារណាឲ្យជ្រៅជ្រះ ហាក់ដូចជាគ្មានប្រយោជន៍ធ្វើឲ្យចាប់អារម្មណ៍ឬមានជំ-នឿទាល់តែសោះ ប៉ុន្តែបើយើងបានតាមដាននិងស្រាវជ្រាវទៅលើអំពើទាំងឡាយនោះ ប្រាកដជានិងយល់ឃើញថាខ្មែរពីបុរាណមានការពិសោធប្រាកដមែន ។

ខ្ញុំធ្លាប់មានការពិសោធចំពោះគ្រឿងនេសាទុបករណ៍ ២ គឺ លួ និង ចម្រប់ ដែលហៅថាស្នាក់ (គឺចេះតែប្រទះបានដោយងាយ) វត្ថុទាំង ២ យ៉ាងនេះខ្ញុំសំគាល់ឃើញថា បើដែកដែលល្អប្រាកដជាស្នាក់ ខុសគ្នាពីដែកដែលមិនសូវល្អ។ ហើយបើដែកដែលល្អនោះភ្លួរមិនត្រូវតាមកម្លាំងថ្ងៃ ក៏មិនសូវជាស្នាក់ដែរ, បើដែកដែលល្អហើយភ្លួរត្រូវទៅតាមកម្លាំងថ្ងៃ និងពេលវេលាដោយត្រឹមត្រូវ ប្រាកដជាស្នាក់មែន ដែលរកបានដោយមិនបាច់ខំប្រឹង ។

សព្វវេលានេះខ្ញុំចង់បញ្ជាក់ឲ្យឃើញច្បាស់ថា ជំនឿត្រូវតែប្រ-

ការទៅដោយប្រាជ្ញាពីការរៀននិងការពិសោធន៍ ហើយវិចារណញ្ញាណ និងក្នុងការពិសោធន៍ទេ គាត់ទុកជាការពិតប្រាកដពិតទៅមិនទាន់បាននៅឡើយ ។

ដូចមានចាស់ៗដែលបានពិពណ៌នាប្រាប់ពីសភាពអស្ចារ្យនៃមន្តអាគមខ្មែរ ដូចជាមន្តវិជ្ជាដែលធ្វើគោម តែងអាចធ្វើវត្ថុដែលឥតវិញ្ញាណ ឲ្យមានជីវិតរស់ឡើងបាន (គោមគឺជារូបគោតូចៗ ដែលគេធ្វើពីសំរិទ្ធិឬក្រហួន ប៉ុន្តែដោយអំណាចឫទ្ធិដែលបន្តគាថា ធ្វើឲ្យវត្ថុដែលឥតវិញ្ញាណនោះ ក្លាយជាមានជីវិតរស់រវើក ដែលអាចប្រើការបាន ដូចជាគេប្រើឲ្យទៅលប់ធ្វើឃាតជនណាមួយ ។ល។ ) នេះគឺជាពាក្យពិពណ៌នាដែលហួសវិស័យមិនអាចឲ្យជឿបាន ប៉ុន្តែពាក្យពិពណ៌នានេះក្លាយទៅជាពាក្យពិត ក្នុងឆ្នាំ១៩៥៨ ដែលគេបានឃើញព្រឹត្តិការណ៍ជាក់ស្តែង (សូមមើលសំនេរខ្ញុំរៀបរាប់ក្នុងសៀវភៅទស្សនៈអំពីវិញ្ញាណ ត្រង់ទំព័រ៩២ ដែលបោះពុម្ពលើកទី១ ។

## XIII. ពិធីបញ្ចូលគ្រូ

ពិធីនេះគួរជាវិធីព្យាបាលរោគបែបបុរាណ ដែលឃើញមានតែអ្នកស្រុក ព្រោះគ្រូដែលចូលនេះគឺជាគ្រូខ្មោចអ្នកតាតា ដែល

គេមានជំនឿជឿថាខ្មាំងព្រៃ កាលបើខ្លួននោះធ្វើអោយកើតជម្ងឺទៅលើបុគ្គលណា បុគ្គលនោះនឹងមានសភាពស័ក្តិសិទ្ធខុសប្រក្រតី.

ឧទាហរណ៍= អ្នកជម្ងឺធ្លាក់លើក្នុងព្រៃទៀតយ៉ាងខ្លាំង ដោយមិនដឹងជាកើតរោគអ្វី ! ទើបគេធ្វើពិធីបញ្ចូលគ្រូភាគនេះ ដើម្បីឲ្យជួយក្នុងការព្យាបាល ។ ហើយគេបានសំគាល់ឃើញថា បន្ទាប់ពីការសែនស្នាធិបួយស្រវឹកមក រូបអ្នកដែលបញ្ចូលគ្រូនេះ ឃើញមានអាការញ័រញាក់សព្វសាច់សរពាង្គកាយ កម្រើកខ្លួនសំរៀងដែលបញ្ជាក់ឲ្យឃើញដឹងថា មានអ្វីមួយមកធ្វើបុគ្គលនោះឲ្យខុសប្លែកពីធម្មតា ។

ហើយបន្ទាប់ពីការញ័រញាក់នោះមក ទើបគេផ្ទុំវិញព្រៃទៀតអ្នកជម្ងឺនោះ ដែលគេសំគាល់ឃើញថា ព្រៃទៀតដែលពីយ៉ាងខ្លាំងក្លានោះ បានថយចុះនូវការឈឺចុកចាប់បន្តិចម្តងៗជាលំដាប់រហូតដល់ជាសះស្បើយ ។

ខ្ញុំសូមបញ្ជាក់ថា វិធីព្យាបាលដោយការចៀរបញ្ចូលគ្រូនេះ ខ្ញុំធ្លាប់បានឃើញការព្យាបាលផ្ទាល់ ព្រោះអ្នកជម្ងឺត្រូវជាសាច់ញាតិរបស់ខ្ញុំ ដែលខ្ញុំសំគាល់ឃើញថា ជាការព្យាបាលមួយយ៉ាងដែលមានសភាពស័ក្តិសិទ្ធណាស់ដែរ ។

## XIV. ការបន់ស្រន់

ការបន់ស្រន់នេះកាន់ទុកជាផ្សាររបៀបព្យាបាលបញ្ហាខាងផ្លូវគំនិត នៅក្នុងគ្រួសារ ដោយគេមានជំនឿថា វត្ថុស័ក្តិសិទ្ធិអាចនឹងជួយការពារបង់កូវរោគាពាធទាំងឡាយបាន ។ ព្រោះហើយទើបបានជាគេបន់ស្រន់ថា សុំបញ្ជាឲ្យអ្នកជម្ងឺបានជាសះស្បើយនោះ គេនឹងថ្វាយដង្វាយជារង្វាន់មាន ស្លាធម៌ បាយសី ឬផ្លែឈើរបស់ភស្តុភារផ្សេងៗ, ជាពិសេសគេច្រើនបន់ស្រន់ទៅលើព្រះពុទ្ធប្បដិមាករ អង្គណាដែលឮល្បីថាខ្លាំងពូកែស័ក្តិសិទ្ធជាងគេ ។

ឧទាហរណ៍=ដូចជាព្រះពុទ្ធរូបមួយព្រះអង្គនៅក្នុងវត្តព្រះសង្ឃយួន ស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង ដែលជាព្រះពុទ្ធពីបរប បុរាណ មិនដឹងជាសាងឡើងពីសតវត្សរ៍ណា ដែលគេហៅថាព្រះផុស ដោយឃើញលេចចេញពីព្រះធរណីមក ។

ហើយបើតាមចាស់ៗតំណាលប្រាប់ថា កាលបើគេឃើញព្រះផុសនោះហើយ អ្នកស្រុកបានបញ្ចូលរូបជាមុនដើម្បីនិមន្តយកទៅទុកក្នុងវត្ត ។ តែរូបដែលបញ្ចូលនោះបញ្ជាក់ប្រាប់ថា ព្រះពុទ្ធអង្គលោកចង់ទៅគង់នៅវត្តហោកយួន ,ទើបគេធ្វើពិធីដង្ហែយ៉ាងអឹកអធឹកគគ្រឹកគគ្រេង ដោយមានដុតឧសជាគំនរយករងើកក្រាលលើផ្លូវ ឲ្យអ្នកដង្ហែរាប់រយនាក់ ដើរជាន់លើររងើកភ្លើង ដោយបាតជើងទទេ ដើម្បីសំដែងឲ្យឃើញពីឫទ្ធិរិទ្ធិនៃព្រះបដិមាអង្គនោះ ថាខ្លាំងពូកែពេក ។

ការបន់ស្រន់នេះយើងធ្លាប់បានឮគេនិយាយច្រើន ដែលបានពីលោកគេរៀបរាប់ប្រាប់ថា គាត់ធ្វើការបន់ស្រន់ ហើយបានសម្រេចទៅតាមគោលបំណងរបស់គាត់យ៉ាងពិតប្រាកដ . ដោយមានអ្នកខ្លះពណ៌នារៀបរាប់ប្រាប់ថា កូនរបស់គាត់មានជំងឺជាទម្ងន់ ដែលគ្រូខ្មែរពេទ្យបារាំងហ៊ានព្យាបាលទេទៅរួច ហើយនៅរង់ចាំតែពេលស្ទើរស្លាប់ប៉ុណ្ណោះ តែដោយអំណាចឫទ្ធិបារមីរបស់ព្រះអង្គ.......... ដែលគាត់រំលឹកនឹកដល់ក្នុងការបន់ស្រន់ បានធ្វើឲ្យកូនរបស់គាត់ជាសះស្បើយរស់ឡើងវិញរហូតមកដល់សព្វថ្ងៃ ។ល។

មានខ្លះទៀតរៀបរាប់ពិពណ៌នាប្រាប់ថា គាត់បានរៀបអាពាហ៍ពិពាហ៍នឹងគ្នាជាប្ដីប្រពន្ធ ហើយរស់នៅជាមួយគ្នាបានច្រើនឆ្នាំ ប៉ុន្តែមិនមានកូនទាល់តែសោះ ទើបតែគាត់ទៅបន់ព្រះអង្គ....... សុំបានកូនឈ្មោះ............និងខ្លះទៀតថាសុំយកកូនចំនួន.........
...នាក់ ។ល។

ហេតុនេះហើយបានជាអ្នកដែលបានពណ៌នារៀបរាប់មកជាច្រើនគ្នា, ប្រហែលជាការបន់ស្រន់នេះមានប្រសិទ្ធិភាព ធ្វើឲ្យសម្រេចនូវគោលបំណងខ្លះៗយ៉ាងពិតប្រាកដ ទើបបានជាខ្មែរយើងកាលពីជំនាន់មុននិយមធ្វើការបន់ស្រន់ ។

បើតាមសេចក្ដីរៀបរាប់របស់អ្នកស្រី មីន.ម៉ែប បានរៀបរាប់ប្រាប់ថា ការសំបូងសួងបន់ស្រន់នេះហើយមានលក្ខណៈពិសេសក្នុង

តែន ព្រោះឪពុករបស់គាត់ឈ្មោះលោក ចំរើន កើតមកទោល តែម្នាក់ឯង គ្មានបងប្អូនឡើយសោះ លុះដល់ពេញវ័យឪពុកម្ដាយ បានឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយនិងនាងឃឹម ជាភរិយា ហើយ គាត់បាននាំគ្នាទៅបន់ស្រន់ព្រះនៅភ្នំជីសូរ ដើម្បីសុំយកកូនចំនួន ១០ នាក់ គឺប្រុស ៥ នាក់, ស្រី ៥ នាក់ ។

ចំណេរកាលតមកលោក តែប និងនាង ឃឹម ជាភរិយាមាន កូនចំនួន ១០ នាក់ ប្រុស ៥ ស្រី ៥ ដូចសេចក្ដីបំណង ។

ហើយលោក តែប បានហាមប្រាមដល់ភរិយាថា កូនយើងនេះ កុំជេរវាយដំវាឲ្យសោះ ព្រោះជាកូនសុំព្រះ ។ ប៉ុន្តែកូនរបស់គាត់ ទាំង ១០ នាក់នោះសុទ្ធតែប្រកបទៅដោយគន្លងធម៌ទាំងអស់ ។

នេះជាសម្ដីដែលអ្នកស្រី ម៉ក់ តែក បាននិយាយប្រាប់, ដែល អ្នកស្រីកំពុងរស់នៅសព្វថ្ងៃនៅទីក្រុង (Lowell, MA) ។ ខ្ញុំក ជាតំណាងក្នុងសំណេរនេះ ។

ហើយបើចង់ដឹងពីរឿងបន់ស្រន់នេះឲ្យបានពិស្តារ សូមមើល សំណេររបស់ខ្ញុំក្នុងសៀវភៅទស្សនៈពិពិធវិញ្ញាណដែលបោះពុម្ពលើក ទី១ ត្រង់ទំព័រ ១៥០ ។

ពេលនេះខ្ញុំសូមលើកយករឿងក្នុងក្រុមគ្រួសារបុគ្គលកម្ពុជា [illegible] ភូមិ ព្រះអារ ខិម.ខាង់ [illegible]

ឱដុន (ពាំងស្ពី) បកល្អងបិត្តអ្នកអានក្នុងការធ្វើភាគទៅលើជំនឿ ការសេចក្តីរៀបរាប់របស់ក្រុមទស្សនាវដ្តីប្រជាប្រិយឆ្នាំ១៩៩៩ដែល មានសេចក្តីទាំងស្រុងដូចតទៅៈ

កន្លែងដែលសំខាន់ ហើយមិនមែនគ្រាន់តែជាកន្លែងបន់ស្រន់ ទូវអរូបីនោះ គឺវត្តតុកងណោះ ដែលឃើញមនុស្សម្នាចេញចូលវត្ត បាក់ដូចជាមានពិធីបុណ្យដ៏ធំមួយនៅក្នុងវត្តជារៀងរាល់ថ្ងៃ ។

មានមនុស្សចាស់ជរា មនុស្សវ័យកណ្តាលនិងក្មេងៗអង្គុយតំ រៀបគ្នាចាំទទួលទឹកមន្ត ដែលព្រះសង្ឃដ៏ចំណាស់មួយអង្គកំពុងតែ ស្រោចទៅលើសរពាង្គកាយរបស់ពួកគេ ។ មនុស្សមួយក្រុមចេញ មនុស្សមួយក្រុមទៀតចូលទៅអង្គុយនៅកន្លែងដដែល, ហើយនៅឯសាលាឥតជញ្ជាំង ២ ពងណោះ មានមនុស្សអង្គុយរងរង់ចាំវេនទទួលទឹកមន្ត ។

បើតាមសំដីរបស់ជនានុជនដែលកំពុងអង្គុយរង់ចាំនៅក្នុងសាលាបានឲ្យដឹងថា ពួកគេឮល្បីៗគ្នាថាព្រះគ្រូចៅអធិការវត្តតុកនេះពូកែណាស់, អ្នកខ្លះបានអះអាងថាកោតអង្គូនរបស់គេបានជាពីជម្ងឺសរសៃប្រសាទ ជម្ងឺស្ទើរ រួចទៅហើយ, មានប្អូនប្រុសម្នាក់បានរៀបរាប់ថា ប្រពន្ធម្នាក់ឈ្មោះ អ៊ុក ប៊ុនថន ជាវរសេនីយ៍ឯក ធ្វើការនៅការិយាល័យកងទ័ពអាកាស ត្រូវបានទទួលការព្យាបាលរួចហើយពីជា "ជំងឺលាក់ជើង" ដែលត្រូវពេទ្យតែរោគ(វិកលចរិត្ត)

ពិរុទ្ធនិងធ្វើការកាត់ផ្ទេរទោសទៅលើគេនោះ ។

នៅមានស្ត្រីម្នាក់ទៀតដែលជាគ្រូទាយទៀត ដែលគេយើងយល់ថា ជាជំពូកជនអ្នកមាន ព្រោះគេឃើញមានសំលៀកបំពាក់និងគ្រឿងអលង្ការថ្លៃៗពាក់ពេញខ្លួន ដែលបានអះអាងថា ធ្លាប់មើលជូនប្តី គាត់និងខ្លួនគាត់បានជាពីជប្តីត្រូវអំពើអំពាន់ ឬត្រូវស្នេហ៍ជាដើម។

ស្ត្រីមិនចំណាស់ម្នាក់ដែលនិយាយបែបឡូវៗពាន់ឲ្យដឹងថា កាលពីឆ្នាំទៅគាត់បានកាត់ប្រស្នាស្តីលោកតា ហើយធ្លាក់ក្នុងយេខ ត្រូវបានប្លន់ប៉ុនរៀល(១០,០០០) ។ល។

ពាក្យសម្តីរបស់អ្នកមានជំនឿទាំងនោះ ស្តាប់មើលទៅលោកគ្រូចៅអធិការវត្ត ហាក់ដូចជាគ្រូហោរយ៉ាងពូកែមួយអង្គ ដែលអាចមើលជូនប្តីក៏បានដែរ ។

ប៉ុន្តែនៅពេលដែលជួបផ្ទាល់និងលោកព្រះតេជគុណ ទិប.ខាន់ ចៅអធិការវត្តគុហ៍នោះ ព្រះអង្គមានសង្ឃដីកាថាព្រះអង្គមិនដែលតាំងខ្លួនជាគ្រូហោរមើលជូនប្តីទេ អ្វីដែលព្រះអង្គបានធ្វើកន្លងមក គឺព្រះអង្គធ្វើតាមវិធីវិបស្សនា ព្រោសសត្វតែប៉ុណ្ណោះ ។

ព្រះអង្គពន្យល់ថា សម្រាប់មនុស្សលោក ផ្លូវចិត្តមានឥទ្ធិពលពី ៧០% ទៅ ១០០% គ្របដណ្តប់លើផ្លូវកាយ. កាលបើមនុស្សមានជំនឿលើព្រះធម៌ហើយ ព្រះធម៌និងជួយមនុស្សឲ្យឈ្នះនូវឧបទ្រពចង្រៃលើរាងកាយបាន ដោយភាគច្រើនជាមិនខាន ។

ទោះបីជាកើតរោគណាក៏ដោយ បើសិនរាងកាយអ្នកជំងឺនោះ រោគរាតត្បាតខ្លាំងក្លាពេកនោះ ព្រះអង្គក៏មិនអាចព្យាបាលឲ្យរស់គេរួចដែរ. នេះជារឿងធម្មតា ដូចជាព្រះធម៌តែងថា មនុស្ស សត្វ ទាំងឡាយ ជៀសមិនផុតពីសេចក្ដីស្លាប់បានឡើយ ។

តទៅនេះសូមជូនការសង្កេតចំណាំ របស់គ្រូពេទ្យខ្មែរបុរាណ ដែលច្រើនទាយទុកជាមុនថា អ្នកជំងឺឈឺខ្លាំងធុនធារ ឬស្រើបន្តិចបន្តួច អាចព្យាបាលជាឬមិនជា រស់ឬស្លាប់ជាដើម ។ ហើយដែលគ្រូខ្លះធ្លាប់មានការពិសោធន៍មកច្រើនទាយត្រូវចំៗមិនខុស ដូចមានការសង្កេតជាឧទាហរណ៍តទៅនេះ៖

១ បើមានអ្នកមករកឬមកជិបន្តនោះ អង្គុយចង្ក្រាយក្រោយពេលជា ១ ពេញពីធ្ងន់ តាមការចំណាំលោកច្រើនទាយថា អ្នកជំងឺភាគច្រើនៗស្លាប់ ។

២ បើអ្នកមកនោះអង្គុយចង្ក្រោយក្រោយពេលជា ២ ពេញ តាមការចំណាំរបស់គ្រូពេទ្យបុរាណខ្មែរ គេច្រើនទាយថាអ្នកជំងឺនោះធ្ងន់ ។

៣ បើអ្នកមករកនោះ មកអង្គុយចង្ក្រោយក្រោយពេលជា ៣ ពេញ គេច្រើនទាយថាអ្នកជំងឺនោះស្លាប់ហើយ ។

៤ បើអ្នកមករកនោះ អង្គុយក្រោយក្រោយពេលជា ៤ ពេញ គេច្រើនទាយថាអ្នកជំងឺនោះមិនជាអ្វីទេ ។

ម្យ៉ាងទៀតលោកឲ្យទាយរកពៀរគុណ ចែក សិទ្ធិភាវិយៈ=បើនិងទាយពីអ្នកជំងឺថាយ៉ាងណាៗ នោះ លោកឲ្យរាប់ពីអាយុរបស់អ្នកជំងឺពីរឡើង ហើយគុណនិង១៨ រួចចែកនិង ៧ ឧទាហរណ៍ថាអ្នកជំងឺអាយុ ៣៥ ដូច្នេះ( ៣៥ x ១៨) : ៧ = ៩០ សល់ ទាយថា ០ តែងតែស្លាប់ ។

បើសេស ៣, ៧, ០ ទាយថាច្បាស់ជាស្លាប់ ។

បើសេស ១, ២, ៤ ទាយថាមិនស្លាប់ទេ និងជាវិញ។

បើសេស ៥, ៦ ទាយថាមិនអីទេ ធូរបន្តិចបន្តួច ។

ម្យ៉ាងទៀតលោកឲ្យរាប់អាយុអ្នកទាយឡើង ហើយយក ៩ គុណ រួចចែកនិង ៧ ហើយទំនាយដូចតទៅ៖

បើសេស ៧, ០ ទាយថាជំងឺធ្ងន់ ស្លាប់ហើយ ។

បើសេស ១, ២, ៣ ទាយថាមិនស្លាប់ អាចព្យាបាល ។

បើសេស ៤ ទាយថាជាជំងឺប្រចាំកាយ ពិបាកព្យាបាល។

បើសេស ៥ ទាយថាជាភោគជរា គ្មានអ្វីសំខាន់ ។

បើសេស ៦ ប្រហែលប្រើថ្នាំខុស ទោសព្រោះអ្នកព្យាបាល។

ម្យ៉ាងបើពេលទាយកើតរកចង្កឹះអាយុពិបាក សិទ្ធិភាវិយៈ=បើគេរកអ៊ីចងទាយដែលកើតរកនោះចង្កឹះអាយុពិបាក ស្មេរ

ឲ្យយកសករាជកំណើតរបស់ទារកតាំងឡើង ហើយយកខែកើត (ខ្នើត-រនោច) របស់ទារកបូក ហើយគុណនឹង៧ រួចចែកនឹង១២ ហើយទាយតាមចំនាយដូចតទៅ៖

-បើសេស ០ ទាយថាទារកនោះមិនរស់ទេ ទោះជាយ៉ាងណាក៏ស្លាប់ដែរ ចិញ្ចឹមមិនបាន ។

-បើសេស ១, ២, ៦, ៨ ទាយថាស្លាប់ក្នុងវ័យក្មេង គឺចិញ្ចឹមមិនបានធំទាន់ ។

-បើសេស ៩, ១០, ១១ ទាយថាល្មមចិញ្ចឹមបាន មានរោគរៀតរៀនជាធម្មតា ។

-បើសេស ៣, ៤, ៥, ៧ ទាយថាចិញ្ចឹមងាយណាស់ និងឲ្យជោគលាភដល់មាតាបិតា ។

របៀបមើលកូនក្នុងផ្ទៃថាភេទស្រីឬប្រុស សិទ្ធិអាចារ្យ៖ បើចង់ដឹងថាកូនក្នុងផ្ទៃប្រុសឬស្រី ត្រូវឲ្យយកអាយុឪពុកម្ដាយបូកចូលគ្នាហើយគុណនឹង ៣ រួចចែកនឹង៧ ទាយតាមចំនាយដូចតទៅ៖

-បើសេស ១ ឬ ៣ ថាជាកូនប្រុស ពិបាកចិញ្ចឹម ។

បើសេស ២, ៤, ៦ ទាយថាកូនស្រី ចិញ្ចឹមងាយ ។

-បើសេស ៧ ឬ ០ ទាយថាកូនស្រី ចិញ្ចឹមពិបាក ហើយច្រើនតែមិនសូវរស់ ។

ម្យ៉ាងទៀតលោកឲ្យសង្កេតអ្នកដែលមករកខូចតទៅ៖

សិទ្ធិអាចារ្យ៖ លោកពោលទុកថា ប្រុសឬស្រីដែលមករកឲ្យ ឲ្យសង្កេតមើលលក្ខណៈ៖

១ បើលោកប្តី ស្ត្រី ណារី ដែលបួរមកឲ្យ ហើយសង្កេតឃើញ ប្តីស្ត្រីណារីនោះជាគ្នានិងគ្នា រមែងមិនល្អ ច្រើនមានគ្រោះថ្នាក់ ។

២ បើលោកប្តីស្ត្រីណារីមកនោះ សង្កេតឃើញថាសេស មិនជាអ្វី ទេ, ជាប្តីខូចជាក្រោធ តែមិនស្លាប់ ។

៣ បើអ្នកនោះតែងខ្លួនស្អាតបាត តែមុខហាក់សោកសៅទាយ ថាជាប្តីឃ្លង់ ។

៤-បើតែងខ្លួនរៀបរយ ទឹកមុខមិនសូវជាទុក្ខសោកទេ ទាយ ថាជាប្តីមិនសូវជាធ្ងន់ធ្ងរ ។

៥ បើអ្នកដែលមករកនោះអង្គុយយកជើងឆ្វេង ក្អែក តែងជើង ស្តាំ ទាយថាអ្នកនោះមានទុក្ខសោកខាងផ្លូវចិត្តខ្លាំង ។

៦ បើយកដៃស្ទាបពោះ ទាយថាអ្នកនេះនៅមិនទាន់បានបរិភោគអ្វីនៅឡើយ ។

៧ បើយកដៃស្ទាបពោះ ទាយថាមុនមកនេះ មានកូនកំពុងយំ ពាល ។

៨ បើយកដៃស្ទាបក្បាល ទាយថា ទើបតែអាលក្អួចហើយ ណាណាក ។

៩ បើយកដៃស្ទាបសក់ ទាយថា ដេកជាប្រយោគទៀងត្រូវ
បកហើយ ។

១០-បើយកដៃស្ទាបចិញ្ចើម ទាយថា បានការផ្លូវកាចជួបនឹង
ព្រះសង្ឃឬអ្នកកាន់សីល ។

១១-បើយកដៃស្ទាបភ្នែក ទាយថា មានរឿងព្រួយហើយទើប
មកនេះ ។

១២-បើយកដៃស្ទាបក្បាល ទាយថា ជួបមនុស្សចាស់ជរានៅ
កណ្ដាលផ្លូវ ។

១៣ បើយកដៃស្ទាបត្រចៀក ទាយថា មានគេពីងពាក់ឬប្រើ
ឲ្យមក ឬក៏បុនមកមានភ្លេចអ្វីៗ ។

១៤-បើយកដៃស្ទាបត្រង់ដើមដៃ ទាយថា ជន្ទល់ទ្វេញគ្នារួច
ទើបមក ។

១៥-បើយកដៃស្ទាប.ក ទាយថាឈ្លោះគ្នារួចហើយទើបមក ។

១៦-បើយកដៃស្ទាបទ្រូង ទាយថា មកនេះដោយទៅរកទាត់
បានរួចទឹកផង ។

១៧-បើយកដៃស្ទាបទៅចុងត្បា ទាយថា បរិភោគអាហាររួច
ហើយទើបមក ។

១៨-បើយកដៃស្ទាបក្បាលជង្គង់ ទាយថាដើរជល់ឈ្មោះឯកហើ
ការ ទើបមក ។

១៩ បើយកដៃស្ទាបជើង ទាយថាដាក់ជណ្ដើរផ្ទះឬបិទជណ្ដើរផ្ទះរួចហើយទើបមក ។

២០- បើយកដៃចាប់ត្រង់ចង្កោយជើង ទាយថា មនុស្សដែលស្រឡាញ់ប្ដីឬប្រពន្ធ ប្រើឲ្យមក ។

២១- បើយកដៃស្ទាបត្រង់បបូរមាត់ ទាយថា ស្ដីជាមួយបងប្អូនរួចហើយទើបមក ។

២២ បើយកដៃចាប់ចង្កា ទាយថាមកនេះមិនសូវជាមានជំនឿជឿលើគ្រូប៉ុន្មានទេ ។

២៣- បើយកបាតដៃទាំងពីរត្រដុសគ្នា ទាយថាមកនេះប្រញាប់ត្រឡប់ទៅផ្ទះវិញ ។

២៤- បើអង្គុយសណ្ដូកជើង ទាយថា មនុស្សនោះឥតមានគោរពរាប់អានអ្នកណាឡើយ ។

សេចក្ដីអធិប្បាយដែលបានរៀបរាប់មកហើយនេះ មិត្តអ្នកអាននឹងបានឃើញថា វិធីព្យាបាលជំងឺគ្រូពេទ្យខ្មែរពីជំនាន់ដើម ដែលវិទ្យាសាស្ត្រនៅមិនទាន់ចំរើនល្អពេកនៅឡើយ ខ្មែរមានវិធីព្យាបាលទាំងខាងផ្លូវសក្ការៈនិងខាងផ្លូវចិត្ត ដែលមានប្រើឱសថនិងមន្តអាគមផ្សំជាមួយគ្នា ។

ប៉ុន្តែរឿងអាពីពេលដែលខុសគ្នាពីរឿងក្នុងបច្ចុប្បន្ន ហើយរឿង

បច្ចុប្បន្នក៏មុខជាខុសគ្នានិងរឿងទៅក្នុងអនាគតទៀតជាមិនខាន ។

បើយើងទាញយកអាកជីវិតរបស់យើងម្នាក់ៗ ចាប់ពីគ្រឹមដឹងក្ដី រហូតដល់វ័យចាស់ យើងនឹងបានឃើញការប្រែប្រួលរបស់មនុស្ស លោកមានប្លែកៗខុសគ្នាឆ្ងាយ តាំងពីគ្រឿងឧបភោគបរិភោគនិង វត្ថុប្រើប្រាស់សព្វសារពើទាំងអស់ ។

ហេតុនេះបើយើងយករឿងក្នុងបច្ចុប្បន្នទៅពណ៌នាប្រាប់ ដល់ មនុស្សពីជំនាន់ដើមថា យានអាកាសហោះទៅកាន់ស្ថានព្រះច័ន្ទ ហើយចុះចតនៅទីនោះ ប្រាកដជាគេមិនជឿទាល់តែសោះ,ហើយ បើយើងយករឿងពីអតីតបកពណ៌នាប្រាប់ដល់មនុស្សជំនាន់ឥឡូវ ថា មនុស្សជំនាន់ដើមមានសមត្ថភាពខាងផ្លូវចិត្ត ផ្លូវវិញ្ញាណ ឬ ចេតភូត រហូតដល់ចេះថ្លែងឫទ្ធិ ជប់ និម្មិត ពាំពោងខ្លួន បំបាំង កាយ មុជ ហោះប្រែកជាដើម នោះប្រាកដជាគ្មាននរណាម្នាក់ ជឿទេ ។

ដូច្នោះបើយើងយករឿងពីអតីតបកប្រៀបធៀប និងរឿងក្នុង បច្ចុប្បន្នប្រាកដជាខុសគ្នា, ហើយបើយើងយកគំនិតមនុស្សក្នុងបច្ចុ ប្បន្ន ទៅប្រៀបធៀបនិងគំនិតមនុស្សពីជំនាន់ដើមក៏ប្រាកដជាខុស គ្នាដែរ, ហើយបើយើងយកទំរើបមនុស្សពីដើមបកប្រៀបធៀបនិង ទំរើបមនុស្សសព្វថ្ងៃក៏មិនដូចគ្នាទៀត, ហើយបើយើងយកគំហើញ មនុស្សសព្វថ្ងៃទៅប្រៀបធៀប និងគំហើញមនុស្សពីជំនាន់ដើមនោះ

ក៏រឹតតែខុសគ្នាឆ្ងាយទៅទៀត ។

ដូចនេះបើយើងមានគំហើញថា ខ្មែរពីដើមដែលយកថ្មមកធ្វើជាប្រាសាទ បើគិតពីទំងន់ក្នុងថ្មមួយដុំៗ ដែលដាប់ពុះច្រៀកកើតបានទៅជាបួយផ្ទាំងៗនោះ មិនដឹងជាចំណាយពេលអស់យូរប៉ុន្មាន និងប្រើកម្លាំងមនុស្សអស់ចំនួនប៉ុន្មាននាក់? ហើយបើលើកបន្តុបឡើងទៅលើកំពូលខ្ពស់ៗនោះទៀតមិនដឹងជាមានគ្រោះថ្នាក់ស្លាប់ជីវិតមនុស្សអស់ចំនួនប៉ុន្មាន? ។ល។

ដូច្នេះការយល់ឃើញនេះជាគំនិតក្នុងបច្ចុប្បន្ន ដែលយើងយល់ថាទំងន់របស់គេ ដូចជាគំនិតរបស់យើងគិត ។

តែបើយើងបានទៅឃើញនៅវាលក្រឡ (ធុងហៃហ៊ុន) នៅប្រទេសលាវសព្វថ្ងៃ យើងនិងបានឃើញថ្មយ៉ាងធំៗ ដែលមានសណ្ឋានដូចជាពាងនៅពាសពេញវាល ដែលជាទំងន់របស់មនុស្សជំនាន់ដើម ដែលធ្វើឲ្យយើងនឹកឆ្ងល់នឹងកោតស្ញប់ស្ញែងថា ថ្មជាធម្មជាតិដែលរឹងទល់គ្នានិងដែក ម្តេចឡើយបានជាគេចោះដាប់ធ្វើជាពាង ហើយឈូសរំលីងឲ្យកើតរាងរៅបានដូចជាធ្វើឈើដូច្នោះ? បើគេធ្វើដោយលំបាកម្តេចឡើយក៏គេធ្វើបានច្រើនម្លេះ?

បើយើងមានវិចារណញ្ញាណដូចនេះ យើងមិនអាចសន្និដ្ឋានថា ថ្មប្រាសាទដែលបុព្វបុរសខ្មែរបានពុះច្រៀក ដឹកជញ្ជូន ឆ្លាក់ហើយលើកបន្តុបឡើងទៅលើវេហាស៍នោះ ជាហេតុបណ្តាលឲ្យស្លាប់

បាត់បង់ជីវិតបន្តស្នូររាប់ពាន់រាប់ម៉ឺន ដូចគំនិតដែលគេរើសគិតឃើញនោះឡើយ ។

ខ្ញុំសូមនិទានរឿងមួយដែលខ្ញុំបានសួរចាស់ៗដើមកាលគេប្រាប់ថា ព្រៃពាំងភាស (ក្នុងស្រុកថ្មពួក-អនុខេត្តថ្មពួក) ព្រៃពាំងនេះមានទំហំធំណាស់ ជាបារាយដែលបុរាណបានជីកក្នុងអតីតកាល ។

នៅក្នុងព្រៃពាំងនោះមានថ្មមួយដុំ តែថ្មនោះគេសំគាល់ឃើញថា តែងធ្វើចលនាចុះឡើងមិននៅនឹងមួយកន្លែងសោះ ជួនកាលឃើញនៅទីនេះ ជួនកាលឃើញនៅឯណោះ ។

ហើយចាស់ៗខ្លះបានដំណាលប្រាប់ថា កាលគាត់នៅពីក្មេងទៅអញ្ចាត់ត្រី គាត់តែងដាក់កញ្ជើរនៅលើថ្មនោះ ខ្លះថាដាក់ត្រុះ ។ ស្រាប់តែមកដល់ឥឡូវ មិនដឹងជាថ្មនោះបាត់ទៅណា ! ខ្លះថាថ្មនោះហោះបាត់ទៅហើយ ព្រោះថ្មនោះចាស់បុរាណគេបានបញ្ចុះកាយសិទ្ធិ (កែយសិទ្ធិ) ។ល។

តទៅនេះសូមបង្ហាញពីអាគមគាថា ដែលល្បីថាពូកែៗ ហៅថា **មហារអាគម** មានដូចតទៅ ៖

អាគមនេះគ្រូដែលមានព្រះពន្លឺបានបញ្ជាក់ថា បើអ្នកណាកាន់មន្តណាមួយដោយខ្ជាប់ខ្ជួន ហើយនឹងតមត្រណមបានដោយត្រឹមត្រូវ អ្នកនោះនឹងបានសម្រេចដូចបំណង ដូចដែលមានចំណង

ដើងបញ្ជាក់ក្រាប់យ៉ាងពិតប្រាកដ ។

ដូច្នោះអ្នកដែលកាន់ខ្ជាប់ខ្ជួនគឺ អ្នកដែលភាវនារំលឹកនឹកដល់ជានិច្ចកាលមិនដែលដាច់ ដែលហៅថាចំរើនឬដាស់ ឬហាត់រៀន រៀនរួចជាហាត់ធ្វើសមាធិឬវិបស្សនាកម្មដ្ឋានយ៉ាងដូច្នោះ ។

ពរព្រហ្មណោបតី បុរាណលោកបានបញ្ញត្តិទុកមកមិនឲ្យប្រព្រឹត្តនូវអំពើទុច្ចរិតផងនានា ដែលជាបិរាបហាមមិនឲ្យធ្វើអំពើអាក្រក់មានលួចទ្រព្យសម្បត្តិ និងប្រពន្ធកូនគេជាដើម ។

ដូច្នោះអ្នកដែលរៀនបន្តភាគនេះពួកែ គឺអ្នកដែលចេះសមាធិចិត្ត ខាងផ្លូវកម្មដ្ឋាន ដែលច្រើនតែព្រះសង្ឃនិងពួកអ្នកមានសីល ៥ សីល ៨ ។

សិទ្ធិការិយៈ= បើអ្នកប្រកាន់យកគាថាណាមួយ ត្រូវបូជាគ្រូដោយមានស្លាធម៌ ១ គូ ធូប ៣ សរសៃ និងទៀន.សធំ១ ផ្កា ៣ ទង ហើយ ៣ ពណ៌ខុសៗគ្នា រំលឹកនឹកគុណជាបឋម ដែលហៅថារៀបគ្រូឬកំណត់គ្រូ ។

## ១ (គាថានេះឈ្មោះថា) **ហង្សព្រះពុទ្ធ**

ឥតិបិសោ ភិសេស ឥឥសេស ពុទ្ធនាមេ ឥឥមេ នា ពុទ្ធ ឥសោ ឥឥសោឥ ពុទ្ធ បិតិឥ ៗ

ចំណាំពើង គាថានេះប្រសើរណាស់ កាលបើសែកទឹកពេលមុខពេលរៀបព្រឹកអាចគេច្រើនអានិយម ហើយការពារបានគ្រប់.

បើពេលមានបង្គុលការផ្សេងៗ ឲ្យសែកគាថានេះដាក់អំបោះទៅ ឬអំបោះខ្លុក, ផ្ដុំក្បាល ឬដេញខ្មោចព្រាយបិសាច ។ល។

## ២- ព្រះ១៦អង្គ

នមនក (អានជាបាលី) **ធកធក** (អានជាសម្រាយ)

**កអធអ** (អានជាសម្រាយ) នអអភអទិ (អានជាបាលី)

គាថានេះសែកសំពត់.សរុំក្បាល ឬក្រវាត់ខ្លួន ការពារសត្រូវ ប្រទូសរ៉ាយក្នុងវេលាធ្វើដំណើរឬចូលទៅក្នុងទីបិទគួរធរ, ពួកបច្ចាមិត្តមិនហ៊ានបៀតបៀន ។ បើពេលចេញពីផ្ទះពោកឲ្យសែកដិតកន្សែងជូតមុខ ហើយក្ដួចចងជាកំណួច ទៅដល់ទីដៅហើយសិបស្រាយ ការពារសត្រូវវិសេសណាស់ ។

## ៣- គាថាប្រសានបាត្រ

ចត្តារោ បត្តេ យថា ឯកោ ត ឈា អធិដ្ឋាហិ

គាថានេះពណ៌នាថា កាលដែលចតុលោកបាលយកបាត្រពីទិសទាំង៤មកថ្វាយព្រះពុទ្ធ តែព្រះអង្គបានបំពេងប្រើបាត្រតែមួយ ហើយទើបព្រះអង្គទ្រង់អធិដ្ឋានបាត្រទាំង៤ឲ្យទៅជាបាត្រ១ ដោយគាថានេះ ។ ដូច្នេះគាថានេះមានអ្នកខ្លះគេយកទៅពោត់ផ្ចិតផ្ចង់ក្នុងការផ្ចិតផ្ចង់ ឬក្នុងការបញ្ចូលស្នេហាកំពូល ដូចជាអេញ្ញាការ

ទ័ពដែលមានពលទាហានច្រើន ហើយគេចង់ឲ្យខ្មាំងមើលឃើញចំនួនពិត ។ល។ គេសំគាល់ដឹងថាគាថានេះសែកផ្លុំដំបៅរបួស ឬឆ្អឹងបាក់បែក ស្រួច ផ្លោះ ហើម ជាំ មានប្រសិទ្ធិភាពណាស់ ។ គេប្រើសែកនិងប្រេងព្រៅ ឬប្រេងក្របួន លាបដំបៅ ឬចឆ្អឹងភ្ជាប់គ្រាក និងឃើញជាស្បើយក្នុងរវាងពី ៣ ទៅ ៧ ថ្ងៃ បើមានបុពដាច់នៅតាមសរពាង្គកាយ លោកឲ្យសែកទឹកលាបស្រឡាបជាហោង ។

## ៨- គាថាឃាត់ឈាម

ឥតោ ឥតិឡ្ហ ឥតិតោ ឥតាមាតោ

គាថានេះលោកឲ្យសែកផ្លុំរបួសដែលឈាមកំពុងចេញ ឬទំពាស្លឹកពេជីសែកបិទចំមុខរបួស ឈាមនិងឈប់ចេញភ្លាមបានទាន់ចិត្តដូចបំណង ។

## ៩- គាថាផ្លុំភ្នែកបាយ.ភ្នែកក្រហម

សហស្ស នេត្តោ នេមិន្ទោ និព្វចក្ខុំ មិសោនយិ ឥកមិតិ ពុទ្ធសំមិ លោកមិន្ទូ

គាថានេះប្រើសែកនិងសន្លឹកប្ញស្រស់ ស្លឹកខ្ទឹម ខ្ទឹមក្រហម ផ្លុំភ្នែកឈឺ រមាំ ឡើងក្រហម ឡើងបាយ បើសែកទឹករៀងសម្រាបចូលភ្នែកឲ្យកែណាស់ ឬនិងប្រើសែកទឹកស្ទូលោងមុខហាត់រាល់ថ្ងៃ

ក៏ជាការប្រសើរ គេសំគាល់ថាជាអារក្ខាភិរក្ស ។

## ៦- គាថារំលត់ភ្លើងនរក

ថេរោ មោគ្គល្លានោ នរកគ្គឹ លោហគព្ភិ និស្សា
អគ្គិបត្តិ ភស្មតិ

គាថានេះជារបស់ព្រះមហាមោគ្គល្លានថេរ ព្រះអគ្គសាវកខាងឆ្វេង ដែលមានឫទ្ធិខ្លាំងពូកែ មានរឿងនិទាននៅក្នុងគម្ពីរថែងថា ព្រះអង្គភាវនាញែកភ្លើងទៅនរកដើម្បីប្រោសសត្វ ។ ដូច្នេះលោកឲ្យប្រើគាថានេះសែកផ្លុំមនុស្សដែលត្រូវទឹកក្តៅរលាក កំចាត់ពិសភ្លើងមិនឲ្យក្តៅមិនឲ្យពង បើអ្នកដែលកាន់ខ្ជាប់ខ្ជួនអាចលូកទឹកក្តៅដែលកំពុងពុះបានគួរឲ្យភិសវង់ ។

## ៧- គាថាព្រះមហាឧបគុត្ត

ឧបគុត្តោ ច មហាថេរោ ឧបគុត្តំ ច មហាថេរំ
ពុទ្ធទេវ ពុទ្ធានុភាវេន ឥមំកាយ ពន្ធនំ អធិដ្ឋាមិ

គាថានេះជារបស់ព្រះមហាឧបគុត្តថេរ លោកឲ្យភាវនាសែករំបោះខ្សែសិញ្ចន៍ចងខ្មោចដែលចូលមនុស្ស បើនិងស្រាយពែង លោកឲ្យប្រើគាថាព្រះនារាយណ៍ ទើបអាចចេញបាន ។

## ៨- គាថាព្រះនារាយណ៍

សោ មា ន ភ ទិ ថា ឆោ

"ប្ល លោ បុ សុ ស មិ ត្ថុ សឹ ត អ"

គាថានេះសែកកំពោរ ឬសែកទឹកធ្វើទឹកបន្ត បើឲ្យស្រីមានគភ៌ផឹកប្រសូត្រកូនងាយ ប្រើសែកស្បៀដកពិសរំពើរំពាន់ខាងផ្លូវភ្លេង និងដេញធ្មប់អាបខ្មោចព្រាយបិសាច ។ល។

## ៩ គាថាខាបឆក

សម្មុហនេយ្យ សម្មុហគតិ សម្មុហគតោ សិមាគ ឥ ពន្ធសេមាយំ សម្មុហនិគព្វោ ឯទំ ឯហិ ន យ្លាព **(អានជាសម្រាយ)** មោ ភ្វាយ ពុទ្ធបក នាយក យមេញធុព

គាថានេះប្រើសែកទឹកអន្តស្រោចស្រព ឬសោបស្រទ្យាបពោប រាងកាយការពារធ្មប់អាបរំពើរំពាន់ និងសូធ្យខាបដកយកចេញនូវវត្ថុជាអាថ៌កំបាំង ដែលជាគាថាយ៉ាងវិសេសស័ក្តិសិទ្ធ ។

## ១០ បណ្តូលឥតិបិសោ

អ សិ មិ សុ លោ បុ ស ពុ ត

គាថានេះភាវនាបុងចេញពីកើរការពារសព្វវិធហ៊ានរៀតរៀន និងជាស្នេហ៍មហានិយម ។ បើរពាកទឹកក្តៅឬភ្លើងរលាក លោកឲ្យប្រើគាថានេះសែកផ្លុំព្រងបុនរបួស ៣-៧ ចប់ មិនក្តៅពិធពោរពង ។

## ១១ បណ្តូលកាលល័ក

ប ភ. ភ ស (ក្រោយវង្វេងកូន)

គាថានេះលោកឲ្យសែកបៀប្លទឹកលោបបុងការពារសត្រូវនិងព្រាយបិសាចផងនានា (៣-៧ចប់) បើ១០៨ចប់វិសេសណាស់ ។

## ១២- ឥតិបិសោ ៨ ទិស

ឥ រ ជា គ ត រ សា

ថែរក្សាការពារនៅខាងទិសបូព៌ា

តិ ហំ ច សោ ទោ ទិ នំ

ថែរក្សាការពារនៅទិសអាគ្នេយ៍

បិ ស ម រ ឈោ បុ ស ត ពុ ទ

ថែរក្សាការពារនៅទិសទក្សិណ

សោ មា ណ ភ រិ ថា ចោ

ថែរក្សាការពារនៅទិសនិរតី

ភ ស្ន ស្ន ទិ ស ទេ ភ

ថែរក្សាការពារនៅទិសបស្ចិម

គ ពុទ្ធ បន្ទ ឆម ទ គ

ថែរក្សាការពារនៅទិសពាយ័ព

ទា យោ នោ អ ម ទា

ថែរក្សាការពារនៅទិសឧត្តរ

អ ទិ ជ សុ ទុ ត សា ទុ ស តិ

ផែរក្សាការពារនៅទិសឦសាន

គាថានេះភាវនាការពារភយន្តរាយ ១០៨ គុណ បានគុណអនេកអនន្ត ។ វេលាដើរដំណើរចូលព្រៃនៅក្នុងព្រៃឲ្យសែកដុំដី ៨ ដុំ ចោលទៅគ្រប់ទិសទាំង ៨ សត្រូវខ្មោចព្រាយបិសាចឬសត្វសាហាវមិនហ៊ានបៀតបៀនឡើយហោង ។

លោកជាធម្មាចារ្យបានពណ៌នាពីសេចក្តីអស្ចារ្យនៃគាថាផតិបិសោ ៨ ទិសនេះថា សម្រាប់ការពារភយន្តរាយយ៉ាងវិសេសដូចតទៅ៖

១-សែកថ្នាំប្រាប់ពិសសត្វខាំ ទិច បុត បានយ៉ាងពូកែ

២-សែកទឹកធ្វើទឹកមន្តស្រោចអ្នកជម្ងឺ ដែលត្រូវស្នេហ៍ ឬត្រូវខ្មោចព្រាយបិសាចធ្លប់អាបចូលបានយ៉ាងវិសេសស័ក្តិសិទ្ធ

៣-ភាវនាការពារសត្រូវគ្រប់យ៉ាង

៤-ភាវនា ១០៨ ចប់សែកធ្វើទឹកមន្តព្រោះព្រំបាចសាចដេញកំចាត់ខ្មោចព្រាយបិសាច និងសម្រាប់ជួយស្ត្រីឲ្យប្រសូត្រកូនងាយ

៥-សែកអង្ករឬម្សៅដើម្បីបញ្ចៀសបញ្ចោរចោល

៦-សែករំពោះទៅឬរំពោះខកក្នុងការចងជាចំណងមន្ត

៧-សែកផ្ទិខនឯងក្នុងការធ្វើដំណើរ ការពារបហន្តរាយ ។

## ១៣- គាថាការពារខ្លួននិងធនធាន

យជេសិ យជេសិ ភីអរណា យជេសិ អហ៊ំ

មិឝំ ជានាមិ ជានាមិ

គាថានេះលោកឲ្យភាវនាមុនដេកការពារសត្រូវបៀតបៀន និងចោរចូលលួចទ្រព្យសម្បត្តិ ឬក្នុងពេលធ្វើដំណើរតាមផ្លូវ ឬកំពុងធ្វើកិច្ចការងារផ្សេងៗ ដែលមានសត្រូវប៉ុនប៉ងប្រទូសរ៉ាយនិងត្រូវរលាយសូន្យ ដោយខ្លាចអំណាចតេជះ ហើយនឹងចូលមកជាមិត្តឲ្យបានឃើញយ៉ាងប្រចក្ស ។

## ១៤- ឥតិបិសោធពុណ

សោ ភគវា ឥតិបិ អរហំ អរហំ

សោ ភគវា ឥតិបិ អរហំសម្មា សម្ពុទ្ធោ

សោ ភគវា ឥតិបិ អរហំវិជ្ជា ចរណ សម្បន្នោ

សោ ភគវា ឥតិបិ អរហំ សុគតោ

សោ ភគវា ឥតិបិ អរហំ លោកវិទូ

សោ ភគវា ឥតិបិ អរហំ អនុត្តរោ បុរិសទម្មសារថិ

សោ ភគវា ឥតិបិ អរហំ សត្ថា ទេវមនុស្សានំ

សោ ភគវា ឥតិបិ អរហំ ពុទ្ធោ

សោ ភគវា ឥតិបិ អរហំ ភគវាតិ ។

គាថានេះប្រើបាន ១០៨ ប្រការពូកែស័ក្តិសិទ្ធ កាលបើមានទុក្ខភ័យកើតឡើងនៅក្នុងផ្ទះ លោកឲ្យភាវនា ១៤ ចប់, ស្តោះផ្លុំពិសសត្វចឹក ខាំ លោកឲ្យភាវនា ៩ ចប់, ប្រើក្នុងការសម្របសម្រួលគ្រួសារដូចជាប្តីប្រពន្ធបែកបាក់គ្នា លោកឲ្យយកក្រូចឆ ឬ

ប្រេងក្បៀនរោបជារូបទឹករបស់សូធ្យសែកពី ២ ៩ ចប់, បើសែកដាក់ប្អូសូក្រាព្វីឲ្យសែក ២ ចប់ ។ បើសែកដាក់ប្អូសូក្រាឲ្យអ្នកជម្ងឺផឹក ដែលត្រូវខ្មោចព្រាយឬប្អប់រាបចូល វាពិងប្រាប់ឈ្មោះរបស់យើងលោកឲ្យសូធ្យសែក ៧ ចប់, បើសូធ្យសែកក្នុងការព្យាបាលជម្ងឺនានា លោកឲ្យសូធ្យសែក ៧ ចប់ដែរ ។

## ១៥ បណ្ដូលព្រះសង្ហា

មិ ចេ រុ និ ឥ ស យេ ន មិ ភ វី គ ទេ

គាថានេះជាគាថាសូធ្យសែកគាថាដទៃៗឲ្យខ្លាំងក្លាឡើង ឬនិងប្រើភាវនាក្នុងពេលដែលមានរាសន្ទរអន្ទ្រក ដូចជានៅក្នុងទីសមរភូមិដើម្បីការពារនូវគ្រឿងសាស្ត្រាវុធនានា ។

## ១៦ ឥតិបិសោបញ្ច្រាស

តិវាគភទ្ធោ ពុ នំសា នុស មវទេថា ស័ត ថិរ

សារម ទ័ម សរិបុរោត នុត រទូវិកលោ តោគសុ នោ

ប័ណ ស័ម ណរចជា វិជ ទ្ធោ ពុ ស័ម សម្មា ហំរអ វា

គភសោ បិតិឥ ៗ

គាថានេះមាន ៥៦ តួ (បើសរសេរអក្សរច្រៀងសូបរានដូចជាតំរាយ) លោកឲ្យភាវនា ៣ ចប់ ឬ ៧ ចប់ មុនពេលចេញដំណើរទៅកាន់ទិសណាទិស ដើម្បីសំរាងនូវទុក្ខវិបត្តិទាំងពួង ។

បើភាវនាបានគ្រប់ ១០៨ ចប់ជាអចិន្ត្រៃយ៍លោកពោលថាជាការប្រសើរបំផុត ព្រោះអ្នកដែលបានហាត់ហ្វឹកហ្វឺនព្រះគាថានេះផល់នូវសមាធិចិត្ត គេអាចនិងសម្រាបខ្លួនបាន ហើយអាចដោះខ្នោះឃ្នាងច្រវាក់ ឬចំណងចងបានយ៉ាងស័ក្តិសិទ្ធ លើកលែងតែមនុស្សដែលប្រព្រឹត្តអំពើទុច្ចរិត ។

## ១៧- មហាអំណាច

ឯវំ រាជសីហោ មហានាទំ សីនាទនំ សីហនាទេ សីលតេជ នាមរាជសីហោ ឥទ្ធិឫទ្ធិ **ព្រះពុទ្ធំរក្សាកំចាត់សត្រូវ** អបរាជយំ ឥទ្ធិឫទ្ធិ **ព្រះធម្មំរក្សាកំចាត់សត្រូវ** អបរាជយំ ឥទ្ធិឫទ្ធិ **ព្រះសង្ឃំរក្សាកំចាត់សត្រូវ** អបរាជយំ

គាថានេះលោកឲ្យសែកទឹកលាងមុខមាត់រាល់ៗព្រឹក ឬមុនធ្វើដំណើរ និងមានស្នេហ៍មានរាសីជាមហានិយម ហើយមានអំណាចអ្នកផងខ្លបខ្លាចចុះចាញ់អានុភាពរាប់អានជាមិត្ត ។ល។

ដូច្នេះមហាភាគមដែលបានពណ៌នាមកនេះ គឺជាចំណែកខាងពុទ្ធមន្តទាំងអស់ បើអ្នកដែលតមបានប្រព្រឹត្តតែអំពើសុចរិត ហើយបានហ្វឹកហ្វឺននូវគាថានេះយ៉ាងខ្ជាប់ខ្ជួន " ហានសីលក្នុងខ្លួន " អ្នកនោះនិងមានឥទ្ធិឫទ្ធិខ្លាំងពូកែ ដូចជាចំណងជើងដែលលោកបានពោលទុកមកជាពិតប្រាកដមេហោង ។

**ខ្ញុំសូមលើកយកការស្រាវជ្រាវនៃបុព្វបុរសខ្មែរ ដែលមានភស្តុតាងបង្ហាញឱ្យឃើញនិងទុកជាកេរបំណែលរហូតមកដល់សព្វថ្ងៃ** ដែលគួរតែខ្មែរយើងសរសេរចុះជាប្រវត្តិអំពីស្នាដៃអ្នកប្រាជ្ញបុរាណ ដែលបានរកឃើញជាពិស្តារដូចតទៅ:

## អំពីត្នោត

ត្នោតជារុក្ខជាតិមួយប្រភេទ ដែលមាននៅលើប្រទេសកម្ពុជា ស្ទើរតែគ្រប់ភូមិ ឃុំ ស្រុក ខេត្តទាំងអស់ ដែលខ្មែរយើងដាំធ្វើជាដំណាំ យកផលប្រយោជន៍ដ៏សំខាន់ ដោយប្រកបការងារបានច្រើនប្រការគឺ:

គាបផ្កាយកទឹក, ទឹកត្នោតប្រើជាភេសជ្ជៈ ឬ ទឹកបាន ដែលមានឱជារសឈ្ងុយឆ្ងាញ់ពិសារគួរឲ្យចង់ភ្លក្សរសជាតិ ទឹកត្នោតគេអាចច្រាំធ្វើជាអេរ៉ៃ ដូចជាទឹកត្នោតជូរ ធៀបបាននិងប៊ីយែរ (bière-beer) ទឹកត្នោតចម្រាញ់ធ្វើទៅជាស្ករ ហៅស្ករត្នោត មាន ២ ប្រភេទគឺ

បើធ្វើឲ្យរឹងចាក់ពុម្ពទៅជាផែន គេហៅថាស្ករផែនឬស្ករស្រាក់ បើធ្វើដាក់ពាង ក្អម ធុង ថាំង គេហៅថាស្ករក្អម ដែលទុកយូរទៅឡើងក្រាមជាគ្រាប់ល្អិតៗ ផ្អែមឈ្ងុយ ជាស្ករធម្មជាតិសុទ្ធសាធ ។

ស្លឹកដេរបាំងធ្វើជាជញ្ជាំងផ្ទះ ហៅថាជញ្ជាំងស្លឹក, បាំងដំបូលផ្ទះ ហៅដំបូលប្រក់ស្លឹក, ត្បាញធ្វើជាកន្ទេល ហៅកន្ទេលស្លឹកត្នោត, ធ្វើជាសំពៀត (Cartable) ចាក់ស្មុគដាក់វត្ថុនានាដូចជាប្រអប់ (box) ចាក់ជាក្រតំច្រកនំ ហៅនំក្រតំ (ខ្មែរភាគខាងជើងច្រើនធ្វើនំនេះ) ធ្វើជាមួកពាក់ ហៅមួកស្លឹកត្នោត, ធ្វើដួនពាក់ ហៅដួនស្លឹកត្នោត, ធ្វើផ្លិតបក់ ជំនួសម៉ាស៊ីនត្រជាក់ (Air-Conditioning) ។

ផ្កាចាស់ស្ងួតដុតធ្វើក្បុង ហៅថាទឹកក្បុង, ផ្លែ. ផ្លែខ្ចីៗធ្វើជាបង្អែមស្ល សម្លផ្លែត្នោត សម្លគមត្នោត ផ្លែខ្ចីល្មមស្ងោរយកគ្រាប់បរិភោគ បានទឹក ដបផ្អែមឆ្ងាញ់ពិសារ, ផ្លែទុំប្រញាប់ធ្វើនំ នំត្នោត ចាហួយត្នោត, គ្រាប់ត្រុះ នៅលើដុះប៉ុចពន្លកឡើង កាប់យកកំពីងបរិភោគ កំពីងត្នោត, ធាងវិញ ធ្វើខ្សែ ខ្សែផតត្នោត ធ្វើជារំពាងចងបាច់សំពោង, ធ្វើជាអំបោស អំបោសផតត្នោត, យកសរសៃផតវែងព្រួញ៉ឹក ធ្វើសាបព្រួងកំពឹស កូន ត្រីញៀតៗ, ធាងងាប់ធ្វើអុសដុត ។

ឫស ឬធាង ប្រើធ្វើជាថ្នាំកែរោគបានយ៉ាងពូកែ ថ្នាំខ្មែរ ឧទាហរណ៍ ដូចជា គេកាត់យកធាងស្រស់ៗ ទៅដុតរោលនិងភ្លើងឲ្យស្រពាប់បន្តិច ហើយម្លូលពួតយកទឹកឲ្យអ្នកជម្ងឺផឹក ដូចជារោគរុះម្លូល ឬដែលផឹក ស៊ី ត្រូវជាតិពុលជាដើម តែបានជាភ្នាមយ៉ាងមានប្រសិទ្ធិភាព ។ល។

ដើមដែលមានអាយុច្រើនឆ្នាំ តែងមានកំពស់ខ្ពស់ពួសពេក ហៅថា ត្នោតវៃ គេកាប់កាត់អារច្រៀក ប្រើធ្វើគ្រឿងផ្ទះ ជិន្ទួសពេរ៉ា ដូចជា រនូត ផ្ទាន ផ្ទោង, នៅផ្នែកខាងគល់ធំៗ គេច្រើនពុះពុងធ្វើទូក ទូក ត្នោត សម្រាប់ជិះឆ្លងជិតៗ ។ល។

ដូច្នេះឃើញថាត្នោតជាដំណាំដែលមានប្រយោជន៍ច្រើនបំផុត គ្រប់ លក្ខណះទាំងអស់ ដែលបុរាណខ្មែរយើងបានស្រាវជ្រាវរកពុតជាកេរ មរតកឲ្យដល់កូនចៅជំនាន់ក្រោយ ជាយូរលង់អង្វែងមកហើយ រាប់រយ ពាន់ឆ្នាំកន្លងផុតទៅ ។

ហេតុនោះបើយើងធ្វើវិភាគទៅលើគំនិតប្រាជ្ញានិងការពិសោធន៍ នៃបុព្វបុរសយើង យើងមុខជានិងកោតស្ញប់ស្ញែងហើយឃើញអស្ចារ្យ

ចំពោះចំរើក្នុងការស្រាវជ្រាវទាំងនោះ ។

ព្រោះធម្មតាត្នោតដែលអាចចេញជាផ្លែផ្កា មិនមែនដើមតាមៗអាច ពេលរាងដល់ដើម្បីធ្វើការពិសោធន៍នោះទេ ត្រូវតែជាក់ជណ្ដើរ ឬ ចងជាបង្គោលឡើងទើបធ្វើទៅបាន ។ ចុះហេតុម្ដេចបានជាគេដឹងថា ផ្កាត្នោតនោះមានទឹកចេញ ទើបបានជាគេធ្វើការពិសោធន៍ ? តែបើថាគេរកឃើញដោយចៃដន្យនោះ ហាក់ដូចជាមិនមែនទាល់តែសោះ ។

ព្រោះការដែលគាបផ្កាយកទឹកនោះ ជាការពិបាកបំផុតក្នុងការរាវរក ជួនកាលផ្កានៅខ្ចីពេក គ្មានទឹក ជួនកាលផ្កាចាស់ពេក ក៏គ្មានទឹកដែរ, ហើយក្នុងការដែលគាបនោះទៀតសោត ក៏ត្រូវចេះគាបឲ្យល្មមទើបបាន ជួនកាលគាបខ្លាំង ដែលហៅថាជ្រុលដៃ មិនចេញទឹកក៏មាន ជួនកាលខ្សោយពេក ដែលហៅថាស្រាលដៃទឹកមិនចេញក៏មាន ។៤។

ហើយក្នុងការគាបនេះត្រូវធ្វើជាច្រើនលើកច្រើនគ្រាច្រើនថ្ងៃទៀតផង, ជួនកាលគាបបានត្រូវហើយ តែចិត្តមិនត្រូវ ទឹកមិនចេញក៏មាន ដូចជាកាំបិតមិនស្វាមុត ក៏អាចធ្វើមិនឲ្យទឹកចេញបានដែរ ។ ជួនកាលឃើញមានរបួតផល់យកទឹកទៅព្រំផ្កាទៀតផង ។៥។ និង ។៦។

ដូចនេះឃើញថាបុព្វបុរសខ្មែរ អ្នកស្រាវជ្រាវរាវរកស្ករត្នោត ជាទង្វើមួយដ៏សែនពិបាកបំផុតក្នុងការពិសោធន៍រាវរក ប្រហែលគ្នានឹងអ្នកស្រាវជ្រាវធ្វើគ្រឿងយន្ត ឲ្យហោះឡើងលើអាកាសយ៉ាងដូច្នោះ (យន្តហោះ) ដែលគួរតែចាត់ទុកអ្នកប្រាជ្ញបុរាណខ្មែរដែលរកឃើញស្ករត្នោត ថាជាអ្នកប្រាជ្ញមួយយ៉ាងឆ្នើម ក្នុងចំណោមអ្នកប្រាជ្ញផងទាំងឡាយនៅលើសាកលលោក ដែលបានទុកស្នាដៃជាប្រយោជន៍ឲ្យដល់មនុស្សជាតិ ។

ហើយបើយើងពិចារណាពាក្យខ្មែរយើងដែលហៅថាស្ករនេះ យកមកប្រៀបធៀបនិងពាក្យអង់គ្លេសថា ស៊ូករ៍ "Sugar" គឺបានសូរសំនៀងប្រហែលគ្នា ហើយឈ្មោះវត្ថុដូចគ្នាទៀតផង ។

ហេតុនេះតើយើងសន្និដ្ឋានថា ខ្មែរយើងយកភាសាប៉ែកខាងប្រទេសអឺរ៉ុប (Europe) មកប្រើឬដូចម្ដេច? បើយើងសន្និដ្ឋានថា ខ្មែរយើងយកភាសាខាងប្រទេសអឺរ៉ុបមកប្រើនោះ តើភាសាបុរាណខ្មែរយើងពីដើមកំណើតខ្មែរមិនមានពាក្យថាស្ករនេះទេឬដូចម្ដេច? តើគួរឲ្យឆ្ងល់ដែរឬទេ? សូមមិត្តអ្នកអានដែលមានសមត្ថភាពជួយពិភាក្សារឿងនេះ ។

### ទំណាញត្នោត

<u>ពាក្យ ១០</u>

ត្នោតកោតណាស់ចាស់ខ្មែរពីបរមបុរាណ ទេះវិសេសរកមកបានពូជផ្ការជាដំណាំ ពុកគេរដំណែលដែលបានមកយូរអង្វា ដោយពីលើដែនដីនៃប្រាយសុវណ្ណភូមិ ។

ត្នោតមានពីរប្រភេទសម្គាល់និងផ្លែផ្កា ដើមដូចគ្នាគ្រប់លក្ខណា ទាំងតូចធំ ខុសតែត្រង់ផ្កាឈ្មោលរាងមូលវែងកញ្ចុំ រលួតផល់ផ្កាកុំពុំបានចេញជាផ្លែ ។

ត្នោតមានប្រយោជន៍យ៉ាងប្រសើរប្រើប្រាស់គ្រប់ ចាស់បុរាណប៉ុនប្រសប់ថ្លៃពេកកែ ប្រើការគ្រប់យ៉ាងទាំងធាង.ស្លឹក ដើម ផ្កា ផ្លែ ពុកគេឲ្យខ្មែរជាតំណាតកូនចៅ ។

ធម្មជាតិដំណាំដាំដុះនៅលើលោក មានតែដែនដីគោកធ្លាកទេ ត្នោតដុះនៅ ខ្មែរបានមុនគេជាដំណាំដាំកូរចៅ ប្រចាំនៅគ្រប់ស្រុក ភូមិ

ឃុំ ខេត្ត ខ័ណ្ឌ ក្រុង ។

ខ្មែរពូកែក្នុងវិជ្ជាវារីវារិកម្មរកជាទឹក តាមរឿងព្រេងពីព្រាហ្មណ៍ចាស់ ព្រឹកពេញបំពង់ មាននវសព្រះអង្គត្រូវរបស់ក្រអាញ់ពេញចំណង់ ចំណូលចិត្តចង់ធ្វើបីដែលកែផាក់ឃើ ។

មានរសជាតិផ្លូវជារបើយសម័យនោះ ដែលខ្មែរប្រុសៗផឹក ក្លែមសាច់គោរាំពៃ (១) ឬសត្វប្រមាញ់ដែលបរបាញ់ក៏ឆ្ងាញ់ដែរ ជំនួស ត្រាបីដែលខ្មែរផឹកត្នោតជូរ ។

ភេសជ្ជៈទឹកត្នោតសោតតឹងបរិសុទ្ធ ប្រសើរបំផុតមានឱជារស មធុរ (២) ផឹកបានតាមចិត្តគ្មានពោយបាត់ឲ្យគិតគូរ តែបើផឹកយូរទៅ ជាញៀនអោយព្រោះញៀន ។

ខ្មែរចម្រាញ់ទឹកល្អិតជាស្ករល្អបំផុត ជាស្ករធម្មជាតិសុទ្ធគ្មានប្រ ផូចគ្មាន ខ្មែរធ្វើស្ករស្រាក់ចាក់ផាក់ពុម្ពតាងក្លូវបាន ខ្មែរចេះចំណាន មានតាំងធ្វើស្ករតាំងពី ។

បញ្ហាស្ករកប្រចិញពីបរទេស ព្រោះជាចំណោះដែលខ្មែរចេះ យ៉ាងពូកែ កសិករធ្វើកសិកម្មរាល់ឆ្នាំខែ ពីស្ពានដែលខ្មែរពីបុរាណបាន ពុករេក ។

បរជកខ្មែរពីបុរាណមានសន្ទឹក ហើយគេកក្នុងទឹកមានគ្រប់ផ្នែក ចេកច្បាំខ្មែរ ព្រៃពេកីត្រីសាច់ច្បូងមាសពេជ្រច្រើនពូរដែរ ហើយ ប្រាសាទខ្មែរមានពាសពេញរាប់រយពាន់ ។

វត្តបុរាណច្រើនអនេករាប់មិនអស់ ដែលជាកេរកោះរបស់ខ្មែរ ច្រើនជំនាន់ មានរូបចម្លាក់ឆ្លាក់ពីថ្មលើឬស្ពាន់ មានខ្លះចង្អិតធាតុពិត

ធ្វើឲ្យអន្តរាយ ។

តែត្រូវឲ្យផ្លាយព្រោះអន្តរាយស្ទើរតែអស់ ដោយមានរបស់ខ្លះ របងរងរាំងរា ខ្មែរយើងមិនខ្លោចឲ្យខ្មាំងលួចប្លន់គ្រប់គ្នា របស់ទ្រព្យ ណាល្អជាគេយកអស់ ។

ខ្មាំងសត្រូវខ្មែរពួកណោះចេះបំផ្លាញ ផ្តាច់ជីនាញប្រទង់ប្រចាញ់ ឲ្យវិនាស ផលផ្សេងៗទៅខ្មែរកានត់បន់នៅតែផេះ ផ្ទះខ្ទមប្តូរណោះ រកតែផេះមិនមានផង ។

អកុសលខ្មែររក្សាផែវេរមិនកើត ព្រោះអស់កំណើតតាំងពីច្រើន ឆ្នាំកន្លង កម្លាំងឥឡូវចុះចេះតែរស់បន្តិចប្តូរ សត្រូវប៉ុនប៉ងរំលាយពូជ ពូជជាតាម ។

១-គោរំពែ គោព្ធច ឬគោធំនិងគោព្ធច

២-បក្សៈ ឬ បក្ស រសធ្មែបប្ដុកាញ់

វចនានុក្រមសម្តេច ជួន ណាត

មានលក់ដុំ និង លក់រាយ

នូវសៀវភៅគ្រប់មុខគ្រប់ប្រភេទ នៅ

“បណ្ណាគារចិត្រតេន” ផ្ទះលេខ 136Eo

វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

សូមមិត្ត និង អញ្ជើញដោយមេត្រីភាព ។